នៅចំពោះមុខអង្គបុរេជំនុំជម្រះ
នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

**ព័ត៌មានពិស្ដារនៃការដាក់ឯកសារ**

| | | |
|---|---|---|
| សំណុំរឿងលេខ | ៖ | ០០៤/០៧-០៩-២០០៩-អវតក/កសចស(អបជ ៦១) |
| ដាក់ទៅ | ៖ | អង្គបុរេជំនុំជម្រះ |
| ថ្ងៃដាក់ | ៖ | ថ្ងៃទី១៤ ខែកុម្ភៈ ឆ្នាំ២០២០ |
| ភាគីអ្នកដាក់ | ៖ | សហព្រះរាជអាជ្ញាអន្តរជាតិ |
| ភាសាដើម | ៖ | អង់គ្លេស |

ឯកសារបកប្រែ
TRANSLATION/TRADUCTION
ថ្ងៃ ខែ ឆ្នាំ (Date): 14-Feb-2020, 14:04
CMS/CFO: Sann Rada

**ចំណាត់ថ្នាក់ឯកសារ**

ប្រភេទឯកសារដែលស្នើឡើងដោយភាគីដាក់ឯកសារ៖ សម្ងាត់

ចំណាត់ថ្នាក់ឯកសារកំណត់ដោយ អបជ៖ សម្ងាត់/Confidential

ប្រភេទនៃចំណាត់ថ្នាក់ឯកសារ៖

ការពិនិត្យឯកសារបណ្ដោះអាសន្នឡើងវិញ៖

ឈ្មោះមន្ត្រីដែលបានពិនិត្យ៖

ហត្ថលេខា៖

---

**ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិទៅនឹងបណ្ដឹងឧទ្ធរណ៍របស់ យឹម ទិត្យ ប្រឆាំងនឹងដីកាបញ្ជូនរឿងទៅជំនុំជម្រះក្នុងសំណុំរឿង ០០៤**

---

**អ្នកដាក់ឯកសារ៖**
លោកស្រី Brenda J. Hollis
**សហព្រះរាជអាជ្ញាអន្តរជាតិ**

**ចម្លងជូន:**
លោកស្រី ជា លាង
**សហព្រះរាជអាជ្ញាជាតិ**

**អ្នកទទួលឯកសារ៖**
**អង្គបុរេជំនុំជម្រះ**
ចៅក្រម ប្រាក់ គឹមសាន, ប្រធាន
ចៅក្រម Olivier BEAUVALLET
ចៅក្រម ន័យ ថុល
ចៅក្រម Kang Jin BAIK
ចៅក្រម ហួត វុទ្ធី

**មេធាវីដើមបណ្ដឹងរដ្ឋប្បវេណីទាំងអស់ក្នុងសំណុំរឿង០០៤**

**សហមេធាវី យឹម ទិត្យ**
លោក សូ ម៉ូស្សេនី
លោក Suzana TOMANOVIĆ

# មាតិកា

I. សេចក្តីផ្តើម ............ 5

II. សារណាបឋម ............ 6

ក. មូលដ្ឋានទី ១, ២ និង ៣ នៃបណ្តឹងឧទ្ធរណ៍ មិនអាចទទួលយកបានទេ ............ 6

ខ. បណ្តឹងឧទ្ធរណ៍មានការអះអាងដែលគ្មានសំអាងត្រឹមត្រូវ ............ 8

គ. មូលដ្ឋានបណ្តឹងឧទ្ធរណ៍សំអាងលើបទដ្ឋាន និងគោលការណ៍គតិយុត្តិដែលមិនត្រឹមត្រូវ ............ 9

III. សារណា ............ 16

ក. មូលដ្ឋានទី១៖ យឹម ទិត្យ មិនបានបង្ហាញពីកំហុសដែលអាចពិនិត្យឡើងវិញបាន ទាក់ទិននឹងការស៊ើបអង្កេតក្នុងសំណុំរឿង ០០៤ និង ការចេញដីកាបញ្ជូនរឿងទៅជំនុំជម្រះទេ ............ 16

១. យឹម ទិត្យ មិនបានបង្ហាញនូវកំហុសណាមួយដែលអាចពិនិត្យឡើងវិញបាន ដោយផ្អែកលើដីកាលើកទី ៣ ទេ ............ 17

២. យឹម ទិត្យ មិនបានបង្ហាញពីការជ្រៀតជ្រែកណាមួយទៅក្នុងកិច្ចការរដ្ឋបាលរបស់តុលាការទេ ............ 19

៣. យឹម ទិត្យ ខកខានមិនបានបង្ហាញពី "ការប្រឡាក់ប្រឡូក" នៃការស៊ើបអង្កេតលើសំណុំរឿង ០០៤ ............ 21

៤. យឹម ទិត្យ ខកខានមិនបានផ្តល់មូលដ្ឋានសមស្របសម្រាប់ពិចារណាឡើងវិញលើបណ្តឹងរបស់គាត់ពាក់ព័ន្ធនឹងសិទ្ធិចូលពិនិត្យសំណុំរឿង ០០៤ "យឺតពេលវេលា" ............ 24

៥. យឹម ទិត្យ ខកខានក្នុងការបង្ហាញកំហុសដែលអាចពិនិត្យមើលឡើងវិញ ពាក់ព័ន្ធនឹងអំឡុងពេលនៃកិច្ចដំណើរការនីតិវិធីក្នុងសំណុំរឿង ០០៤ ............ 24

ខ. មូលដ្ឋានទី ២ ៖ យឹម ទិត្យ ខកខានក្នុងការបង្ហាញកំហុសដែលអាចពិនិត្យមើល ឡើងវិញបាន នៅក្នុងសំអាងហេតុរបស់ ស.ច.ស.អ ក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ ............ 26

១. យឹម ទិត្យ ខកខានក្នុងការបង្ហាញកំហុសដែលអាចពិនិត្យមើលឡើងវិញចំពោះ ទម្រង់ និងអង្គសេចក្តីនៃផ្នែក "ទទួលខុសត្រូវខ្ពស់បំផុត" នៃដីកាបញ្ជូនរឿងទៅ ជំនុំជម្រះ ............ 27

២. យឹម ទិត្យ ខកខានក្នុងការបង្ហាញពីកំហុសដែលអាចពិនិត្យមើលឡើងវិញបាន ចំពោះទម្រង់ ឬ អង្គសេចក្តីនៅក្នុងវិធីសាស្ត្ររបស់ ស.ច.ស.អ ចំពោះឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ ............ 29

ក. យឹម ទិត្យ ខកខានក្នុងការបង្ហាញកំហុសដែលអាចពិនិត្យមើលឡើងវិញចំពោះការសម្រេចរបស់ ស.ច.ស.អ ពាក់ព័ន្ធនឹងខ្មែរក្រោមក្នុងនាមជាក្រុម ............ 29

ខ. យឹម ទិត្យ ខកខានមិនបានបង្ហាញពីកំហុសដែលអាចពិនិត្យមើលឡើងវិញចំពោះការយល់ ឃើញរបស់ ស.ច.ស.អ ពាក់ព័ន្ធនឹងចេតនាជាក់លាក់របស់ យឹម ទិត្យ ............ 30

៣. យឹម ទិត្យ ខកខានក្នុងការបង្ហាញកំហុសដែលអាចពិនិត្យមើលឡើងវិញបាន ទាំងទម្រង់ ឬអង្គសេចក្តីចំពោះវិធីសាស្ត្ររបស់ ស.ច.ស.អ លើការទទួលខុសត្រូវរបស់ថ្នាក់លើ ............ 31

គ. មូលដ្ឋានទី ៣ ៖ យឹម ទិត្យ ខកខានមិនបានបង្ហាញកំហុសដែលអាចពិនិត្យឡើងវិញ បានលើវិសាលភាពនៃអង្គហេតុដែលមាននៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ ....................................32

ឃ. មូលដ្ឋានទី ៤៖ យឹម ទិត្យ ខកខានមិនបានបង្ហាញកំហុសណាមួយដែលអាចពិនិត្យ ឡើងវិញបាន ចំពោះការពឹងផ្អែករបស់ ស.ច.ស.អ លើសហឧក្រិដ្ឋកម្មរួម....................................35

ង. មូលដ្ឋានទី ៥ ៖ យឹម ទិត្យ ខកខានមិនបានបង្ហាញកំហុសណាមួយដែលអាច ពិនិត្យឡើងវិញបាននៅក្នុងការសន្និដ្ឋានថា គាត់គឺជា "ជនទទួលខុសត្រូវខ្ពស់បំផុត" ហេតុដូច្នេះ ស្ថិតក្រោមយុត្តាធិការបុគ្គលរបស់ អ.វ.ត.ក....................................37

១. យឹម ទិត្យ ខកខានមិនបានបង្ហាញថា ការសន្និដ្ឋានដែលថា គាត់ទំនងជាមានសិទ្ធិអំណាចជាក់ស្តែង និងស្ថិតក្នុងចំណោម "ជនដែលទទួលខុសត្រូវខ្ពស់បំផុត" ផ្អែកតែទៅលើទំនាក់ទំនងរបស់គាត់ ជាមួយ តាម៉ុក ប៉ុណ្ណោះ ....................................38

ក. យឹម ទិត្យ ខកខានមិនបានបង្ហាញកំហុសណាមួយដែលអាចពិនិត្យឡើងវិញបាន ក្នុងការសន្និដ្ឋាន ថាគាត់ទំនងជាមួយទំនាក់ទំនងជិតស្និទ្ធជាមួយ តាម៉ុក ....................................38

ខ. យឹម ទិត្យ ខកខានមិនបានបង្ហាញកំហុសណាមួយដែលអាចពិនិត្យឡើងវិញបានក្នុងការសន្និដ្ឋាន ថា គាត់ទំនងជាមានសិទ្ធិអំណាចដំណាលគ្នានៅក្នុងភូមិភាគនិរតី និងភូមិភាគពាយ័ព្យ ស្រដៀងគ្នានឹងតាម៉ុក 41

២. យឹម ទិត្យ ខកខានមិនបានបង្ហាញកំហុសណាមួយដែលអាចពិនិត្យឡើងវិញ ក្នុងការសន្និដ្ឋានថា គាត់មានមុខតំណែងតាមផ្លូវច្បាប់ និងសិទ្ធិអំណាចជាក់ស្តែងក្នុងស្រុកគិរីវង់ ....................................43

ក. យឹម ទិត្យ ខកខានមិនបានបង្ហាញពីកំហុសធ្ងន់ណាមួយដែលអាចពិនិត្យឡើងវិញបាននៅក្នុងការ សន្និដ្ឋានថា គាត់ទំនងជាកាន់មុខតំណែងតាមផ្លូវច្បាប់នៅក្នុងស្រុកគិរីវង់ ....................................44

ខ. យឹម ទិត្យ ខកខានមិនបានបង្ហាញកំហុសណាមួយដែលអាចពិនិត្យឡើងវិញបាន នៅក្នុងការសន្និដ្ឋានថា គាត់ទំនងជាមានសិទ្ធិអំណាចជាក់ស្តែងនៅក្នុងស្រុកគិរីវង់....................................46

៣. យឹម ទិត្យ ខកខានមិនបានបង្ហាញកំហុសណាមួយដែលអាចពិនិត្យឡើងវិញបានក្នុងការសន្និដ្ឋានថា គាត់ទំនងជាកាន់មុខតំណែងតាមផ្លូវច្បាប់ និងសិទ្ធិអំណាចជាក់ស្តែងនៅក្នុងតំបន់១៣ ....................................48

ក. យឹម ទិត្យ ខកខានមិនបានបង្ហាញពីកំហុសណាមួយដែលអាចពិនិត្យឡើងវិញបាន ក្នុងការសន្និដ្ឋានថា គាត់ទំនងជាកាន់មុខតំណែងតាមផ្លូវច្បាប់ក្នុងគណៈកម្មាធិការតំបន់ ១៣....................................49

ខ. យឹម ទិត្យ ខកខានមិនបានបង្ហាញពីកំហុសណាមួយដែលអាចពិនិត្យឡើងវិញបាន ក្នុងការសន្និដ្ឋានថា គាត់ទំនងជាមានសិទ្ធិអំណាចជាក់ស្តែងក្នុងតំបន់ ១៣....................................50

៤. យឹម ទិត្យ ខកខានមិនបានបង្ហាញពីកំហុសណាមួយដែលអាចពិនិត្យឡើងវិញបាន ក្នុងការសន្និដ្ឋានថា គាត់ទំនងជាលេខាតំបន់១....................................53

ក. យឹម ទិត្យ ខកខានមិនបានបង្ហាញកំហុសណាមួយដែលអាចពិនិត្យឡើងវិញបាន ក្នុងការសន្និដ្ឋានថា គាត់ទំនងជាត្រូវបានតែងតាំងជាលេខាតំបន់ ១....................................53

ខ. យឹម ទិត្យ ខកខានមិនបានបង្ហាញកំហុសណាមួយដែលអាចពិនិត្យឡើងវិញបានក្នុងការសន្និដ្ឋានថា គាត់ទំនងជាអនុវត្តសិទ្ធិអំណាចក្នុងនាមជាលេខាតំបន់១.....58

៥. យឹម ទិត្យ ខកខានមិនបានបង្ហាញពីកំហុសណាមួយដែលអាចពិនិត្យឡើងវិញបាននៅក្នុងការសន្និដ្ឋានថា គាត់ទំនងជាលេខាតំបន់៣.....63

៦. យឹម ទិត្យ មិនបានបង្ហាញកំហុសណាមួយដែលអាចពិនិត្យឡើងវិញបាន នៅក្នុងការសម្រេចថា គាត់ប្រហែលជាលេខាតំបន់ ៤.....66

៧. យឹម ទិត្យ មិនបានបង្ហាញពីកំហុសណាមួយ ដែលអាចពិនិត្យឡើងវិញបាន ក្នុងការសម្រេចថា គាត់ប្រហែលជាសមាជិកនៃគណៈកម្មាធិការភូមិភាគពាយ័ព្យ.....68

៨. យឹម ទិត្យ មិនបានបង្ហាញកំហុសណាមួយ ដែលអាចពិនិត្យឡើងវិញបាន នៅក្នុងការសម្រេចថា គាត់ប្រហែលជាបានចូលរួមយ៉ាងសំខាន់ក្នុងការអនុវត្តគោលនយោបាយបក្សកុម្មុយនីស្តកម្ពុជា នៅភូមិភាគពាយ័ព្យ (សហឧក្រិដ្ឋកម្មរួម ក).....73

ក. យឹម ទិត្យ មិនបានបង្ហាញពីកំហុសណាមួយ ដែលអាចពិនិត្យឡើងវិញបាន ក្នុងការសម្រេចថា គាត់ប្រហែលជាបានចូលរួមក្នុងការបង្កើត និងគ្រប់គ្រងគោលនយោបាយសហករណ៍ និងការដ្ឋាន.....73

ខ. យឹម ទិត្យ មិនបានបង្ហាញអំពីកំហុសឆ្គងណាមួយ ដែលអាចពិនិត្យឡើងវិញបាន នៅក្នុងការសម្រេចថា គាត់ប្រហែលជាបានចូលរួមពាក់ព័ន្ធក្នុងការកំណត់គោលដៅខ្មាំងបក្សកុម្មុយនីស្តកម្ពុជា.....77

គ. យឹម ទិត្យ មិនបានបង្ហាញពីកំហុសឆ្គងណាមួយ ដែលអាចពិនិត្យឡើងវិញបាន ក្នុងការសម្រេចដែលថា គាត់ប្រហែលជាបានចូលរួមក្នុងការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ.....78

៩. យឹម ទិត្យ មិនបានបង្ហាញកំហុសណាមួយ ដែលអាចពិនិត្យឡើងវិញបាន នៅក្នុងការសម្រេចថា គាត់ប្រហែលជាបានចូលរួមយ៉ាងសំខាន់ក្នុងអំពើប្រល័យពូជសាសន៍ខ្មែរក្រោម (សហឧក្រិដ្ឋកម្មរួម ខ).....79

១០. យឹម ទិត្យ មិនបានបង្ហាញកំហុសណាមួយ ដែលអាចពិនិត្យឡើងវិញបាន នៅក្នុងការសម្រេចថា គាត់ប្រហែលជាបានចូលរួមយ៉ាងសំខាន់ក្នុងការធ្វើបាបនៅវត្តព្រះធាតុ (សហឧក្រិដ្ឋកម្មរួម ខ).....83

ក. យឹម ទិត្យ មិនបានបង្ហាញកំហុសឆ្គងណាមួយ ដែលអាចពិនិត្យឡើងវិញបាន ក្នុងការសម្រេចថា យឹម ទិត្យ ប្រហែលជាមួយទៅពិនិត្យវត្តព្រះធាតុជាទៀងទាត់.....83

ខ. យឹម ទិត្យ មិនបានបង្ហាញកំហុសណាមួយ ដែលអាចពិនិត្យឡើងវិញបាន ក្នុងការសម្រេចថា យឹម ទិត្យ ប្រហែលជាបានចូលរួម ក្នុងការសួរចម្លើយនៅវត្តព្រះធាតុ.....87

គ. យឹម ទិត្យ មិនបានបង្ហាញកំហុសណាមួយ ដែលអាចពិនិត្យឡើងវិញបាន ក្នុងការសម្រេចថា យឹម ទិត្យ ប្រហែលបានចូលរួម ក្នុងការសម្លាប់មនុស្សនៅវត្តព្រះធាតុ.....89

១១. យឹម ទិត្យ មិនបានបង្ហាញថា ភ័ស្តុតាងរបស់ ចាន់ វិចិត្រ មានភាពពាក់ព័ន្ធជាមួយនឹងការសម្រេចដែលថា យឹម ទីត្យ ប្រហែលជាស្ថិតក្នុងចំណោម “អ្នកទទួលខុសត្រូវខ្ពស់បំផុត”.....93

IV. សេចក្ដីសន្និដ្ឋាន.....95

# I. សេចក្ដីផ្ដើម

1. សហព្រះរាជអាជ្ញាអន្តរជាតិ ("ស.ព.អ") សូមឆ្លើយតបទៅនឹងបណ្ដឹងឧទ្ធរណ៍របស់ យឹម ទិត្យ[1] ប្រឆាំងដីកាដោះស្រាយស្រាយ ("ដីកាបញ្ជូនរឿងទៅជំនុំជម្រះ") របស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ("ស.ច.ស.អ") ដែលបានចេញនៅថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៩[2] ("បណ្ដឹងឧទ្ធរណ៍របស់ យឹម ទិត្យ")។ ស.ច.ស.អ បានចោទប្រកាន់ យឹម ទិត្យ ចំពោះអំពើប្រល័យពូជសាសន៍ ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ឧក្រិដ្ឋកម្មសង្គ្រាម និងការរំលោភបំពានលើក្រមព្រហ្មទណ្ឌកម្ពុជា ឆ្នាំ១៩៥៦ ដោយបញ្ជូនគាត់ទៅជំនុំជម្រះ[3]។

2. បណ្ដឹងឧទ្ធរណ៍របស់ យឹម ទិត្យ មិនបានបំពេញទៅតាមបទដ្ឋានជាធរមាននៃការពិនិត្យលើបណ្ដឹងឧទ្ធរណ៍ឡើយ។ ទីមួយ មូលដ្ឋានជាច្រើនរបស់ យឹម ទិត្យ មិនអាចទទួលយកបានទេ ដោយសារគាត់មិនបានបង្ហាញថា អន្តរាគមន៍លើបណ្ដឹងឧទ្ធរណ៍របស់អង្គបុរេជំនុំជម្រះ ("អ.ប.ជ") មានភាពចាំបាច់អនុលោមតាមវិធាន ២១ នៃវិធានផ្ទៃក្នុង[4] ដើម្បីបង្ការនូវព្យសនកម្មដែលមិនអាចកែបានដល់ភាពត្រឹមត្រូវនៃកិច្ចដំណើរការនីតិវិធី ឬដល់សិទ្ធិជាសារវ័ន្តនៃការជំនុំជម្រះក្ដីដោយយុត្តិធម៌។ ទីពីរ ហួសឆ្ងាយពីអង្គហេតុដែលថា មូលដ្ឋានជាច្រើននៃបណ្ដឹងឧទ្ធរណ៍របស់ យឹម ទិត្យ ពុំមានភាពច្បាស់លាស់ពាក់ព័ន្ធនឹងប្រភេទកំហុសដែលត្រូវបានចោទប្រកាន់ ពុំមានទឡ្ហីករណ៍ណាមួយដែលមាននៅក្នុងមូលដ្ឋាន ឬមូលដ្ឋានរងរបស់គាត់ បង្ហាញនូវកំហុសលើអង្គច្បាប់ដែលធ្វើឲ្យដីកាបញ្ជូនរឿងទៅជំនុំជម្រះអស់សុពលភាព កំហុសលើអង្គហេតុដែលធ្វើឲ្យមានភាពអយុត្តិធម៌ ឬការបំពានឆន្ទានុសិទ្ធិដែលបង្ខំឲ្យធ្វើសេចក្ដីសន្និដ្ឋានថា ស.ច.ស.អ មិនបានអនុវត្តឆន្ទានុសិទ្ធិរបស់ខ្លួនឲ្យមានភាពយុត្តិធម៌ដែរ។ សរុបមក យឹម ទិត្យ មិនបានបង្ហាញកំហុសណាមួយ ឬការបំពានដែលធ្វើឲ្យបាត់បង់តម្លៃជាមូលដ្ឋាននៃសេចក្ដីសម្រេចតាមឆន្ទានុសិទ្ធិរបស់ ស.ច.ស.អ ដែលសន្និដ្ឋានថា យឹម ទិត្យ ស្ថិតក្នុងចំណោម "អ្នកទទួលខុសត្រូវខ្ពស់បំផុត" ចំពោះឧក្រិដ្ឋកម្មដែលបាន

---

[1] ឯកសារ **D382/22** បណ្ដឹងឧទ្ធរណ៍របស់ យឹម ទិត្យ ប្រឆាំងនឹងដីកាដំណោះស្រាយរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិក្នុងសំណុំរឿង០០៤ ចុះថ្ងៃទី០២ ខែធ្នូ ឆ្នាំ២០១៩ ("បណ្ដឹងឧទ្ធរណ៍របស់ យឹម ទិត្យ")។

[2] ឯកសារ **D382** ដីកាដំណោះស្រាយ។

[3] ឯកសារ **D382** ដីកាដំណោះស្រាយ EN 01580615-21។

[4] អង្គជំនុំជម្រះវិសាមញ្ញនៅក្នុងតុលាការកម្ពុជា ("អ.វ.ត.ក") វិធានផ្ទៃក្នុង (វិសោធនកម្មទី ៩) ដែលបានកែប្រែនៅថ្ងៃទី១៦ ខែមករា ឆ្នាំ ២០១៥ ("វិធានផ្ទៃក្នុង" ឬ "វិធាន")។

ប្រព្រឹត្តក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ (“DK”) និងបានចោទប្រកាន់បញ្ជូនគាត់ទៅជំនុំជម្រះឡើយ។

## II. **សារណាបឋម**

3. បណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ ត្រូវយកមកអានដោយប្រុងប្រយ័ត្ន។ ដូចដែលនឹងលើកឡើងលម្អិតនៅក្នុងចម្លើយតបនេះទាំងមូល យឹម ទិត្យ វាយតម្លៃតាមបែបជ្រើសរើសចំពោះដីកាបញ្ជូនរឿងទៅជំនុំជម្រះ និងភស្តុតាងជាមូលដ្ឋាននៃដីកានេះ ដោយមិនវាយតម្លៃទៅលើភស្តុតាងជារួមទេ និង បកស្រាយខុសចំពោះភស្តុតាងរបស់សាក្សី។ បញ្ហាសំខាន់ៗខាងក្រោមនេះនឹងត្រូវលើកយកមកដោះស្រាយមុនគេ រួមមានៈ មូលដ្ឋានបណ្តឹងឧទ្ធរណ៍ដែលមិនអាចទទួលយកបាន ការអះអាងដែលគ្មានសំអាងត្រឹមត្រូវ និង បទដ្ឋាន និងគោលការណ៍គតិយុត្តិដែលមិនអាចអនុវត្តបាន។

### **ក. មូលដ្ឋានទី ១, ២ និង ៣ នៃបណ្តឹងឧទ្ធរណ៍ មិនអាចទទួលយកបានទេ**

4. យឹម ទិត្យ អះអាងដោយមិនត្រឹមត្រូវថា “ការបកស្រាយទូលាយរបស់ អ.ប.ជ លើវិធាន ២១ ពង្រីកសិទ្ធិប្តឹងឧទ្ធរណ៍”[5]។ ការពិត អ.ប.ជ បានសម្រេចថា វិធាន ២១ មិនបើកផ្លូវដោយស្វ័យប្រវត្តិឱ្យមានយុត្តាធិការលើបណ្តឹងឧទ្ធរណ៍ ដើម្បីពិចារណាទៅលើទឡ្ហីករណ៍នានាដោយផ្អែកលើសិទ្ធិទទួលបានការជំនុំជម្រះក្តីដោយយុត្តិធម៌ ឬបញ្ហានានាពាក់ព័ន្ធនឹងភាពយុត្តិធម៌នៃកិច្ចដំណើរការនីតិវិធីឡើយ[6]។ ផ្ទុយទៅវិញ ភាគីដែលកើតទុក្ខមិនសុខចិត្តត្រូវ “បង្ហាញថា កាលៈទេសៈតម្រូវឱ្យអង្គជំនុំជម្រះធ្វើអន្តរាគមន៍នៅដំណាក់កាលដែលបណ្តឹងឧទ្ធរណ៍ ត្រូវបានដាក់ ដើម្បីជៀសវាង *ព្យសនកម្មដែលមិនអាចកែបាន*ដល់ភាពត្រឹមត្រូវនៃកិច្ចដំណើរការនីតិវិធី ឬដល់សិទ្ធិជាសារវន្តនៃ

---

[5] ឯកសារ **D382/22** បណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ ៥៨។

[6] សំណុំរឿង ០០៤/២-**D359/24** & **D360/33** (អ.ប.ជ) សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ កថាខណ្ឌ ១៤៧ និងឯកសារយោងភ្ជាប់មកជាមួយ។

ការជំនុំជម្រះក្តីដោយយុត្តិធម៌”[7]។ ទទ្បីករណ៍នានាដែលផ្អែកលើបញ្ហាសម្មតិកម្ម និងការស្មានៗ មិនអាចទទួលយកបានទេ[8]។

5. <u>មូលដ្ឋានទី១ របស់ យឹម ទិត្យ មិនអាចទទួលយកបាន៖</u> យឹម ទិត្យ មិនបានបង្ហាញថា ការអះអាងជាច្រើនរបស់គាត់អំពីការរំលោភលើសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ ពាក់ព័ន្ធនឹងការបើកកិច្ចស៊ើបសួរដោយឡែកក្តី ឬជារួមក្តី ធ្វើឱ្យប៉ះពាល់ដល់សុចរិតភាពនៃកិច្ចដំណើរការនីតិវិធីដែលមិនអាចឱ្យមានការជំនុំជម្រះក្តីដោយយុត្តិធម៌ឡើយ។ មូលដ្ឋានរងទី ១.១ មិនអាចទទួលយកបានទេ ដោយសារករណីខ្វែងយោបល់របស់សហព្រះរាជអាជ្ញាមិនពាក់ព័ន្ធនឹងភាពត្រឹមត្រូវនៃកិច្ចដំណើរការនីតិវិធីទេ ពីព្រោះដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលើកទី៣ (“ដីកាលើកទី៣”) ត្រូវបានបញ្ជូនយ៉ាងត្រឹមត្រូវទៅសហចៅក្រមស៊ើបអង្កេត (“ស.ច.ស”)។ មូលដ្ឋានរងទី ១.២ មិនអាចទទួលយកបានទេ ដោយសារឥទ្ធិពលដែលបានអះអាងពីការការបែកធ្លាយដីកាលើកទី៣ គឺត្រឹមតែស្មានៗប៉ុណ្ណោះ បើយោងទៅលើព័ត៌មានសម្រាប់សាធារណជនពាក់ព័ន្ធនឹងការចោទប្រកាន់ក្នុងសំណុំរឿង ០០៤។ មូលដ្ឋានរងទី ១.៣ មិនអាចទទួលយកបានទេ ដោយសារការអះអាងថា មជ្ឈមណ្ឌលឯកសារកម្ពុជា (“DC-Cam”) ប្រឡាក់ប្រឡូសក្នុងការស៊ើបអង្កេតក្នុងសំណុំរឿង ០០៤ គឺផ្អែកតែទៅលើការទាយស្មានៗប៉ុណ្ណោះ។ មូលដ្ឋានរងទី ១.៤ មិនអាចទទួលយកបានទេ ដោយសារបញ្ហានៃការចូលពិនិត្យមើលរបស់ យឹម ទិត្យ ទៅក្នុងសំណុំរឿង ០០៤ ត្រូវបានវិនិច្ឆ័យសេចក្តីដោយ អ.ប.ជ រួចហើយ។ មូលដ្ឋានរងទី ១.៥ មិនអាចទទួលយកបានទេ ដោយសារការអះអាងរបស់ យឹម ទិត្យ អំពីការពន្យារពេលមិនសមហេតុផលមិនពាក់ព័ន្ធទៅនឹងភាពត្រឹមត្រូវនៃកិច្ចដំណើរការនីតិវិធីទេ ដោយសារសិទ្ធិរបស់គាត់ត្រូវបានការពារ ក្នុងអំឡុងដំណើរការទាំងមូល ហើយការអះអាងរបស់គាត់ដែលថា ពេលវេលាកន្លងទៅមានឥទ្ធិពលជាអវិជ្ជមានដល់ភ័ស្តុតាង គឺគ្រាន់តែជាការទាយស្មានៗប៉ុណ្ណោះ។

6. <u>មូលដ្ឋានទី២ របស់ យឹម ទិត្យ មិនអាចទទួលយកបាន៖</u> យឹម ទិត្យ អះអាងថា ដីកាបញ្ជូនរឿងទៅជំនុំជម្រះមានវិការៈ ដោយសារមិនបានកំណត់អំពីអង្គហេតុសម្ភារៈ និងការកំណត់បទល្មើសតាម

---

[7] សំណុំរឿង ០០៤/២-**D359/24** & **D360/33** (អ.ប.ជ) សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ កថាខណ្ឌ ១៤៧ (មានបញ្ជាក់បន្ថែម)។ *សូមមើល ផងដែរ* ឯកសារ **D284/1/4** (អ.ប.ជ) សាលដីកាសម្រេចលើការបង្ហាញឯកសារ កថាខណ្ឌ ២១។ ឯកសារ **D236/1/1/8** (អ.ប.ជ) សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ *អ៊ឹម ចែម* កាខណ្ឌ ២៨។ ឯកសារ **D205/1/1/2** (អ.ប.ជ) សាលដីកាលើសំណើសុំការបំភ្លឺ កថាខណ្ឌ ៧។

[8] ឯកសារ **D284/1/4** (អ.ប.ជ) សាលដីកាសម្រេចលើការបង្ហាញឯកសារ កថាខណ្ឌ ២៤។

ផ្លូវច្បាប់។ អ.ប.ជ បានសម្រេចថា "កំហុសដែលបានចោទប្រកាន់ជាទម្រង់នៃដីកាបញ្ជូនរឿងទៅជំនុំជម្រះ [...] ច្បាស់ណាស់ថា មិនមែនមានលក្ខណៈជាបញ្ហាយុត្តាធិការឡើយ និង [...] ហេតុដូច្នេះ មិនអាចទទួលយកបាននៅក្នុងដំណាក់កាលមុនជំនុំជម្រះ នៃកិច្ចដំណើរការនីតិវិធីឡើយ ដោយគិតដល់អត្ថន័យទាំងមូលនៃវិធាន ៧៤(៣)(ក) និងជំពូក II នៃច្បាប់បង្កើត អ.វ.ត.ក"[9]។

7. <u>មូលដ្ឋានទី៣ របស់ យឹម ទិត្យ មិនអាចទទួលយកបាន៖</u> ការអះអាងរបស់ យឹម ទិត្យ ដែលថា ដីកាបញ្ជូនរឿងទៅជំនុំជម្រះពង្រីកហួស "វិសាលភាពពេលវេលា និងភូមិសាស្ត្រនៃកិច្ចស៊ើបសួរ"[10] គឺជាការជំទាស់ដែលមិនត្រូវបានអនុញ្ញាតទៅតាមទម្រង់នៃដីកាបញ្ជូនរឿងទៅជំនុំជម្រះ[11]។ អ.ប.ជ បានសម្រេចថា ការអះអាងពី "វិសាលភាពភូមិសាស្ត្រដែលចោទប្រកាន់មិនសមស្រប" មិនអាច "បង្កើតជាការជំទាស់ដាក់បន្ទុកលើយុត្តាធិការបុគ្គល" ទេ ដោយសារវា "មិនបានដាក់បន្ទុកដោយផ្ទាល់លើភាពធ្ងន់ធ្ងរនៃឧក្រិដ្ឋកម្មដែលបានចោទប្រកាន់ ឬការទទួលខុសត្រូវ [របស់ជនត្រូវចោទ]ឡើយ"[12]។

## ខ. បណ្តឹងឧទ្ធរណ៍មានការអះអាងដែលគ្មានសំអាងត្រឹមត្រូវ

8. អង្គជំនុំជម្រះតុលាការកំពូលបានសម្រេចថា ទឡ្ហីករណ៍នានា "ដែលគ្រាន់តែលើកឡើងថា សេចក្តីសម្រេច ឬសំអាងហេតុ [...] មានកំហុស ដោយពុំបានលើកមូលដ្ឋានគាំទ្រ ថាតើមូលហេតុអ្វីបានជាសេចក្តីសម្រេច ឬសំអាងហេតុនេះ មានកំហុស" មិនត្រូវបានយកមកពិចារណាឡើយ[13]។ បណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ ធ្វើការអះអាងមួយចំនួនដែលអាចទទួលយកបាន តែគ្មានមូលដ្ឋានគាំទ្រ។

[9] សំណុំរឿង ០០៤/២-**D359/24** & **D360/33** (អ.ប.ជ) សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ កថាខណ្ឌ ១៣៩ និងឯកសារយោងភ្ជាប់មកជាមួយ។

[10] ឯកសារ **D382/22** បណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ kfaxNjD ៩៧។

[11] សំណុំរឿង ០០៤/២-**D359/24** & **D360/33** (អ.ប.ជ) សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ កថាខណ្ឌ ១៥៦។ *សូមមើល ផងដែរ* សំណុំរឿង ០០២ ឯកសារ **D427/1/30** (អ.ប.ជ) សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ *អៀង សារី* ប្រឆាំងនឹងដីកាដំណោះស្រាយ កថាខណ្ឌ ៤៧។ សំណុំរឿង ០០២ ឯកសារ **D427/2/15** & **D427/3/15** (អ.ប.ជ) សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ កថាខណ្ឌ ៦៣។

[12] សំណុំរឿង ០០៤/២-**D359/24** & **D360/33** (អ.ប.ជ) សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ កថាខណ្ឌ ១៥៦។

[13] *សូមមើល* សំណុំរឿង ០០២ ឯកសារ **F36** សាលដីកាលើសំណុំរឿង ០០២/០១ កថាខណ្ឌ ១០១-១០២។

9. ឧទាហរណ៍ យឹម ទិត្យ លើកឡើងនូវទឡ្ហីករណ៍មួយនៅក្នុងសេចក្តីសន្និដ្ឋានក្នុងមូលដ្ឋានរងទី ៥.២.i ដោយអះអាងថា ពុំមានភ័ស្តុតាងដែលថា យឹម ទិត្យ មាន ឬបានអនុវត្តភារកិច្ច ឬការទទួលខុសត្រូវជាក់លាក់ទេ[14]។ នៅក្នុងសេចក្តីសន្និដ្ឋានរបស់គាត់ក្នុងមូលដ្ឋានរងទី ៥.២.vi យឹម ទិត្យ ចោទប្រកាន់ថា ស.ច.ស.អ មិនបានបង្ហាញពី ធាតុផ្សំជា "សមាជិកភាព" នៃសហឧក្រិដ្ឋកម្មរួម ("JCE")[15] ទេ ហើយបានលើកឡើងពីទឡ្ហីករណ៍នៃការបង្ខិតបង្ខំ[16]។ ចាប់ពីដំបូងនៃមូលដ្ឋានរងទី ៥.៣.ii យឹម ទិត្យ លើកឡើងថា ការចោទប្រកាន់ពាក់ព័ន្ធនឹងសេចក្តីថ្លែងការណ៍របស់គាត់ប្រឆាំងនឹងវៀតណាម ពុំចាត់ទុកជាការចូលរួមចំណែកជាដុំកំភួនទេ ទោះបីមានភ័ស្តុតាងបង្ហាញក៏ដោយ[17]។ នៅក្នុងរង្វង់ក្រចក យឹម ទិត្យ អះអាងថា ការចោទប្រកាន់ទាំងនេះ "មិនបានកើតឡើងនោះទេ"[18]។ នៅក្នុងមូលដ្ឋានរងដដែលនេះ យឹម ទិត្យ លើកឡើងថា ដីកាបញ្ជូនរឿងទៅជំនុំជម្រះ "មិនមានភាពជាក់លាក់អំពីការទទួលខុសត្រូវរបស់លោក យឹម ទិត្យ នៅដំណាក់កាលផ្សេងៗគ្នាក្នុងអំឡុងពេលដែលគាត់ត្រូវបានចោទប្រកាន់ទេ"[19]។

10. ទឡ្ហីករណ៍ទាំងនេះពុំបានពង្រីកបន្ថែមឲ្យហួសពីការអះអាងធម្មតានោះឡើយ ហើយពុំមានយោង ឬដកស្រង់នូវសម្រង់អត្ថបទដើម្បីគាំទ្រឡើយ។ ចំណុចនេះពិតជាមិនពេញលេញសម្រាប់ យឹម ទិត្យ បំពេញទៅតាមបន្ទុកបង្ហាញភ័ស្តុតាងលើបណ្តឹងឧទ្ធរណ៍របស់ខ្លួនទេ។

## គ. មូលដ្ឋានបណ្តឹងឧទ្ធរណ៍សំអាងលើបទដ្ឋាន និងគោលការណ៍គតិយុត្តិដែលមិនត្រឹមត្រូវ

11. <u>បទដ្ឋាននៃភ័ស្តុតាងសម្រាប់ដីកាបញ្ជូនរឿងទៅជំនុំជម្រះ៖</u> អ.ប.ជ បានសម្រេចថា បទដ្ឋាននៃភ័ស្តុតាងសម្រាប់ចេញដីកាបញ្ជូនរឿងទៅជំនុំជម្រះគឺជា "ភ័ស្តុតាងគ្រប់គ្រាន់ៗ" នៃបទចោទ[20]

---

[14] ឯកសារ **D382/22** បណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ កថាខណ្ឌ ១៥១-១៥២។

[15] ឯកសារ **D382/22** បណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ កថាខណ្ឌ ២១៩។

[16] ឯកសារ **D382/22** បណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ កថាខណ្ឌ ២១៧ ("ស.ច.ស.អ មិនបានពិចារណា ឬអនុវត្តដោយមិនត្រឹមត្រូវចំពោះការសម្រេចផ្ទាល់របស់ខ្លួន នៅក្នុងសំណុំរឿង ០០៤/១ ដែលថា 'សេចក្តីសម្រេចត្រូវបានធ្វើឡើងនៅថ្នាក់កំពូល និងបន្ទាប់មក ត្រូវបានអនុវត្តដោយថ្នាក់ក្រោមៗ ដោយមិនខ្វល់ពីផលវិបាកក្នុងលក្ខណៈបុគ្គល ទោះនៅថ្នាក់ណាក៏ដោយ' ហើយ [...] ថ្នាក់ដឹកនាំកំពូល [...] ដែលអាចជ្រៀតជ្រែកតាមចិត្តចង់របស់ពួកគេ")។

[17] ឯកសារ **D382/22** បណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ កថាខណ្ឌ ២៤៦។

[18] ឯកសារ **D382/22** បណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ កថាខណ្ឌ ២៤៦។

[19] ឯកសារ **D382/22** បណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ កថាខណ្ឌ ២៤៩។

[20] សំណុំរឿង ០០៤/២-**D359/24** & **D360/33** (អ.ប.ជ) សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ កថាខណ្ឌ ៨៤។ សំណុំរឿង ០០៤/១ ឯកសារ **D308/3/1/20** (អ.ប.ជ) សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍របស់សហព្រះរាជ

មានន័យថា មាន “*ភាពអាចជឿជាក់បាន*” ឬ “*ភវនីយភាព*” នៃពិរុទ្ធភាព[21]។ បទដ្ឋាននេះនៅទាប ជាង “ហួសពីវិមតិសង្ស័យ”[22] ដោយសារ ការកំណត់នៅ “ដំណាក់កាលមុនការជំនុំជម្រះ [...] មិនពាក់ព័ន្ធនឹងការកំណត់ថាមានពិរុទ្ធ ឬគ្មានពិរុទ្ធភាពនោះទេ”[23]។

12. យឹម ទិត្យ សំអាងម្តងហើយម្តងទៀតទៅលើបទដ្ឋាននៃភស្តុតាងដែលមិនត្រឹមត្រូវ នៅពេលចោទប្រកាន់ពីកំហុស។ ឧទាហរណ៍ យឹម ទិត្យ អះអាងដោយមិនត្រឹមត្រូវថា នៅពេលប្រឈមនឹងភស្តុតាងប្រយោល ភស្តុតាងផ្ទុយ ឬភស្តុតាងដោះបន្ទុក ស.ច.ស ត្រូវបង្ហាញថា សេចក្តីសន្និដ្ឋានត្រូវតែជា “សេចក្តីសន្និដ្ឋានសមហេតុសមផល *តែមួយគត់* ដែលមាន ដោយផ្អែកលើភស្តុតាង”[24] ឬថា “ពុំមានអ្នកវិនិច្ឆ័យអង្គហេតុដែលមានហេតុផលអាចធ្វើការសន្និដ្ឋាន *ផ្សេង*ក្រៅពីនេះទេ”[25]។ ហេតុនេះ យឹម ទិត្យ សំអាងដោយមិនត្រឹមត្រូវទៅលើបទដ្ឋាននៃភស្តុតាងជាធរមាននៅដំណាក់កាលមុនការជំនុំជម្រះនៃកិច្ចដំណើរការនីតិវិធី។

13. ក្រៅពីនេះ និងផ្ទុយពីការអះអាងរបស់ យឹម ទិត្យ[26] គោលការណ៍ *វិមតិសង្ស័យបានជាប្រយោជន៍ដល់ជនជាប់ចោទ* មិនអនុវត្តចំពោះសេចក្តីសន្និដ្ឋានលើអង្គហេតុនៅដំណាក់កាលមុនការជំនុំជម្រះទេ។ ផ្ទុយទៅវិញ *វិមតិសង្ស័យបានជាប្រយោជន៍ដល់ជនជាប់ចោទ* គឺជាវិធានមួយនៃការបង្ហាញ

---

អាជ្ញាអន្តរជាតិ ប្រឆាំងនឹងដីកាដំណោះស្រាយ កថាខណ្ឌ ៦១។

[21] សំណុំរឿង ០០៤/២-**D359/24** & **D360/33** (អ.ប.ជ) សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ កថាខណ្ឌ ៨៤-៨៥ និងឯកសារយោងដែលភ្ជាប់មកជាមួយ។ សំណុំរឿង ០០៤/១ ឯកសារ **D308/3/1/20** (អ.ប.ជ) សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិ ប្រឆាំងនឹងដីកាដំណោះស្រាយ កថាខណ្ឌ ៦១។

[22] សំណុំរឿង ០០៤/២-**D359/24** & **D360/33** (អ.ប.ជ) សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ កថាខណ្ឌ ៨៤-៨៥។ សំណុំរឿង ០០៤/១ ឯកសារ **D308/3/1/20** (អ.ប.ជ) សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិ ប្រឆាំងនឹងដីកាដំណោះស្រាយកថាខណ្ឌ ៦១-៦២។ សំណុំរឿង ០០២ ឯកសារ **D427** ដីកាដំណោះស្រាយ កថាខណ្ឌ ១៣២៣។

[23] សំណុំរឿង ០០៤/២-**D359/24** & **D360/33** (អ.ប.ជ) សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ កថាខណ្ឌ ១៦៣។ *សូមមើល ផងដែរ* កថាខណ្ឌ ៨៥។ សំណុំរឿង ០០២ ឯកសារ **D427** ដីកាដំណោះស្រាយ កថាខណ្ឌ ១៣២៣។

[24] ឯកសារ **D382/22** បណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ កថាខណ្ឌ ១៨ (មានសេចក្តីបញ្ជាក់បន្ថែម) ។

[25] ឯកសារ **D382/22** បណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ កថាខណ្ឌ ១៨៨ (មូលដ្ឋានរងទី ៥.២.iii) (មានសេចក្តីបញ្ជាក់បន្ថែម) ។ *សូមមើល ផងដែរ* កថាខណ្ឌ ១៤០ (មូលដ្ឋានរងទី ៥.១), ១៩៧ (មូលដ្ឋានរងទី ៥.១.iv), ២០២ 202 (sub-(មូលដ្ឋានរងទី ៥.១.v), ២១៥ (មូលដ្ឋានរងទី ៥.១.vi)។

[26] ឯកសារ **D382/22** បណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ កថាខណ្ឌ ១៨។

ភ័ស្តុតាងដែលជាការទាញសេចក្តីសន្និដ្ឋានពីសច្ចធារណ៍និរទោស និងដែលអាចអនុវត្តបាន នៅពេលមានវិមតិសង្ស័យ រារាំងមិនឱ្យអ្នកវិនិច្ឆ័យអង្គហេតុធ្វើការសន្និដ្ឋានហួសពីមតិសង្ស័យ[27]។ ផ្នែកច្បាប់ជាធរមានរបស់ យឹម ទិត្យ រួមទាំងមូលដ្ឋានរងទី ៥.២.iii ដល់ ៥.២.vi របស់គាត់ អះអាងដោយមិនត្រឹមត្រូវថា គោលការណ៍ *វិមតិសង្ស័យបានជាប្រយោជន៍ដល់ជនជាប់ចោទ* អនុវត្តចំពោះការសន្និដ្ឋាននៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ[28]។

14. <u>គោលការណ៍សេរីភាពនៃភ័ស្តុតាង៖</u> អ.ប.ជ បានសម្រេចថា "រាល់ភ័ស្តុតាងទាំងអស់ត្រូវតែទទួលយក"[29] "ជាទូទៅមានតម្លៃជាភ័ស្តុតាងដូចគ្នា"[30] និង "ទទួលបាននូវសច្ចធារណ៍នៃភាពអាចជឿជាក់បាន តាមផ្លូវច្បាប់ដូចៗគ្នា ប្រសិនបើភ័ស្តុតាងទាំងនោះត្រូវបានប្រមូលមកដោយស្របច្បាប់"[31]។ ផ្ទុយពីការលើកឡើងរបស់ យឹម ទិត្យ ពុំមានភ័ស្តុតាង "គាំទ្រមានភាពទន់ខ្សោយ" នៅ អ.វ.ត.ក ទេ[32]។ ហេតុនេះ ភ័ស្តុតាងចចាមអារាមអាចទទួលយកបាន និងអាចយកមកសំអាងបានដែរ[33]។ ដូចគ្នាដែរ ពុំតម្រូវឱ្យមានការបញ្ជាក់បន្ថែមទេ ជាបញ្ញាគតិយុត្តិនៅ អ.វ.ត.ក[34]។ ហេតុ

---

[27] សំណុំរឿង ០០២ ឯកសារ **F36** សាលដីកាលើសំណុំរឿង ០០២/០១ កថាខណ្ឌ កថាខណ្ឌ ៨៤១។ *សូមមើល ផងដែរ* សាលដីកាលើរឿងក្តី *Limaj* កថាខណ្ឌ ២១។ សាលដីកាលើរឿងក្តី *Renzaho* កថាខណ្ឌ ៤៧៤។ *សូមមើល ខ្ទា.* សំណុំរឿង ០០៤/១ ឯកសារ **D308/3/1/20** (អ.ប.ជ) សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិ ប្រឆាំងនឹងដីកាដំណោះស្រាយ កថាខណ្ឌ ៦០-៦៣។ សំណុំរឿង ០០៤/១ ឯកសារ **D308/3** ដីកាដំណោះស្រាយ (សំអាងហេតុ) កថាខណ្ឌ ២។

[28] ឯកសារ **D382/22** បណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ កថាខណ្ឌ ១៨ (ច្បាប់ជាធរមាន), ១៨៨ (មូលដ្ឋានរងទី ៥.២.iii), ១៩៧ (មូលដ្ឋានរងទី ៥.២.iv), ២០២ (មូលដ្ឋានរងទី ៥.២.v), ២១៥ (មូលដ្ឋានរងទី ៥.២.vi)។

[29] សំណុំរឿង ០០៤/២-**D359/24** & **D360/33** (អ.ប.ជ) សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ កថាខណ្ឌ ៧៦។ *សូមមើល ផងដែរ* កថាខណ្ឌ ៧៧។ សំណុំរឿង ០០៤/១ ឯកសារ **D308/3/1/20** (អ.ប.ជ) សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិ ប្រឆាំងនឹងដីកាដំណោះស្រាយ កថាខណ្ឌ ៤៤, ៤៧, ៥១។ ឯកសារ **D370/1/1/6** (អ.ប.ជ) សេចក្តីសម្រេចលើពាក្យសុំធ្វើមោឃភាព កថាខណ្ឌ ១៧។

[30] សំណុំរឿង ០០៤/២-**D359/24** & **D360/33** (អ.ប.ជ) សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ កថាខណ្ឌ ៧៦។ *សូមមើល ផងដែរ* កថាខណ្ឌ ៧៧។ សំណុំរឿង ០០៤/១ ឯកសារ **D308/3/1/20** (អ.ប.ជ) សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិ ប្រឆាំងនឹងដីកាដំណោះស្រាយ កថាខណ្ឌ ៤៤, ៤៧, ៥១។ ឯកសារ **D370/1/1/6** (អ.ប.ជ) សេចក្តីសម្រេចលើពាក្យសុំធ្វើមោឃភាព កថាខណ្ឌ ១៧។

[31] សំណុំរឿង ០០៤/១ ឯកសារ **D308/3/1/20** (អ.ប.ជ) សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិ ប្រឆាំងនឹងដីកាដំណោះស្រាយ កថាខណ្ឌ ៥១។

[32] ឯកសារ **D382/22** បណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ កថាខណ្ឌ ១៩។

[33] សំណុំរឿង ០០៤/១ ឯកសារ **D308/3/1/20** (អ.ប.ជ) សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិ

នេះ យឹម ទិត្យ បានអះអាងដោយមិនត្រឹមត្រូវនៅក្នុងមូលដ្ឋានវងទី ៥.១, ៥.២, ៥.៣.i និង ៥.៣.iii ថា ស.ច.ស.អ មានកំហុសដោយសំអាងលើភស្តុតាងចចាមអារាម[35] ភស្តុតាងគ្មានការបញ្ជាក់បន្ថែម[36] និងភស្តុតាងចចាមអារាមគ្មានការបញ្ជាក់បន្ថែម[37]។

15. <u>សេចក្តីសម្រេចមានសំអាងហេតុ៖</u> មានការសន្មតថា ចៅក្រមបានវាយតម្លៃទៅលើភស្តុតាងទាំងអស់ ហើយពុំចាំបាច់លើកឡើងនូវគ្រប់ភស្តុតាងទាំងអស់ដែលមាននៅក្នុងសំណុំរឿងទេ[38] ដរាបណាពុំមានការបញ្ជាក់ថា ចៅក្រមពុំបានអើពើទាំងស្រុងលើភស្តុតាងជាក់លាក់ណាមួយនោះ[39]។ ទោះជាយ៉ាងណាក្តី សច្ចធារណ៍នេះអាចត្រូវបានជំទាស់ នៅពេលភស្តុតាងដែល *ជាប់ពាក់ព័ន្ធច្បាស់លាស់* ទៅនឹងការយល់ឃើញ មិនត្រូវបានដោះស្រាយនៅក្នុងការផ្តល់សំអាងហេតុរបស់ខ្លួននោះ[40]។

16. យឹម ទិត្យ មិនបានបង្ហាញនៅក្នុងមូលដ្ឋានវងទី ៥.២ ថា ស.ច.ស.អ មិនបានពិចារណាទៅលើភស្តុតាងរបស់សាក្សីដែល យឹម ទិត្យ អះអាងថាមិនធ្លាប់ឮពីឈ្មោះគាត់ទេ នៅពេលធ្វើការកំណត់ទៅលើមុខតំណែង និងសិទ្ធិអំណាចរបស់ យឹម ទិត្យ ដែលអាចមាន នៅភូមិភាគនិរតី និងភូមិភាគ

---

ប្រឆាំងនឹងដីកាដំណោះស្រាយ កថាខណ្ឌ ៤៤។ សំណុំរឿង ០០២ ឯកសារ **F36** សាលដីកាលើសំណុំរឿង ០០២/០១ កថាខណ្ឌ ៤៩។

[34] *សូមមើល* សំណុំរឿង ០០៤/១ ឯកសារ **D308/3/1/20** (អ.ប.ជ) សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិ ប្រឆាំងនឹងដីកាដំណោះស្រាយ កថាខណ្ឌ ៥១-៥២។ សំណុំរឿង ០០២ ឯកសារ **F36** សាលដីកាលើសំណុំរឿង ០០២/០១ កថាខណ្ឌ ៤៤។ *សូមមើល ផងដែរ* សាលដីកាលើសំណុំរឿង កថាខណ្ឌ ៣៥។

[35] ឯកសារ **D382/22** បណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ កថាខណ្ឌ ១៥០ (មូលដ្ឋានវងទី ៥.២.i)។

[36] ឯកសារ **D382/22** បណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ កថាខណ្ឌ ១៣៦ (មូលដ្ឋានវងទី ៥.១), ១៥៨ (មូលដ្ឋានវងទី ៥.២.ii), កថាខណ្ឌ ១៦៥វ១៦៦, ១៧១, ១៧៦, ១៧៩, ១៨២ (មូលដ្ឋានវងទី ៥.២.iii), ១៩៥ (មូលដ្ឋានវងទី ៥.២.iv), ១៩៨ (មូលដ្ឋានវងទី ៥.២.v), ២២៣-២២៤, ២២៨ (មូលដ្ឋានវងទី ៥.៣.i), ២៦០ (មូលដ្ឋានវងទី ៥.៣.iii)។

[37] ឯកសារ **D382/22** បណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ ១៥៧-១៥៨ (មូលដ្ឋានវងទី ៥.២.ii), ១៦៦-១៦៧(មូលដ្ឋានវងទី ៥.២.iii), ២០៥ (មូលដ្ឋានវងទី ៥.៣.iv), ២៣៨ (មូលដ្ឋានវងទី ៥.៣.i), ២៥៥ (មូលដ្ឋានវងទី ៥.៣.iii)។ ទោះជាក្នុងករណីណាក៏ដោយ ស.ច.ស.អ បានសម្រេចយ៉ាងច្បាស់ក្នុងការប្រើប្រាស់វិធីសាស្ត្រដោយប្រុងប្រយ័ត្ន ចំពោះភស្តុតាងចចាមអារ៉ាម និងមិនស៊ីសង្វាក់គ្នា *សូមមើល* ឯកសារ **D382** ដីកាដំណោះស្រាយ កថាខណ្ឌ ១២២-១២៤។

[38] សំណុំរឿង ០០២ ឯកសារ **F36** សាលដីកាលើសំណុំរឿង ០០២/០១ កថាខណ្ឌ ២០៧, ៣០៤។ សំណុំរឿង ០០២ ឯកសារ **D353/2/3** (អ.ប.ជ) សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹង 'ដីកាសម្រេចលើសំណើសុំបំពេញកិច្ចស៊ើបសួរ' កថាខណ្ឌ ៣០។

[39] សំណុំរឿង ០០២ ឯកសារ **F36** សាលដីកាលើសំណុំរឿង ០០២/០១ កថាខណ្ឌ ៣៥២។

[40] សំណុំរឿង ០០២ ឯកសារ **F36** សាលដីកាលើសំណុំរឿង ០០២/០១ កថាខណ្ឌ ៣៥២។

ពាយ័ព្យ[41]។ ស្រដៀងគ្នាដែរ ឧបសម្ព័ន្ធ ក នៃបណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ ដែលគាត់បាន ដកស្រង់*ផ្នែកខ្លះ*នៃចម្លើយរបស់សាក្សីនានាដែលគាត់អះអាងថា មិនដែលឮឈ្មោះគាត់នោះ ពុំប៉ះពាល់ ឬមិនជាប់ពាក់ព័ន្ធច្បាស់លាស់ទៅនឹងការលើកឡើងជាក់លាក់របស់សាក្សីទាំងអស់ដែលមិនស្គាល់ យឹម ទិត្យ និងបានផ្តល់ភ័ស្តុតាងអំពីអំពើ និងការប្រព្រឹត្តិរបស់គាត់នោះឡើយ[42]។ យឹម ទិត្យ មិនអើពើចំពោះការរក្សាការសម្ងាត់នៅសម័យបក្សកុម្មុយនីស្តកម្ពុជា ("ប.ក.ក") ដែលមិនឱ្យសាក្សីដឹងឮពីឈ្មោះគាត់ និងហានិភ័យដល់អាយុជីវិតចំពោះបុគ្គលណាដែលសាកសួរព័ត៌មានអំពីអាជ្ញាធរនោះ[43]។ ជាងនេះទៀត មូលដ្ឋានរងទី ៥.២.iii, ៥.២.v, ៥.២.vi និង ៥.៣ របស់ យឹម ទិត្យ[44] មិនបានជំទាស់ទៅនឹងសច្ចធារណ៍នោះ ដោយគ្រាន់តែលើកឡើងថា ស.ច.ស.អ មិនបានលើកយកចំណុចមួយចំនួននៃភ័ស្តុតាងនោះឡើយ[45]។

17. <u>បទដ្ឋាននៃការពិនិត្យលើសេចក្តីសម្រេចតាមឆន្ទានុសិទ្ធិ៖</u> ភាគីដែលស្នើសុំបដិសេធសេចក្តីសម្រេចតាមឆន្ទានុសិទ្ធិ*ត្រូវបង្ហាញថា* សេចក្តីសម្រេចនោះ៖ (១) ផ្អែកលើកំហុសលើអង្គច្បាប់ដែលនាំឱ្យសេចក្តីសម្រេចនោះគ្មានសុពលភាព (២) ផ្អែកលើកំហុសលើអង្គហេតុដែលបណ្តាលឱ្យមានភាពអយុត្តិធម៌ ឬ (៣) មានភាពអយុត្តិធម៌ ឬមិនសមហេតុសមផល ដែលជាការបំពានលើឆន្ទានុសិទ្ធិ និងបង្ខំឱ្យ ស.ច.ស ធ្វើការសន្និដ្ឋានដោយមិនបានអនុវត្តឆន្ទានុសិទ្ធិរបស់ខ្លួនដោយយុត្តិធម៌[46]។

---

[41] ឯកសារ **D382/22** បណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ ១៦០-១៦១ (មូលដ្ឋានរង ៥.២.ii), (មូលដ្ឋានរង ៥.២)។ យឹម ទិត្យ ធ្វើការជំទាស់តវ៉ាស្រដៀងគ្នានេះដែរ ចំពោះការចូលរួមចំណែកលេចធ្លោរបស់គាត់ នៅក្នុងសហឧក្រិដ្ឋកម្មរួមប្រភេទ ក។ *សូមមើល* កថាខណ្ឌ ២៣៤ (មូលដ្ឋានរង ៥.៣.i)។

[42] *Contra* ឯកសារ **D382/22** បណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ ១៦០-១៦១ ២៣៤ (មូលដ្ឋានរង ៥.៣.ii), ២១៧ (មូលដ្ឋានរង ៥.២.vi) ២៣៤ (មូលដ្ឋានរង ៥.៣.i)។ ឯកសារ **D382/22.2** ឧបសម្ពន្ធ ក។

[43] សំណុំរឿង ០០១ ឯកសារ **E188** សាលក្រម *ឌុច* កថាខណ្ឌ ៩៧។ សំណុំរឿង ០០២ ឯកសារ **E313** សាលក្រមសំណុំរឿង ០០២/១ កថាខណ្ឌ ១៩៩, ២៥០, ៦៤១, ៧២៦, ៧៣១, ៧៣៧។ សំណុំរឿង ០០២ ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣៩២, ៣៩៨, ៤៥៩, ៣៩២៧, ៣៩៣៨វ៣៩៣៩។ សំណុំរឿង ០០២ ឯកសារ **F36** សាលដីកាលើសំណុំរឿង ០០២/០១ កថាខណ្ឌ ១០៦៨។ *សូមមើល ខ.* ឯកសារ **D118/293** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ស៊ូ ឡុន ឆ.៦២-៦២។ ឯកសារ **D219/294** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី មូល អេង ឆ.១២៤។

[44] ឯកសារ **D382/22** បណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ កថាខណ្ឌ ១៦៥, ១៧៤-១៧៥, ១៨៤-១៨៥, ១៨៧ (មូលដ្ឋានរងទី ៥.២.iii), ១៩៩-២០០, ២០២ (មូលដ្ឋានរងទី ៥.២.v), ២០៦, ២០៩-២១២, ២១៨ (មូលដ្ឋានរងទី ៥.២.vi), ២២៣, ២២៧, ២២៨ (មូលដ្ឋានរងទី ៥.៣)។

[45] សំណុំរឿង ០០២ ឯកសារ **F36** សាលដីកាលើសំណុំរឿង ០០២/០១ កថាខណ្ឌ ៣៥៧។

[46] *សូមមើល* សំណុំរឿង ០០៤/២-**D359/24** & **D360/33** (អ.ប.ជ) សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកា

និយាយម្យ៉ាងទៀត គេត្រូវបង្ហាញថា មានកំហុស ឬការបំពានដែលមានអានុភាពទៅលើការអនុវត្តឆន្ទានុសិទ្ធិរបស់ ស.ច.ស[47]។ តទៅនេះ ការលើកយោងទាំងអស់នៅក្នុងសារណានេះសំដៅដល់កំហុសលើអង្គច្បាប់ កំហុសលើអង្គហេតុ ឬការបំពានលើឆន្ទានុសិទ្ធិដែលអាចពិនិត្យឡើងវិញបាន សំដៅដល់បទដ្ឋានទាំងនេះ។

18. យឹម ទិត្យ ជំទាស់ថា ស.ច.ស.អ បានប្រព្រឹត្តកំហុសលើអង្គច្បាប់ កំហុសលើអង្គហេតុ និងបានបំពានឆន្ទានុសិទ្ធិរបស់ខ្លួនក្នុងការសន្និដ្ឋានថា យឹម ទិត្យ ជា "អ្នកទទួលខុសត្រូវខ្ពស់បំផុត" ចំពោះឧក្រិដ្ឋកម្មក្នុងសម័យកម្ពុជាប្រជាធិបតេយ្យ[48]។ ចំពោះវិសាលភាពដែលថា យឹម ទិត្យ បានចោទប្រកាន់នៅក្នុងបណ្ដឹងឧទ្ធរណ៍ទាំងមូលរបស់ខ្លួនថា ស.ច.ស.អ បានបំពានឆន្ទានុសិទ្ធិរបស់ខ្លួននោះ ស.ព.អ យល់ថា ចំណុចនេះពាក់ព័ន្ធនឹងយុត្តាធិការបុគ្គល។ ទោះជាយ៉ាងណាក្ដី នៅពេល ស.ច.ស យល់ឃើញថា មានភ័ស្តុតាងគ្រប់គ្រាន់ដែលជនត្រូវចោទស្ថិតក្នុងយុត្តាធិការបុគ្គលរបស់ អ.វ.ត.ក នោះ ពុំមានឆន្ទានុសិទ្ធិក្នុងការបញ្ជូនទៅជំនុំជម្រះ ឬក៏អត់នោះឡើយ[49]។

19. យឹម ទិត្យ ខកខានម្ដងហើយម្ដងទៀតមិនបានបញ្ជាក់ឲ្យច្បាស់នូវបទដ្ឋានត្រឹមត្រូវនៃការពិនិត្យឡើងវិញនៅក្នុងមូលដ្ឋាននានានៃបណ្ដឹងឧទ្ធរណ៍របស់ខ្លួនទេ។ ទឡ្ហីករណ៍របស់ យឹម ទិត្យ នៅក្នុងមូលដ្ឋានរងទី ១.២.i.ខ ដែលថា ការស៊ើបអង្កេតក្នុងសំណុំរឿង ០០៤ មានភាពប្រឡាក់ប្រឡូសសន្និដ្ឋានដោយលើកឡើងថា សំណុំរឿងគួរតែត្រូវបានច្រានចោលដើម្បីចៀសវាងភាពអយុត្តិធម៌[50] គឺជាបទដ្ឋាននៃការពិនិត្យឡើងវិញចំពោះកំហុសលើអង្គហេតុ។ ទោះជាយ៉ាងណាក្ដី សេចក្ដីផ្ដើមរបស់គាត់នៅក្នុងមូលដ្ឋានរងទី ១.២ កំណត់អំពីកំហុសដែលត្រូវបានចោទប្រកាន់នៅក្នុងផ្នែកនោះជាការបំពានឆន្ទានុសិទ្ធិទៅវិញ[51] រីឯចំណងជើងមូលដ្ឋានទី១ ចោទប្រកាន់ពីកំហុសលើអង្គ

---

ដំណោះស្រាយ កថាខណ្ឌ ២៩។ សំណុំរឿង ០០៤/១ ឯកសារ **D308/3/1/20** (អ.ប.ជ) សេចក្ដីពិចារណាលើបណ្ដឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិ ប្រឆាំងនឹងដីកាដំណោះស្រាយ កថាខណ្ឌ២១។

[47] *សូមមើល* សំណុំរឿង ០០៤/២-**D359/24** & **D360/33** (អ.ប.ជ) សេចក្ដីពិចារណាលើបណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ កថាខណ្ឌ ២៩។ សំណុំរឿង ០០៤/១ ឯកសារ **D308/3/1/20** (អ.ប.ជ) សេចក្ដីពិចារណាលើបណ្ដឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិ ប្រឆាំងនឹងដីកាដំណោះស្រាយ កថាខណ្ឌ ២១។

[48] ឯកសារ **D382/22** បណ្ដឹងឧទ្ធរណ៍របស់ យឹម ទិត្យ កថាខណ្ឌ ១, ២៦៧។

[49] សំណុំរឿង ០០១ ឯកសារ **D99/3/42** (អ.ប.ជ) សាលដីកាលើបណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាបញ្ជូនរឿងទៅជំនុំជម្រះ កថាខណ្ឌ ៣៧។

[50] ឯកសារ **D382/22** បណ្ដឹងឧទ្ធរណ៍របស់ យឹម ទិត្យ កថាខណ្ឌ ៣៥។

[51] ឯកសារ **D382/22** បណ្ដឹងឧទ្ធរណ៍របស់ យឹម ទិត្យ កថាខណ្ឌ ២៦។

ច្បាប់[52]។ ជាងនេះទៀត យឹម ទិត្យ លើកឡើងនៅក្នុងសេចក្តីសន្និដ្ឋានសម្រាប់មូលដ្ឋានទី១ ថា "អ.ប.ជ ត្រូវតែកែប្រែកំហុសលើអង្គច្បាប់យ៉ាងធ្ងន់ធ្ងររបស់ ស.ច.ស.អ ដែលបានចេញដីកាបញ្ជូនទៅជំនុំជម្រះ [...] ហេតុនេះសូមបដិសេធសំណុំរឿង ០០៤ ដើម្បីបញ្ចៀសកុំឱ្យភាពអយុត្តិធម៌ធ្ងន់ធ្ងរ"[53]។

20. ដូចគ្នាដែរ មូលដ្ឋានទី ៤ របស់ យឹម ទិត្យ ត្រូវបានកំណត់ថាជាកំហុសលើអង្គច្បាប់ តាំងពីដំបូងមក[54]។ ទោះជាយ៉ាងណាក្តី សេចក្តីសន្និដ្ឋានរបស់គាត់ចំពោះមូលដ្ឋាននេះយោងទៅបទដ្ឋាននៃការពិនិត្យឡើងវិញសម្រាប់កំហុសលើអង្គហេតុ និងចោទប្រកាន់ពីការបំពានឆន្ទានុសិទ្ធិទៅវិញ[55]។ ហើយ មូលដ្ឋានទី ៥ របស់ យឹម ទិត្យ ចោទប្រកាន់ពីកំហុសលើអង្គហេតុ និងលើអង្គច្បាប់តាំងពីដំបូង ហើយបានយោងទៅជាការបំពានឆន្ទានុសិទ្ធិនៅក្នុងមូលដ្ឋានរងទី ៥.២.iii ទៅវិញ[56]។

21. ជាងនេះទៀត យឹម ទិត្យ បានអនុវត្តមិនត្រឹមត្រូវនូវលក្ខខណ្ឌវិនិច្ឆ័យជាធរមានសម្រាប់កំណត់អំពីការបំពានឆន្ទានុសិទ្ធិ ដោយចោទប្រកាន់យ៉ាងខុសឆ្គងថា កំហុសលើអង្គច្បាប់ក្នុងមូលដ្ឋានរងទី ២.៣ និង មូលដ្ឋានទី ៣ ព្រមទាំងកំហុសលើអង្គហេតុនៅក្នុងមូលដ្ឋានរងទី ៥.១, ៥.២.iii, ៥.២.iv, ៥.៣.i, និង ៥.៣.iii គឺជា "ការបំពានឆន្ទានុសិទ្ធិ"[57]។ ទោះជាយ៉ាងណាក្តី ការចោទប្រកាន់ពីកំហុសលើអង្គច្បាប់ ឬលើអង្គហេតុត្រូវបានយកមកវិនិច្ឆ័យទៅតាមបទដ្ឋានថាតើ មានការមិនអនុវត្តឆន្ទានុសិទ្ធិដោយយុត្តិធម៌ ឬយ៉ាងណា ចំណែកឯ "ការបំពានឆន្ទានុសិទ្ធិ" អនុវត្តចំពោះកត្តានានាក្រៅពីកំហុសលើអង្គច្បាប់ ឬលើអង្គហេតុដែល "មានភាពអយុត្តិធម៌ "មិនសមហេតុសមផល ដែលជាបំពានលើឆន្ទានុសិទ្ធិរបស់សហចៅក្រមស៊ើបអង្កេត"[58]។ ជាងនេះទៀត

[52] ឯកសារ **D382/22** បណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ ERN 01636726។

[53] ឯកសារ **D382/22** បណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ កថាខណ្ឌ ៥៥។

[54] ឯកសារ **D382/22** បណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ ERN 01636790-1។

[55] ឯកសារ **D382/22** បណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ កថាខណ្ឌ ១២០។

[56] ឯកសារ **D382/22** បណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ ERN 01636800-1, 01636814-5 កថាខណ្ឌ ១៧៥។

[57] ឯកសារ **D382/22** បណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ កថាខណ្ឌ ៨១ (មូលដ្ឋានរងទី ២.៣), ៩៩, ១០២-១០៣មូលដ្ឋានទី ៣), ១២៦ មូលដ្ឋានរងទី ៥.១), ១៧៥ (មូលដ្ឋានរងទី ៥.២.iii), ១៩០, ១៩៣, ១៩៧ (មូលដ្ឋានរងទី ៥.២.iv), ២៤០-២៤១ (មូលដ្ឋានរងទី ៥.៣.i), ២៥៤, ២៥៨, ២៦៤ ២៤១ (មូលដ្ឋានរងទី ៥.៣.iii)។

[58] *សូមមើល* សំណុំរឿង ០០៤/២-**D359/24** & **D360/33** (អ.ប.ជ) សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ កថាខណ្ឌ ២៩។ សំណុំរឿង ០០៤/១ ឯកសារ **D308/3/1/20** (អ.ប.ជ) សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិ ប្រឆាំងនឹងដីកាដំណោះស្រាយ កថាខណ្ឌ ២១។

យឹម ទិត្យ ខកខានមិនបានបង្ហាញថា ទឡ្ហីករណ៍នានារបស់គាត់បំពេញទៅតាមលក្ខខណ្ឌវិនិច្ឆ័យ មិនត្រឹមត្រូវដែលគាត់មានបំណងយកមកអនុវត្ត កុំថាឡើយដល់បទដ្ឋានត្រឹមត្រូវទៀតនោះ។ មូលដ្ឋានទី ២ និងទី៤ និង មូលដ្ឋានទី ១.២, ៥.២ និង ៥.៣ របស់គាត់ត្រឹមតែអះអាងថា ស.ច.ស.អ បានបំពានឆន្ទានុសិទ្ធិរបស់ខ្លួន ដោយមិនបានបង្ហាញពីរបៀប ឬ សំអាងគាំទ្រដល់ការអះអាងរបស់គាត់តាមវិធីណាមួយឡើយ[59]។ ហេតុនេះ ទឡ្ហីករណ៍ទាំងនេះគួរតែត្រូវបានច្រានចោលដោយពុំចាំបាច់យកមកពិភាក្សាឡើយ។

22. ការណ៍ដែល យឹម ទិត្យ ប្រើប្រាស់បទដ្ឋាននៃបណ្តឹងឧទ្ធរណ៍មិនត្រឹមត្រូវ មិនគួរទទួលបានការអនុញ្ញាតឲ្យពង្រីកវិសាលភាពនៃការអះអាងរបស់គាត់ដោយមិនសមរម្យនោះឡើយ។ ការណ៍ដែល យឹម ទិត្យ ខកខានម្តងហើយម្តងទៀតមិនបានបង្ហាញអំពីបទដ្ឋានត្រឹមត្រូវនៃការពិនិត្យឡើងវិញនោះ បណ្តាលឲ្យមានការខកខានក្នុងការបង្ហាញថា គាត់បានបំពេញទៅតាមបទដ្ឋានបណ្តឹងឧទ្ធរណ៍ដែលគាត់បានចោទប្រកាន់នោះ។

## III. សារណា

### ក. មូលដ្ឋានទី១÷ យឹម ទិត្យ មិនបានបង្ហាញពីកំហុសដែលអាចពិនិត្យឡើងវិញបាន ទាក់ទិននឹងការស៊ើបអង្កេតក្នុងសំណុំរឿង ០០៤ និង ការចេញដីកាបញ្ជូនរឿងទៅជំនុំជម្រះនេ

23. ប្រសិនបើអង្គជំនុំជម្រះយល់ឃើញថាអាចទទួលយកបាន[60] យឹម ទិត្យ ខកខានមិនបានបង្ហាញអំពីកំហុសលើអង្គច្បាប់ដែលអាចពិនិត្យឡើងវិញ ឬការបំពានឆន្ទានុសិទ្ធិនៅក្នុងដំណើរការស៊ើបអង្កេតក្នុងសំណុំរឿង ០០៤ របស់ ស.ច.ស.អ និងការសម្រេចចេញដីកាបញ្ជូនរឿងទៅជំនុំជម្រះ ដោយផ្អែកលើការអះអាងរបស់ យឹម ទិត្យ ដែលថា សិទ្ធិជាសារវន្តរបស់គាត់ក្នុងការទទួលបានការជំនុំជម្រះក្តីដោយយុត្តិធម៌ត្រូវបានរំលោភបំពាន។ ផ្ទុយពីការអះអាងរបស់ យឹម ទិត្យ ស.ច.ស.អ បានពិចារណាទៅលើទឡ្ហីករណ៍ទាំងនេះ ហើយហេតុនេះ គាត់មិនបានរំលោភលើសិទ្ធិផ្តល់សក្ខីកម្ម

---

[59] ឯកសារ **D382/22** បណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ កថាខណ្ឌ ២៦ (មូលដ្ឋានរងទី ២.១), ៧៩ (មូលដ្ឋានរងទី ២.២), ៩៤ (មូលដ្ឋានរងទី ២.៣), ១២០ (មូលដ្ឋានរងទី ៤), ២២០ (មូលដ្ឋានរងទី ៥.២), ២២៦, ២៣១, ២៤០, ២៤១ (មូលដ្ឋានរងទី ៥.៣.i), ២៥០ (មូលដ្ឋានរងទី ៥.៣.ii), ២៥៤, ២៥៨, (មូលដ្ឋានរងទី ៥.៣.iii), ២៦៧ (សេចក្តីសន្និដ្ឋានរួមនៃបណ្តឹងឧទ្ធរណ៍)។

[60] *សូមមើល* សំណើបឋមនានា កថាខណ្ឌ ៤-៥ (ភាពមិនអាចទទួលយកបាន)។

របស់ យឹម ទិត្យ ឡើយ[61]។ ជាងនេះទៀត សំណើដែលពុំមានមូលដ្ឋានរបស់ យឹម ទិត្យ សុំច្រាន ចោលសំណុំរឿង ០០៤ គឺជារឿងមិនសមហេតុសមផល និងមិនសមាមាត្រទៅលើព្យសនកម្ម ដែលគាត់អាចទទួលរងឡើយ[62]។

## ១. យឹម ទិត្យ មិនបានបង្ហាញនូវកំហុសណាមួយដែលអាចពិនិត្យឡើងវិញបាន ដោយផ្អែកលើដីកាលើកទី ៣ ទេ

24. យឹម ទិត្យ ខកខានមិនបានបង្ហាញពីកំហុសលើអង្គច្បាប់ដែលអាចពិនិត្យឡើងវិញបាន ក្នុងការចាប់ផ្ដើមការស៊ើបអង្កេតក្នុងសំណុំរឿង ០០៤ តាមរយៈការដាក់ដីកាលើកទី ៣ ទេ[63]។

25. ទីមួយ ការអះអាងរបស់ យឹម ទិត្យ ត្រូវបានលើកឡើងមិនទាន់ពេលវេលា និងគ្មានមូលដ្ឋាន សំអាង។ គាត់អាចស្នើសុំឱ្យធ្វើមោឃភាពផ្នែកណាមួយនៃកិច្ចដំណើរការនីតិវិធី ក្នុងអំឡុងពេល ស៊ើបអង្កេត ដោយផ្អែកលើមូលដ្ឋាននៃការអះអាងរបស់គាត់នៅពេលនេះ។ គាត់បែរជាមិនជ្រើស រើសធ្វើបែបនេះទេ ផ្ទុយទៅវិញ គាត់បានរង់ចាំរហូតដល់ពេលបញ្ចប់ការស៊ើបអង្កេតដើម្បីលើក ឡើងនូវបញ្ហានេះជាដំបូង[64]។ ជាងនេះទៀត សំណើសុំធ្វើមោឃភាពរបស់ យឹម ទិត្យ ក្នុងអំឡុង ពេលស៊ើបអង្កេតបង្ហាញថា គាត់ទទួលយកសុពលភាពនៃដីកាលើកទី ៣ និងលទ្ធផលនៃការស៊ើប អង្កេតក្នុងសំណុំរឿង ០០៤[65]។

---

[61] ឯកសារ **D382/22** បណ្ដឹងឧទ្ធរណ៍របស់ យឹម ទិត្យ កថាខណ្ឌ២០។ ឯកសារ **D382** ដីកាសំណោះស្រាយ កថាខណ្ឌ ២៤។

[62] *សូមមើល* ឯកសារ **D382/22** បណ្ដឹងឧទ្ធរណ៍របស់ យឹម ទិត្យ កថាខណ្ឌ ២០, ៥៥។

[63] ឯកសារ **D382/22** បណ្ដឹងឧទ្ធរណ៍របស់ យឹម ទិត្យ កថាខណ្ឌ ២១-២៤ (មូលដ្ឋានរងទី ១.១)។

[64] ឯកសារ **D378/5** ចម្លើយតបរួមរបស់ យឹម ទិត្យ ទៅនឹងដីកាសន្និដ្ឋានស្ថាពររបស់សហព្រះរាជអាជ្ញាជាតិ និងសហព្រះរាជអាជ្ញាអន្តរជាតិ ចុះថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ២០១៨ ("ចម្លើយតបរួមរបស់ យឹម ទិត្យ ទៅនឹងដីកាសន្និដ្ឋានស្ថាពរ") កថាខណ្ឌ ២៤៨-២៥៨។

[65] *សូមមើល ឧទា.* កសារ **D370** ពាក្យសុំរបស់ យឹម ទិត្យ ស្នើឱ្យអង្គបុរេជំនុំជម្រះធ្វើមោឃភាពលើសំណើសុំ និង ការប្រើប្រាស់ព័ត៌មានបន្ថែមរបស់ដើមបណ្ដឹងរដ្ឋប្បវេណី និង សម្ភារះស៊ើបអង្កេតពាក់ព័ន្ធនានា នៅក្នុងសំណុំរឿង ០០៤ ចុះថ្ងៃទី ១២ ខែកញ្ញា ឆ្នាំ ២០១៧។ ឯកសារ **D360/1/1/2** ពាក្យសុំរបស់ យឹម ទិត្យ សុំធ្វើមោឃភាពការដាក់សក្ខីកម្មផ្ទាល់មាត់ពី សំណុំរឿង ០០២ ទៅក្នុងសំណុំរឿង ០០៤ ចុះថ្ងៃទី៣០ ខែមិថុនា ឆ្នាំ ២០១៧។ ឯកសារ **D351/1/2** សំណើសុំរបស់ យឹម ទិត្យ សុំធ្វើមោឃភាពឯកសារស៊ើបអង្កេតដែលធ្វើឡើងដោយ Paolo Stocchi ចុះថ្ងៃទី២៨ ខែមេសា ឆ្នាំ ២០១៧។

26. ទីពីរ អ.ប.ជ បានពិចារណាករណីខ្វែងយោបល់គ្នារវាងសហព្រះរាជអាជ្ញា អនុលោមតាមវិធាន ៧១(១)(២) ទាក់ទិននឹងកិច្ចដំណើរការនីតិវិធីជាមួយសំណុំរឿង ០០៤[66] និងមិនអាចទទួលបានសំឡេងគាំទ្រភាគច្រើនតាមការចាំបាច់បាន[67]។ លទ្ធផលដែលមិនមានសម្លេងភាគច្រើនបែបនេះអនុលោមតាមវិធាន ៧១(៤)(ឃ) គឺថា ដីកាលើកទី ៣ បានបញ្ជូនរឿងទៅស៊ើបអង្កេត ហើយ ស.ច.ស បានទទួលយកទៅស៊ើបអង្កេតយ៉ាងត្រឹមត្រូវ[68]។

27. ទីបី ដំណើរការស៊ើបអង្កេតក្នុងសំណុំរឿង ០០៤ បានធ្វើឱ្យទឡ្ហីករណ៍របស់ យឹម ទិត្យ ទទួលបរាជ័យ ដូចដែលបានបង្ហាញម្តងហើយម្តងទៀតនូវសុពលភាពរបស់ដីកាលើកទី ៣[69]។ នៅក្នុងសំណុំរឿង ០០៤/២ អ.ប.ជ បានដោះស្រាយនាពេលថ្មីៗនូវភាពសមហេតុផលនៃដីកាដំណោះស្រាយចំនួនពីរ និងអង្គសេចក្តីនៃដីកាទាំងពីរនៅក្នុងសំណុំរឿងនោះ[70]។ ប្រសិនបើដីកាលើកទី ៣ និងលទ្ធផលនៃការស៊ើបអង្កេតមិនមានសុពលភាពវិញនោះ អ.ប.ជ ពុំចាំបាច់ពិចារណាទៅលើបញ្ហាទាំងនេះឡើយ។ ដូចគ្នាដែរ នៅក្នុងសំណុំរឿង ០០៤/១ ស.ច.ស បានចេញសេចក្តីសម្រេចរួមមួយទៅលើអង្គសេចក្តីនៃការស៊ើបអង្កេត ហើយ អ.ប.ជ បានចេញសេចក្តីពិចារណារបស់ខ្លួនលើបណ្តឹងឧទ្ធរណ៍នៃអង្គសេចក្តីទាំងនោះ ដោយមិនបានសន្និដ្ឋានថា ដីកាលើកទី ៣ ឬការស៊ើបអង្កេតក្នុងសំណុំរឿង ០០៤ ពុំមានសុពលភាពនោះឡើយ[71]។

---

[66] *ផ្ទុយពី* ឯកសារ **D382/22** បណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ កថាខណ្ឌ ២៣។

[67] ឯកសារ **D1/1.3** (អ.ប.ជ) ការពិចារណារបស់អង្គបុរេជំនុំជម្រះពាក់ព័ន្ធនឹងករណីខ្វែងយោបល់គ្នារបស់សហព្រះរាជអាជ្ញា អនុលោមតាមវិធាន ៧១ នៃវិធានផ្ទៃក្នុង។

[68] យឹម ទិត្យ អះអាងខុសថា ដីកាបញ្ជូនរឿងឱ្យស៊ើបសួរលើកទីបីពុំមានសុពលភាពទេ ដោយសារដីកានេះត្រូវបានចុះហត្ថលេខាដោយ ស.ព.អ ស្តីទីតែម្នាក់គត់។ ឯកសារ **D382/22** បណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ កថាខណ្ឌ ២៤។ ប៉ុន្តែ *សូមមើល* ឯកសារ **D1** ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរទី៣របស់សហព្រះរាជអាជ្ញា ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០០៨ ("ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរទី៣") EN 00292472។

[69] សំណុំរឿង ០០៤/២ ឯកសារ **D360** ដីកាដំណោះស្រាយ កថាខណ្ឌ ៤១-៤២។

[70] សំណុំរឿង ០០៤/២-**D359/24** & **D360/33** (អ.ប.ជ) សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ កថាខណ្ឌ ៨៨-១២៤។

[71] សំណុំរឿង ០០៤/១ ឯកសារ **D308/3** ដីកាដំណោះស្រាយ (សំអាងហេតុ)។ សំណុំរឿង ០០៤/១ ឯកសារ **D308/3/1/20** (អ.ប.ជ) សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិ ប្រឆាំងនឹងដីកាដំណោះស្រាយ។

## ២. យឹម ទិត្យ មិនបានបង្ហាញពីការជ្រៀតជ្រែកណាមួយទៅក្នុងកិច្ចការរដ្ឋបាលរបស់តុលាការទេ

28. យឹម ទិត្យ ខកខានមិនបានបង្ហាញថា ស.ច.ស បានបំពានឆន្ទានុសិទ្ធិរបស់ខ្លួនដោយចេញដីកាបញ្ជូនរឿងទៅជំនុំជម្រះ ដោយមានការបែកធ្លាយដីកាលើកទី ៣[72]។ ទោះបីការបែកធ្លាយគួរឱ្យសោកស្តាយក្តី តែ យឹម ទិត្យ មិនបានបង្ហាញថា ការផ្សព្វផ្សាយជាសាធារណៈនូវការចោទប្រកាន់ជាទូទៅ រំលោភបំពានទៅលើសច្ចធារណ៍និរទោស ឬធ្វើឱ្យប៉ះពាល់ដល់ការស៊ើបអង្កេតនោះទេ។

29. សច្ចធារណ៍និរទោសការពារប្រឆាំងនឹងការប្រកាសជាមុនថាមានពិរុទ្ធភាព។ អ.ប.ជ បានគូសបញ្ជាក់ថា ដំណាក់កាលមុនជំនុំជម្រះ "មិនពាក់ព័ន្ធនឹងការកំណត់ថា មានពិរុទ្ធភាព ឬគ្មានពិរុទ្ធភាពនោះទេ" ហើយថា "សច្ចធារណ៍និរទោសត្រូវបានការពារគ្រប់គ្រាន់ ដោយហេតុថា អនុលោមតាមវិធាន ៩៨(៤) *ការសម្រេចផ្តន្ទាទោស*នៅក្នុងដំណាក់កាលជំនុំជម្រះក្តី ទាមទារឱ្យមានសំឡេងគាំទ្រយ៉ាងហោចណាស់ពីចៅក្រមបួនសំឡេង និងនៅពេលរកសម្លេងភាគច្រើនតាមតម្រូវការមិនបានទេ "មានន័យថា ជនជាប់ចោទត្រូវរួចផុតពីបទចោទ""[73]។ ប្រសិនបើសនិទានភាពមានកំហុសរបស់ យឹម ទិត្យ ត្រូវបានទទួលយកនោះ ការស៊ើបសួរជាសាធារណៈ បេសកកម្មស្វែងរកការពិត ឬគណៈកម្មការស្វែងរកការពិត និងការផ្សះផ្សារដែលបង្ហាញឈ្មោះអ្នកដែលអាចជាជនដៃដល់ នឹងរារាំងមិនឱ្យមានការស៊ើបអង្កេតព្រហ្មទណ្ឌនាពេលក្រោយទេ។

30. ទឡ្ហីករណ៍របស់ យឹម ទិត្យ ក៏ផ្ទុយផងដែរទៅនឹងវិធាននៃផ្ទៃក្នុងដែលចែងឱ្យមានការជូនដំណឹងដល់សាធារណជនក្នុងអំឡុងពេលស៊ើបអង្កេត[74]។ យឹម ទិត្យ បានទទួលស្គាល់នូវការពិតនេះក្នុងឆ្នាំ ២០១៦ នៅពេលលើកឡើងថា "ព័ត៌មានតែមួយគត់ដែលអាចរកបាននាពេលថ្មីៗនេះទាក់ទិននឹងលោក យឹម ទិត្យ នៅក្នុងផ្នែកសាធារណៈគឺជាការពណ៌នាយ៉ាងសង្ខេបមួយនៅលើគេហទំព័ររបស់ អ.វ.ត.ក ដោយបង្ហាញពីឈ្មោះរបស់គាត់ បទឧក្រិដ្ឋដែលបានចោទប្រកាន់ និងទីតាំងនៃបទឧក្រិដ្ឋដែលបានចោទប្រកាន់នោះ"[75]។ ការណ៍ដែល យឹម ទិត្យ មិនបានយោងទៅដល់ការបែកធ្លាយនៃ

---

[72] *ផ្ទុយពី* ឯកសារ **D382/22** បណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ កថាខណ្ឌ ២៧-២៩ (មូលដ្ឋានរងទី ១.២.i.ក)។

[73] សំណុំរឿង ០០៤/២-**D359/24** & **D360/33** (អ.ប.ជ) សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ កថាខណ្ឌ ១៦៣ (មានសេចក្តីបញ្ជាក់បន្ថែមក្នុងឯកសារដើម)។ *សូមមើល ផងដែរ* សំណុំរឿង ០០២ ឯកសារ **E176/2/1/4** (អ.ជ.ត.ក) សេចក្តីសម្រេចលើបណ្តឹងសាទុក្ខរបស់ នួន ជា ប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងលើសំណើសុំឱ្យចាត់ការជាបន្ទាន់ តាមវិធាន ៣៥ នៃវិធានផ្ទៃក្នុង កថាខណ្ឌ ៥២។

[74] *សូមមើល ឧទា.* វិធាន ៥៤ និង ៥៦ នៃវិធានផ្ទៃក្នុង។

[75] ឯកសារ **D193/76** សំណើរបស់ យឹម ទិត្យ សុំឱ្យពិចារណាឡើងវិញចំពោះសេចក្តីសម្រេចលើសំណើរបស់សហព្រះរាជ

ដីកាលើកទី ៣ នៅឆ្នាំ២០១៦ បង្ហាញពីភាពគ្មានមូលដ្ឋាន និងដាក់មិនទាន់ពេលវេលានូវទឡ្ហីករណ៍របស់គាត់នាពេលនេះ។

31. ក្រៅពីនេះ ការអះអាងរបស់ យឹម ទិត្យ ត្រូវបានបដិសេធដោយការអនុវត្តនៅ អ.វ.ត.ក។ ឧទាហរណ៍ តុលាការបានផ្សព្វផ្សាយនូវព័ត៌មានលម្អិតនៃការចោទប្រកាន់ដែលកំពុងស៊ើបអង្កេត ដើម្បីអាចឱ្យជនរងគ្រោះដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីបាន[76]។ ជាងនេះទៀត ក្នុងអំឡុងពេលស៊ើបអង្កេតក្នុងសំណុំរឿង ០០៤ សាក្សីបានផ្តល់សក្ខីកម្មជាសាធារណៈដោយបានធ្វើសម្បថនៅក្នុងសំណុំរឿង ០០២/០២ អំពីទំនាក់ទំនងរបស់ យឹម ទិត្យ ជាមួយ តាម៉ុក មុខតំណែងរបស់ យឹម ទិត្យ នៅក្នុងគណៈកម្មាធិការតំបន់ ១៣ និងការចេញបទបញ្ជានានានៅក្នុងមុខតំណែងនានា ព្រមទាំងការចូលរួមរបស់គាត់ក្នុងការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ[77]។ អ.ប.ជ បានសម្រេចថា ការយោងទៅ "ឈ្មោះ មុខងារ ឬតួនាទី [របស់ជនសង្ស័យក្នុងសំណុំរឿង ០០៤] នៅក្នុងសំណុំរឿង ០០២ គឺជារឿងមិនអាចជៀសបានឡើយ ដោយសារតែអង្គហេតុ និងភ័ស្តុតាងជាន់គ្នា ហើយ [...] មិនមែនជាការរំលោភបំពានទៅលើភាពយុត្តិធម៌ ឬការកែប្រែបន្ទុកនៃការបង្ហាញភ័ស្តុតាងនោះឡើយ"[78]។

32. យឹម ទិត្យ មិនបានដកស្រង់ចម្លើយសាក្សីណាមួយដើម្បីគាំទ្រដល់ការចោទប្រកាន់បែបស្មានៗរបស់គាត់អំពីភាពប្រឡាក់ប្រឡូករបស់សាក្សីដោយសារការបែកធ្លាយដីកាលើកទី ៣ នោះទេ[79]។ ប្រសិនបើ យឹម ទិត្យ យល់ឃើញថាកំណត់ស្តាប់ចម្លើយសាក្សីណាមួយទទួលរងផលប៉ះពាល់នោះ គាត់អាចស្នើសុំធ្វើមោឃភាពអនុលោមតាមវិធាន ៧៦ ក្នុងអំឡុងពេលស៊ើបអង្កេតមិនខាន។ ផ្ទុយទៅវិញ យឹម ទិត្យ បានរៀបចំជាបញ្ជីឈ្មោះបុគ្គលដែល ស.ច.ស បានស្តាប់ចម្លើយ ដែលអះអាង

---

អាជ្ញាអន្តរជាតិ សុំដាក់បង្ហាញឯកសារចំនួន ១ នៃសំណុំរឿង ០០៤ នៅក្នុងសំណុំរឿង ០០២ (D193/69) ចុះថ្ងៃទី១៩ ខែឧសភា ឆ្នាំ២០១៦ ("សំណើរបស់ យឹម ទិត្យ សុំឱ្យពិចារណាឡើងវិញ") កថាខណ្ឌ ២៣។

[76] *សូមមើល ឧទា.* សេចក្តីប្រកាសព័ត៌មានរបស់ អ.វ.ត.ក ចុះខែវិច្ឆិកា ឆ្នាំ២០០៩។ សេចក្តីប្រកាសព័ត៌មានរបស់ អ.វ.ត.ក ចុះខែសីហា ឆ្នាំ២០០៩។

[77] *សូមមើល* សំណុំរឿង ០០២ ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ លេខយោងជើងទំព័រ ២៧៦៦ (យឹម ទិត្យ ជាលេខាតំបន់ ១៣)។ លេខយោងជើងទំព័រ ៣៧៣៧ (បញ្ជាទៅថ្នាក់ស្រុក បន្ទាប់ពីទស្សនៈកិច្ចរបស់ យឹម ទិត្យ)។ លេខយោងជើងទំព័រ ១២២២៦ (ការចូលរួមពាក់ព័ន្ធរបស់ យឹម ទិត្យ នៅក្នុងការរៀបការដោយបង្ខំ)។

[78] ឯកសារ **D284/1/4** (អ.ប.ជ) សាលដីកាសម្រេចលើការបង្ហាញឯកសារ កថាខណ្ឌ ២៤។

[79] ឯកសារ **D382/22** បណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ កថាខណ្ឌ ២៩។

ថាមិនដែលឮឈ្មោះគាត់ពីមុនមកទេ[80]។ ហេតុនេះ ការអះអាងរបស់ យឹម ទិត្យ ពីការគ្មានសុចរិតភាពក្នុងការស៊ើបអង្កេតក្នុងសំណុំរឿង ០០៤[81] ហាក់ដូចជាកម្រិតត្រឹមតែចម្លើយសាក្សីដែលគាត់មិនឯកភាពតាមប៉ុណ្ណោះ។

## ៣. យឹម ទិត្យ ខកខានមិនបានបង្ហាញពី "ការប្រឡាក់ប្រឡូក" នៃការស៊ើបអង្កេតលើសំណុំរឿង ០០៤

33. ការអះអាងគ្មានមូលដ្ឋានរបស់ យឹម ទិត្យ ថា មជ្ឈមណ្ឌលឯកសារកម្ពុជាបានបើកកិច្ចស៊ើបសួរនៅក្នុងសំណុំរឿង ០០៤[82] ខកខានមិនបានបង្ហាញកំហុសអង្គច្បាប់ ឬអង្គហេតុ ឬការបំពានចំពោះការចេញដីកាបញ្ជូនរឿងទៅជំនុំជម្រះរបស់ ស.ច.ស.អ។

34. យឹម ទិត្យ ពុំបានដកស្រង់ភ័ស្តុតាងយកមកគាំទ្រការចោទប្រកាន់ដោយស្មានៗថា មជ្ឈមណ្ឌលឯកសារកម្ពុជាបានប្រើប្រាស់សម្ភារដែលបានលេចធ្លាយ ដើម្បីធ្វើជាមូលដ្ឋានសម្រាប់កិច្ចសម្ភាសន៍របស់ខ្លួន។ ផ្ទុយមកវិញ យឹម ទិត្យ ទទួលស្គាល់ថា នៅពេលមជ្ឈមណ្ឌលឯកសារបានរកឃើញភ័ស្តុតាងអំពីគាត់នៅក្នុងឆ្នាំ ២០២០ "ឈ្មោះ "ទិត្យ" មិនត្រូវបានលើកឡើងក្នុងសេចក្តីប្រកាសព័ត៌មាន ឬសេចក្តីថ្លែងការណ៍ជាសាធារណៈនាពេលនោះ ពាក់ព័ន្ធនឹងកិច្ចស៊ើបសួរក្នុងសំណុំរឿង ០០២ ឬនៅក្នុងបរិបទនៃដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរលើកទីបីរបស់ ស.ព.អ ក៏ដោយ តែមជ្ឈមណ្ឌលឯកសារកម្ពុជាកំពុងស្វែងរកលោក យឹម ទិត្យ យ៉ាងសកម្មនៅក្នុងស្រុកគិរីវង់"[83]។ ឯកសារ មជ្ឈមណ្ឌលឯកសារកម្ពុជា ដែល យឹម ទិត្យ បានដកស្រង់តាមពិតបានលើកឡើងថា "យោងតាមបទសម្ភាសន៍របស់លោក Ben Kiernan និងអ្នកផ្តល់ព័ត៌មានដែលជាអ្នកស្រុកគិរីវង់ បានបញ្ជាក់ថា ស្រុក ១០៩ ត្រូវបានកាន់កាប់ដោយលេខាស្រុកម្នាក់ដែលមានឈ្មោះថា ទិត្យ ដែលជាប្អូនថ្លៃប្រុសរបស់តាម៉ុក"[84]។ ក្រោយមក ឯកសារនេះត្រូវបានបញ្ជាក់សាជាថ្មីដោយបុគ្គល

---

[80] ឯកសារ **D382/22** បណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ ឧបសម្ព័ន្ធ ក។

[81] ឯកសារ **D382/22** បណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ កថាខណ្ឌ ២៩។

[82] *ផ្ទុយពី* ឯកសារ **D382/22** បណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ កថាខណ្ឌ ៣០-៣៥ (មូលដ្ឋានរងទី ១.២.i.ខ)។

[83] ឯកសារ **D382/22** បណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ កថាខណ្ឌ ៣២។

[84] ឯកសារ **D65.1.2** មជ្ឈមណ្ឌលឯកសារកម្ពុជា: គំរោងលើកកម្ពស់គណេយ្យភាព ERN 01555853-4 ដែលបានចង្អុលបង្ហាញនៅក្នុងឯកសារ **D382/22** បណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ កថាខណ្ឌ ៣២។

ផ្សេងៗដែលមជ្ឈមណ្ឌលឯកសារកម្ពុជា បានទៅសម្ភាស[85] ដែលបញ្ជាក់អំពីសិទ្ធិអំណាចរបស់ យឹម ទិត្យ នៅស្រុកគីរីវង់។

35. ស.ច.ស.អ បានប្រើប្រាស់យ៉ាងត្រឹមត្រូវនូវកិច្ចសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជា ដើម្បីយកមកធ្វើជាតម្រុយក្នុងការស៊ើបអង្កេត។ អ.ប.ជ បានបញ្ជាក់អំពីឆន្ទានុសិទ្ធិយ៉ាងទូលំទូលាយរបស់ ស.ច.ស[86] នៅក្នុងវិធីធ្វើសម្ភាសន៍ និងបានសម្រេចថា ការយកភ័ស្តុតាងពីក្នុងសំណុំរឿងមកសាកសួរអ្នកដែលត្រូវបានសម្ភាស ពុំមែនជា "ការអនុវត្តការស៊ើបអង្កេតត្រឹមត្រូវមួយ" ប៉ុន្តែ "ជាការអនុវត្តដោះបន្ទុក ដោយសារធ្វើឱ្យមានការដេញដោលទៅលើភ័ស្តុតាងដាក់បន្ទុកដែលមាននៅក្នុងសំណុំរឿង"[87]។ យឹម ទិត្យ ច្រានចោលយុត្តិសាស្ត្រនេះ នៅពេលបកស្រាយខុសពីកិច្ចរបស់អ្នកស៊ើបអង្កេតមួយរូបរបស់ ស.ច.ស.អ[88] ដែលគ្រាន់តែធ្វើអ្វីដែល អ.ប.ជ យល់ឃើញថាជាកិច្ចស៊ើបសួរសមស្របមួយតែប៉ុណ្ណោះ។

36. លើសពីនេះទៀត ឧទាហរណ៍របស់ យឹម ទិត្យ លើកឡើងអំពីកំណត់ហេតុនៃការស្តាប់ចម្លើយដែលបង្ហាញអំពី "ការពឹងផ្អែកខ្លាំង" របស់ ស.ច.ស.អ លើការងាររបស់មជ្ឈមណ្ឌល ឯកសារកម្ពុជា ពុំមានអ្វីលើកឡើងបញ្ជាក់ថា បុគ្គលនោះធ្លាប់សម្ភាស ជាមួយមជ្ឈមណ្ឌលឯកសារ កម្ពុជានោះទេ[89]។ ស្រដៀងគ្នានេះដែរ យឹម ទិត្យ មានកំហុសនៅពេល សំអាងលើចម្លើយរបស់សាក្សីមួយរូបយកមកធ្វើជា "ឧទាហរណ៍" ដែលបង្ហាញថា ស.ច.ស.អ បានដឹងថា មជ្ឈមណ្ឌលឯកសារកម្ពុជាបានលាតត្រដាងព័ត៌មានសម្ងាត់ពាក់ព័ន្ធនឹងកិច្ចស៊ើបសួរ នៅ អ.វ.ត.ក ដែលកំពុងបន្តនោះ[90]។ កិច្ចសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជា ដែលត្រូវបានជំទាស់នោះ

---

[85] ឯកសារ **D65.1.2** មជ្ឈមណ្ឌលឯកសារកម្ពុជា: គំរោងលើកកម្ពស់គណេយ្យភាព ERN 01555876, 01555880-1, 01555897។

[86] ឯកសារ **D351/1/4** សាលដីកាលើសំណើសុំធ្វើមោឃភាពឯកសារស៊ើបអង្កេត កថាខណ្ឌ ៣៨។

[87] សំណុំរឿង ០០៤/២ ឯកសារ **D338/1/5** សាលដីកាលើសំណើសុំធ្វើមោឃភាពលើកំណត់ហេតុនៃការស្តាប់ចម្លើយ កថាខណ្ឌ ២១។

[88] ឯកសារ **D382/22** បណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ កថាខណ្ឌ ៣៤។

[89] ឯកសារ **D382/22** បណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ កថាខណ្ឌ ៣០។ *សូមមើល* ឯកសារ **D3/8** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ទន់ ស៊ូន ឆ.៤។ លោក ទន់ ស៊ូន លើកឡើងថា គាត់បាននិយាយជាមួយមនុស្សមួយក្រុម ដែលមានជនជាតិឥណ្ឌាម្នាក់ អាមេរិកកាំងម្នាក់ និងជនជាតិជប៉ុនម្នាក់។ យឹម ទិត្យ ប្រហែលជានិយាយស្មាន ដោយពុំមានមូលដ្ឋានថា ក្រុមនេះគឺមកពីមជ្ឈមណ្ឌលឯកសារកម្ពុជា។

[90] ឯកសារ **D382/22** បណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ កថាខណ្ឌ ៣៤។

គឺកិច្ចសម្ភាសន៍ជាមួយភរិយារបស់ជនសង្ស័យ ស៊ូ ម៉េត ក្នុងសំណុំរឿង ០០៣ ដែលត្រូវបានស្ដាប់ចម្លើយអំពីកិច្ចដំណើរការនីតិវិធីនៅ អ.វ.ត.ក ជាច្រើនខែក្រោយមក ក្រោយ ពេលមេធាវីការពារក្ដីបានជូនដំណឹងជាសាធារណៈថា ជនសង្ស័យ ស៊ូ ម៉េត បានទទួល មរណភាព[91]។

37. សេចក្ដីសន្និដ្ឋានមុនៗរបស់ យឹម ទិត្យ កាន់តែមានចំណុចផ្ទុយគ្នានឹងការអះអាងរបស់គាត់។ ឧទាហរណ៍ យឹម ទិត្យ បានស្នើសុំនៅក្នុងឆ្នាំ ២០១៤ ថា គាត់គួរត្រូវបានអនុញ្ញាតឲ្យបំពេញកិច្ចស៊ើបសួរដោយខ្លួនឯង ហើយលើកឡើងថា ស.ច.ស អាច "អនុវត្តតាមនីតិវិធីដូចដែលខ្លួនប្រើនៅពេលទទួលយកលទ្ធផលនៃការស៊ើបអង្កេតរបស់មជ្ឈមណ្ឌលឯកសារកម្ពុជាដាក់ចូលក្នុងសំណុំរឿងនៃរឿងក្ដីផ្សេងទៀតរបស់ អ.វ.ត.ក"[92]។ នៅក្នុងឆ្នាំ ២០១៦ យឹម ទិត្យ បានបង្ហាញការប្រៀបធៀបរវាងកិច្ចសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារជាមួយ ម៉ឹង វ៉េត និងកិច្ចសម្ភាសន៍របស់ ក.ស.ច.ស ជាមួយ ម៉ឹង ម៉េត នាពេលក្រោយមកទៀត ដោយបានប្រកាសថា "ខ្លឹមសារនៃឯកសារទាំងពីរមានភាពស្ទួនគ្នាតិចតួចណាស់"[93]។ នៅក្នុងចម្លើយតបទៅនឹងសេចក្ដីសន្និដ្ឋានស្ដាពរ យឹម ទិត្យ ក៏បានសំអាងលើកិច្ចសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជា ដោយគាត់បានអះអាងថា បានបង្ហាញឲ្យឃើញថា ភ័ស្ដុតាងផ្ដល់ទៅមជ្ឈមណ្ឌលឯកសារកម្ពុជាពុំស្របគ្នានឹងចម្លើយដែលបានផ្ដល់ជូន ស.ច.ស នាពេលក្រោយមកនោះទេ[94]។ ជាក់ស្ដែង បណ្ដឹងរបស់ យឹម ទិត្យ នាពេលនេះពាក់ព័ន្ធតែទៅនឹងនឹងចម្លើយរបស់សាក្សីដែលគាត់ពុំយល់ស្របជាមួយតែប៉ុណ្ណោះ[95]។

38. ចំណុចចុងក្រោយ ការដាក់បណ្ដឹងរបស់ យឹម ទិត្យ ពុំស្របតាមពេលវេលាកំណត់ បង្ហាញបន្ថែមទៀតអំពីការខ្វះមូលដ្ឋាន។ ប្រសិនបើគាត់យល់ថា កំណត់ហេតុនៃការស្ដាប់ចម្លើយដែលបានផ្អែក

---

[91] ឯកសារ **D219/903.1** មជ្ឈមណ្ឌលឯកសារកម្ពុជាសម្ភាសន៍ជាមួយ ម៉ា ស៊ីវន ERN 01375640-1។ អត្ថបទសារព័ត៌មាន ឃែមបូឌាដេលី ("លោក Michael Karnavas អតីតមេធាវីការពារក្ដីឲ្យខ្មោច អៀង សារី ដែលជាចុងចោទក្នុងសំណុំរឿង ០០២ និងជាមេធាវីការពារ មាស មុត ដែលជាជនសង្ស័យក្នុងសំណុំរឿង ០០៣ បាននិយាយថា 'ការលាចាកលោកទៅរបស់ ស៊ូ ម៉េត នឹងមិនប៉ះពាល់អ្វីជាសំខាន់មកលើភាពសេសសល់នៃសំណុំរឿង ០០៣ នោះឡើយ'")។

[92] ឯកសារ **D203** សំណើរបស់លោក យឹម ទិត្យ សុំការបំភ្លឺថា គាត់អាចអនុវត្តកិច្ចស៊ើបសួរដោយខ្លួនឯងបាន ចុះថ្ងៃទី០៣ ខែមិថុនា ឆ្នាំ២០១៤ កថាខណ្ឌ ២១។

[93] ឯកសារ **D193/76** សំណើរបស់ យឹម ទិត្យ សុំឲ្យពិចារណាឡើងវិញ") កថាខណ្ឌ ២៨។ យឹម ទិត្យ បានដាក់ជូននូវឧបសម្ព័ន្ធមួយច្បាប់ដែលរៀបរាប់ពីភាពខុសគ្នាលើខ្លឹមសាររវាងចម្លើយនានា *សូមមើល* ឯកសារ **D193/76.1.1** ឧបសម្ព័ន្ធ ក។

[94] *សូមមើល ឧ.ទា* ឯកសារ **D378/5** ចម្លើយតបរួមរបស់ យឹម ទិត្យ ទៅនឹងដីកាសន្និដ្ឋានស្ដាពរ កថាខណ្ឌ ៧៩៨, ៩៧២, ១២៣៤។

[95] ឯកសារ **D382/22** បណ្ដឹងឧទ្ធរណ៍របស់ យឹម ទិត្យ កថាខណ្ឌ ៣៣។

លើកិច្ចសម្ភាសន៍ដើមរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា មាន "ប្រឡាក់ប្រឡូក" គាត់គួរស្នើសុំមោឃ ភាពអនុលោមតាមវិធាន ៧៦ នៅក្នុងអំឡុងពេលស៊ើបអង្កេត។

## ៤. យឹម ទិត្យ ខកខានមិនបានផ្តល់មូលដ្ឋានសមស្របសម្រាប់ពិចារណាឡើងវិញលើបណ្តឹងរបស់គាត់ពាក់ព័ន្ធនឹងសិទ្ធិចូលពិនិត្យសំណុំរឿង ០០៤ "យឺតពេលវេលា"

39. យឹម ទិត្យ ខកខានក្នុងការផ្តល់មូលដ្ឋានសមស្របមួយអំពីមូលហេតុដែល អ.ប.ជ គួរចាត់ទុកថាជាករណីពិសេសលើបញ្ហារបស់គាត់ពាក់ព័ន្ធនឹងសិទ្ធិចូលមើលសំណុំរឿង ០០៤ "យឺតពេល"[96] នោះ។ យឹម ទិត្យ ពុំបង្ហាញឲ្យឃើញពី "មូលហេតុដែលគួរឲ្យជឿជាក់បាន រួមទាំងការប្រែប្រួលនៃកាលៈទេសៈណាមួយ" ដែលតម្រូវឲ្យយកមកពិចារណាឡើងវិញ[97]។ អ.ប.ជ បានសម្រេចរួចហើយថា យឹម ទិត្យ ដែលបានទទួលសិទ្ធិចូលពិនិត្យមើលសំណុំរឿងនៅពេលគាត់ត្រូវបានចោទប្រកាន់ជាផ្លូវការ ពុំបង្កព្យសនកម្មដែលពុំអាចជួសជុលបានចំពោះសិទ្ធិទទួលបានការជំនុំជម្រះប្រកបដោយយុត្តិធម៌របស់គាត់ ឬភាពយុត្តិធម៌នៃកិច្ចដំណើរការនីតិវិធីក្នុងសំណុំរឿង ០០៤ ទេ[98]។

## ៥. យឹម ទិត្យ ខកខានក្នុងការបង្ហាញកំហុសដែលអាចពិនិត្យមើលឡើងវិញ ពាក់ព័ន្ធនឹងអំឡុងពេលនៃកិច្ចដំណើរការនីតិវិធីក្នុងសំណុំរឿង ០០៤

40. យឹម ទិត្យ ខកខានក្នុងការបង្ហាញកំហុសអង្គច្បាប់ ឬ អង្គហេតុ ដែលអាចពិនិត្យមើលឡើងវិញចំពោះការចេញដីកាបញ្ជូនរឿងទៅជំនុំជម្រះរបស់ ស.ច.ស.អ នៅពេលបញ្ចប់កិច្ចស៊ើបសួរក្នុងសំណុំរឿង ០០៤[99]។

---

[96] សំណុំរឿង ០០៤/២ ឯកសារ **D359/24 & D360/33** (អ.ប.ជ) សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ កថាខណ្ឌ ១៦៤។ *ផ្ទុយពី* ឯកសារ **D382/22** បណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ ៣៦ (មូលដ្ឋានរងទី ១.២.i.គ)។

[97] សំណុំរឿង ០០២ ឯកសារ **F2/10/3** (អ.ជ.ត.ក) សេចក្តីសម្រេចលើសំណើសុំការពិចារណាឡើងវិញ ERN 01202795-6។ *សូមមើល ផងដែរ ឧទា.* ឯកសារ **D193/71.1.3** (អ.ប.ជ) សេចក្តីសម្រេចលើសំណើសុំការពិចារណាឡើងវិញ កថាខណ្ឌ ២៥។ សំណុំរឿង ០០២ ឯកសារ **D364/1/6** (អ.ប.ជ) សាលដីកាសម្រេចអំពីការពិចារណាសារជាថ្មីឡើងវិញ អំពីការទទួលយកពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី កថាខណ្ឌ ៦។ ឯកសារ **D193/89** ដីកាសម្រេចរួមលើសំណើរបស់ *យឹម ទិត្យ* សុំពិចារណាឡើងវិញ កថាខណ្ឌ ៦២។

[98] ឯកសារ **D361/4/1/10** (អ.ប.ជ) សាលដីកាលើបណ្តឹងឧទ្ធរណ៍សុំពេលវេលារៀបចំឲ្យបានគ្រប់គ្រាន់ កថាខណ្ឌ ៣០, ៣៥។ *សូមមើល ផងដែរ* ឯកសារ **D192/1** ដីកាសម្រេចលើសំណើជាបន្ទាន់របស់ *យឹម ទិត្យ* កថាខណ្ឌ ១០។

[99] *សូមមើល* សំណើបឋម កថាខណ្ឌ ៤-៥ (ភាពមិនអាចទទួលយកបាន), ១៧, ១៩, ២២ (បទដ្ឋាននៃការពិនិត្យឡើងវិញ)។ *ផ្ទុយពី* ឯកសារ **D382/22** បណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ កថាខណ្ឌ ៣៧-៥៣ (មូលដ្ឋានរងទី ១.២.ii)។

41. យឹម ទិត្យ បង្ហាញមិនត្រឹមត្រូវអំពីអំឡុងពេលនៃសំណុំរឿង ០០៤។ ផ្ទុយពីការអះអាងរបស់គាត់[100] "ចំណុចចាប់ផ្ដើមនៃ [ការវាយតម្លៃលើរយៈពេលសមហេតុផលនៃកិច្ចដំណើរការនីតិវិធីព្រហ្មទណ្ឌ] គឺនៅពេលជនសង្ស័យត្រូវបានជូនដំណឹងជាផ្លូវការថា ជនសង្ស័យនឹងត្រូវចោទប្រកាន់ បើទោះជាជនសង្ស័យមិនត្រូវបានចោទប្រកាន់ជាផ្លូវការរហូតដល់ពេលក្រោយមកក៏ដោយ"[101]។ សំណុំរឿង ០០៤ គឺនៅថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ២០១២ ពុំមែនថ្ងៃទី១០ ខែតុលា ឆ្នាំ២០០៦ ដូច យឹម ទិត្យ អះអាងនោះឡើយ[102]។

42. ការសំអាងរបស់ យឹម ទិត្យ លើយុត្តិសាស្ត្ររបស់តុលាការសិទ្ធិមនុស្សអឺរ៉ុប គឺជាការសំអាងមិនត្រឹមត្រូវទេ[103]។ គាត់បានសំអាងលើយុត្តិសាស្ត្រដែលមិនអាចប្រដូចគ្នាបាន និងមើលរំលងរឿងក្ដីពាក់ព័ន្ធនឹងឧក្រិដ្ឋកម្មអន្តរជាតិ ដែលត្រូវបានវាយតម្លៃដោយខុសគ្នាដោយសារតែភាពស្មុគស្មាញ[104]។ ចំណុចនេះគួរឲ្យភ្ញាក់ផ្អើល ដោយសារតែ យឹម ទិត្យ បានលើកឡើងពីមុនរួចហើយថា គាត់ "ប្រឈមជាមួយម៉ាទ្រីសអង្គហេតុ និងអង្គច្បាប់ ដែលស្មុគស្មាញបំផុត ក្នុងចំណោមសំណុំរឿងនានា ដែលត្រូវបានជំនុំជម្រះនៅចំពោះមុខ អ.វ.ត.ក" និងបានបង្ហាញការវិភាគតាមបែបស្ថិតិ

---

[100] យឹម ទិត្យ ប្រើប្រាស់ច្បាប់យុត្តិសាស្ត្រខុស ថាគាត់យោងទៅលើការអះអាងថា ចំណុចចាប់ផ្ដើមសម្រាប់ការវាយតម្លៃលើពេលវេលាសមស្របនៃសំណុំរឿង ០០៤ គឺនៅពេលដែលកិច្ចស៊ើបសួរបឋមត្រូវបានបើកធ្វើឡើងប្រឆាំងអញ្ញត្រជនអស់រយៈពេលជាច្រើនខែ ក្រោយពេលបើកឲ្យ អ.វ.ត.ក ដំណើរការ។ *សូមមើល* ឯកសារ **D382/22** បណ្ដឹងឧទ្ធរណ៍របស់ យឹម ទិត្យ លេខជើងទំព័រយោង ៩៤។ ឯកសារ **D378/5** ចម្លើយតបរួមរបស់ យឹម ទិត្យ ទៅនឹងដីកាសន្និដ្ឋានស្ថាពរ កថាខណ្ឌ ១៤-១៥។ *ផ្ទុយពី* ឯកសារ **D382/22** បណ្ដឹងឧទ្ធរណ៍របស់ យឹម ទិត្យ កថាខណ្ឌ ៣២។

[101] សំណុំរឿង ០០៣ ឯកសារ **D120/3/1/8** យោបល់របស់ចៅក្រមអន្តរជាតិនៃ អ.ប.ជ លើពាក្យសុំលុបចោលដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែម កថាខណ្ឌ៣៥ លេខជើងទំព័រយោង ១៣៤ (ដែលយោងទៅលើរឿងក្ដី *Eckle ទល់នឹង ប្រទេសអាល្លឺម៉ង់* កថាខណ្ឌ ៧៣)។

[102] ឯកសារ **D109** ការជូនដំណឹងអំពីសិទ្ធិរបស់ជនសង្ស័យ។ *សូមមើល ផងដែរ* ឯកសារ **D186/1** សេចក្ដីជូនដំណឹងទាក់ទងនឹងសំណើរបស់ យឹម ទិត្យ សុំចូលពិនិត្យមើលសំណុំរឿង កថាខណ្ឌ ៤៥-៤៦។ *ផ្ទុយពី* ឯកសារ **D382/22** បណ្ដឹងឧទ្ធរណ៍របស់ យឹម ទិត្យ កថាខណ្ឌ ៤០, ៤២។

[103] *សូមមើល ឧទា.* ឯកសារ **D382/22** បណ្ដឹងឧទ្ធរណ៍របស់ យឹម ទិត្យ លេខជើងទំព័រយោង ១០០។

[104] *សូមមើល ឧទា.* រឿងក្ដី *X ទល់នឹង FRG* ទំព័រ ១១៥-១១៦។ រឿងក្ដី *Korbely ទល់នឹង ប្រទេសហុងគ្រី* កថាខណ្ឌ ១០៤។ រឿងក្ដី *Kononov ទល់នឹង ប្រទេសឡាតៀ* ទំព័រ ៤០។ រឿងក្ដី *Larionovs ទល់នឹង ប្រទេសឡាតៀ* កថាខណ្ឌ ១៩០។

អំពីទំហំនៃភស្តុតាង និងលក្ខណៈ ព្រមទាំងចំនួនបទចោទប្រឆាំងនឹងគាត់ ដើម្បីសន្និដ្ឋានថា "ទំហំដ៏ធំនៃសម្ភារភស្តុតាងនៅក្នុងសំណុំរឿង ០០៤ មានភាពធំមហិមា"[105]។

43. ការអះអាងរបស់ យឹម ទិត្យ ថា រយៈពេលនៃកិច្ចស៊ើបសួរក្នុងសំណុំរឿង ០០៤ មានការពន្យារពេលមិនសមស្រប ក៏មិនស្របជាមួយនឹងជំហររបស់គាត់នៅក្នុងខែមិថុនា ឆ្នាំ២០១៧ ផងដែរ គឺរយៈពេល ២ ខែ មុនពេលបញ្ចប់កិច្ចស៊ើបសួរ នៅពេលគាត់បានតវ៉ាថា កិច្ចស៊ើបសួរសំណុំរឿង ០០៤ មិនត្រូវបិទមុនកាលកំណត់លឿនពេកនោះទេ[106]។

44. ម្យ៉ាងវិញទៀត យឹម ទិត្យ បានលើកទឡ្ហីករណ៍ដោយប៉ាន់ស្មានអំពីរយៈពេលនៃការជំនុំជម្រះ និងកិច្ចដំណើរការនីតិវិធីបណ្ដឹងសាទុក្ខនាពេលខាងមុខ លទ្ធភាពនៃការបាត់បង់ភស្តុតាង និងស្ថានភាពថវិកាមិនប្រាកដប្រជារបស់ អ.វ.ត.ក[107]។ ការអះអាងដោយស្មានៗនេះមិនពាក់ព័ន្ធនឹងបញ្ហាចោទនៃរយៈពេលកិច្ចដំណើរការនីតិវិធីមកទល់ពេលបច្ចុប្បន្ននេះឡើយ ទោះបីជា អ.ប.ជ បានច្រានចោលបញ្ហានៃភាពមិនប្រាកដប្រជាផ្នែកហិរញ្ញវត្ថុនៅក្នុងសំណុំរឿង ០០៤/២ ដោយបានសម្រេចថា "សិទ្ធិរបស់ជនជាប់ចោទក្នុងការទទួលបានភាពត្រឹមត្រូវផ្នែកនីតិវិធីក្នុងដំណាក់កាលបច្ចុប្បន្ននេះមិនមានហានិយភ័យទទួលការបំពានដោយមិនអាចប្រកែកបាននោះឡើយ"[108]។

### ខ. មូលដ្ឋានទី ២ ៖ យឹម ទិត្យ ខកខានក្នុងការបង្ហាញកំហុសដែលអាចពិនិត្យមើលឡើងវិញបាននៅក្នុងសំអាងហេតុរបស់ ស.ច.ស.អ ក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ

45. ប្រសិនបើអាចទទួលយកបាន[109] យឹម ទិត្យ ខកខានក្នុងការបង្ហាញកំហុសអង្គច្បាប់ ដែលអាចពិនិត្យមើលឡើងវិញបាន អំពីភាពគ្រប់គ្រាន់នៃការសម្រេចរបស់ ស.ច.ស.អ[110]។ ផ្ទុយពីការ

---

[105] ឯកសារ **D355/4** សារណារបស់ យឹម ទិត្យ ស្ដីពីស្ថានភាពថវិការបស់ អ.វ.ត.ក និងផលប៉ះពាល់ទៅលើសំណុំរឿង ០០៤ ចុះថ្ងៃទី០៥ ខែមិថុនា ឆ្នាំ២០១៧ ("សារណារបស់ យឹម ទិត្យ ស្ដីពីស្ថានភាពថវិការបស់ អ.វ.ត.ក និងផលប៉ះពាល់") កថាខណ្ឌ ៣៨, ៣៧។ *សូមមើលផងដែរ* កថាខណ្ឌ៣៥-៣៦, ៣៩-៤៦។ ឯកសារ **D312** សំណើបន្ទាន់របស់ យឹម ទិត្យ សុំឱ្យសហចៅក្រមស៊ើបអង្កេតបង្គាប់អង្គភាពគាំពារការការពារក្ដី ឱ្យផ្ដល់ក្រុមមេធាវីការពារក្ដីរបស់ យឹម ទិត្យ នូវធនធានដែលបានលៃទុកពីដំបូង ចុះថ្ងៃទី០១ ខែមិថុនា ឆ្នាំ២០១៦ កថាខណ្ឌ ២៩, ៣១, ៣៨)។

[106] ឯកសារ **D355/4** សារណារបស់ យឹម ទិត្យ ស្ដីពីស្ថានភាពថវិការបស់ អ.វ.ត.ក និងផលប៉ះពាល់ កថាខណ្ឌ ៣៣។

[107] *ផ្ទុយពី* ឯកសារ **D382/22** បណ្ដឹងឧទ្ធរណ៍របស់ យឹម ទិត្យ កថាខណ្ឌ ៤០, ៤២, ៥១-៥៣។

[108] សំណុំរឿង ០០៤/២-**D359/24** & **D360/33** (អ.ប.ជ) សេចក្ដីពិចារណាលើបណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ កថាខណ្ឌ ១៦៧។

[109] *សូមមើល* សំណើបឋមនានា កថាខណ្ឌ ៤, ៦ (ភាពមិនអាចទទួលយកបាន).

អះអាងរបស់ យឹម ទិត្យ[111] ដីកាបញ្ជូនរឿងទៅជំនុំជម្រះកំណត់ពីធាតុផ្សំជាលក្ខខណ្ឌស្របតាមវិធាន ៦៧(២)។

46. អ.ប.ជ បានសម្រេចថា ដីកាបញ្ជូនរឿងទៅជំនុំជម្រះបង្ហាញពីចំណុចជាក់លាក់គ្រប់គ្រាន់ "នៅពេលពួកគាត់ថែងអំពីអង្គហេតុនានានៃបណ្ដឹងអាជ្ញា ដោយត្រូវមានព័ត៌មានលម្អិតគ្រប់គ្រាន់ក្នុងការជូនដំណឹងដល់ចុងចោទឲ្យបានច្បាស់អំពីប្រភេទ និងមូលហេតុនៃការចោទប្រកាន់លើ បុគ្គលនោះ ដើម្បីឲ្យបុគ្គលនោះអាចរៀបចំការការពារខ្លួនឲ្យមានប្រសិទ្ធភាព និងសក្តិសម"[112]។ នៅពេលធ្វើសេចក្ដីសម្រេច "ដីកាដំណោះស្រាយនឹងត្រូវបានយកមកពិនិត្យជារួម នៅពេលកំណត់បទចោទប្រកាន់ និងអង្គហេតុគាំទ្រជាមូលដ្ឋាន"[113]។

## ១. យឹម ទិត្យ ខកខានក្នុងការបង្ហាញកំហុសដែលអាចពិនិត្យមើលឡើងវិញចំពោះ ទម្រង់ និងអង្គសេចក្ដីនៃផ្នែក "ទទួលខុសត្រូវខ្ពស់បំផុត" នៃដីកាបញ្ជូនរឿងទៅ ជំនុំជម្រះ

47. យឹម ទិត្យ អះអាងដោយមិនត្រឹមត្រូវថា ស.ច.ស.អ ខកខានក្នុងការបង្ហាញពីចំណុចពិចារណាពាក់ព័ន្ធ និងអង្គហេតុចម្បងៗដែលចាំបាច់ត្រូវជូនដំណឹងដល់ យឹម ទិត្យ អំពីមូលដ្ឋានសម្រាប់ការវាយតម្លៃថា គាត់ស្ថិតនៅក្នុងចំណោមអ្នកទាំងឡាយដែល "ទទួលខុសត្រូវខ្ពស់បំផុត"[114]។ តាមពិត ស.ច.ស.អ បានសំអាងលើចំណុចពិចារណា ដែល អ.ប.ជ បានគាំទ្រ សម្រាប់វាយតម្លៃលើយុត្តាធិការបុគ្គល[115] ដែលរួមមាន (i) ចំនួនជនរងគ្រោះ (ii) លក្ខណៈនៃឧក្រិដ្ឋហេតុ (iii) ផល

[110] ឯកសារ **D382/22** បណ្ដឹងឧទ្ធរណ៍របស់ យឹម ទិត្យ កថាខណ្ឌ ៥៦-៥៨។

[111] ឯកសារ **D382/22** បណ្ដឹងឧទ្ធរណ៍របស់ យឹម ទិត្យ កថាខណ្ឌ ៥៦-៩៥។

[112] សំណុំរឿង ០០២ ឯកសារ **D97/15/9** (អ.ប.ជ) សាលដីកាលើបណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេតចំពោះការអនុវត្តសហឧក្រិដ្ឋកម្មរួម កថាខណ្ឌ ៣២។ *សូមមើល ផងដែរ* សំណុំរឿង ០០២ ឯកសារ **E122** (អ.ជ.ស.ដ) សេចក្ដីសម្រេចលើអញ្ញត្រកម្មនានារបស់មេធាវីការពារក្ដី (អាជ្ញាយុកាលនៃបទឧក្រិដ្ឋតាមច្បាប់ជាតិ) កថាខណ្ឌ ១៩។

[113] សំណុំរឿង ០០២ ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ១៧៣។ សំណុំរឿង ០០២ ឯកសារ **E100/6** (អ.ជ.ស.ដ) សេចក្ដីសម្រេចលើភាពអាចអនុវត្តបាននូវសហឧក្រិដ្ឋកម្មរួម កថាខណ្ឌ ២១។ សំណុំរឿង ០០២ ឯកសារ **D404/2/4** (អ.ប.ជ) សាលដីកាលើគ្រប់បណ្ដឹងឧទ្ធរណ៍ទាំងអស់ ប្រឆាំងនឹងដីកាសម្រេចនានារបស់សហចៅក្រមស៊ើបអង្កេតលើភាពអាចទទួលយកបាននៃពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី កថាខណ្ឌ ៨០-៨១។

[114] ឯកសារ **D382/22** បណ្ដឹងឧទ្ធរណ៍របស់ យឹម ទិត្យ កថាខណ្ឌ ៥៩, ៦១។

[115] សំណុំរឿង ០០៤/២-**D359/24** & **D360/33** (អ.ប.ជ) សេចក្ដីពិចារណាលើបណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ កថាខណ្ឌ ១៤០-១៤១។

ប៉ះពាល់លើជនរងគ្រោះ (iv) កម្រិតនៃការចូលរួមរបស់ យឹម ទិត្យ (v) ឋានៈផ្លូវការរបស់ យឹម ទិត្យ និង (vi) តួនាទី និងការទទួលខុសត្រូវ*តាមព្រឹត្តន័យ* របស់ យឹម ទិត្យ[116]។

48. យឹម ទិត្យ អះអាងដោយមិនត្រឹមត្រូវថា ស.ច.ស.អ មានកំហុសអង្គច្បាប់ ដោយសារពុំបានរៀបរាប់ឱ្យអស់អំពីលក្ខណវិនិច្ឆ័យ ដែលគាត់បានសំអាងសម្រាប់វាយតម្លៃលើការទទួលខុសត្រូវខ្ពស់បំផុត[117]។ គាត់ខកខានក្នុងការបង្ហាញថា មានច្បាប់ជាធរមានបែបនេះ ពាក់ព័ន្ធនឹងលក្ខណវិនិច្ឆ័យ ដែលត្រូវយកមកពិចារណាសម្រាប់វាយតម្លៃលើយុត្តាធិការបុគ្គល។ ផ្ទុយមកវិញ ការវាយតម្លៃត្រូវ "ផ្អែកទាំងស្រុកលើអង្គសេចក្តីនៃរឿងក្តីនីមួយៗ"[118]។

49. យឹម ទិត្យ ក៏បានកំណត់មិនត្រឹមត្រូវអំពីចំណុចយោងរបស់ ស.ច.ស.អ ពាក់ព័ន្ធនឹងអង្គច្បាប់អំពីយុត្តាធិការបុគ្គល[119]។ ខ្លឹមសារនៃចំណុចយោង ពុំពាក់ព័ន្ធនឹងចំណុចពិចារណា ដែលត្រូវយកមកគិតគូរនៅពេលវាយតម្លៃថាតើបុគ្គលម្នាក់ពិតជាស្ថិតនៅក្នុងចំណោមជនទាំងឡាយ "ដែលទទួលខុសត្រូវខ្ពស់បំផុត"[120]។ ហេតុនេះ ការអះអាងរបស់ យឹម ទិត្យ ថា ដីកាបញ្ជូនរឿងទៅជំនុំជម្រះពុំបានជូនដំណឹងគ្រប់គ្រាន់អំពីរឿងក្តីប្រឆាំងនឹងគាត់ ពុំមានមូលដ្ឋាននោះទេ[121]។

---

[116] ឯកសារ **D382** ដីកាដំណោះស្រាយ កថាខណ្ឌ ៩៩៧ (ចំនួនជនរងគ្រោះ), ៩៩៧ (ចរិតលក្ខណៈនៃព្រឹត្តិការណ៍នានា), ៩៩៨ (ផលប៉ះពាល់មកលើជនរងគ្រោះ), ៩៩៦ (កម្រិតនៃការចូលរួម), ៩៩៣ (ឋានៈផ្លូវការ), ៩៩៤ (តួនាទី*ជាក់ស្តែង* និងការទទួលខុសត្រូវ)។ *សូមមើល ផងដែរ* កថាខណ្ឌ ៩៩២-៩៩៩។.

[117] ឯកសារ **D382/22** បណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ កថាខណ្ឌ ៥៩-៦០។

[118] សំណុំរឿង ០០៤/១ ដីកាដំណោះស្រាយ (សំអាងហេតុ) កថាខណ្ឌ ៣៧។ សំណុំរឿង ០០៤/១ ឯកសារ **D308/3/1/20** (អ.ប.ជ) សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិ ប្រឆាំងនឹងដីកាដំណោះស្រាយ កថាខណ្ឌ ៣២១។ សំណុំរឿង ០០៤/២-**D359/24** & **D360/33** (អ.ប.ជ) សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ កថាខណ្ឌ ៣៥២។

[119] ឯកសារ **D382/22** បណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ កថាខណ្ឌ ៦០។

[120] *ផ្ទុយពី* ឯកសារ **D382/22** បណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ កថាខណ្ឌ ៦០។

[121] ឯកសារ **D382/22** បណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ កថាខណ្ឌ ៦០។

## ២. យឹម ទិត្យ ខកខានក្នុងការបង្ហាញពីកំហុសដែលអាចពិនិត្យមើលឡើងវិញបាន ចំពោះទម្រង់ ឬ អង្គសេចក្តី នៅក្នុងវិធីសាស្ត្ររបស់ ស.ច.ស.អ ចំពោះឧក្រិដ្ឋកម្មប្រល័យពូជសាសន៍

50. យឹម ទិត្យ ខកខានក្នុងការបង្ហាញថា ស.ច.ស.អ ពុំបានបង្ហាញពីធាតុផ្សំផ្លូវច្បាប់នៃឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ ឬមូលដ្ឋានអង្គហេតុនៃការសម្រេចពាក់ព័ន្ធនឹងខ្មែរក្រោមក្នុងនាមជាក្រុម និង *ធាតុផ្សំអត្តនោម័ត* របស់ យឹម ទិត្យ[122]។

### <u>ក. យឹម ទិត្យ ខកខានក្នុងការបង្ហាញកំហុសដែលអាចពិនិត្យមើលឡើងវិញចំពោះការសម្រេចរបស់ ស.ច.ស.អ ពាក់ព័ន្ធនឹងខ្មែរក្រោមក្នុងនាមជាក្រុម</u>

51. យឹម ទិត្យ អះអាងដោយមិនត្រឹមត្រូវថា ស.ច.ស.អ ពុំបានយល់ឃើញថា ខ្មែរក្រោម គឺជាក្រុមដែលអាចកំណត់អត្តសញ្ញាណបាន សម្រាប់គោលបំណងនៃឧក្រិដ្ឋកម្មប្រល័យពូជសាសន៍[123]។ តាមពិត ស.ច.ស.អ បានកំណត់អត្តសញ្ញាណខ្មែរក្រោមជាក្រុម ដោយផ្អែកលើជាតិពិន្ទុ ពូជសាសន៍ និងសញ្ជាតិ[124]។ ស.ច.ស.អ បានលើកឡើងអំពីបុគ្គលិកលក្ខណៈជាក់លាក់របស់ក្រុម *ឧទាហរណ៍* សំដីសំដៅដោយឡែករបស់ពួកគេ ពណ៌សម្បុរ វប្បធម៌ និងដើមកំណើត[125]។ លក្ខណៈកំណត់បាននៃក្រុមក៏ត្រូវបានបង្ហាញនៅក្នុងការយល់ឃើញរបស់ ស.ច.ស.អ ផងដែរ អំពីវិធី ប.ក.ក ស្វែងរកខ្មែរក្រោមដើម្បីដកចេញ[126]។

52. យឹម ទិត្យ ក៏អះអាងដោយមិនត្រឹមត្រូវថា ស.ច.ស.អ ពុំបានបង្ហាញពីចំណុចពាក់ព័ន្ធនៃចំណងរវាងការកំណត់គោលដៅនៃខ្មែរក្រោម និងវៀតណាម[127]។ ករណីនេះមិនបានពិចារណាលើការយល់ឃើញរបស់ ស.ច.ស.អ (i) ពាក់ព័ន្ធនឹងបុគ្គលិកលក្ខណៈស្រដៀងគ្នារវាងខ្មែរក្រោម និង

---

[122] ឯកសារ **D382/22** បណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ កថាខណ្ឌ ៦៥។

[123] ឯកសារ **D382/22** បណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ កថាខណ្ឌ ៦៩-៧១។

[124] ឯកសារ **D382** ដីកាដំណោះស្រាយ កថាខណ្ឌ ១០០៨ (ជាតិពិន្ទុ) ១៩៦ (ជាតិសាសន៍) ១៨៦-១៨៧, ១៨៩-១៩១ (សញ្ជាតិ)។

[125] ឯកសារ **D382** ដីកាដំណោះស្រាយ កថាខណ្ឌ ១៨៧, ១៩៦, ២៦៥, ២៦៧, ៣១២, ៧៦៩, ៧៩២, ៩០១ (សំនៀង), ២៦៧, ៧៤១, ៩០៩ (ពណ៌សម្បុរ), ១៨៦-១៨៧, ១៨៧-១៨៨ (វប្បធម៌), ២៦៦-២៦៧ (ដើមកណើត).

[126] ឯកសារ **D382** ដីកាដំណោះស្រាយ កថាខណ្ឌ ២១៤, ២៦៧, ៥៣៩។

[127] ឯកសារ **D382/22** បណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ កថាខណ្ឌ ៧១។

វៀតណាម[128] (ii) ប.ក.ក បានចាត់ទុកខ្មែរក្រោមជា "វៀតណាម ឬ យ៉ាងហោចណាស់ ក៏ជាក្រុមពិសេសមួយ ដែលមានភាពប្រហែលគ្នាខាងជាតិសាសន៍ ឬមានទំនាក់ទំនងជិតស្និទ្ធជាមួយវៀតណាម"[129] និង (iii) ដោយសារហេតុផលនេះ ខ្មែរក្រោម "ត្រូវទទួលរងគោលនយោបាយប្រឆាំងជនជាតិវៀតណាមរបស់បក្សកុម្មុយនីស្តកម្ពុជា"[130]។

<u>ខ. យឹម ទិត្យ ខកខានមិនបានបង្ហាញពីកំហុសដែលអាចពិនិត្យមើលឡើងវិញចំពោះការយល់ ឃើញរបស់ ស.ច.ស.អ ពាក់ព័ន្ធនឹងចេតនាជាក់លាក់របស់ យឹម ទិត្យ</u>

53. យឹម ទិត្យ បង្ហាញការយល់ឃើញរបស់ ស.ច.ស.អ មិនត្រឹមត្រូវ នៅពេលអះអាងថា ស.ច.ស.អ ខកខានមិនបានញែកឲ្យដាច់ស្រឡះរវាងចេតនារើសអើង ដែលជាលក្ខខណ្ឌចាំបាច់សម្រាប់ឧក្រិដ្ឋកម្មនៃការធ្វើទុក្ខបុកម្នេញ និងចេតនាជាក់លាក់ ដែលជាលក្ខខណ្ឌចាំបាច់សម្រាប់ឧក្រិដ្ឋកម្មប្រល័យពូជសាសន៍[131]។ ចំណុចទី១ ស.ច.ស.អ បង្ហាញយ៉ាងត្រឹមត្រូវអំពី*ធាតុផ្សំអត្តនោម័ត* ជាធរមាននៃឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ "ត្រូវមានចេតនាក្នុងការបំផ្លិចបំផ្លាញទាំងស្រុង ឬ មួយផ្នែកចំពោះក្រុមពាក់ព័ន្ធ"[132]។ ក្រោយមក នៅពេលសំអាងលើសំអាងហេតុនៃអំពើ និងសកម្មភាពរបស់ យឹម ទិត្យ ស.ច.ស.អ បានសន្និដ្ឋានថា "យឹម ទិត្យ បានចូលរួមចំណែកចេតនាពិសេសក្នុងការកម្ទេចខ្មែរក្រោម តាមរយៈសកម្មភាពជាមូលដ្ឋានក្នុងការសម្លាប់សមាជិកប្រជាជនខ្មែរក្រោម"[133]។

54. ម្យ៉ាងវិញទៀត យឹម ទិត្យ អះអាងដោយមិនត្រឹមត្រូវថា ស.ច.ស.អ ខកខានមិនបានបង្ហាញអង្គហេតុសំខាន់ ដែលបញ្ជាក់អំពីចេតនារបស់ យឹម ទិត្យ ឬ បញ្ជាក់ថាតើ ការយល់ឃើញណា

---

[128] ឯកសារ **D382** ដីកាដំណោះស្រាយ កថាខណ្ឌ ១៨៧, ១៩៦, ២៦៤, ២៦៧, ៧៦៩, ៧៩២, ៩០១, ៩០៩។ ដីកាលើកសម្រេចលែងចោទប្រកាន់បានសម្រេចដូចគ្នា *សូមមើល* ឯកសារ **D381** ដីកាសម្រេចលើកលែងចោទប្រកាន់ កថាខណ្ឌ ២១៩-២២០, ២៣៥, ៤០៥។

[129] ឯកសារ **D382** ដីកាដំណោះស្រាយ កថាខណ្ឌ ១៩៦។

[130] ឯកសារ **D382** ដីកាដំណោះស្រាយ កថាខណ្ឌ ១៩៨។ ដីកាលើកចម្រេចលែងចោទប្រកាន់បានសម្រេចដូចគ្នា *សូមមើល* ឯកសារ **D381** ដីកាសម្រេចលើកលែងចោទប្រកាន់ កថាខណ្ឌ ១៣៥, ១៥៣, ៣២៨-៣២៩, ៣៤២, ៣៥៨។

[131] ឯកសារ **D382/22** បណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ កថាខណ្ឌ ៧២-៧៣។ យឹម ទិត្យ លុបចោលដើម្បីធ្វើឲ្យច្រឡំនូវពាក្យ "ជាក់លាក់" ចេញពីការសម្រេចរបស់ ស.ច.ស.អ ដែលថា "យឹម ទិត្យ មានចេតនាទំនើងចិត្តជាក់លាក់ចំពោះអំពើប្រល័យពូជសាសន៍ និងការធ្វើទុកបុកម្នេញ" *សូមើល* ឯកសារ **D382** ដីកាដំណោះស្រាយ កថាខណ្ឌ ១០៤០។

[132] ឯកសារ **D382/22** បណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ កថាខណ្ឌ ៦៨។

[133] ឯកសារ **D382** ដីកាដំណោះស្រាយ កថាខណ្ឌ ១០២៣។

មួយពាក់ព័ន្ធនឹង យឹម ទិត្យ ពុំមែន ប.ក.ក ទេ[134]។ ជាក់ស្តែង ស.ច.ស.អ បានយល់ឃើញថា យឹម ទិត្យ បានលើកឡើងអំពីការស្អប់ខ្មែរក្រោម និងបំណងរបស់គាត់ចង់កម្ទេចពួកគេចោល[135] យឹម ទិត្យ បានធ្វើជាប្រធានក្នុងពេលប្រជុំដែលមានយោធា និងជនស៊ីវិលនៅភូមិភាគនិរតី និង ពាយ័ព្យចូលរួម ដែលនៅពេលនោះគាត់បានបញ្ជាក់ថា ខ្មែរក្រោម[136] "យួនខ្មែរ"[137] និង "យួន"[138] គឺជាខ្មាំង និងជាការគំរាមកំហែងដល់កម្ពុជាប្រជាធិបតេយ្យ[139] យឹម ទិត្យ បាន ណែនាំ "គ្រប់ ផ្នែកទាំងអស់ក្នុងសង្គម រួមទាំង កម្មាភិបាល ប.ក.ក ថ្នាក់ក្រោមឲ្យតាមដាន និងរាយការណ៍ពី អ្នកណា ដែលគេសង្ស័យថាមានខ្សែបណ្ដាញទាំងនេះ ដើម្បីយកទៅសម្លាប់"[140]។ ដោយផ្អែកលើ ការយល់ឃើញទាំងនេះ និងការយល់ឃើញផ្សេងទៀត ស.ច.ស.អ បានសន្និដ្ឋានថា យឹម ទិត្យ ទំនងជាអ្នកផ្ដួចផ្ដើមឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ចំពោះខ្មែរក្រោម[141]។

### ៣. យឹម ទិត្យ ខកខានក្នុងការបង្ហាញកំហុសដែលអាចពិនិត្យមើលឡើងវិញបាន ទាំងទម្រង់ ឬអង្គសេចក្ដី ចំពោះវិធីសាស្ត្ររបស់ ស.ច.ស.អ លើការទទួលខុសត្រូវរបស់ថ្នាក់លើ

55. យឹម ទិត្យ អះអាងដោយមិនត្រឹមត្រូវថា ស.ច.ស.អ ពុំបានកំណត់ត្រឹមត្រូវពីធាតុផ្សំផ្នែកច្បាប់ និង កំណត់ពីមូលដ្ឋានអង្គហេតុសម្រាប់សំអាងច្បាប់អំពីការទទួលខុសត្រូវរបស់ថ្នាក់លើ[142]។ ទី១ យឹម ទិត្យ ខកខានក្នុងការបង្ហាញថា ភស្តុតាងអំពីចំណងហេតុផលរវាងការខកខានក្នុងការទប់ស្កាត់ បទឧក្រិដ្ឋកម្មរបស់ថ្នាក់ក្រោម ជាមួយនឹងហេតុការណ៍នៃបទឧក្រិដ្ឋកម្មទាំងនោះ គឺជាធាតុផ្សំ ចាំបាច់មួយអំពីទម្រង់នៃការទទួលខុសត្រូវពាក់ព័ន្ធនឹងការទទួលខុសត្រូវរបស់ថ្នាក់លើ នៅក្នុងឆ្នាំ ១៩៧៥[143]។ យុត្តិសាស្ត្រ អ.វ.ត.ក ពុំទាមទារឲ្យមានធាតុផ្សំនេះទេ[144] ហើយ យឹម ទិត្យ សំអាង

[134] ឯកសារ D382/22 បណ្ដឹងឧទ្ធរណ៍របស់ យឹម ទិត្យ កថាខណ្ឌ ៧៦

[135] ឯកសារ D382 ដីកាដំណោះស្រាយ កថាខណ្ឌ ៣៨៧, ១០១១។

[136] ឯកសារ D382 ដីកាដំណោះស្រាយ កថាខណ្ឌ ៣៩០។

[137] ឯកសារ D382 ដីកាដំណោះស្រាយ កថាខណ្ឌ ៣៩០។

[138] ឯកសារ D382 ដីកាដំណោះស្រាយ កថាខណ្ឌ ៣៩០, ៣៩៤, ៣៩៧។

[139] ឯកសារ D382 ដីកាដំណោះស្រាយ កថាខណ្ឌ ៣៨៨-៣៩៧។

[140] ឯកសារ D382 ដីកាដំណោះស្រាយ កថាខណ្ឌ ៣៨៦។

[141] ឯកសារ D382 ដីកាដំណោះស្រាយ កថាខណ្ឌ ៩៩៦។

[142] ឯកសារ D382/22 បណ្ដឹងឧទ្ធរណ៍របស់ យឹម ទិត្យ កថាខណ្ឌ ៨១។

[143] ឯកសារ D382/22 បណ្ដឹងឧទ្ធរណ៍របស់ យឹម ទិត្យ កថាខណ្ឌ ៩២

លើប្រភព ដែលកើតក្រោយរយៈពេលយុត្តាធិការពេលវេលារបស់ អ.វ.ត.ក ដោយពុំបានបង្ហាញ ប្រភពទាំងនេះតំណាងច្បាប់ទំនៀមទម្លាប់អន្តរជាតិទេ[145]។ លើសពីនេះទៀត ទឡ្ហីករណ៍របស់ យឹម ទិត្យ ផ្តោតលើភារកិច្ចរបស់ថ្នាក់លើ ដើម្បីទប់ស្កាត់ឧក្រិដ្ឋកម្ម និងច្រានចោលការទទួលខុសត្រូវរបស់ថ្នាក់លើក្នុងការកំណត់លើអំពើសកម្ម ឬអំពើសកម្មដែលបានកើតឡើងក្រោយការប្រព្រឹត្តិបទឧក្រិដ្ឋកម្ម គឺនៅពេលថ្នាក់លើខកខានក្នុងការដាក់ទោសលើឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តឡើងដោយថ្នាក់ក្រោម[146]។

56. ចំណុចទី២ យឹម ទិត្យ ខកខានក្នុងការបង្ហាញថា សំអាងច្បាប់របស់ ស.ច.ស.អ ស្តីពីការគ្រប់គ្រងប្រកបដោយប្រសិទ្ធភាពរបស់គាត់ ពុំមានភស្តុតាងគ្រប់គ្រាន់[147]។ ដូចបានពន្យល់លម្អិតនៅក្នុងចម្លើយតបទៅនឹងមូលដ្ឋានទី ៥[148] យឹម ទិត្យ ខកខានក្នុងការបង្ហាញពីកំហុសដែលអាចពិនិត្យមើលឡើងវិញ នៅក្នុងការសម្រេចរបស់ ស.ច.ស.អ ថា យឹម ទិត្យ ទំនងកាន់តួនាទី *តាមផ្លូវច្បាប់* និងសិទ្ធិអំណាច*តាមព្រឹត្តន័យ* នៅក្នុងភូមិភាគនិរតី និងភូមិភាគពាយ័ព្យ។

## គ. មូលដ្ឋានទី ៣ ៖ យឹម ទិត្យ ខកខានមិនបានបង្ហាញកំហុសដែលអាចពិនិត្យឡើងវិញបានលើវិសាលភាពនៃអង្គហេតុដែលមាននៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ

57. ប្រសិនបើយល់ឃើញថាអាចទទួលយកបាន[149] ទឡ្ហីករណ៍របស់ យឹម ទិត្យ ផ្អែកលើការយល់ខុសអំពីដែនកំណត់ផ្នែកអង្គហេតុនៃការស៊ើបអង្កេត និងខកខានមិនបានបង្ហាញពីកំហុសអង្គច្បាប់ដែលអាចពិនិត្យឡើងវិញបាន ឬការបំពាននៅក្នុងការចេញដីកាបញ្ជូនរឿងទៅជំនុំជម្រះរបស់ ស.ច.ស.អ[150]។ ការយោងរបស់ ស.ច.ស.អ ទៅលើមុខតំណែងរបស់ យឹម ទិត្យ នៅគិរីវង់ និងការពិព័ណ៌នាអំពី "ការបោសសម្អាត" កម្មាភិបាលភូមិភាគពាយ័ព្យនៅក្នុងដីកាសន្និដ្ឋានបញ្ជូន

[144] សំណុំរឿង ០០១ ឯកសារ **E188** សាលក្រម *ឌុច* កថាខណ្ឌ ៥៣៨, ៥៤០-៥៤៧។ សំណុំរឿង ០០២ ឯកសារ **E313** សាលក្រមសំណុំរឿង ០០២/០១ កថាខណ្ឌ ៧១៥-៧១៦។ សំណុំរឿង ០០២ ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣៧២៥-៣៧២៦។

[145] ឯកសារ **D382/22** បណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ កថាខណ្ឌ ៨៩-៩០។

[146] *សូមមើល ឧទា.* សំណុំរឿង ០០២ ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣៧២៦។

[147] ឯកសារ **D382/22** បណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ កថាខណ្ឌ ៨១។

[148] *សូមមើល* កថាខណ្ឌ ៨០-១២៩ (ផ្នែក III.ង.២-៧)។

[149] *សូមមើល* សំណើបឋមនានា កថាខណ្ឌ ៤, ៧ (ភាពមិនអាចទទួលយកបាន)។

[150] ឯកសារ **D382/22** បណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ កថាខណ្ឌ ៩៧-១០៣។

រឿងឲ្យស៊ើបសួរលើកទី៣ មិនបានកម្រិតវិសាលភាពអង្គហេតុនៃការស៊ើបអង្កេតសំណុំរឿង០០៤ លើឧក្រិដ្ឋកម្មនៅភូមិភាគនិរតី និងភូមិភាគពាយ័ព្យឡើយ[151]។

58. "អង្គហេតុ" ដែល ស.ច.ស បានទទួលស៊ើបអង្កេតពាក់ព័ន្ធនឹងអំពើព្រហ្មទណ្ឌ[152]។ ចំណុចនេះមានភាពច្បាស់លាស់ពីការសម្រេចរបស់ អ.ប.ជ ដែលថា ស.ច.ស មាន "កាតព្វកិច្ចធ្វើការស៊ើបសួរលើអង្គហេតុទាំងអស់ដែលបានចោទប្រកាន់" នៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែម និងថា "កាលៈទេសៈដែលគេចោទថាឧក្រិដ្ឋកម្មបានប្រព្រឹត្តឡើង ហើយនាំដល់ការកំណត់បទចោទ មិនត្រូវគេយល់ឃើញថាជាអង្គហេតុថ្មី ហើយកាលៈទេសៈទាំងនេះជាផ្នែកមួយនៃការស៊ើបសួរ"[153]។ អ.ប.ជ ក៏បានកត់សម្គាល់ដែរថា នៅពេលចេញដីកាដំណោះស្រាយ ស.ច.ស "ត្រូវតែសម្រេចលើអង្គហេតុទាំងអស់ ដែលជាផ្នែកមួយនៃការស៊ើបសួររបស់ខ្លួន អាចច្រានចោលអង្គហាតុទាំងនេះ ដោយផ្អែកលើហេតុផលមួយក្នុងចំណោមហេតុផលនានាដែលបានលើកឡើងនៅក្នុងវាក្យខណ្ឌទី ៣ នៃ [វិធាន៦៧] ឬក៏បញ្ជូនជនត្រូវចោទទៅជំនុំជម្រះដោយសំអាងលើអំពើទាំងនេះ"[154]។ វិធាន៦៧ (៣) នៃវិធានផ្ទៃក្នុងចែងអំពីការលើកលែងចោទប្រកាន់ នៅពេលដែលជនប្រព្រឹត្តបទឧក្រិដ្ឋមិនទាន់កំណត់អត្តសញ្ញាណបាននៅឡើយ ពុំមានភស្តុតាងគ្រប់គ្រាន់ដើម្បីផ្តន្ទាទោសជនត្រូវចោទ ឬ "អំពើដែលចោទប្រកាន់មិនរាប់ចូលជាបទឧក្រិដ្ឋ"[155]។

59. បញ្ហាដែលជាកត្តាកំណត់គឺថាតើឧក្រិដ្ឋកម្មដែលត្រូវបានចោទនៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ ឬដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ ត្រូវបានកម្រិតពេលវេលាដែរឬទេ។ ឧក្រិដ្ឋកម្មនៅភូមិភាគនិរតី និងភូមិពាយ័ព្យ ដែល យឹម ទិត្យ ត្រូវបានចោទប្រកាន់ ពុំមានការកម្រិតពេលវេលាឡើយ នៅក្នុងការចោទប្រកាន់ដែល ស.ព.អ បានដាក់ជូន ស.ច.ស[156]។ ហេតុដូច្នេះ

---

[151] *ផ្ទុយពី* ឯកសារ **D382/22** បណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ កថាខណ្ឌ ៩៧-១០៣។

[152] ផ្ទុយពី ឯកសារ **D382/22** បណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ កថាខណ្ឌ ៩៩-១០២។

[153] សំណុំរឿង ០០១-ឯកសារ **D99/3/42** សាលដីការបស់ អ.ប.ជ លើដីកាបញ្ជូនរឿងទៅជំនុំជម្រះ កថាខណ្ឌ ៣៥។

[154] សំណុំរឿង ០០១-ឯកសារ **D99/3/42** សាលដីការបស់ អ.ប.ជ លើដីកាបញ្ជូនរឿងទៅជំនុំជម្រះ កថាខណ្ឌ ៣៧។

[155] គូសបញ្ជាក់បន្ថែម។

[156] សូមមើល ឯកសារ **D1** ដីកាសន្និដ្ឋានបញ្ជូនរឿងទៅស៊ើបសួរលើកទីបី កថាខណ្ឌ ៦០-៨១។ ឯកសារ **D196/1** ចម្លើយតបទៅនឹងដីកាបញ្ជូនសំណុំរឿងទៅពិនិត្យ D196 ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០១៤ កថាខណ្ឌ ២។ ឯកសារ **D65** ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែមរបស់សហព្រះរាជអាជ្ញាទាក់ទងទៅនឹងទីតាំងឧក្រិដ្ឋកម្មនានានៅក្នុងតំបន់ ១ និងការធ្វើទុក្ខបុកម្នេញចំពោះខ្មែរក្រោម ចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០១១ ("ដីកាបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែមលើតំបន់ ១ និងខ្មែរក្រោម")

ស.ច.ស.អ សម្រេចចោទប្រកាន់ដោយត្រឹមត្រូវចំពោះ យឹម ទិត្យ ពីឧក្រិដ្ឋកម្មដែលប្រព្រឹត្តនៅក្នុងភូមិភាគនិរតីពេញរបបកម្ពុជាប្រជាធិបតេយ្យ និងឧក្រិដ្ឋកម្មនៅភូមិភាគពាយ័ព្យ ចាប់តាំងពីយ៉ាងហោចណាស់ដើមឆ្នាំ១៩៧៧ រហូតដល់ថ្ងៃទី០៦ ខែមករា ឆ្នាំ១៩៧៩[157]។

60. យឹម ទិត្យ អះអាងដោយមិនត្រឹមត្រូវថា ស.ច.ស.អ "បានទទួលស្គាល់អនីត្យានុកូលនៃការសំអាងលើ [...] អង្គហេតុ" ដែលថា ការចោទប្រកាន់ យឹម ទិត្យ ស្ថិតនៅក្រៅវិសាលភាពនៃការស៊ើបអង្កេត[158]។ យឹម ទិត្យ លើកមកសំអាងផ្នែកនៃដីកាបញ្ជូនរឿងទៅជំនុំជម្រះដោយបញ្ជាក់ច្បាស់អំពីសហឧក្រិដ្ឋកម្មរួម ដែលគាត់ត្រូវបានចោទប្រកាន់[159] ដោយដាក់បញ្ចូលគ្នាដោយមិនត្រឹមត្រូវពី "អង្គហេតុ"ជាមួយនឹងទម្រង់នៃការទទួលខុសត្រូវ។ មិនតែប៉ុណ្ណោះ វិសាលភាពពេលវេលានៃសហឧក្រិដ្ឋកម្មរួមទាំងបីនៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ[160] មានលក្ខណៈដូចគ្នាប្រសិនបើមិនចង្អៀតជាងអ្វីដែលត្រូវបានចោទប្រកាន់ ក្នុងកំណត់ហេតុបង្ហាញខ្លួនលើកដំបូងរបស់ យឹម ទិត្យ នៅថ្ងៃទី ៩ ខែធ្នូ ឆ្នាំ២០១៥[161]។ នៅពេលនោះ យឹម ទិត្យ អាចតវ៉ាថា គាត់ត្រូវបានចោទប្រកាន់លើអង្គហេតុដែលនៅក្រៅការស៊ើបអង្កេតនៅក្នុងឆ្នាំទាំងនោះ។ ការសម្រេចចិត្តរបស់គាត់ក្នុងការរង់ចាំលើកឡើងចំណុចនេះនៅក្នុងចម្លើយតបចំពោះដីកាសន្និដ្ឋានស្ថាពរ[162] និងពេលនេះ នៅក្នុងបណ្តឹងឧទ្ធរណ៍ បង្ហាញថា វាមិនទាន់ពេលវេលា និងមិនមានមូលដ្ឋាន។

---

កថាខណ្ឌ ៥-២០។ ឯកសារ **D191** ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែមរបស់សហព្រះរាជអាជ្ញាអន្តរជាតិទាក់ទងនឹងអាពាហ៍ពិពាហ៍ដោយបង្ខំ ឬអំពើហិង្សាយេនឌ័រ ចុះថ្ងៃទី២៤ ខែមេសា ឆ្នាំ២០១៤ កថាខណ្ឌ ២-១០។

[157] ផ្ទុយពី ឯកសារ **D382/22** បណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ កថាខណ្ឌ ៩៩-១០២។

[158] ឯកសារ **D382/22** បណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ កថាខណ្ឌ ១០០, ១០២។

[159] ឯកសារ **D382** ដីកាបញ្ជូនរឿងទៅជំនុំជម្រះ កថាខណ្ឌ ១០២០ ដកស្រង់នៅក្នុងឯកសារ **D382/22** បណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ កថាខណ្ឌ ១០០, ១០២។

[160] ឯកសារ **D382** បញ្ជូនរឿងទៅជំនុំជម្រះ កថាខណ្ឌ ១០១៦។

[161] ឯកសារ **D281** កំណត់ហេតុនៃការបង្ហាញខ្លួនលើកដំបូងរបស់ យឹម ទិត្យ ERN 01178414-01178417។ វិសាលភាពពេលវេលានៃអ្វីដែល ស.ច.ស.អ ពណ៌នាថាជា សហឧក្រិដ្ឋកម្មរួម ក និងសហឧក្រិដ្ឋកម្មរួម ខ នៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ ដូចគ្នានៅក្នុងកំណត់ហេតុនៃការបង្ហាញខ្លួនលើកដំបូង។ វិសាលភាពពេលវេលានៃអ្វីដែល ស.ច.ស.អ ពណ៌នាថាជាសហឧក្រិដ្ឋកម្មរួម គ នៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ មានភាពចង្អៀតជាងនៅក្នុងកំណត់ហេតុនៃការបង្ហាញខ្លួនលើកដំបូង។

[162] ឯកសារ **D378/5** ចម្លើយតបរបស់ យឹម ទិត្យ ទៅនឹងដីកាសន្និដ្ឋានស្ថាពរ កថាខណ្ឌ ៤៤៧-៤៦៣។

## ឃ. មូលដ្ឋានទី ៤÷ យឹម ទិត្យ ខកខានមិនបានបង្ហាញកំហុសណាមួយដែលអាចពិនិត្យឡើងវិញបាន ចំពោះការពឹងផ្អែករបស់ ស.ច.ស.អ លើសហឧក្រិដ្ឋកម្មរួម

61. យឹម ទិត្យ ខកខានមិនបានបង្ហាញថា ស.ច.ស.អ ពឹងផ្អែកលើសហឧក្រិដ្ឋកម្មរួមក្នុងការវាយតម្លៃលើយុត្តាធិការបុគ្គល និងបើទោះជា ស.ច.ស.អ ធ្វើយ៉ាងដូចនេះក្តី ក៏វាជាកំហុសអង្គច្បាប់ដែលអាចពិនិត្យឡើងវិញបានដែរ[163]។ ទឡ្ហីករណ៍របស់ យឹម ទិត្យ មិនយកចិត្តទុកដាក់លើយុត្តាធិការរបស់ អ.វ.ត.ក និងផ្អែកលើការយល់ខុសលើច្បាប់ និងការបង្ហាញមិនត្រឹមត្រូវពីការសន្និដ្ឋានរបស់ស.ច.ស.អ[164]។

62. ទីមួយ យឹម ទិត្យ ខកខានមិនបានបង្ហាញថា ស.ច.ស.អ ពឹងផ្អែកលើសហឧក្រិដ្ឋកម្មរួមក្នុងការវាយតម្លៃលើយុត្តាធិការបុគ្គលឡើយ។ យឹម ទិត្យ គ្រាន់តែស្នើថា "ស.ច.ស.អ ទំនងបានសំអាងការសម្រេចរបស់ខ្លួនលើសិទ្ធិអំណាចតាមឋានានុក្រម របស់លោក យឹម ទិត្យដែលនៅដាច់ឆ្ងាយខ្លាំងពីគេ"[165]។ យឹម ទិត្យ អះអាងដោយមិនត្រឹមត្រូវថា យុត្តាធិការបុគ្គលអាចត្រឹមតែពិចារណាលើអំពើ និងការប្រព្រឹត្តិ ដែលមិននៅកៀកកិត ឬមិនមែនជាការប្រព្រឹត្តិផ្ទាល់។ ចំណុចនេះត្រូវបានបដិសេធដោយច្បាប់ និងការអនុវត្តរបស់ អ.វ.ត.ក[166]។

63. ទីពីរ យឹម ទិត្យ ខកខានមិនបានបង្ហាញថា ក្នុងករណីដែល ស.ច.ស.អ ពឹងផ្អែកលើសហឧក្រិដ្ឋកម្មរួម ក្នុងការវាយតម្លៃលើយុត្តាធិការបុគ្គល នេះគឺជាកំហុសមួយ។ ទឡ្ហីករណ៍របស់ យឹម ទិត្យ មានភាពមិនត្រឹមត្រូវក្នុងការជំទាស់ការអនុវត្តសហឧក្រិដ្ឋកម្មរួមថាជាទម្រង់មួយនៃការទទួលខុសត្រូវនៅ អ.វ.ត.ក ដែលត្រូវបានដោះស្រាយរួចយូរណាស់មកហើយនៅក្នុងយុត្តិសាស្ត្រ

---

[163] ឯកសារ **D382/22** បណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ កថាខណ្ឌ ១០៤-១២០។

[164] ឯកសារ **D382/22** បណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ កថាខណ្ឌ ១០៤-១២០។

[165] ឯកសារ **D382/22** បណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ ជើងទំព័រ ២៥៤ (គូសបញ្ជាក់បន្ថែម)។ សូមមើលផងដែរ កថាខណ្ឌ ១០៤។

[166] សំណុំរឿង ០០២-ឯកសារ **F36** សាលដីកាសំណុំរឿង ០០២/០១ កថាខណ្ឌ ៨១៦។ សំណុំរឿង ០០២-ឯកសារ **E313** សាលក្រមសំណុំរឿង ០០២/០១ កថាខណ្ឌ ៦៩១, ៧៧៨, ៨០៤, ៨៣៤។ សំណុំរឿង ០០២-ឯកសារ **E100/6** សេចក្តីសម្រេចរបស់ អ.ជ.ស.ដ លើភាពអាចអនុវត្តបាននូវសហឧក្រិដ្ឋកម្មរួម កថាខណ្ឌ ២២។ សំណុំរឿង ០០១-ឯកសារ **E188** សាលក្រមរឿងក្តី ឌុច កថាខណ្ឌ ៥១១-៥១២។ សំណុំរឿង ០០២-ឯកសារ **D97/15/9** សាលដីការបស់ អ.ប.ជ លើសហឧក្រិដ្ឋកម្មរួម កថាខណ្ឌ ៧២, ១០២។

របស់សាលាក្តី[167]។ យឹម ទិត្យ ពឹងផ្អែកលើសាលដីកាបណ្តឹងឧទ្ធរណ៍របស់ Braanin[168] ដោយលុបចំណុចថា អង្គជំនុំជម្រះសាលាឧទ្ធរណ៍នៅតុលាការ ICTY នៅក្នុងករណីនេះ បានសន្និដ្ឋានថា សហឧក្រិដ្ឋកម្មរួម "ផ្តល់ការធានាគ្រប់គ្រាន់ប្រឆាំងនឹងការជ្រុលជ្រួស ឬការភ្លាំងភ្លាត់ទៅក្នុងពិរុទ្ធភាពដោយការចូលរួម"[169]។ យឹម ទិត្យ ក៏លើកឡើងដោយមិនត្រឹមត្រូវផងដែរថា សហឧក្រិដ្ឋកម្មរួមគ្រាន់តែជាទម្រង់មួយនៃការទទួលខុសត្រូវដែលមិនពាក់ព័ន្ធនឹងជនជាប់ចោទអនុវត្តផ្នែកណាមួយនៃធាតុផ្សំសត្យានុម័តនៃបទល្មើសមូលដ្ឋានឡើយ[170]។ មិនតែប៉ុណ្ណោះ អំណះអំណាងរបស់ យឹម ទិត្យ ដែលថា ស.ច.ស.អ ប្រាសចាកពីវិធីសាស្ត្រក្នុងការវាយតម្លៃលើយុត្តាធិការបុគ្គលដែលប្រើក្នុងសំណុំរឿង ០០៤/១[171] ត្រូវបានបដិសេធដោយការដែលថា ស.ច.ស បានពឹងផ្អែកដោយច្បាស់លាស់លើការទទួលខុសត្រូវតាមសហឧក្រិដ្ឋកម្មរួម នៅពេលកំណត់លើយុត្តាធិការបុគ្គលនៅក្នុងរឿងក្តីនោះ[172]។

64. ទីបី ស.ច.ស.អ សន្និដ្ឋានថា យឹម ទិត្យ ស្ថិតក្នុងចំណោម "ជនដែលទទួលខុសត្រូវខ្ពស់បំផុត" ដោយសារ [យឹម ទិត្យ បានដើរ] "តួនាទីដ៏សំខាន់" នៅក្នុងអំពើយង់ឃ្នងទាំងអស់"[173] ក្នុងនោះរួមមាន "ការរៀបចំ" របស់គាត់នៅក្នុងអំពើប្រល័យពូជសាសន៍លើខ្មែរក្រោម[174] និងការដែលថា "ជនស៊ីវិលផ្សេងទៀត និងអតីតកម្មាភិបាល ប.ក.ក បានក្លាយជាជនរងគ្រោះនៅក្រោម យឹម ទិត្យ មានចំនួនរាប់ម៉ឺននាក់"[175] ក្នុងនោះរួមមាន "បុរស និងស្ត្រីត្រូវបានដាក់ឲ្យស្ថិតនៅក្រោម យឹម ទិត្យ

---

[167] សំណុំរឿង ០០២-ឯកសារ **F36** សាលដីកាសំណុំរឿង ០០២/០១ កថាខណ្ឌ ៧៦៧-៨១០។ សំណុំរឿង ០០២-ឯកសារ **E313** សាលក្រមសំណុំរឿង ០០២/០១ កថាខណ្ឌ ៦៩១, ៧៧៨, ៨០៤, ៨៣៤។ សំណុំរឿង ០០២-ឯកសារ **E100/6** សេចក្តីសម្រេចរបស់ អ.ជ.ស.ដ លើភាពអាចអនុវត្តបាននូវសហឧក្រិដ្ឋកម្មរួម កថាខណ្ឌ ២២។ សំណុំរឿង ០០១-ឯកសារ **E188** សាលក្រមរឿងក្តី ឌុច កថាខណ្ឌ ៥១១-៥១២។ សំណុំរឿង ០០២-ឯកសារ **D97/15/9** សាលដីការបស់ អ.ប.ជ លើសហឧក្រិដ្ឋកម្មរួម កថាខណ្ឌ ៧២, ១០២។

[168] ឯកសារ **D382/22** បណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ កថាខណ្ឌ ១១៦-១១៧។

[169] សាលដីការឿងក្តី *Brđanin* កថាខណ្ឌ ៤២៦។ សូមមើលផងដែរ កថាខណ្ឌ ៤២៨។

[170] សូមមើលឧទាហរណ៍ សំណុំរឿង ០០២-ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣៧១៧, ៣៧១៩, ៣៧២៥។ សំណុំរឿង ០០២-ឯកសារ **E313** សាលក្រមសំណុំរឿង ០០២/០១ កថាខណ្ឌ ៧១៥-៧១៦។

[171] ឯកសារ **D382/22** បណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ កថាខណ្ឌ ១១៤-១១៦។

[172] សំណុំរឿង ០០៤/១-ឯកសារ **D308/3** ដីកាដំណោះស្រាយ កថាខណ្ឌ ៣០៨-៣១១, ៣១៣។

[173] ឯកសារ **D382** បញ្ជូនរឿងទៅជំនុំជម្រះ កថាខណ្ឌ ៩៩៩។

[174] ឯកសារ **D382** បញ្ជូនរឿងទៅជំនុំជម្រះ កថាខណ្ឌ ៩៩៦។

[175] ឯកសារ **D382** បញ្ជូនរឿងទៅជំនុំជម្រះ កថាខណ្ឌ ៩៩៧។

និងអ្នកដែលគាត់សហការជាមួយចំពោះការពិសោធន៍សង្គមដែលគួរឲ្យខ្ពើមរបស់ ប.ក.ក ក្នុងការបន្ទាបបន្ថោកប្រពៃណីរៀបអាពាហ៍ពិពាហ៍ ឲ្យមកត្រឹមជាឧទាហរណ៍សម្រាប់ឃោសនា ចំពោះមនុស្ស"[176]។ យឹម ទិត្យ មិនយកចិត្តទុកដាក់ ដោយមិនត្រឹមត្រូវថា ការសន្និដ្ឋានទាំងនេះនៅក្នុងការវាយតម្លៃលើយុត្តាធិការបុគ្គលត្រូវបានគាំទ្រដោយសំអាងហេតុដ៏ច្រើនអនេកអំពីការពាក់ព័ន្ធរបស់គាត់នៅក្នុងការប្រព្រឹត្តិឧក្រិដ្ឋកម្ម[177]។

## ខ. មូលដ្ឋានទី ៥ ៖ យឹម ទិត្យ ខកខានមិនបានបង្ហាញកំហុសណាមួយដែលអាចពិនិត្យឡើងវិញបាននៅក្នុងការសន្និដ្ឋានថា គាត់គឺជា "ជនទទួលខុសត្រូវខ្ពស់បំផុត" ហេតុដូច្នេះ ស្ថិតក្រោមយុត្តាធិការបុគ្គលរបស់ អ.វ.ត.ក

65. យឹម ទិត្យ ខកខានមិនបានបង្ហាញកំហុសអង្គច្បាប់ កំហុសអង្គហេតុដែលអាចពិនិត្យឡើងវិញបាន ឬការបំពានណាមួយលើឆន្ទានុសិទ្ធិ ក្នុងការសន្និដ្ឋានថា យឹម ទិត្យ ស្ថិតក្នុងចំណោម "ជនដែលទទួលខុសត្រូវខ្ពស់បំផុត" ចំពោះឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងក្នុងរបបកម្ពុជាប្រជាធិបតេយ្យ[178]។ ការបង្ហាញភស្តុតាងដោយមិនត្រូវតាមការជ្រើសរើស និងច្រំដែលរបស់ យឹម ទិត្យ មិនបានប៉ះពាល់ដល់ការសន្និដ្ឋានអំពីសិទ្ធិអំណាចជាក់ស្តែង និងសិទ្ធិអំណាចតាមផ្លូវច្បាប់របស់គាត់នៅក្នុងភូមិភាគនិរតី និងភូមិភាគពាយ័ព្យ ឬការចូលរួមដ៏សំខាន់របស់គាត់នៅក្នុង សហឧក្រិដ្ឋកម្មរួមចំនួនបីដាច់ដោយឡែកពីគ្នា ក្នុងការប្រព្រឹត្តិឧក្រិដ្ឋកម្ម ទូទាំងប្រទេសកម្ពុជាពេញរបបកម្ពុជាប្រជាធិបតេយ្យឡើយ។ មិនតែប៉ុណ្ណោះ យឹម ទិត្យ មិនយកចិត្តទុកដាក់លើយុត្តិសាស្ត្រពាក់ព័ន្ធនឹងការទទួលខុសត្រូវតាមរយៈសហឧក្រិដ្ឋកម្មរួម ដោយដាក់លក្ខខណ្ឌតម្រូវដោយមិនត្រឹមត្រូវឲ្យមានការសន្និដ្ឋានថា គាត់បានចូលរួមយ៉ាងសំខាន់នៅក្នុងឧក្រិដ្ឋកម្មនីមួយៗនៅក្នុងផែនការរួម នៅពេលច្បាប់ជាធរមានតម្រូវតែការចូលរួមបែបនេះនៅក្នុងផែនការរួមតែប៉ុណ្ណោះ[179]។ គាត់

---

[176] ឯកសារ **D382** បញ្ជូនរឿងទៅជំនុំជម្រះ កថាខណ្ឌ ៩៩៨។

[177] ឯកសារ **D382/22** បណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ កថាខណ្ឌ ១០៨-១២០។

[178] ឯកសារ **D382/22** បណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ កថាខណ្ឌ ១២២-១២៣។

[179] សូមមើលឧទាហរណ៍ សំណុំរឿង ០០២-ឯកសារ **D97/15/9** សាលដីការបស់ អ.ប.ជ លើសហឧក្រិដ្ឋកម្មរួម កថាខណ្ឌ ៣៨។ សំណុំរឿង ០០១-ឯកសារ **E188** សាលក្រមរឿងក្តី ឌុច កថាខណ្ឌ ៥០៨។ សំណុំរឿង ០០២-ឯកសារ **E313** សាលក្រមសំណុំរឿង ០០២/០១ កថាខណ្ឌ ៦៩៣។ ឯកសារ **D382** Indictment, ជើងទំព័រ ២៦៧។ សាលដីការឿងក្តី *Brđanin* កថាខណ្ឌ ៤២៧។ សាលដីការឿងក្តី *Popović* កថាខណ្ឌ ១៣៧៨។ សាលដីការឿងក្តី *Simba* កថាខណ្ឌ ២៥០។ សាលដីការឿងក្តី *Sesay* កថាខណ្ឌ ៦១១, ១០៣៤។

លើកឡើងដដែលៗពីកំហុសឆ្គងនេះនៅក្នុងមូលដ្ឋានទាំងឡាយរបស់គាត់ពាក់ព័ន្ធនឹងសហឧក្រិដ្ឋកម្ម ក សហឧក្រិដ្ឋកម្ម ខ និងសហឧក្រិដ្ឋកម្ម គ។

**១. យឹម ទិត្យ ខកខានមិនបានបង្ហាញថា ការសន្និដ្ឋានដែលថា គាត់ទំនងជាមានសិទ្ធិអំណាចជាក់ស្តែង និងស្ថិតក្នុងចំណោម "ជនដែលទទួលខុសត្រូវខ្ពស់បំផុត" ផ្អែកតែទៅលើទំនាក់ទំនងរបស់គាត់ ជាមួយ តាម៉ុក ប៊ុណ្ណោះ**

66. ចំណងជើងនៃមូលដ្ឋានរងនៃបណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ លេខ ៥.១ លើកឡើងអំពីកំហុសមិនជាក់លាក់ ពាក់ព័ន្ធនឹងសិទ្ធិអំណាចជាក់ស្តែងតាមភវនីយភាព នៅក្នុងភូមិភាគនិរតី និងភូមិភាគពាយ័ព្យ ក៏ដូចជា នៅក្នុងការសន្និដ្ឋានដែលថា គាត់ទំនងជា "ជនដែលទទួលខុសត្រូវខ្ពស់បំផុត" ទាំងអស់ នេះ ផ្អែកលើចំណងសាច់ញាតិជាមួយតាម៉ុក[180]។ បណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ មិនមានភាព ច្បាស់លាស់ថាតើសារណារបស់គាត់ណាខ្លះដែលពាក់ព័ន្ធនឹងការតវ៉ាទាំងនេះ ប៉ុន្តែ លើកមកសំអាង សម្រាប់តែផ្នែកនៃដីកាបញ្ជូនរឿងទៅជំនុំជម្រះ ពាក់ព័ន្ធនឹងសិទ្ធិអំណាចជាក់ស្តែងរបស់គាត់តាមភវនីយភាពនៅក្នុងតំបន់ ១៣ និងភូមិភាគនិរតីទាំងមូល។ នៅក្នុងករណីណាក៏ដោយ ក៏ យឹម ទិត្យ ខកខានមិនបានបង្ហាញពីកំហុសអង្គច្បាប់ណាមួយ ដែលបដិសេធដីកាបញ្ជូនរឿងទៅជំនុំជម្រះ ឬកំហុសអង្គហេតុណាមួយដែលបណ្តាលឲ្យមានភាពអយុត្តិធម៌ នៅក្នុងការសន្និដ្ឋានទាំងឡាយ របស់ ស.ច.ស.អ នោះឡើយ។

<u>ក. យឹម ទិត្យ ខកខានមិនបានបង្ហាញកំហុសណាមួយដែលអាចពិនិត្យឡើងវិញបាន ក្នុងការសន្និដ្ឋានថាគាត់ទំនងជាមួយទំនាក់ទំនងជិតស្និទ្ធជាមួយ តាម៉ុក</u>

67. យឹម ទិត្យ បង្ហាញរូបភាពមួយផ្នែក និងនាំខុស នៃគំរូភស្តុតាងដែល ស.ច.ស.អ បានពឹងផ្អែកលើក្នុងការសន្និដ្ឋានថា យឹម ទិត្យ ទំនងជាមាន "ចំណងជិតស្និទ្ធ" ជាមួយតាម៉ុក[181] ខណៈដែលមិនយកចិត្តទុកដាក់លើការពឹងផ្អែករបស់ ស.ច.ស.អ ទៅលើសាក្សីជាច្រើននាក់ដែលរៀបរាប់អំពីសិទ្ធិអំណាចរបស់ យឹម ទិត្យ[182]។ ដូចនេះ ផ្ទុយទៅនឹងអំណះអំណាងរបស់ យឹម ទិត្យ ដីកាបញ្ជូនរឿងទៅជំនុំជម្រះមិនបានសន្និដ្ឋានថា យឹម ទិត្យ ទំនងជាមានសិទ្ធិអំណាចជាក់ស្តែងនៅក្នុង

---

[180] ឯកសារ **D382/22** បណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ កថាខណ្ឌ ១២៤-១៤១ (មូលដ្ឋានរងទី ៥.១)។

[181] ឯកសារ **D382/22** បណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ កថាខណ្ឌ ១២៤-១២៧។

[182] សូមមើល ឯកសារ **D382** បញ្ជូនរឿងទៅជំនុំជម្រះ កថាខណ្ឌ ៣៤៩។

ភូមិភាគនិរតី និងភូមិភាគពាយ័ព្យ ដោយផ្អែកតែទៅលើទំនាក់ទំនងសាច់ញាតិរបស់គាត់ ជាមួយ តាម៉ុក ឡើយ[183]។

68. ទទ្បីករណ៍របស់ យឹម ទិត្យ គឺជាការតវ៉ាជំទាស់នឹងភស្តុតាងរបស់សាក្សីចំនួនបីនាក់។ ផ្ទុយទៅនឹងការលើកឡើងរបស់ យឹម ទិត្យ ថា រៀល សន ដឹងតិចតួចអំពី យឹម ទិត្យ[184] រៀល សន ថ្លែងថា គាត់ពុំមាន "ទំនាក់ទំនងផ្ទាល់"[185]ជាមួយ យឹម ទិត្យ ទេ នៅក្នុងអំឡុងរបបខ្មែរក្រហម ប៉ុន្តែ គាត់ឃើញ យឹម ទិត្យ និងតាម៉ុក ធ្វើដំណើរជាមួយគ្នា[186]។

69. យឹម ទិត្យ អះអាងដោយមិនត្រឹមត្រូវថា សាន់ ឡូន មិនដឹងអំពីទំនាក់ទំនងរវាងតាម៉ុក និងយឹម ទិត្យ ឬមិនទាំងដឹងអ្វីទាំងអស់អំពី យឹម ទិត្យ ផង[187]។ តាមពិត សាន់ ឡូន ជាប់សាច់ញាតិជាមួយ យឹម ទិត្យ[188] និងបានផ្តល់ចម្លើយដល់អ្នកស៊ើបអង្កេត ក.ស.ច.ស ថា "តាទិត្យគឺជាប្អូនថ្លៃតាម៉ុក"[189] យឹម ទិត្យ ជាលេខាតំបន់១៣[190] តាម៉ុក ឲ្យតាទិត្យ ទៅធ្វើការនៅតំបន់ផ្សេង"[191] យឹម ទិត្យ និងតាម៉ុក "តែងតែរាយការណ៍ពីនេះពីនោះរវាងគ្នាហើយឲ្យគ្នាដឹងទៅវិញទៅមក"[192] ហើយ តាម៉ុក "ជាអ្នកយក តាទិត្យ ទៅជាមួយ"ទៅភូមិភាគពាយ័ព្យ[193]។

70. ភស្តុតាងរបស់ ណុប ធឹម ក៏មិនដូច យឹម ទិត្យ បង្ហាញដែរ[194]។ យឹម ទិត្យ អះអាងថា ណុប ធឹម មិនដឹងមុខតំណែងរបស់ យឹម ទិត្យ ឬ រចនាសម្ព័ន្ធរបស់ភូមិភាគនិរតីទេ[195]។ ប៉ុន្តែ ណុប ធឹម ថ្លែង

---

[183] ឯកសារ **D382/22** បណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ កថាខណ្ឌ ១២៤។

[184] ឯកសារ **D382/22** បណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ កថាខណ្ឌ ១២៦។

[185] ឯកសារ **D118/181** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី រៀល សន ឆ.៧២។

[186] ឯកសារ **D118/181** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី រៀល សន ឆ.៧៧-៨០។

[187] ឯកសារ **D382/22** បណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ កថាខណ្ឌ ១២៦។

[188] ឯកសារ **D219/19** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សាន់ ឡូន ឆ.៧១១, ៨២៨។

[189] ឯកសារ **D219/19** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សាន់ ឡូន ឆ.៧០៩, ៨២៧, ៩៥៥។

[190] ឯកសារ **D219/19** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សាន់ ឡូន ឆ.៨៨៤។

[191] ឯកសារ **D219/19** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សាន់ ឡូន ឆ.៨២១, ៨២៤។

[192] ឯកសារ **D219/19** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សាន់ ឡូន ឆ.៩៨៣។

[193] ឯកសារ **D219/19** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សាន់ ឡូន ឆ.៧៧៤។

[194] ផ្ទុយពី ឯកសារ **D382/22** បណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ កថាខណ្ឌ ១២៦។

[195] ឯកសារ **D382/22** បណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ កថាខណ្ឌ ១២៦។

ថា គាត់ស្គាល់ យឹម ទិត្យ មុនរបបខ្មែរក្រហម[196] ថា យឹម ទិត្យ គឺជា "មេដឹកនាំម្នាក់នៅក្នុងភូមិភាគនិរតី"[197] "តាម៉ុកមានឋានៈធំជាងតាទិត្យ"[198] ថា តាម៉ុក និងតាទិត្យ មកមើលកងរបស់គាត់ ជារៀងរាល់ខែ ដោយជិះរថយន្តដដែល[199] ថា គាត់បានចូលរួមប្រជុំនានាដែលរៀបចំឡើងដោយ យឹម ទិត្យ និង តាម៉ុក ជាមួយនឹងតំណាងស្រុក និងតំបន់[200] និងថា គេបង្ខំគាត់ឲ្យរៀបការជាមួយ យឹម ទិត្យ ហើយ តាម៉ុក មានវត្តមាននៅក្នុងថ្ងៃពិធីនោះ[201]។

71. មិនតែប៉ុណ្ណោះ ស.ច.ស.អ មិនចាំបាច់ញែកពីគ្នាពីតួនាទី និងសកម្មភាពរបស់ យឹម ទិត្យ ពី តាម៉ុក ទេ នៅពេលពួកគេដឹកនាំកិច្ចប្រជុំរួមគ្នានៅក្នុងតំបន់១[202]។ វត្តមានរបស់ យឹម ទិត្យ នៅកៀកជាប់នឹង តាម៉ុក នៅពេលប្រជុំ បង្ហាញអំពីការជាប់ពាក់ព័ន្ធ និងការយល់ព្រមរបស់ យឹម ទិត្យ លើគោលនយោបាយដែលបានពិភាក្សា និងអនុវត្ត[203]។ យឹម ទិត្យ ក៏ឡើងនិយាយនៅក្នុងកិច្ចប្រជុំបែបនោះដែរ[204] ដោយលើកឡើងដោយមិនគួរឲ្យជឿថា ស.ច.ស.អ ទម្លាក់កំហុសលើសកម្មភាពរបស់តាម៉ុក មកលើគាត់តែប៉ុណ្ណោះ។ ស្រដៀងគ្នានេះដែរ យឹម ទិត្យ អះអាងថា ស.ច.ស.អ មានកំហុសដោយ "ពឹងផ្អែកលើទំនាក់ទំនងសាច់ញាតិរបស់ យឹមទិត្យ ជាមួយតាម៉ុក" នៅពេលយល់ឃើញថា យឹម ទិត្យ គឺជាលេខាតំបន់ ៣[205] ក៏ប៉ុន្តែ ការសន្និដ្ឋានរបស់ ស.ច.ស.អ លើ យឹម

---

[196] ឯកសារ **D118/285** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ណុប ង៉ឹម ឆ.១១។

[197] ឯកសារ **D118/285** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ណុប ង៉ឹម ឆ.៩, ១២។

[198] ឯកសារ **D118/285** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ណុប ង៉ឹម ឆ.១៧។

[199] ឯកសារ **D118/285** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ណុប ង៉ឹម ឆ.៧-៨, ១៧។

[200] ឯកសារ **D118/285** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ណុប ង៉ឹម ឆ.៥៥។

[201] ឯកសារ **D118/285** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ណុប ង៉ឹម ឆ.៦៨, ៧៣។

[202] *ផ្ទុយពី* ឯកសារ **D382/22** បណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ កថាខណ្ឌ ១៨២។

[203] *សូមមើល* ឯកសារ **D382** ដីកាបញ្ជូនរឿងទៅជំនុំជម្រះ កថាខណ្ឌ ៣៦៦ *ដកស្រង់ក្នុងចំណោមនោះ* ឯកសារ **D118/285** កំណត់ហេតុស្តាប់ចម្លើយសាក្សី ណុប ង៉ឹម ឆ.៥៥-៥៦។ ឯកសារ **D219/298** កំណត់ហេតុស្តាប់ចម្លើយសាក្សី ណុប ង៉ឹម ឆ.១៣-១៤។ *សូមមើលផងដែរ* ឯកសារ **D219/835** កំណត់ហេតុស្តាប់ចម្លើយសាក្សី ណុប ង៉ឹម ឆ.៧៩, ៨១, ៨៨, ១០៧, ១១៣។ ឯកសារ **D382** ដីកាបញ្ជូនរឿងទៅជំនុំជម្រះ កថាខណ្ឌ ១០១៦។

[204] *សូមមើល* ឯកសារ **D219/835** កំណត់ហេតុស្តាប់ចម្លើយសាក្សី ណុប ង៉ឹម ឆ.៨៨, ១១៦, ១១៨, ៩៩។ ឯកសារ **D219/298** កំណត់ហេតុស្តាប់ចម្លើយសាក្សី ណុប ង៉ឹម ឆ.១៤, ១៦, ២២។ ឯកសារ **D118/285** កំណត់ហេតុស្តាប់ចម្លើយសាក្សី ណុប ង៉ឹម ឆ.៨៤, ៥៥-៥៦។ ឯកសារ **D219/974.1.2** ប្រតិចារិកនៃសក្ខីកម្មរបស់សាក្សី ណុប ង៉ឹម ថ្ងៃទី០៥ ខែកញ្ញា ឆ្នាំ២០១៦ ទំព័រ ៣៣ បន្ទាត់ ៨។

[205] ឯកសារ **D382/22** បណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ កថាខណ្ឌ ១៩៧។

ទិត្យ ទំនងជាលេខាតំបន់ ៣ ពុំមានការយោងណាមួយទៅដល់ទំនាក់ទំនងយឹម ទិត្យ ជាមួយ តាម៉ុក ឡើយ[206]។

<u>ខ. យឹម ទិត្យ ខកខានមិនបានបង្ហាញកំហុសណាមួយដែលអាចពិនិត្យឡើងវិញបានក្នុងការសន្និដ្ឋាន ថា គាត់ទំនងជាមានសិទ្ធិអំណាចដំណាលគ្នានៅក្នុងភូមិភាគនិរតី និងភូមិភាគពាយ័ព្យ ស្រដៀងគ្នានឹងតាម៉ុក</u>

72. យឹម ទិត្យ តាមការជ្រើសរើស ពឹងផ្អែកលើផ្នែកផ្សេងៗនៃចម្លើយនីមួយៗ ចេញពីមូលដ្ឋានភស្តុតាងទូលំទូលាយដែលត្រូវបានពឹងផ្អែកលើនៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះក្នុងការសន្និដ្ឋានថា គាត់ទំនងជាមានសិទ្ធិអំណាច និងការទទួលខុសត្រូវដំណាលគ្នានៅក្នុងភូមិភាគនិរតី និងពាយ័ព្យ[207]។

73. ផ្ទុយទៅនឹងការអះអាងរបស់ យឹម ទិត្យ សាន់ ឡូន ដឹងថា យឹម ទិត្យ ធ្វើដំណើរពីភូមិភាគមួយទៅភូមិភាគមួយ ពីព្រោះ សាន់ ឡូន ត្រូវបញ្ជូនទៅមន្ទីររបស់ តាម៉ុក នៅបាត់ដំបងក្នុងឆ្នាំ១៩៧៨ និងត្រូវបានគេប្រាប់ថា យឹម ទិត្យ បានចេញទៅតាកែវហើយ[208]។

74. ពេជ្រ ជឹម ដូចដែល យឹម ទិត្យ លើកឡើង មិន "ប្តូរភស្តុតាងរបស់គាត់ឡើយ" ដែលឮវិទ្យុផ្សាយនៅចុងឆ្នាំ១៩៧៨ថា យឹម ទិត្យ ទទួលស្វាគមន៍ភ្ញៀវនៅមន្ទីរតំបន់១៣[209]។ តាមការពិត ពេជ្រ ជឹម ត្រូវបានចោទសួរដោយអ្នកស៊ើបអង្កេតនៃ ក.ស.ច.ស នៅក្នុងការស្តាប់ចម្លើយបន្ទាប់មក ថាតើការនិយាយអំពីការផ្សាយវិទ្យុនោះ ជាការត្រឹមត្រូវ ឬយ៉ាងណានោះ គាត់ឆ្លើយថា "បាទ ត្រឹមត្រូវហើយ។ ថ្ងៃក្រោយមកទៀត និរសាររបស់ខ្ញុំបានប្រាប់ខ្ញុំអំពីរឿងនេះទៀត"[210]។

[206] ឯកសារ **D382** ដីកាបញ្ជូនរឿងទៅជំនុំជម្រះ កថាខណ្ឌ ៣៧២-៣៧៦។ យឹម ទិត្យ បានលើកជាទឡ្ហីករណ៍ដែលគ្មានមូលដ្ឋានស្រដៀងគ្នាទាក់ទិននឹងមុខងារផ្សេងទៀត *សូមមើល* ឯកសារ **D382/22** បណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ កថាខណ្ឌ ១៨៨ (តំបន់ ១), ២០២ (តំបន់ ៥), ២១៤ (ភូមិភាគពាយ័ព្យ)។

[207] ឯកសារ **D382/22** បណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ កថាខណ្ឌ ១៣៦។ *សូមមើល* ឯកសារ **D382** ដីកាបញ្ជូនរឿងទៅជំនុំជម្រះ កថាខណ្ឌ ៣៥២ ជើងទំព័រ ៩២៥។

[208] ឯកសារ **D219/19** កំណត់ហេតុស្តាប់ចម្លើយសាក្សី សាន់ ឡូន ឆ.៧៧៦-៧៨១។

[209] *ផ្ទុយពី* ឯកសារ **D382/22** បណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ កថាខណ្ឌ ១៣៦។

[210] ឯកសារ **D118/259** កំណត់ហេតុស្តាប់ចម្លើយសាក្សី ពេជ្រ ជឹម ឆ.១៣៦។

75. ដូចគ្នានេះដែរ ផាន់ សារ៉ូ មិន "ប្តូរសក្ខីកម្មរបស់គាត់ទេ" ដូចដែល យឹម ទិត្យ ជំទាស់ទេ[211]។ ការដឹងរបស់ ផាន់ សារ៉ូ អំពីមុខតំណែងរបស់ យឹម ទិត្យ នៅក្នុងស្រុកគិរីវង់ ខុសគ្នាពីការជឿរបស់ ផាន់ សារ៉ូ ដែលថា យឹម ទិត្យ ត្រូវបានតម្លើងឋានៈនៅរដ្ឋសភា[212]។ ប៉ាន់ សារ៉ូ ថ្លែងថា យឹម ទិត្យ គឺជា លេខាស្រុក "រហូតដល់ជិតចប់របបខ្មែរក្រហម"[213] ដោយហេតុថា ផាន់ សារ៉ូ ឃើញ យឹម ទិត្យ ប្រជុំនៅក្នុងភូមិនិងឃុំក្នុងគិរីវង់ជាញឹកញាប់[214]។

76. យឹម ទិត្យ បង្ហាញភស្តុតាង សឹម ឈឿន ខុស ដោយអះអាងថា សឹម ឈឿន "មិនបានឃើញគាត់"[215]។ តាមពិត សឹម ឈឿន បានឆ្លើយថា យឹម ទិត្យ គឺជាប្រធានស្រុកគិរីវង់ "រហូតទាល់តែចុងបញ្ចប់នៃរបបខ្មែរក្រហម ហើយ ខ្ញុំឃើញគាត់ញឹកញាប់"[216]។ សឹម ជឿន បញ្ជាក់ថា គាត់មិនឃើញ យឹម ទិត្យ ប៉ុន្មានខែមុនរបបនោះដួលរលំ "ប៉ុន្តែខ្ញុំដឹងថាកាត់នៅគ្រប់គ្រងស្រុកគិរីវង់"[217]។

77. ចុងក្រោយ យឹម ទិត្យ បង្ហាញភស្តុតាងរបស់ ហ៊ុយ ក្រឹម ខុស ថាមិនពាក់ព័ន្ធនឹងពេលវេលា[218]។ ហ៊ុយ ក្រឹម ថ្លែងថា គាត់ឃើញរូប យឹម ទិត្យ នៅក្នុងទស្សនាវដ្តីកម្ពុជាប្រជាធិបតេយ្យទាំងនៅក្នុងឆ្នាំ១៩៧៦ និងឆ្នាំ១៩៧៧[219] ប៉ុន្តែ ចំណុចនេះខុសពីការដឹងរបស់គាត់អំពីសិទ្ធិអំណាចរបស់ យឹម ទិត្យ។ ហ៊ុយ ក្រឹម ប្រាប់ ស.ច.ស.អ ថា "តាទិត្យ ចុះឡើងរទៅភូមិភាគនិរតីនិងភូមិភាគពាយ័ព្យ។ ហេតុដូច្នេះហើយបានជាគាត់មានអំណាចគ្រប់គ្រាន់ក្នុងការដកកម្មាភិបាលភាគពាយ័ព្យបានដោយស្រួល"[220]។ ហ៊ុយ ក្រឹម មិនបានថ្លែងថា ការដឹងរបស់គាត់មានកម្រិតត្រឹមតែ ឆ្នាំ១៩៧៦ ឬ ១៩៧៧ នោះទេ។

---

211 *ផ្ទុយពី* ឯកសារ **D382/22** បណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ កថាខណ្ឌ ១៣៦។

212 ឯកសារ **D118/302** កំណត់ហេតុស្តាប់ចម្លើយសាក្សី ប៉ាន់ សារ៉ូ ឆ.៤៧-៥២។

213 ឯកសារ **D118/302** កំណត់ហេតុស្តាប់ចម្លើយសាក្សី ប៉ាន់ សារ៉ូ ឆ.២៦។

214 ឯកសារ **D118/302** កំណត់ហេតុស្តាប់ចម្លើយសាក្សី ប៉ាន់ សារ៉ូ ឆ.៣៣-៣៦។

215 ឯកសារ **D118/259** កំណត់ហេតុស្តាប់ចម្លើយសាក្សី ពេជ្រ ជឹម ឆ.១៣៦។

216 ឯកសារ **D219/189** កំណត់ហេតុស្តាប់ចម្លើយសាក្សី សឹម ឈឿន ឆ.២៥។

217 ឯកសារ **D219/189** កំណត់ហេតុស្តាប់ចម្លើយសាក្សី សឹម ឈឿន ឆ.២៧។

218 ឯកសារ **D382/22** បណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ កថាខណ្ឌ ១៣៦។

219 ឯកសារ **D118/75** កំណត់ហេតុស្តាប់ចម្លើយសាក្សី ហ៊ុយ ក្រឹម ឆ.២៧, ៣០។

220 ឯកសារ **D118/75** កំណត់ហេតុស្តាប់ចម្លើយសាក្សី ហ៊ុយ ក្រឹម ឆ.២៩។

78. ការអះអាងរបស់ យឹម ទិត្យ ដែលថា ស.ច.ស.អ មិនបានសន្និដ្ឋានថា គាត់មិនមានអ្នកនៅក្រោមបង្គាប់ ផ្ទុយទៅនឹងផ្នែកសំខាន់ៗទាំងឡាយនៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ ដែលកំណត់ថា មានភស្តុតាងគ្រប់គ្រាន់អំពី យឹម ទិត្យ ក្នុងចំណោមបញ្ហាផ្សេងទៀត តែងតាំងមុខតំណែង ត្រួតពិនិត្យការដ្ឋាន ចេញបញ្ជា និងការណែនាំដល់ថ្នាក់ក្រោម រៀបចំកិច្ចប្រជុំ ចាត់ចែងការផ្គត់ផ្គង់ និងទទួលរបាយការណ៍អំពីការអនុវត្តគោលនយោបាយពីកម្មាភិបាលថ្នាក់ក្រោម[221]។ ការសន្និដ្ឋានបែបនេះត្រូវបានធ្វើឡើងពាក់ព័ន្ធនឹងមុខតំណែង និងតួនាទីសិទ្ធិអំណាចដែលគាត់មាន ទាំងនៅភូមិភាគនិរតី និងភូមិភាគពាយ័ព្យ[222]។

79. យឹម ទិត្យ សន្និដ្ឋាន ដោយមិនត្រឹមត្រូវថា ស.ច.ស.អ ខកខានមិនបានបង្ហាញថា ទំនាក់ទំនងរបស់គាត់ជាមួយ តាម៉ុក "មានន័យស្មើនឹងសិទ្ធិអំណាចតាមព្រឹត្តន័យរបស់ យឹម ទិត្យ នៅក្នុងតំបន់១៣ នៃភូមិភាគនិរតី និងនៅក្នុងភូមិភាគពាយ័ព្យ"[223]។ ការសន្និដ្ឋាននេះកំណត់ខុសទៅលើការសន្និដ្ឋានរបស់ ស.ច.ស.អ។ ដីកាបញ្ជូនរឿងទៅជំនុំជម្រះមិនបានសន្និដ្ឋានដោយ ច្បាស់លាស់ ឬដោយន័យធៀបថា សិទ្ធិអំណាចជាក់ស្តែងរបស់ យឹម ទិត្យ ត្រូវបានបង្ហាញត្រឹមតែ តាមរយៈចំណងសាច់ញាតិជាមួយ តាម៉ុក ប៉ុណ្ណោះ[224]។ ផ្ទុយទៅវិញ ខណៈដែលសិទ្ធិអំណាចជាក់ស្តែងរបស់ យឹម ទិត្យ អាចកើតចេញពីទំនាក់ទំនងសាច់ញាតិជាមួយ តាម៉ុក ប៉ុន្តែ អំពើ និងការប្រព្រឹត្តិរបស់ យឹម ទិត្យ គឺជាមូលដ្ឋាននៃការចោទប្រកាន់លើរូបគាត់[225]។

## ២. យឹម ទិត្យ ខកខានមិនបានបង្ហាញកំហុសណាមួយដែលអាចពិនិត្យឡើងវិញ ក្នុងការសន្និដ្ឋានថា គាត់មានមុខតំណែងតាមផ្លូវច្បាប់ និងសិទ្ធិអំណាចជាក់ស្តែងក្នុងស្រុកគិរីវង់

80. ការបែងចែកតាមទំនើងចិត្តលើភស្តុតាងរបស់ យឹម ទិត្យ ដែលគាំទ្រការសន្និដ្ឋានរបស់ដីកាបញ្ជូនរឿងទៅជំនុំជម្រះលើមុខតំណែងតាមផ្លូវច្បាប់ចេញពីសិទ្ធិអំណាចជាក់ស្តែងរបស់គាត់ នៅស្រុកគិរីវង់ បង្ហាញអំពីការខកខានរបស់គាត់ក្នុងបង្ហាញដោយត្រឹមត្រូវលើភស្តុតាងទាំងមូល។ ការវាយតម្លៃមិនតាមត្រឹមត្រូវទៅលើចម្លើយសាក្សី និងការសន្និដ្ឋានដោយមិនត្រឹមត្រូវដែលថា ស.ច.ស.អ បានពឹងផ្អែកលើភស្តុតាងពុំគ្រប់គ្រាន់ លុបចោលដំណើររឿងដែលផ្ទុយ និងធ្វើការសន្និដ្ឋានមិន

[221] ឯកសារ **D382** ដីកាបញ្ជូនរឿងទៅជំនុំជម្រះ កថាខណ្ឌ ៣២៧-៤២៧។

[222] ឯកសារ **D382** ដីកាបញ្ជូនរឿងទៅជំនុំជម្រះ កថាខណ្ឌ ៣២៧-៤២៧។

[223] ឯកសារ **D382/22** បណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ កថាខណ្ឌ ១៣៧។

[224] ឯកសារ **D382** ដីកាបញ្ជូនរឿងទៅជំនុំជម្រះ កថាខណ្ឌ ៣៤៨-៣៥២។

[225] ឯកសារ **D382** ដីកាបញ្ជូនរឿងទៅជំនុំជម្រះ កថាខណ្ឌ ៣៤៨-៣៥២។

ប្រាកដប្រជា ខកខានមិនបានបង្ហាញកំហុសអង្គច្បាប់ កំហុសអង្គហេតុ ឬការបំពានឆន្ទានុសិទ្ធិដែលអាចពិនិត្យឡើងវិញបាន[226]។ ក្រៅពីកំហុសឆ្គងនៅក្នុងការពិព័ណ៌នារបស់គាត់ទៅលើភស្តុតាងរបស់សាក្សីមួយចំនួនតូច សារណារបស់ យឹម ទិត្យ មិនអើពើថា ដីកាបញ្ជូនរឿងទៅជំនុំជម្រះបានពឹងផ្អែកលើសាក្សីដទៃទៀតដែលផ្តល់ភស្តុតាងអំពីមុខតំណែងតាមផ្លូវច្បាប់[227] និងសិទ្ធិអំណាចជាក់ស្តែងរបស់យឹមទិត្យ ក្នុងស្រុកគិរីវង់[228]។

## ក. យឹម ទិត្យ ខកខានមិនបានបង្ហាញពីកំហុសឆ្គងណាមួយដែលអាចពិនិត្យឡើងវិញបាននៅក្នុងការសន្និដ្ឋានថា គាត់ទំនងជាកាន់មុខតំណែងតាមផ្លូវច្បាប់នៅក្នុងស្រុកគិរីវង់

81. យឹម ទិត្យ មិនបង្ហាញពីរូបភាពត្រឹមត្រូវនៃចម្លើយ "ផ្ទុយ" របស់សាក្សីពីរនាក់ ដែលគាត់ចោទថា ស.ច.ស.អ មិនអើពើ[229]។ យឹម ទិត្យ ដកស្រង់ចម្លើយរបស់ តុប ផាន ថា គាត់ "មិនដឹងមុខតំណែងរបស់ យឹម ទិត្យ ទេ"[230] ប៉ុន្តែ ខកខានមិនទទួលស្គាល់ថា តុប ផាន បានប្រាប់អ្នកស៊ើបអង្កេតនៅក្នុងការស្តាប់ចម្លើយដដែលថា "តាទិត្យ យាយបូ និងតាគុំ ពួកគេសហការធ្វើការជាមួយគ្នា។ ខ្ញុំគិតថា តាទិត្យមានតំណែងធំ"[231] ហើយចំពោះ តា ទិត្យ គាត់ក៏ធ្វើការនៅមន្ទីរស្រុក [គិរីវង់] ប៉ុន្តែ ផ្ទះរបស់គាត់នៅក្រោមមន្ទីរស្រុក"[232]។

82. ស្រដៀងគ្នានេះ យឹម ទិត្យ ដកស្រង់ចម្លើយរបស់ ម៉ឹង វេត ថា "តាទិត្យមិនធ្វើការងារស្រុកដោយផ្ទាល់ទេ"[233] ប៉ុន្តែ លុបថា ម៉ឹង វេត ក៏បានប្រាប់អ្នកស៊ើបអង្កេតផងដែរថា យឹម ទិត្យ គឺជាគណៈស្រុក គិរីវង់ ក្នុងឆ្នាំ១៩៧៥[234] ថា គាត់ (ម៉ឹង វេត) គឺជានិរសារ និងយកសំបុត្រទៅឱ្យ យឹម ទិត្យ និងថា យឹម ទិត្យ បានសម្រេចលើការបែងចែកស្បៀងអាហារនៅក្នុងស្រុកនោះ[235] ថា មាន

[226] *ផ្ទុយពី* ឯកសារ **D382/22** បណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ កថាខណ្ឌ ១៤២-១៥១។

[227] *សូមមើល* ឯកសារ **D382** ដីកាបញ្ជូនរឿងទៅជំនុំជម្រះ ជើងទំព័រ ៨០៧-៨០៨។

[228] ឯកសារ **D382** ដីកាបញ្ជូនរឿងទៅជំនុំជម្រះ កថាខណ្ឌ ៣៣២-៣៤១។

[229] ឯកសារ **D382/22** បណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ កថាខណ្ឌ ១៤៤។

[230] ឯកសារ **D382/22** បណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ កថាខណ្ឌ ១៤៤។

[231] ឯកសារ **D118/305** កំណត់ហេតុស្តាប់ចម្លើយសាក្សី តុប ផាន ឆ.២៩។

[232] ឯកសារ **D118/305** កំណត់ហេតុស្តាប់ចម្លើយសាក្សី តុប ផាន ឆ.៥៦។

[233] ឯកសារ **D382/22** បណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ កថាខណ្ឌ ១៤៤។

[234] ឯកសារ **D119/85** កំណត់ហេតុស្តាប់ចម្លើយសាក្សី ម៉ឹង វេត ឆ.៣២។ ឯកសារ **D219/488** កំណត់ហេតុស្តាប់ចម្លើយសាក្សី ម៉ឹង វេត ឆ.៣។

[235] ឯកសារ **D219/488** កំណត់ហេតុស្តាប់ចម្លើយសាក្សី ម៉ឹង វេត ឆ.៨, ១២។

មន្ទីរស្រុកគិរីវង់ចំនួនពីរ[236] និង "មួយនៅផ្ទះតាទិត"[237] "កន្លែងរបស់ តាទិត្យ គឺជាមន្ទីរស្រុកគិរីវង់" ព្រមទាំងផ្តល់សក្ខីកម្មនៅក្នុងសំណុំរឿង០០២ ថា យឹម ទិត្យ "គណៈ"ស្រុកគិរីវង់ ឋានៈខ្ពស់ជាងលេខាស្រុក[238]។

83. យឹម ទិត្យ ជំទាស់ថា ស.ច.ស.អ ពឹងផ្អែកលើសក្ខីកម្មអំពី "ត្រឹមតែវត្តមាន" របស់គាត់នៅក្នុងគិរីវង់ ពីឆ្នាំ១៩៧២ ដល់ឆ្នាំ១៩៧៤ ក្នុងការសន្និដ្ឋានថា យឹម ទិត្យ មានមុខតំណែងតាមផ្លូវច្បាប់ក្នុងគិរីវង់[239]។ ក៏ប៉ុន្តែ ពុំមានការបង្ហាញនៅក្នុងដីកាបញ្ជូនទៅជំនុំជម្រះទេថា ស.ច.ស.អ បានពឹងផ្អែកលើវត្តមានរបស់ យឹម ទិត្យ នៅក្នុងគិរីវង់ពីឆ្នាំ១៩៧២ ដល់ ឆ្នាំ១៩៧៤ ក្រៅពីបង្ហាញអំពីភាពជាក់ស្តែងនៅក្នុងតំបន់នោះមុនរយៈពេលនៃការចោទប្រកាន់ទៀតផង[240]។

84. ចំពោះកំហុសឆ្គងពាក់ព័ន្ធនឹងដីកាបញ្ជូនរឿងទៅជំនុំជម្រះ យឹម ទិត្យ មានកំហុសឆ្គងនៅពេលពិភាក្សាលើដីកាសម្រេចលើកលែងចោទប្រកាន់។ ផ្ទុយទៅនឹងការអះអាងរបស់ យឹម ទិត្យ ដែលថា ដីកាសម្រេចលើកលែងចោទប្រកាន់ "មិនអាចធ្វើការសន្និដ្ឋានដាច់ខាត" ថាតើគាត់ជាលេខាស្រុក គិរីវង់ ពីខែមិថុនា ឆ្នាំ១៩៧៦ ដល់ឆ្នាំ១៩៧៧[241]ឬយ៉ាងណានោះ ដីកាលើកលែងចោទប្រកាន់ចែងផ្សេងៗគ្នាថា "តាទិត្យ ជាលេខាស្រុកក្នុងឆ្នាំ១៩៧៦"[242] "តាទិត្យជាលេខាស្រុកគិរីវង់ចន្លោះឆ្នាំ១៩៧៦ ដល់ឆ្នាំ១៩៧៧ និងក្រោយមកត្រូវបានផ្លាស់ទៅបាត់ដំបងប្រហែលពាក់កណ្តាល ឆ្នាំ១៩៧៧"[243] និង"យឹម ទិត្យ ក្លាយជាលេខាស្រុកគិរីវង់ និងលេខាតំបន់១៣ ចន្លោះឆ្នាំ១៩៧៦ ដល់ពាក់កណ្តាលឆ្នាំ ១៩៧៧"[244]។

85. យឹម ទិត្យ ក៏អះអាងដោយមិនត្រឹមត្រូវដែរថា ដីកាលើកលែងចោទប្រកាន់ "មិនបានសន្និដ្ឋានថា យឹម ទិត្យ អាចធ្វើជាគណៈស្រុកនោះមុនខែមករា ឆ្នាំ១៩៧៦ ហើយសំអាងហេតុរបស់

---

[236] ឯកសារ **D119/84** កំណត់ហេតុស្តាប់ចម្លើយសាក្សី ម៉ឹង វេត ឆ.៤១។

[237] ឯកសារ **D119/85** កំណត់ហេតុស្តាប់ចម្លើយសាក្សី ម៉ឹង វេត ឆ.៧។

[238] ឯកសារ **D219/899.1.4** ប្រតិចារិកនៃសក្ខីកម្មរបស់សាក្សី ម៉ឹង វេត ថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១៦ ទំព័រ ៣០ បន្ទាត់ ១១-១៥។

[239] ឯកសារ **D382/22** បណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ កថាខណ្ឌ ១៤៥។

[240] *សូមមើល* ឯកសារ **D382** ដីកាបញ្ជូនរឿងទៅជំនុំជម្រះ កថាខណ្ឌ ៣២៨។

[241] ឯកសារ **D382/22** បណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ កថាខណ្ឌ ១៤៦។

[242] ឯកសារ **D381** ដីកាលើកលែងចោទប្រកាន់ កថាខណ្ឌ ១៨៥។

[243] ឯកសារ **D381** ដីកាលើកលែងចោទប្រកាន់ កថាខណ្ឌ ១៨៧។ *សូមមើលផងដែរ* កថាខណ្ឌ ៦៦៧។

[244] ឯកសារ **D381** ដីកាលើកលែងចោទប្រកាន់ កថាខណ្ឌ ៦៨០។

ស.ច.ស.ជ មិនគាំទ្រសំអាងហេតុរបស់ ស.ច.ស.អ ត្រង់ចំណុចនេះទេ”[245]។ ប៉ុន្តែ ដីកាលើកលែងចោទប្រកាន់ សន្និដ្ឋានថា យឹម ទិត្យ “គឺជាអនុលេខា”ស្រុកគិរីវង់ក្នុងឆ្នាំ ១៩៧៥[246]។

86. ជាក់ស្តែង យឹម ទិត្យ ខកខានមិនបានទទួលស្គាល់ថា ដីកាបញ្ជូនរឿងទៅជំនុំជម្រះ និងដីកាលើកលែងចោទប្រកាន់ សន្និដ្ឋានថា គាត់គឺជាអនុលេខាស្រុកគិរីវង់ មុនត្រូវបានតែងតាំងជាលេខាស្រុក និងថា ហេតុដូចនេះ មិនអាចញែកដាច់ពីគ្នារវាងសិទ្ធិអំណាចតាមផ្លូវច្បាប់របស់គាត់ក្នុងគណៈកម្មាធិការស្រុកគិរីវង់ឡើយ[247]។

<u>ខ. យឹម ទិត្យ ខកខានមិនបានបង្ហាញកំហុសណាមួយដែលអាចពិនិត្យឡើងវិញបាន នៅក្នុងការសន្និដ្ឋានថា គាត់ទំនងជាមានសិទ្ធិអំណាចជាក់ស្តែងនៅក្នុងស្រុកគិរីវង់</u>

87. យឹម ទិត្យ អះអាងថា ស.ច.ស.អ បកស្រាយខុសលើភស្តុតាងរបស់សាក្សី និងខកខានមិនបានរៀបរាប់ភស្តុតាងផ្ទុយ និងដោះបន្ទុក ដោយលើកមកសំអាងបុគ្គលចំនួនបីនាក់ គឺ ទឹម ភួន, ង៉ែត ងយ និងម៉ឹង វេត[248]។ ប៉ុន្តែ ការពិនិត្យទៅលើភស្តុតាងទាំងអស់បង្ហាញថា យឹម ទិត្យ ជាថ្មីម្តងទៀត លើកឡើងចោះៗតែប៉ុណ្ណោះនៅក្នុងសារណាររបស់គាត់។

88. យឹម ទិត្យ ពឹងផ្អែកលើការស្តាប់ចម្លើយចំនួនពីររបស់ ក្មួយប្រុស យឹម ទិត្យ គឺ ទឹម ភួន ដែលក្នុងនោះ ទឹម ភួន និយាយថា គាត់មិនដឹងអំពីមុខតំណែងរបស់ យឹម ទិត្យ[249]។ ប៉ុន្តែ យឹម ទិត្យ លុបថា ទឹម ភួន បានប្រាប់អ្នកស៊ើបអង្កេតនៅក្នុងការស្តាប់ចម្លើយលើកទីមួយថា គាត់ត្រូវគេបញ្ជូនឲ្យទៅរស់នៅពេជ្រស ក្នុងស្រុកគិរីវង់ឲ្យស្ទូងស្រូវ នៅ “កន្លែងដែលតាទិត្យគ្រប់គ្រង”[250] និងថា “ខ្ញុំគ្រាន់តែដឹងថា [យឹម ទិត្យ] មានតួនាទីធំ តែមិនដឹងគាត់មានតំណែងអ្វីទេ”[251]។ នៅក្នុងការស្តាប់ចម្លើយមួយបន្ទាប់មកទៀត ទឹម ភួន ឆ្លើយតបទៅនឹងសំណួរបំភ្លឺថាតើ គាត់ចង់និយាយថា យឹម ទិត្យ ជាអ្នកដឹកនាំម្នាក់ឬយ៉ាងណា ដោយនិយាយថា “បាទ តែខ្ញុំមិនដឹងគាត់មានតំណែង

---

[245] ឯកសារ **D382/22** បណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ កថាខណ្ឌ ១៤៦។

[246] ឯកសារ **D381** ដីកាលើកលែងចោទប្រកាន់ កថាខណ្ឌ ១៨៥។

[247] ឯកសារ **D382** ដីកាបញ្ជូនរឿងទៅជំនុំជម្រះ កថាខណ្ឌ ១៩៥។ ឯកសារ **D381** ដីកាលើកលែងចោទប្រកាន់ កថាខណ្ឌ ៣៣០។

[248] ឯកសារ **D382/22** បណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ កថាខណ្ឌ ១៤៧-១៥០។

[249] ឯកសារ **D382/22** បណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ កថាខណ្ឌ ១៤៨។

[250] ឯកសារ **D118/20** កំណត់ហេតុស្តាប់ចម្លើយសាក្សី ទឹម ភួន ឆ.៤-៦។

[251] ឯកសារ **D118/20** កំណត់ហេតុស្តាប់ចម្លើយសាក្សី ទឹម ភួន ឆ.១០។

អ្វីទេ”[252] និងបន្ថែមថា “ខ្ញុំគិតថាគាត់ប្រហែលនៅថ្នាក់ស្រុក ស្រុកគិរីវង់”[253]។ លើសពីនេះទៀត ទឹម ភួន និយាយថា “ខ្ញុំគ្រាន់តែដឹងថាក្នុងចំណោមអ្នកដឹកនាំក្នុងស្រុកគិរីវង់មាន យាយ ចែម តាតុំ និងតាទិត្យ ប៉ុន្តែខ្ញុំមិនដឹងថានណាធំជាងនណាទេ...”[254]។ យឹម ទិត្យ សំអាងទាំងខុសដល់ចម្លើយបន្ថែមមួយថាជាចម្លើយរបស់ ទឹម ភួន ដែលតាមការពិតគឺជាចម្លើយរបស់សាក្សី តុប ផាន[255]។ ចម្លើយដែលយោងខុសនេះមិនគាំទ្រការអះអាងរបស់ យឹម ទិត្យ ឡើយក្នុងករណីណាក៏ដោយ[256]។

89. យឹម ទិត្យ អះអាងថា ង៉ែត ងយ “និយាយថាគាត់មិនដឹងអ្វីទាំងអស់អំពីលោក យឹម ទិត្យ តាមការឆ្លងកាត់ផ្ទាល់របស់គាត់”[257]។ ប៉ុន្តែ ង៉ែត ងយ បានប្រាប់អ្នកស៊ើបអង្កេតថា គាត់ឃើញ យឹម ទិត្យ “ញឹកញាប់ពីព្រោះ [យឹម ទិត្យ]ចុះមើលតាមភូមិ” ក្នុងស្រុកគិរីវង់[258]។ ភស្តុតាងរបស់ ង៉ែត ងយ ក៏បានផ្តល់ក្របខ័ណ្ឌពេលវេលាច្បាស់លាស់មួយសម្រាប់ពេលដែល យឹម ទិត្យ ធ្វើជាលេខាស្រុកគិរីវង់[259] ដោយប្រាប់អ្នកស៊ើបអង្កេត ក.ស.ច.ស ថា គាត់ធ្វើការនៅភូមិស្វាយស ស្រុកគិរីវង់ រហូតដល់ចុងឆ្នាំ១៩៧៧[260]ហើយអំឡុងពេលនោះហើយដែលគាត់ឃើញ និងនិយាយជាមួយ យឹម ទិត្យ[261]។ លើសពីនេះទៀត ការអះអាងរបស់ យឹម ទិត្យដែលថា ស.ច.ស.អ បានពឹងផ្អែកដោយមិនត្រឹមត្រូវលើ ង៉ែត ងយ “ជាប្រភពនៃការសន្និដ្ឋានថា យឹម ទិត្យ គឺជា “មេ”របស់គាត់ ត្រូវបានកុហកដោយការពិនិត្យលើកំណត់សម្គាល់ជើងទំព័រនៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ ដែលលើកសក្ខីកម្មសំណុំរឿង ០០២ មកសំអាង និងចម្លើយរបស់សាក្សីម្នាក់ទៀតក្នុងសំណុំរឿង ០០៤[262]។

---

[252] ឯកសារ **D219/466** កំណត់ហេតុស្តាប់ចម្លើយសាក្សី ទឹម ភួន ស.&ឆ.២៤៥។

[253] ឯកសារ **D219/466** កំណត់ហេតុស្តាប់ចម្លើយសាក្សី ទឹម ភួន ឆ.២៤៧។

[254] ឯកសារ **D219/466** កំណត់ហេតុស្តាប់ចម្លើយសាក្សី ទឹម ភួន ឆ.២៧៧។ *សូមមើលផងដែរ* កថាខណ្ឌ ២៦៣-២៦៤, ៣១៨។

[255] ឯកសារ **D118/305** កំណត់ហេតុស្តាប់ចម្លើយសាក្សី តុប ផាន។

[256] ឯកសារ **D118/305** កំណត់ហេតុស្តាប់ចម្លើយសាក្សី តុប ផាន ឆ.២៩, ៥៦។

[257] ឯកសារ **D382/22** បណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ កថាខណ្ឌ ១៤៩។

[258] ឯកសារ **D118/44** កំណត់ហេតុស្តាប់ចម្លើយសាក្សី ង៉ែត ងយ ឆ.១៣។

[259] *ផ្ទុយពី* ឯកសារ **D382/22** បណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ កថាខណ្ឌ ១៤៩។

[260] ឯកសារ **D118/44** កំណត់ហេតុស្តាប់ចម្លើយសាក្សី ង៉ែត ងយ ឆ.១-២។

[261] ឯកសារ **D118/44** កំណត់ហេតុស្តាប់ចម្លើយសាក្សី ង៉ែត ងយ ឆ.១១-១៤។

[262] *សូមមើល* ឯកសារ **D382** ដីកាបញ្ជូនរឿងទៅជំនុំជម្រះ ជើងទំព័រ ៨៦៩។

90. ចំពោះការលើកឡើងរបស់គាត់ពាក់ព័ន្ធនឹងការសន្និដ្ឋានលើមុខតំណែងតាមផ្លូវច្បាប់របស់គាត់ យឹម ទិត្យ ខកខានមិនបានធ្វើឲ្យប៉ះពាល់ដល់ភស្តុតាងរបស់ ម៉ឹង វេត ទាក់ទិននឹងសិទ្ធិអំណាចជាក់ស្តែងឡើយ។ ផ្ទុយនឹងការលើកឡើងថា ភស្តុតាងរបស់ ម៉ឹង វេត បានពាក់ព័ន្ធនឹងពេលវេលាខ្លីមួយ ម៉ឹង វេត បានប្រាប់អ្នកស៊ើបអង្កេតថា យឹម ទិត្យ គឺជាគណៈស្រុកគិរីវង់រួចទៅហើយ នៅពេល ម៉ឹង វេត បានទៅដល់ក្នុងខែកញ្ញា ឆ្នាំ១៩៧៥[263] និងថា (ម៉ឹង វេត) "យកសំបុត្រទៅដល់ដៃផ្ទាល់ យឹម ទិត្យ តែម្តង"[264] នៅពេលគាត់ចាប់ផ្តើមនាំសារទៅមន្ទីររបស់ យឹម ទិត្យ "ចន្លោះដើមឆ្នាំ១៩៧៦ រហូតដល់ចុងឆ្នាំ១៩៧៦"[265]។ ម៉ឹង វេត និយាយទៀតថា ពុំមានការផ្លាស់ប្តូរបុគ្គលិកនៅក្នុងមន្ទីររបស់ យឹម ទិត្យ ទេ ចន្លោះខែកញ្ញា ឆ្នាំ១៩៧៥ ដល់ខែមីនា ឆ្នាំ១៩៧៧[266]។ ដូចគ្នានេះដែរ ការអះអាងដែលថា ការដឹងជាមូលដ្ឋានរបស់ ម៉ឹង វេត អំពី យឹម ទិត្យ មានប្រភពមកពីម្តាយរបស់ ម៉ឹង វេត ពិតជាផ្ទុយជាមួយនឹងការឆ្លងកាត់ជាក់ស្តែងផ្ទាល់របស់ ម៉ឹង វេត ក្នុងនាម ជានិរសារយកសំបុត្រឲ្យ យឹម ទិត្យ[267]។ ម៉ឹង វេត បានប្រាប់អ្នកស៊ើបអង្កេតថា ម្តាយរបស់គាត់ប្រាប់ថា តាគុំ ត្រូវបានចាប់ខ្លួន[268] និងថា យឹម ទិត្យ មានឋានៈខ្ពស់ជាង តាគុំ[269]។ អ្វីដែល សំខាន់គឺថា ម្តាយរបស់ ម៉ឹង វេត គឺជាបងប្អូនជីដូនមួយ របស់ តាគុំ[270]។

### ៣. យឹម ទិត្យ ខកខានមិនបានបង្ហាញកំហុសណាមួយដែលអាចពិនិត្យឡើងវិញបានក្នុងការសន្និដ្ឋានថា គាត់ទំនងជាកាន់មុខតំណែងតាមផ្លូវច្បាប់ និងសិទ្ធិអំណាចជាក់ស្តែងនៅក្នុងតំបន់១៣

91. ដូចនៅក្នុងមូលដ្ឋានរងមុន យឹម ទិត្យ បង្ហាញការខកខានរបស់គាត់ក្នុងការលើកឡើងពីភស្តុតាងត្រឹមត្រូវ ជារួម ដោយជាថ្មីម្តងទៀតញែកតាមអំពើចិត្តលើភស្តុតាងដែលគាំទ្រការសន្និដ្ឋានរបស់ ស.ច.ស.អ អំពីមុខតំណែងតាមផ្លូវច្បាប់របស់គាត់ ពីសិទ្ធិអំណាចជាក់ស្តែងរបស់គាត់ក្នុងតំបន់១៣។ ការលើកឡើងរបស់ យឹម ទិត្យ ថា ស.ច.ស.អ មិនគួរសន្និដ្ឋានថា យឹម ទិត្យ មានសិទ្ធិ

---

[263] ឯកសារ **D119/85** កំណត់ហេតុស្តាប់ចម្លើយសាក្សី ម៉ឹង វេត ឆ.២២។ ឯកសារ **D119/85** កំណត់ហេតុស្តាប់ចម្លើយសាក្សី ម៉ឹង វេត ឆ.៣២។

[264] ឯកសារ **D219/488** កំណត់ហេតុស្តាប់ចម្លើយសាក្សី ម៉ឹង វេត ឆ.១០។

[265] ឯកសារ **D219/488** កំណត់ហេតុស្តាប់ចម្លើយសាក្សី ម៉ឹង វេត ឆ.៦-៧។

[266] ឯកសារ **D219/488** កំណត់ហេតុស្តាប់ចម្លើយសាក្សី ម៉ឹង វេត ឆ.៣០-៣១។

[267] *សូមមើលឧទាហរណ៍* ឯកសារ **D219/488** កំណត់ហេតុស្តាប់ចម្លើយសាក្សី ម៉ឹង វេត ឆ.៨, ១២។

[268] ឯកសារ **D119/85** កំណត់ហេតុស្តាប់ចម្លើយសាក្សី ម៉ឹង វេត ស.&ឆ.២៨។

[269] ឯកសារ **D119/85** កំណត់ហេតុស្តាប់ចម្លើយសាក្សី ម៉ឹង វេត ឆ.២៥។

[270] ឯកសារ **D119/85** កំណត់ហេតុស្តាប់ចម្លើយសាក្សី ម៉ឹង វេត ឆ.១, ២៥។

អំណាចជាក់ស្តែង ដោយគ្មានភស្តុតាងអំពីមុខតំណែងតាមផ្លូវច្បាប់ គឺជាឧទាហរណ៍នៃការវិភាគដែលប្រាសចាកពីនិយាម[271]។ វិធីសាស្ត្រជ្រើសរើសភស្តុតាងរបស់ យឹម ទិត្យ និងការសន្និដ្ឋានដោយមិនត្រឹមត្រូវ ខកខានមិនបានបង្ហាញពីកំហុសអង្គច្បាប់ ឬអង្គហេតុណាមួយដែលអាចពិនិត្យឡើងវិញបាន[272]។

<u>ក. យឹម ទិត្យ ខកខានមិនបានបង្ហាញពីកំហុសណាមួយដែលអាចពិនិត្យឡើងវិញបាន ក្នុងការសន្និដ្ឋានថា គាត់ទំនងជាកាន់មុខតំណែងតាមផ្លូវច្បាប់ក្នុងគណៈកម្មាធិការតំបន់ ១៣</u>

92. ផ្ទុយនឹងការអះអាងរបស់ យឹម ទិត្យ ដែលថា ដីកាបញ្ជូនរឿងទៅជំនុំជម្រះ "មិនអាចធ្វើការសន្និដ្ឋានថា លោក យឹម ទិត្យ ធ្វើជាលេខាតំបន់ ១៣"[273] ស.ច.ស.អ "សន្និដ្ឋានថា យឹម ទិត្យ ជាលេខាតំបន់ ១៣ នៅពេលមួយក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ"[274]។ ស.ច.ស.អ បានពឹងផ្អែកលើ "សាក្សីផ្ទៃក្នុង" មួយចំនួន ក្នុងការសន្និដ្ឋានថា យឹម ទិត្យ កាន់មុខតំណែងតាមផ្លូវច្បាប់នេះ[275]។ ការដែលសាក្សីផ្តល់ភស្តុតាងអំពី យឹម ទិត្យ កាន់តំណែងនេះក្នុងឆ្នាំ១៩៧៥ ១៩៧៦ ១៩៧៧ ឬ ១៩៧៨[276] គ្រាន់តែដើម្បីបង្កើតរូបភាពថា យឹម ទិត្យ មានវត្តមាននៅក្នុងតំបន់ ១៣ ពេញអំឡុងពេលនៃការចោទប្រកាន់តែប៉ុណ្ណោះ។ ចំណុចគួរកត់សម្គាល់គឺថា ដីកាលើកលែងចោទប្រកាន់ក៏សន្និដ្ឋានថា យឹម ទិត្យ "បានក្លាយជាលេខាតំបន់ ១៣ តែ ១(មួយ) ឆ្នាំមុនពេញទៅភូមិភាគពាយ័ព្យ"[277] និងថា "យឹម ទិត្យ ទទួលឋានៈជាលេខាស្រុកគិរីវង់ និងលេខាតំបន់ ១៣ ចន្លោះឆ្នាំ ១៩៧៦ ដល់ពាក់កណ្តាលឆ្នាំ ១៩៧៧"[278]។

---

[271] ឯកសារ **D382/22** បណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ កថាខណ្ឌ ១៦១។

[272] *ផ្ទុយពី* ឯកសារ **D382/22** បណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ កថាខណ្ឌ ១៥៤-១៦៣ (មូលដ្ឋានរងទី ៥.២.ii)។

[273] ឯកសារ **D382/22** បណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ កថាខណ្ឌ ១៥៥។

[274] ឯកសារ **D382** ដីកាបញ្ជូនរឿងទៅជំនុំជម្រះ កថាខណ្ឌ ៣៤៦។

[275] ឯកសារ **D382** ដីកាបញ្ជូនរឿងទៅជំនុំជម្រះ កថាខណ្ឌ ៣៤៦។

[276] ឯកសារ **D382** ដីកាបញ្ជូនរឿងទៅជំនុំជម្រះ កថាខណ្ឌ ៣៤៦។

[277] ឯកសារ **D381** ដីកាលើកលែងចោទប្រកាន់ កថាខណ្ឌ ៦៦៨។

[278] ឯកសារ **D381** ដីកាលើកលែងចោទប្រកាន់ កថាខណ្ឌ ៦៨០។

ខ. យឹម ទិត្យ ខកខានមិនបានបង្ហាញពីកំហុសណាមួយដែលអាចពិនិត្យឡើងវិញបាន ក្នុងការសន្និដ្ឋានថា គាត់ទំនងជាមានសិទ្ធិអំណាចជាក់ស្តែងក្នុងតំបន់ ១៣

93. យឹម ទិត្យ ខកខានមិនបានពន្យល់ថាតើភស្តុតាងបញ្ជាក់ពីគាត់ត្រួតពិនិត្យការដ្ឋាន ចូលរួមប្រជុំ ឬធ្វើការនៅមន្ទីរភូមិភាគនិរតី គឺជា "កត្តាមិនពាក់ព័ន្ធ" នៅពេលវាយតម្លៃសិទ្ធិអំណាចជាក់ស្តែង នៅក្នុងបរិបទនៃរចនាសម្ព័ន្ធតាមឋានានុក្រមតឹងរ៉ឹងរបស់ ប.ក.ក[279]។ ដីកាបញ្ជូនរឿងទៅជំនុំជម្រះ ពឹងផ្អែកលើសាក្សីជាច្រើនក្នុងការសន្និដ្ឋានថា យឹម ទិត្យ ទំនងជាមានសិទ្ធិអំណាចជាក់ស្តែង ក្នុងតំបន់១៣ និងនៅក្នុងភូមិភាគនិរតី ដែលសាក្សីភាគច្រើន យឹម ទិត្យ មិនលើកឡើងនៅក្នុង ទទ្បីករណ៍របស់គាត់ឡើយ[280]។ ផ្ទុយទៅវិញ យឹម ទិត្យ ធ្វើការអះអាងដោយមិនត្រឹមត្រូវមួយចំនួន ដោយផ្អែកលើការបង្ហាញភស្តុតាងសាក្សីមួយផ្នែក។

94. ឧទាហរណ៍ យឹម ទិត្យ អះអាងថា ដីកាបញ្ជូនរឿងទៅជំនុំជម្រះសន្និដ្ឋានថា គាត់រៀបចំប្រជុំជា ទៀងទាត់នៅមន្ទីរតំបន់ ១៣ ដោយផ្អែកលើសាក្សី ពេជ្រ ជឹម ឮការផ្សាយរបស់វិទ្យុមួយ[281]។ ប៉ុន្តែ ដីកាបញ្ជូនរឿងទៅជំនុំជម្រះនៅក្នុងវគ្គដែលពាក់ព័ន្ធ លើកមកសំអាងផ្អែកនានានៃការស្តាប់ចម្លើយ របស់ ពេជ្រ ជឹម ចំនួន ២ ដែលគ្មានមួយណាត្រូវបានយោងដល់ យឹម ទិត្យ សោះ។ តាមពិត ពេជ្រ ជឹម និយាយថា "[នៅពេល]អង្គការហៅមកប្រជុំ ខ្ញុំជួប [យឹម ទិត្យ] នៅមន្ទីរតំបន់ ១៣"[282]។ នៅពេលសួរថា តើគាត់ជួប យឹម ទិត្យ ញឹកញាប់កម្រិតណានៅមន្ទីរតំបន់ ពេជ្រ ជឹម ឆ្លើយថា "ខ្ញុំបានជួបគាត់ជាច្រើនដងណាស់"[283]។

95. ស្រដៀងគ្នានេះដែរ យឹម ទិត្យ អះអាងថា ស.ច.ស.អ មិនយកចិត្តទុកដាក់លើភស្តុតាងផ្ទុយពី ម៉ឹង វេត ដោយពុំបានលើកឡើងសោះឡើយថាតើភស្តុតាងផ្ទុយនេះមានអ្វីខ្លះ[284]។ យឹម ទិត្យ លើកមក សំអាងចម្លើយជាច្រើនដែលក្នុងនោះ ម៉ឹង វេត រៀបរាប់ពីការដឹងរបស់គាត់អំពីតួនាទីទាំងឡាយ របស់ យឹម ទិត្យ នៅថ្នាក់តំបន់ ១៣ ក្នុងនោះ រួមមាន ជំនួយការតំបន់ ១៣ ក្នុងឆ្នាំ១៩៧៥ អនុតំបន់ក្នុងឆ្នាំ ១៩៧៦ លេខាតំបន់បន្ទាប់ពី តាគុំ ក្នុងឆ្នាំ១៩៧៧ និងលេខាតំបន់ ក្នុងឆ្នាំ

---

[279] ឯកសារ **D382/22** បណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ កថាខណ្ឌ ១២៥។

[280] ឯកសារ **D382** ដីកាបញ្ជូនរឿងទៅជំនុំជម្រះ កថាខណ្ឌ ៣៤៨-៣៥១។

[281] ឯកសារ **D382/22** បណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ កថាខណ្ឌ ១៥៣។

[282] ឯកសារ **D118/79** កំណត់ហេតុស្តាប់ចម្លើយសាក្សី ពេជ្រ ជឹម ឆ.៣១។

[283] ឯកសារ **D118/79** កំណត់ហេតុស្តាប់ចម្លើយសាក្សី ពេជ្រ ជឹម ឆ.៣២។

[284] ឯកសារ **D382/22** បណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ កថាខណ្ឌ ១៥៨។

១៩៧៨[285]។ យឹម ទិត្យ ថែមទាំងមិនបានបញ្ជាក់ច្បាស់ថាចង់មានន័យយ៉ាងដូចម្ដេច ដោយការពន្លើសរបស់ ម៉ឹង វេត ឬដោយច្រឡំភស្តុតាងរបស់គាត់[286]។ ដោយសន្មតថា យឹម ទិត្យ យោងដល់ ម៉ឹង វេត ប្រាប់អ្នកស៊ើបអង្កេត នៅក្នុងកិច្ចស្ដាប់ចម្លើយមួយថា យឹម ទិត្យ "តែងតែអង្គុយនៅខាងស្ដាំដៃ" របស់លេខាតំបន់ ១៣[287] និងកិច្ចស្ដាប់ចម្លើយមួយទៀត ដែលលើកឡើងថា "ខ្ញុំឃើញ [យឹម ទិត្យ] ម្ដង"[288] ចំណុចនេះអាចត្រូវបានពន្យល់ដោយចម្លើយលើកក្រោយទាក់ទិននឹងកិច្ចប្រជុំមួយដែលមានរយៈពេល ១០ ថ្ងៃ ក្នុងអំឡុងពេលនោះ ម៉ឹង វេត និយាយថា "តាទិត្យអង្គុយនៅកន្លែងដដែល នៅខាងស្ដាំដៃ លើវេទិកា"[289]។ យឹម ទិត្យ ក៏កំណត់ភស្តុតាងរបស់ ម៉េង វេត ដោយមិនត្រឹមត្រូវ នៅត្រង់ចំណុចនេះ ដោយអះអាងថា ម៉ឹង វេត បានប្រាប់អ្នកស៊ើបអង្កេតថា យឹម ទិត្យ អង្គុយជាមួយគណៈស្រុក នៅជួរមុខនៅក្នុងកិច្ចប្រជុំ នៅពេល ម៉ឹង វេត និយាយច្បាស់ថា យឹម ទិត្យ អង្គុយជាមួយគណៈតំបន់នៅលើវេទិកា[290]។

96. យឹម ទិត្យ អះអាងថា ស.ច.ស.អ ពុំធ្វើការបានសន្និដ្ឋានអំពីសិទ្ធិអំណាចជាក់ស្ដែងរបស់បុគ្គលដទៃនៅក្នុងគណៈកម្មាធិការតំបន់ ១៣ ឡើយ ពាក់ព័ន្ធនឹងសិទ្ធិអំណាចរបស់ យឹម ទិត្យ[291]។ ចំណុចនេះមិនមានភាពពាក់ព័ន្ធ ដោយមូលហេតុពីរយ៉ាង។ ទីមួយ ស.ច.ស.អ ត្រូវបានតម្រូវឱ្យស៊ើបអង្កេត និងវាយតម្លៃលើអំពើ និងការប្រព្រឹត្តិរបស់ យឹម ទិត្យ មិនមែនរបស់បុគ្គលដទៃទៀត ដែលមិនមានឈ្មោះនៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ និងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមទេ[292]។ ទីពីរ ឧទាហរណ៍ដែល យឹម ទិត្យ ផ្ដល់អំពី បុគ្គលម្នាក់ឈ្មោះ "វ៉ាញ ប៊ិត"

---

[285] ឯកសារ **D119/84** កំណត់ហេតុស្ដាប់ចម្លើយសាក្សី ម៉ឹង វេត ឆ.៣៤។ ឯកសារ **D119/85** កំណត់ហេតុស្ដាប់ចម្លើយសាក្សី ម៉ឹង វេត ឆ.១១-១២, ២៤។ ឯកសារ **D219/488** កំណត់ហេតុស្ដាប់ចម្លើយសាក្សី ម៉ឹង វេត ឆ.៣៤-៣៥, ៣៧-៣៩, ៩៣។ *សូមមើលផងដែរ* ឯកសារ **D219/899.1.4** ប្រតិចារិកនៃសក្ខីកម្មរបស់សាក្សី ម៉ឹង វេត ថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១៦ ទំព័រ ៣០ បន្ទាត់ ១១-១៥។

[286] ឯកសារ **D382/22** បណ្ដឹងឧទ្ធរណ៍របស់ យឹម ទិត្យ កថាខណ្ឌ ១៥៨។

[287] ឯកសារ **D119/85** កំណត់ហេតុស្ដាប់ចម្លើយសាក្សី ម៉ឹង វេត ឆ.១២។

[288] ឯកសារ **D219/488** កំណត់ហេតុស្ដាប់ចម្លើយសាក្សី ម៉ឹង វេត ឆ.៤០។

[289] ឯកសារ **D219/488** កំណត់ហេតុស្ដាប់ចម្លើយសាក្សី ម៉ឹង វេត ឆ.៥៧។ *ផ្ទុយពី* ឯកសារ **D382/22** បណ្ដឹងឧទ្ធរណ៍របស់ យឹម ទិត្យ កថាខណ្ឌ ១៣៤។ *សូមមើលឧទាហរណ៍* សំណុំរឿង ០០២-ឯកសារ **E313** សាលក្រមក្នុងសំណុំរឿង ០០២/០១ កថាខណ្ឌ ២១៥-២២០, ៨៥៩, ៩១៣។

[290] ឯកសារ **D219/488** កំណត់ហេតុស្ដាប់ចម្លើយសាក្សី ម៉ឹង វេត ឆ.៥៦-៥៨។

[291] ឯកសារ **D382/22** បណ្ដឹងឧទ្ធរណ៍របស់ យឹម ទិត្យ កថាខណ្ឌ ១៥៩។

[292] *សូមមើល* វិធាន ៥៥(២), (៤) នៃវិធានផ្ទៃក្នុង។

ជាអ្នកមានអំណាចម្នាក់នៅក្នុងភូមិភាគនិរតី គឺជាការនាំឲ្យយល់ ខុស[293]។ យឹម ទិត្យ លើកមកសំអាងនូវស្នាដៃស្រាវជ្រាវមួយដែលស្នាដៃនោះមិនបានយកអ្វីមក យោងដើម្បីគាំទ្រការអះអាងនេះឡើយ[294]។ សាលក្រមសំណុំរឿង ០០២/០២ មិនយោងដល់បុគ្គលណាម្នាក់ដែលមានឈ្មោះ "វ៉ាញ ប៊ិត" ឡើយ នៅក្នុងការសន្និដ្ឋានលើរចនាសម្ព័ន្ធសិទ្ធិអំណាចនៅក្នុងភូមិភាគនិរតី[295] និងជាពិសេស យឹម ទិត្យ គួរតែបានស្នើឲ្យបំពេញកិច្ចស៊ើបសួរពាក់ព័ន្ធនឹង "វ៉ាញ ប៊ិត" ឬបុគ្គលណាមួយផ្សេងទៀត ដែលគាត់ចាត់ទុកថាមានមុខតំណែងមានអំណាចដែល យឹម ទិត្យ ខ្លួនឯងចោទថា អ្នកនោះបានកាន់ នៅពេលវេលាណាមួយក្នុងអំឡុងពេលនៃការស៊ើបអង្កេត[296]។ យឹម ទិត្យ មិនបានធ្វើដូច្នេះឡើយ។

97. លើសពីនេះទៀត យឹម ទិត្យ ជំទាស់យ៉ាងច្រើនទៅនឹងភស្តុតាងរបស់ ចាន់ វិចិត្រ[297] ប៉ុន្តែ ខកខានមិនបានបង្ហាញពីកំហុសណាមួយនៅក្នុងការពឹងផ្អែករបស់ ស.ច.ស.អ លើសាក្សីរូបនេះ។ យឹម ទិត្យ អះអាងដោយមិនត្រឹមត្រូវថា ភស្តុតាងរបស់ ចាន់ វិចិត្រ ពាក់ព័ន្ធនឹង តួនាទីរបស់ យឹម ទិត្យ នៅក្នុងភូមិភាគនិរតី ទាក់ទិននឹងរយៈពេលចាប់ពីខែមេសា ដល់ខែកក្កដា ឆ្នាំ១៩៧៧[298]។ យឹម ទិត្យ ពឹងផ្អែកលើពេលវេលាមិនទៀងនេះ ដើម្បីអះអាងថា ចម្លើយរបស់ ចាន់ វិចិត្រ ផ្ទុយលើចំណុចពេលវេលាជាមួយនឹងភស្តុតាងរបស់ សៅ ផុប អំពីតួនាទីរបស់យឹម ទិត្យ នៅក្នុងភូមិភាគពាយ័ព្យ[299]។ ប៉ុន្តែ ចាន់ វិចិត្រ បានប្រាប់អ្នកស៊ើបអង្កេតថា គាត់ឃើញ យឹម ទិត្យ ស្ទើររៀងរាល់ថ្ងៃនៅក្នុងមន្ទីរភូមិភាគ នៅតាកែវ ក្នុរយៈពេល ៤ ខែ ឆ្នាំ១៩៧៥[300]។ ជាលទ្ធផល ពុំមានការផ្ទុយគ្នារវាងភស្តុតាងរបស់សាក្សីទាំងពីរនាក់នេះទេ និងពុំមានកំហុសឆ្គងនៅក្នុងការពឹងផ្អែករបស់ ស.ច.ស.អ លើការរៀបរាប់របស់សាក្សីទាំងនេះក្នុងការគាំទ្រដល់ការសន្និដ្ឋានលើតួនាទីភរនីយភាពរបស់ យឹម ទិត្យ នៅក្នុង ភូមិភាគនិរតី និងភូមិភាគពាយ័ព្យ[301]។

[293] ឯកសារ **D382/22** បណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ កថាខណ្ឌ ១៥៩។

[294] ឯកសារ **D1.3.15.2** អត្ថបទនិពន្ធដោយ Timothy Carney EN 00332370-72, 00332381-82។

[295] សំណុំរឿង ០០២-ឯកសារ **E465** សាលក្រមក្នុងសំណុំរឿង ០០២/០២ កថាខណ្ឌ ៩១០-៩១៧។

[296] *សូមមើល* វិធាន ៧៦ នៃវិធានផ្ទៃក្នុង។

[297] ឯកសារ **D382/22** បណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ កថាខណ្ឌ ១២៧-១៣៣។

[298] ឯកសារ **D382/22** បណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ កថាខណ្ឌ ១២៩។

[299] ឯកសារ **D382/22** បណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ កថាខណ្ឌ ១២៩។

[300] ឯកសារ **D219/853** កំណត់ហេតុស្តាប់ចម្លើយសាក្សី ចាន់ វិចិត្រ ឆ.១៥-១៦, ១៨-២០។

[301] *ផ្ទុយពី* ឯកសារ **D382/22** បណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ កថាខណ្ឌ ១២៩។

98. ការអះអាងរបស់ យឹម ទិត្យ ថា ភស្តុតាងរបស់ ចាន់ វិចិត្រ មានភាពផ្ទុយ ឬដោះបន្ទុក ទាក់ទិននឹងអំពើ និងការប្រព្រឹត្តិរបស់ យឹម ទិត្យ ក៏គឺជាកំហុសផងដែរ[302]។ ចាន់ វិចិត្រ បានប្រាប់អ្នកស៊ើបអង្កេតរបស់ ក.ស.ច.ស ថា យឹម ទិត្យ បានទទួលភ្ញៀវនៅមន្ទីររបស់គាត់សម្រាប់ "ការងារសំខាន់ៗ"[303] ភ្ញៀវ "មកពីថ្នាក់ស្រុក"នៅត្រាំកក់[304] ហើយ យឹម ទិត្យ ធ្វើការទាក់ទងជាមួយអ្នកនៅក្នុងស្រុកអង្គរបុរី ស្រុកកោះអណ្តែត និងស្រុកព្រៃកប្បាស ដោយ ចាន់ វិចិត្រ មិនប្រាកដថាអ្នកទាំងនោះ "ជាថ្នាក់កងពល តំបន់ ឬ មូលដ្ឋានប៉ុណ្ណោទេ" ប៉ុន្តែ ដឹងច្បាស់ថា "ក្រោមបញ្ជារបស់ តាទិត្យ"[305]។

99. ដោយខកខានពុំបានបង្ហាញពីកំហុសណាមួយនៅក្នុងការពិនិត្យ និងវាយតម្លៃលើភស្តុតាងពីសំណាក់ ស.ច.ស.អ ការអះអាងរបស់ យឹម ទិត្យ ដែលថា ស.ច.ស.អ បានអនុវត្តបទដ្ឋានច្បាប់មិនត្រឹមត្រូវ នៅពេលវាយតម្លៃលើចម្លើយសាក្សី ពុំមានមូលដ្ឋានឡើយ[306]។ សារណារបស់ យឹម ទិត្យ គឺជាការមិនយល់ស្របជាមួយនឹងការសន្និដ្ឋាននៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ មិនមែនជាកំហុសអង្គច្បាប់ ឬអង្គហេតុឡើយ។

## ៤. យឹម ទិត្យ ខកខានមិនបានបង្ហាញពីកំហុសណាមួយដែលអាចពិនិត្យឡើងវិញបាន ក្នុងការសន្និដ្ឋានថា គាត់ទំនងជាលេខាតំបន់១

### ក. យឹម ទិត្យ ខកខានមិនបានបង្ហាញកំហុសណាមួយដែលអាចពិនិត្យឡើងវិញបាន ក្នុងការសន្និដ្ឋានថា គាត់ទំនងជាត្រូវបានតែងតាំងជាលេខាតំបន់ ១

100. យឹម ទិត្យ ខកខានមិនបានបង្ហាញអំពីរបៀបថាតើ ការសន្និដ្ឋានរបស់ ស.ច.ស.អ ថា គាត់ទំនងជាលេខាតំបន់ ១ ចាប់ពីរង្វង់ខែមិថុនា ឆ្នាំ១៩៧៨ រហូតដល់ចុងរបបកម្ពុជាប្រជាធិបតេយ្យ គឺជា

[302] ឯកសារ **D382/22** បណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ កថាខណ្ឌ ១៣២-១៣៣។

[303] ឯកសារ **D219/853** កំណត់ហេតុស្តាប់ចម្លើយសាក្សី ចាន់ វិចិត្រ ឆ.៣១។ ទាក់ទិននឹងចម្លើយរបស់ យឹម ទិត្យ ដែលថាមន្ទីរគឺជាផ្ទះមានកុមារនៅទីនោះ (ឯកសារ **D382/22** បណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ កថាខណ្ឌ ១៣២) សាក្សី ចាន់ វិចិត្រ បានលើកឡើងថា "ពេលមានប្រជុំអ៊ីចឹង គឺគេដេញក្មេងៗចេញអស់ហើយ" *សូមមើល* ឆ.៣៣។

[304] ឯកសារ **D219/853** កំណត់ហេតុស្តាប់ចម្លើយសាក្សី ចាន់ វិចិត្រ ឆ.១១១។

[305] ឯកសារ **D219/853** កំណត់ហេតុស្តាប់ចម្លើយសាក្សី ចាន់ វិចិត្រ ឆ.១៥៨។

[306] ឯកសារ **D382/22** បណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ កថាខណ្ឌ ១៦៣។

កំហុសអង្គច្បាប់ ឬអង្គហេតុដែលអាចពិនិត្យឡើងវិញ[307]។ ផ្អែកលើមូលហេតុដូចពិភាក្សាខាងក្រោម ស.ច.ស.អ សន្និដ្ឋានដោយត្រឹមត្រូវ ដោយផ្អែកលើតុល្យភាពនៃភវនីយភាពថា មានភស្តុតាងគ្រប់គ្រាន់បង្ហាញថា យឹម ទិត្យ ទំនងធ្វើជាលេខាតំបន់១ ក្នុងខែមិថុនា ឆ្នាំ១៩៧៨ ដោយផ្អែកលើភស្តុតាង (i) នៅពេល ដែល តាប៉ែត អ្នកកាន់តំណែងមុន យឹម ទិត្យ ត្រូវបានដកពីតំណែងជាលេខាតំបន់១ ឬ ឬលែងឃើញបំពេញតួនាទីនេះ[308] និង (ii) ពីសាក្សីជាច្រើនដែលដឹងថា យឹម ទិត្យ មានមុខតំណែងជាលេខាតំបន់១ តាមរយៈការងារ ក្នុងនោះរួមមាន កិច្ចប្រជុំនានាដែលពួកគេបានចូលរួម[309]។

---

[307] *ផ្ទុយពី* ឯកសារ **D382/22** បណ្ដឹងឧទ្ធរណ៍របស់ យឹម ទិត្យ កថាខណ្ឌ ១៦៥-១៨៨ (មូលដ្ឋានរងទី ៥.២.iii)។ *សូមមើល* សារណាបឋម កថាខណ្ឌ ១៧, ២០ (បទដ្ឋាននៃការពិនិត្យបណ្ដឹងឧទ្ធរណ៍)។

[308] ឯកសារ **D382** ដីកាបញ្ជូនរឿងទៅជំនុំជម្រះ ជើងទំព័រ ៩៣៨ (*ដកស្រង់ក្នុងចំណោមនោះ* ឯកសារ **D219/117** កំណត់ហេតុស្ដាប់ចម្លើយសាក្សី គុប សឹង ឆ.៦៨។ ឯកសារ **D219/210** កំណត់ហេតុស្ដាប់ចម្លើយសាក្សី លេខ ភីវ ឆ.៤។ ឯកសារ **D219/85** កំណត់ហេតុស្ដាប់ចម្លើយសាក្សី រី ផាន់ ឆ.៣។ ឯកសារ **D118/69** កំណត់ហេតុស្ដាប់ចម្លើយសាក្សី នួន មួន ឆ.១២-១៣), ៩៤៣ (*ដកស្រង់ក្នុងចំណោមនោះ* ឯកសារ **D118/69** កំណត់ហេតុស្ដាប់ចម្លើយសាក្សី នួន មួន ឆ.១១២។ ឯកសារ **D219/117** កំណត់ហេតុស្ដាប់ចម្លើយសាក្សី គុប សឹង ឆ.៦៧, ៧៩។ ឯកសារ **D118/77** កំណត់ហេតុស្ដាប់ចម្លើយសាក្សី ណង នី ឆ.៣៣-៣៦, ៤៥។ ឯកសារ **D118/136** កំណត់ហេតុស្ដាប់ចម្លើយសាក្សី ឈាន ប៊ា ឆ.៤៣។ ឯកសារ **D219/368** កំណត់ហេតុស្ដាប់ចម្លើយសាក្សី ឈឿង ប៊ាន ឆ.៣៩)។ *សូមមើលផងដែរ* ឯកសារ **D34.1.9** បទសម្ភាសន៍របស់ ហេង ទាវ ដោយ Steve Heder EN 00965622 (*សូមមើល* ឯកសារ **D1.3.18.2** ចម្លើយសារភាពរបស់ មូល សម្បត្តិ ហៅ រស់ ញឹម នៅមន្ទីរ ស-២១ EN 00024652)។ ឯកសារ **D118/77** កំណត់ហេតុស្ដាប់ចម្លើយសាក្សី ណង នី ឆ.១, ៤៥។ ឯកសារ **D219/532** កំណត់ហេតុស្ដាប់ចម្លើយសាក្សី លៀស គង់ ឆ.១៧ *អះអាងជាថ្មី* ឯកសារ **D219/416** កំណត់ហេតុស្ដាប់ចម្លើយសាក្សី លៀស គង់ ឆ.១។ ឯកសារ **D118/136** កំណត់ហេតុស្ដាប់ចម្លើយសាក្សី ឈាន ប៊ា ឆ.២។ ឯកសារ **D219/233** កំណត់ហេតុស្ដាប់ចម្លើយសាក្សី ឈាន ប៊ា ឆ.២១។ ឯកសារ **D219/689** កំណត់ហេតុស្ដាប់ចម្លើយសាក្សី សុខ ជាតិ ឆ.២០។ ឯកសារ **D219/953** កំណត់ហេតុស្ដាប់ចម្លើយសាក្សី ឈឹង ឈឿត ឆ.៥៥-៥៦។

[309] ឯកសារ **D382** ដីកាបញ្ជូនរឿងទៅជំនុំជម្រះ ជើងទំព័រ ៩៣៨ (*ដកស្រង់ក្នុងចំណោមនោះ* ឯកសារ **D118/243** កំណត់ហេតុស្ដាប់ចម្លើយសាក្សី ឆាំ លយ ឆ.១០-១១។ ឯកសារ **D118/245** កំណត់ហេតុស្ដាប់ចម្លើយសាក្សី ជួន ថន ឆ.៤, ១៧-១៨។ ឯកសារ **D118/299** កំណត់ហេតុស្ដាប់ចម្លើយសាក្សី ជួន ថន ឆ.២៥។ ឯកសារ **D118/285** កំណត់ហេតុស្ដាប់ចម្លើយសាក្សី ណុប ធីម ឆ.៧, ៦៣។ ឯកសារ **D118/77** កំណត់ហេតុស្ដាប់ចម្លើយសាក្សី ណង នី ឆ.២៣-២៤។ ឯកសារ **D219/416** កំណត់ហេតុស្ដាប់ចម្លើយសាក្សី លៀស គង់ ឆ.១១-១២។ ឯកសារ **D219/368** កំណត់ហេតុស្ដាប់ចម្លើយសាក្សី ឈឿង ប៊ាន ឆ.១០-១៤)។

101. យឹម ទិត្យ លើកឡើងដោយមិនត្រឹមត្រូវថា "ភស្តុតាងផ្ទាល់" នៃការតែងតាំងគាត់ ចាំបាច់ក្នុងការបង្ហាញថា គាត់កាន់តំណែងជាលេខាតំបន់[310]។ ផ្ទុយទៅវិញ ស.ច.ស.អ ពឹងផ្អែកដោយត្រឹមត្រូវលើសាក្សីដែលដឹងអំពីមុខតំណែងរបស់ យឹម ទិត្យ តាមរយៈសកម្មភាពរបស់ យឹម ទិត្យ តាមរយៈអ្នកដែលធ្វើការទាក់ទងផ្ទាល់ជាមួយ យឹម ទិត្យ និងតាមរយៈការដឹងជាទូទៅរបស់អ្នកដែលរស់នៅ និងធ្វើការនៅក្នុងតំបន់ ១[311]។ ឧទាហរណ៍ គុប សឹង (i) ធ្វើការនៅការដ្ឋានតំបន់១ (ii) លែងឃើញ តាប៉ែត ពិនិត្យការដ្ឋាននោះ ក្នុងពាក់កណ្ដាលឆ្នាំ ១៩៧៨ និង(iii) ក្នុងពេលប្រហាក់ប្រហែលគ្នា បានឃើញមនុស្សថ្មីម្នាក់មកពិនិត្យការដ្ឋាននោះជាទៀងទាត់ និងជួបជាមួយមេរបស់គាត់[312]។ គុប សឹង ដឹងពីមេរបស់គាត់ថា អ្នកដែលមកពិនិត្យការដ្ឋាននោះ គឺ យឹម ទិត្យ ថា យឹម ទិត្យ បានមកជំនួស តាប៉ែត និងថា គាត់គឺជា គណៈតំបន់[313]។ ភស្តុតាងដែលបញ្ជាក់ថា យឹម ទិត្យ ជំនួស តាប៉ែត ជាលេខាតំបន់១ ក្នុងពាក់កណ្ដាលឆ្នាំ១៩៧៨ ត្រូវបានគាំទ្រដោយភស្តុតាងដទៃទៀត ដែលជាមូលដ្ឋាននៃការសន្និដ្ឋានរបស់ ស.ច.ស.អ[314] ព្រមទាំងភស្តុតាងបន្ថែមនៅក្នុង

---

[310] *សូមមើល* សារណាបឋម កថាខណ្ឌ ១៤ (សេរីភាពនៃភស្តុតាង)។ *ផ្ទុយពី* ឯកសារ **D382/22** បណ្ដឹងឧទ្ធរណ៍របស់ យឹម ទិត្យ កថាខណ្ឌ ១៦៥។

[311] *សូមមើលឧទាហរណ៍* ឯកសារ **D118/77** កំណត់ហេតុស្ដាប់ចម្លើយសាក្សី ណង នី ឆ.៤៥, ២៩, ៣៦។ ឯកសារ **D118/243** កំណត់ហេតុស្ដាប់ចម្លើយសាក្សី ឆាំ លុយ ឆ.១១។ ឯកសារ **D219/263** កំណត់ហេតុស្ដាប់ចម្លើយសាក្សី ឆាំ លុយ ឆ.៣៦-៣៨។ ឯកសារ **D118/245** កំណត់ហេតុស្ដាប់ចម្លើយសាក្សី ជួន ថន ឆ.១៨។

[312] ឯកសារ **D219/117** កំណត់ហេតុស្ដាប់ចម្លើយសាក្សី គុប សឹង ឆ.៤៩, ១០៨ (មុខតំណែងរបស់សាក្សី), ឆ.៥៩-៦១, ៦៥ (មុខតំណែងរបស់ តាប៉ែត និងការងារនៅទីកន្លែង), ឆ.៦៨-៦៩, ៧២-៧៣, ៧៥, ៩០-៩១ (ការបាត់ខ្លួន តាប៉ែត ក្រោយពេលវត្តមានរបស់ យឹម ទិត្យ), ឆ.១៤៣, ១៥៣ (ការប្រជុំថ្នាក់លើរបស់សាក្សីជាមួយ យឹម ទិត្យ)។ *ផ្ទុយពី* ឯកសារ **D382/22** បណ្ដឹងឧទ្ធរណ៍របស់ យឹម ទិត្យ កថាខណ្ឌ ១៦៥។

[313] ឯកសារ **D219/117** កំណត់ហេតុស្ដាប់ចម្លើយសាក្សី គុប សឿង ឆ.៧៩ (ថ្នាក់លើរបស់សាក្សីបញ្ជាក់អំពីអត្តសញ្ញាណ និងមុខតំណែងរបស់ យឹម ទិត្យ)។ *ផ្ទុយពី* ឯកសារ **D382/22** បណ្ដឹងឧទ្ធរណ៍របស់ យឹម ទិត្យ កថាខណ្ឌ ១៦៥។

[314] ឯកសារ **D382** ដីកាបញ្ជូនរឿងទៅជំនុំជម្រះ ជើងទំព័រ ៩៣៨ (*ដកស្រង់ក្នុងចំណោមនោះ* ឯកសារ **D219/210** កំណត់ហេតុស្ដាប់ចម្លើយសាក្សី លេខ ភីរ ឆ.៣-៥។ ឯកសារ **D219/85** កំណត់ហេតុស្ដាប់ចម្លើយសាក្សី រី ផាន់ ឆ.២-៣។ ឯកសារ **D118/69** កំណត់ហេតុស្ដាប់ចម្លើយសាក្សី នួន មួន ឆ.១២-១៣), ៩៤៣ (*ដកស្រង់ក្នុងចំណោមនោះ* ឯកសារ **D118/69** កំណត់ហេតុស្ដាប់ចម្លើយសាក្សី នួន មួន ឆ.១១-១២។ ឯកសារ **D219/117** កំណត់ហេតុស្ដាប់ចម្លើយសាក្សី គុប សឿង ឆ.៦៧, ៧៩។ ឯកសារ **D118/77** កំណត់ហេតុស្ដាប់ចម្លើយសាក្សី ណង នី ឆ.៣៣-៣៦, ៤៥។ ឯកសារ **D118/136** កំណត់ហេតុស្ដាប់ចម្លើយសាក្សី ឈាន ប៊ា ឆ.៤៣។ ឯកសារ **D219/368** កំណត់ហេតុស្ដាប់ចម្លើយសាក្សី ឈឿង ប៊ាន ឆ.៣៩)។

សំណុំរឿង[315]។ ចំណុចនេះ រួមបញ្ចូលទាំង តាប៉ែត ខ្លួនឯងនិយាយថា យឹម ទិត្យ ក្លាយជាលេខាតំបន់ ១ ក្រោយពី ការចាប់ខ្លួន រស់ ញឹម លេខាភូមិភាគពាយ័ព្យ ដែលឯកសារនៅមន្ទីរសន្តិសុខ ស២១ បង្ហាញថា ការចាប់ខ្លួននេះ កើតឡើងមិនហួសថ្ងៃទី១៤ ខែមិថុនា ឆ្នាំ១៩៧៨ ឡើយ[316]។

102. យឹម ទិត្យ ក៏ខិតខំព្យាយាមដោយមិនសមស្របក្នុងការមិនផ្តល់តម្លៃដល់សាក្សីដែលភស្តុតាងរបស់ពួកគាត់គាំទ្រដល់ការសន្និដ្ឋានរបស់ ស.ច.ស.អ។ ការខកខានរបស់ យឹម ទិត្យ ក្នុងការពិនិត្យលើភស្តុតាងទាំងមូល ត្រូវបានបង្ហាញដោយរូបគាត់មិនយកចិត្តទុកដាក់លើការដែលថា (i) លេខ ភីវ មិនដឹងច្បាស់អំពី តួនាទីរបស់ យឹម ទិត្យ និង តាប៉ែត នៅពេលពួកគេដឹកនាំប្រជុំទាំងអស់គ្នា ប៉ុន្តែក្រោយពីការចាប់ខ្លួនតាប៉ែតមក ដឹងថា យឹម ទិត្យ ដឹកនាំប្រជុំក្នុងនាមជាលេខាភូមិភាគ១[317]។ (ii) វី ផាន ត្រូវតែបានឃើញ យឹម ទិត្យ ជាមួយនឹង តាប៉ែត មុនខែវិច្ឆិកា ឆ្នាំ១៩៧៨ ពីព្រោះ តាប៉ែត និយាយថា គាត់ត្រូវបានចាប់ខ្លួន រង្វង់ខែសីហា ឆ្នាំ១៩៧៨[318]។ (iii) ណុប ធឹម ដឹងអំពីតំណែង

---

[315] *សូមមើលឧទាហរណ៍* ឯកសារ **D118/77** កំណត់ហេតុស្តាប់ចម្លើយសាក្សី ណាង នី ឆ.១, ៤៥។ ឯកសារ **D219/532** កំណត់ហេតុស្តាប់ចម្លើយសាក្សី លៀស គង់ ឆ.១៧ *អះអាងជាថ្មី* ឯកសារ **D219/416** កំណត់ហេតុស្តាប់ចម្លើយសាក្សី លៀស គង់ ឆ.១។ ឯកសារ **D118/136** កំណត់ហេតុស្តាប់ចម្លើយសាក្សី ឈាន ប៊ា ឆ.២។ ឯកសារ **D219/233** កំណត់ហេតុស្តាប់ចម្លើយសាក្សី ឈាន ប៊ា ឆ.២១។ ឯកសារ **D219/689** កំណត់ហេតុស្តាប់ចម្លើយសាក្សី សុខ ជាតិ ឆ.២០។ ឯកសារ **D219/953** កំណត់ហេតុស្តាប់ចម្លើយសាក្សី ឈឹង ឈឿត ឆ.៥៥-៥៦។

[316] ឯកសារ **D34.1.9** បទសម្ភាសន៍របស់ ហេង ទារ ដោយ Steve Heder EN 00965622 ("វាឲ្យខ្ញុំមកធ្វើអនុលេខារបស់តំបន់១ហ្នឹង។ វាចាប់ តាញឹម [...] វាចាត់តាំងឲ្យអាឈ្មោះ អាទិត១ [...] ធ្វើជាលេខា វាឲ្យខ្ញុំធ្វើអនុលេខារបស់វា")។ (*សូមមើល* ឯកសារ **D1.3.18.2** ចម្លើយសារភាពរបស់ មូល សម្បត្តិ ហៅ រស់ ញឹម នៅមន្ទីរ ស-២១ EN 00024652)។ *ផ្ទុយពី* ឯកសារ **D382/22** បណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ កថាខណ្ឌ ១៦៦។

[317] ឯកសារ **D219/210** កំណត់ហេតុស្តាប់ចម្លើយសាក្សី លេខ ភីវ ឆ.៤, ៦-៧។ *សូមមើលផងដែរ* ឯកសារ **D219/236** កំណត់ហេតុស្តាប់ចម្លើយសាក្សី លេខ ភីវ ឆ.៤, ១៧។ *ផ្ទុយពី* ឯកសារ **D382/22** បណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ កថាខណ្ឌ ១៦៥។

[318] តាប៉ែត និយាយថា គេចាប់ខ្លួនគាត់មួយ ឬពីរខែក្រោយពេលពេលចាប់ខ្លួន តាញឹម ទោះបីគាត់រម្លឹកឡើងវិញដោយមានកំហុសថា តាញឹម ត្រូវបានចាប់ខ្លួនក្រោយកាលបរិច្ឆេទនៅក្នុងចម្លើយសារភាពរបស់ តាញឹម នៅមន្ទីរ ស-២១ ក្តី *សូមមើល* ឯកសារ **D34.1.9** បទសម្ភាសន៍របស់ ហេង ទារ ហៅ តាប៉ែត ដោយ Steve Heder EN 00965647-48 (នៅពេលគេចាប់ខ្លួន តាញឹម កូនប្រុសគាត់បានហៅទូរស័ព្ទទៅភ្នំពេញ "ប្រហែលក្នុងខែហ្នឹង ខែ៨ហ្នឹង"), EN 00965615 ("ដល់ខែ៩ ខែ១០ ឆ្នាំ៧៨ ត្រូវចាប់យកមកដាក់គុក")។ *សូមមើលផងដែរ* ឯកសារ **D219/85** កំណត់ហេតុស្តាប់ចម្លើយសាក្សី វី ផាន់ ឆ.៣។ ឯកសារ **D219/825.1.2** បញ្ជីឈ្មោះអ្នកទោសនៅមន្ទីរ ស-២១ របស់ ក.ស.ច.ស EN 01222369 លេខ ៩១៣។ ឯកសារ **D382** ដីកាបញ្ជូនរឿងទៅជំនុំជម្រះ ជើងទំព័រ ៩៤៥ (*ដកស្រង់ក្នុងចំណោមនោះ* ឯកសារ **D118/136** កំណត់ហេតុស្តាប់ចម្លើយសាក្សី ឈាន ប៊ា ឆ.៣៧)។ ចម្លើយតបស្រដៀងគ្នានេះក៏អនុវត្តចំពោះការជំទាស់របស់ យឹម ទិត្យ ទាក់ទិននឹងសាក្សី នួន មួន ដែរ។ *ផ្ទុយពី* ឯកសារ **D382/22** បណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ កថាខណ្ឌ ១៦៥។

របស់ យឹម ទិត្យ នៅពេលគាត់នៅក្នុងគណៈកម្មាធិការស្រុកសំឡូត តំបន់១[319]។ ស្រដៀងគ្នានេះដែរ ការអះអាងរបស់ យឹម ទិត្យ ពាក់ព័ន្ធនឹង ឈាន ប៊ា, ហាន ធី និងអត្ថបទស្រាវជ្រាវមួយមើលរំលងភស្តុតាងនៅក្នុងសំណុំរឿង ដែលបញ្ជាក់ថា តាប៉ែត ត្រូវបានចាប់ខ្លួន ប្រហែលជាមិនយូរជាង ២ ខែក្រោយពីការចាប់ខ្លួន រស់ ញឹម[320]។

103. យឹម ទិត្យ ក៏លើកឡើងដោយមិនត្រឹមត្រូវផងដែរថា ភស្តុតាងរបស់ ណាង នី និងលៀស គង់ មានភាពផ្ទុយគ្នា ពីព្រោះ យឹម ទិត្យ ធ្វើការសន្និដ្ឋានដោយពុំមានមូលដ្ឋានថា សាក្សីទាំងនោះបានចូលរួមកិច្ចប្រជុំតែមួយនៅក្នុងឃុំបាយដំរាំ[321]។ យឹម ទិត្យ ធ្វេសប្រហែសមិនបានពន្យល់មូលហេតុអ្វីដែលអាចមានតែកិច្ចប្រជុំតែមួយនៅក្នុងភូមិសាស្ត្រដូចគ្នាក្រោយខែមិថុនា ឆ្នាំ១៩៧៨។

104. មិនតែប៉ុណ្ណោះ ការជំទាស់របស់ យឹម ទិត្យ ពាក់ព័ន្ធនឹងការរៀបរាប់របស់សាក្សីអំពីវត្តមានផ្ទាល់របស់គាត់នៅក្នុងរយៈកាលកម្ពុជាប្រជាធិបតេយ្យ ពុំត្រឹមត្រូវទេ ដោយហេតុថា ស.ច.ស.អ មិនពឹងផ្អែកការសន្និដ្ឋានរបស់ខ្លួនលើការពិព័ណនាជាលក្ខណៈអត្តនោម័តទាំងនោះឡើយ[322]។

---

[319] ឯកសារ **D118/285** កំណត់ហេតុស្តាប់ចម្លើយសាក្សី ណុប ងឹម ឆ.៥១ (*កត់សម្គាល់៖* ឯកសារ **D219/835** កំណត់ហេតុស្តាប់ចម្លើយសាក្សី ណុប ងឹម ឆ.១៣៧), ឆ.៥៥, ៤៤។ *សូមមើល* ផងដែរ ឯកសារ **D118/285** កំណត់ហេតុស្តាប់ចម្លើយសាក្សី ណុប ងឹម ឆ.៤២, ៦៥។ *ផ្ទុយពី* ឯកសារ **D382/22** បណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ កថាខណ្ឌ ១៦៥។

[320] *សូមមើលឧទាហរណ៍* ឯកសារ **D34.1.9** បទសម្ភាសន៍របស់ ហេង ទាវ ហៅ តាប៉ែត ដោយ Steve Heder EN 00965615។ តាប៉ែត និយាយថា គេចាប់ខ្លួនគាត់មួយ ឬពីរខែក្រោយពេលពេលចាប់ខ្លួន តាញឹម ទោះបីគាត់រម្លឹកឡើងវិញដោយមានកំហុសថា តាញឹម ត្រូវបានចាប់ខ្លួនក្រោយកាលបរិច្ឆេទនៅក្នុងចម្លើយសារភាពរបស់ តាញឹម នៅមន្ទីរ ស-២១ ក្តី *សូមមើល* **D34.1.9** បទសម្ភាសន៍របស់ ហេង ទាវ ហៅ តាប៉ែត ដោយ Steve Heder EN 00965647-48, 615។ *សូមមើលផងដែរ* ឯកសារ **D382** ដីកាបញ្ជូនរឿងទៅជំនុំជម្រះ ជើងទំព័រ ៩៤៥ (*ដកស្រង់ក្នុងចំណោមនោះ* ឯកសារ **D118/136** កំណត់ហេតុស្តាប់ចម្លើយសាក្សី ឈាន ប៊ា ឆ.៣៧។ ឯកសារ **D118/86** កំណត់ហេតុស្តាប់ចម្លើយសាក្សី ញ៉ឹក លី ឆ.១៣។ ឯកសារ **D219/654** កំណត់ហេតុស្តាប់ចម្លើយសាក្សី សុខ ជាតិ ឆ.៦៩)។ ឯកសារ **D219/689** កំណត់ហេតុស្តាប់ចម្លើយសាក្សី សុខ ជាតិ ឆ.២០។ *ផ្ទុយពី* ឯកសារ **D382/22** បណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ កថាខណ្ឌ ១៦៧-១៦៩, ១៦៦។

[321] *ផ្ទុយពី* ឯកសារ **D382/22** បណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ កថាខណ្ឌ ១៦៥។

[322] *ផ្ទុយពី* ឯកសារ **D382/22** បណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ កថាខណ្ឌ ១៦៥។

<u>ខ. យឹម ទិត្យ ខកខានមិនបានបង្ហាញកំហុសណាមួយដែលអាចពិនិត្យឡើងវិញបានក្នុងការសន្និដ្ឋានថា គាត់ទំនងជាអនុវត្តសិទ្ធិអំណាចក្នុងនាមជាលេខាតំបន់១</u>

105. យឹម ទិត្យ ខកខានមិនបានបង្ហាញថាតើ ការសន្និដ្ឋានរបស់ ស.ច.ស.អ ថា គាត់ទំនងជាបានអនុវត្តសិទ្ធិអំណាចជាលេខាតំបន់១រហូតដល់ចុងរបបកម្ពុជាប្រជាធិបតេយ្យ គឺជាកំហុសអង្គច្បាប់ កំហុសអង្គហេតុ ឬការបំពានឆន្ទានុសិទ្ធិដែលអាចពិនិត្យឡើងវិញបាន ដោយរបៀបណា[323]។ ផ្អែកលើមូលហេតុដែលពិភាក្សាខាងក្រោម ស.ច.ស.អ សន្និដ្ឋានដោយត្រឹមត្រូវដោយផ្អែកលើតុល្យភាពភវនីយភាពថា មានភស្តុតាងគ្រប់គ្រាន់ថា យឹម ទិត្យ បានអនុវត្តសិទ្ធិអំណាចរបស់គាត់ក្នុងនាមជាលេខាតំបន់១ លើអ្នកនៅក្រោមបង្គាប់របស់គាត់[324] ពាក់ព័ន្ធនឹងបញ្ហាសន្តិសុខ[325] និងសេដ្ឋកិច្ច[326] និងថា គាត់ធ្វើយ៉ាងដូច្នេះ តាមរយៈកិច្ចប្រជុំ[327] របាយការណ៍[328] និងលិខិត[329] ការពិនិត្យការដ្ឋាន[330]។

106. ការជំទាស់របស់ យឹម ទិត្យ អំពីការខ្វះភស្តុតាងដែលគាំទ្រការសន្និដ្ឋាន គឺជាលទ្ធផលនៃការខកខានរបស់គាត់ក្នុងការអានដីកាបញ្ជូនរឿងទៅជំនុំជម្រះទាំងមូល។ គាត់បំភ្លេចភស្តុតាងគ្រប់គ្រាន់សម្រាប់ការសន្និដ្ឋានរបស់ ស.ច.ស.អ ថា គាត់ទំនងជាមានអ្នកនៅក្រោមបង្គាប់ និងការគ្រប់គ្រងប្រកបដោយប្រសិទ្ធភាពលើពួកគេ[331] និងថា គាត់ទំនងបានបញ្ជាអ្នកនៅក្រោមបង្គាប់គាត់ “អប់រំ”

---

[323] *ផ្ទុយពី* ឯកសារ **D382/22** បណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ កថាខណ្ឌ ១៦៤-១៨៨ (មូលដ្ឋានរងទី ៥.២.iii)។ *សូមមើល* សារណាបឋម កថាខណ្ឌ ១៧, ២០, ២២ (បទដ្ឋាននៃការពិនិត្យលើបណ្តឹងឧទ្ធរណ៍)។

[324] ឯកសារ **D382** ដីកាបញ្ជូនរឿងទៅជំនុំជម្រះ ជើងទំព័រ ៩៦២-៩៧៤, ៩៧៦-៩៨១, ៩៨៣-៩៨៧។

[325] ឯកសារ **D382** ដីកាបញ្ជូនរឿងទៅជំនុំជម្រះ ជើងទំព័រ ៩៥៣-៩៥៨, ៩៦៩, ៩៧១-៩៧២, ៩៨០, ៩៨៣-៩៨៤។ *សូមមើលផងដែរ* ជើងទំព័រ ៩៨៤, ៩៨៧។

[326] ឯកសារ **D382** ដីកាបញ្ជូនរឿងទៅជំនុំជម្រះ ជើងទំព័រ ៩៥៩-៩៦១, ៩៦៨, ៩៨១។ *សូមមើលផងដែរ* ជើងទំព័រ ៩៨៧។

[327] ឯកសារ **D382** ដីកាបញ្ជូនរឿងទៅជំនុំជម្រះ ជើងទំព័រ ៩៦៣-៩៦៧, ៩៧៣-៩៧៤, ៩៧៦-៩៧៨, ៩៨៣, ៩៨៧។

[328] ឯកសារ **D382** ដីកាបញ្ជូនរឿងទៅជំនុំជម្រះ ជើងទំព័រ ៩៨៦, ៩៧០, ៩៧៩។

[329] ឯកសារ **D382** ដីកាបញ្ជូនរឿងទៅជំនុំជម្រះ ជើងទំព័រ ៩៨៥។

[330] ឯកសារ **D382** ដីកាបញ្ជូនរឿងទៅជំនុំជម្រះ ជើងទំព័រ ៩៦១, ៩៨៤, ៩៨៧។

[331] *សូមមើលឧទាហរណ៍* ឯកសារ **D382** ដីកាបញ្ជូនរឿងទៅជំនុំជម្រះ កថាខណ្ឌ ៣៦០ (មុខតំណែង), ៣៦៤ (សិទ្ធិអំណាច និងអំណាច), ៣៦៣-៣៦៦, ៣៧១ (អ្នកក្រោមបង្គាប់)។ *សូមមើលផងដែរ* ឯកសារ **D382** ដីកាបញ្ជូនរឿងទៅជំនុំជម្រះ កថាខណ្ឌ ១៧៨-១៨២ (លក្ខន្តិកៈ ប.ក.ក)។ *ផ្ទុយពី* ឯកសារ **D382/22** បណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ កថាខណ្ឌ ១៧៥។

"កម្មេច" និងរាយការណ៍[332] ក្នុងចំណោមបញ្ហាដទៃៗទៀត។ ស្រដៀងគ្នានេះ យឹម ទិត្យ មើលរំលងថា ស.ច.ស.អ បានពឹងផ្អែកលើភស្តុតាងច្រើនជាង យឹម ទិត្យ អះអាង ក្នុងការសន្និដ្ឋានថា យឹម ទិត្យ ទំនងជា (i) មានអំណាចការពារបុគ្គលមិនឱ្យគេចាប់ខ្លួន និងសម្លាប់[333] (ii) ទទួលខុសត្រូវសេដ្ឋកិច្ច[334] និង(iii) ចេញសេចក្ដីណែនាំជាលាយលក្ខណ៍អក្សរ ជាការសន្និដ្ឋានដែលគាំទ្រដោយភស្តុតាងផ្សេងទៀតនៅក្នុងសំណុំរឿង[335]។

107. ការជំទាស់របស់ យឹម ទិត្យ ទៅនឹងការយល់ឃើញរបស់ ស.ច.ស.អ លើលក្ខន្តិកៈ ប.ក.ក ក្នុងការសន្និដ្ឋានថា យឹម ទិត្យ ទំនងជាមានសិទ្ធិអំណាចតាមផ្លូវច្បាប់លើកម្មាភិបាលថ្នាក់ស្រុក និងថ្នាក់ឃុំនៅក្នុងតំបន់ ១ មិនយកចិត្តទុកដាក់លើចំណុចពាក់ព័ន្ធដែលថា លក្ខន្តិកៈ ប.ក.ក មាន

---

[332] *សូមមើល* ឯកសារ **D382** ដីកាបញ្ជូនរឿងទៅជំនុំជម្រះ ជើងទំព័រ ៩៥៥ (*ដកស្រង់ក្នុងចំណោមនោះ* ឯកសារ **D118/245** កំណត់ហេតុស្ដាប់ចម្លើយសាក្សី ជួន ចន ឆ.១៧។ ឯកសារ **D118/285** កំណត់ហេតុស្ដាប់ចម្លើយសាក្សី ណុប ធីម ឆ.៥៦។ ឯកសារ **D219/117** កំណត់ហេតុស្ដាប់ចម្លើយសាក្សី ណុប សឿង ឆ.១២៥ (*សូមមើលផងដែរ* ឆ.៧៩, ៨៧, ១៤៣)។ ឯកសារ **D219/85** កំណត់ហេតុស្ដាប់ចម្លើយសាក្សី វី ផាន់ ឆ.៥។ ឯកសារ **D219/533** កំណត់ហេតុស្ដាប់ចម្លើយសាក្សី ឈឿង ប៊ាន ឆ.១៤), ៩៧០-៩៧២)។ <u>ការចេញបទបញ្ជាផ្សេងទៀត៖</u> *សូមមើល* ឯកសារ **D382** ដីកាបញ្ជូនរឿងទៅជំនុំជម្រះ ជើងទំព័រ ៩៥៥ (*ដកស្រង់ក្នុងចំណោមនោះ* ឯកសារ **D219/117** កំណត់ហេតុស្ដាប់ចម្លើយសាក្សី ណុប សឿង ឆ.១០០។ ឯកសារ **D219/368** កំណត់ហេតុស្ដាប់ចម្លើយសាក្សី ឈឿង ប៊ាន ឆ.៩០, ៩៤។ ឯកសារ **D219/533** កំណត់ហេតុស្ដាប់ចម្លើយសាក្សី ឈឿង ប៊ាន ឆ.១២), ៩៧០។ *ផ្ទុយពី* ឯកសារ **D382/22** បណ្ដឹងឧទ្ធរណ៍របស់ យឹម ទិត្យ កថាខណ្ឌ ១៧៥។

[333] *សូមមើល* ឯកសារ **D382** ដីកាបញ្ជូនរឿងទៅជំនុំជម្រះ ជើងទំព័រ ៩៥៦-៩៥៧ (ការសម្លាប់), ៩៥៨ (ការចាប់ខ្លួន)។ *សូមមើលផងដែរ* ឯកសារ **D34.1.10** បទសម្ភាសន៍របស់ ហេង ទារ ដោយ Steve Heder EN 00964054-55។ ឯកសារ **D1.3.11.15** បទសម្ភាសន៍របស់ ហេង ទារ ដោយ Steve Heder EN 00388312-13។ *ផ្ទុយពី* ឯកសារ **D382/22** បណ្ដឹងឧទ្ធរណ៍របស់ យឹម ទិត្យ កថាខណ្ឌ ១៧៦។

[334] *សូមមើល* ឯកសារ **D382** ដីកាបញ្ជូនរឿងទៅជំនុំជម្រះ ជើងទំព័រ ៩៦១. ៩៨១ (*ដកស្រង់ក្នុងចំណោមនោះ* ឯកសារ **D219/210** កំណត់ហេតុស្ដាប់ចម្លើយសាក្សី លេខ ភីវ ឆ.៨។ ឯកសារ **D219/292** កំណត់ហេតុស្ដាប់ចម្លើយសាក្សី លេខ ភីវ ឆ.៣៥)។ ឯកសារ **D219/368** កំណត់ហេតុស្ដាប់ចម្លើយសាក្សី ឈឿង ប៊ាន ឆ.២៤, ឆ.៥៨។ *សូមមើលផងដែរ* ឯកសារ **D382** ដីកាបញ្ជូនរឿងទៅជំនុំជម្រះ ជើងទំព័រ ៩៨១ (*ដកស្រង់ក្នុងចំណោមនោះ* ឯកសារ **D118/285** កំណត់ហេតុស្ដាប់ចម្លើយសាក្សី ណុប ធីម ឆ.៥៥។ ឯកសារ **D219/515** កំណត់ហេតុស្ដាប់ចម្លើយសាក្សី ឆឹន ឈួយ ឆ.៣០)។ ឯកសារ **D219/298** កំណត់ហេតុស្ដាប់ចម្លើយសាក្សី ណុប ធីម ឆ.១៥។ *ផ្ទុយពី* ឯកសារ **D382/22** បណ្ដឹងឧទ្ធរណ៍របស់ យឹម ទិត្យ កថាខណ្ឌ ១៨០។

[335] ឯកសារ **D382** ដីកាបញ្ជូនរឿងទៅជំនុំជម្រះ ជើងទំព័រ ៩៨៥។ *សូមមើលផងដែរ* ឯកសារ **D219/62** កំណត់ហេតុស្ដាប់ចម្លើយសាក្សី ព្រាប កប ឆ.៤៤។ *ផ្ទុយពី* ឯកសារ **D382/22** បណ្ដឹងឧទ្ធរណ៍របស់ យឹម ទិត្យ កថាខណ្ឌ ១៨៦។

សម្រាប់បង្កើតការគ្រប់គ្រងរបស់គាត់លើអ្នកនៅក្រោមបង្គាប់ និងអាចគាំទ្រភស្តុតាងអំពីអំណាច និងភារកិច្ចដែល យឹម ទិត្យ បានអនុវត្តជាក់ស្តែង[336]។

108. យឹម ទិត្យ ធ្វើការជំទាស់ដោយគ្មានមូលដ្ឋានអំពីការសន្និដ្ឋានរបស់ ស.ច.ស.អ ថា គាត់ទំនងជាមានសិទ្ធិអំណាច និងការគ្រប់គ្រងលើយោធានៅក្នុងតំបន់ ១[337]។ ស.ច.ស.អ បានសំអាងលើ សឿន ម៉ាត់ ជាសាក្សីម្នាក់ដែលមានមេៗដែល "និយាយអំពីទាហានរបស់ តា ទិត្យ" ទៅកាន់គាត់[338] ដឹង "ប្រជាជនគ្រប់គ្នា [...]ល្បីថា តា ទិត្យ ជា មេទ័ពក៏ខ្លាំង"[339] និងចូលរួមប្រជុំនៅក្នុងតំបន់ ១ ដែលក្នុងនោះ យឹម ទិត្យ ពិភាក្សាអំពីបញ្ហាសន្តិសុខ[340] ក្រោយពី តាប៉ែត ត្រូវបានបោសសម្អាត[341]។ ក្នុងករណីណាក៏ដោយ យឹម ទិត្យ មើលរំលងភស្តុតាងគាំទ្រផ្សេងទៀតនៅក្នុងសំណុំរឿង[342]។

109. យឹម ទិត្យ ខិតខំព្យាយាមដោយមិនសមស្របក្នុងការមិនផ្តល់តម្លៃដល់សាក្សីដែលភស្តុតាងរបស់ពួកគាត់គាំទ្រដល់ការសន្និដ្ឋានរបស់ ស.ច.ស.អ ថា គាត់ទំនងជាមានសិទ្ធិអំណាចលើអ្នកនៅ

---

336 *សូមមើល* ឯកសារ **D382** ដីកាបញ្ជូនរឿងទៅជំនុំជម្រះ ជើងទំព័រ ២៣៩។ សំណុំរឿង ០០២-ឯកសារ **D427** ដីកាដំណោះស្រាយ កថាខណ្ឌ ១៣២៧។ សំណុំរឿង ០០២-ឯកសារ **E313** សាលក្រមក្នុងសំណុំរឿង ០០២/០១ កថាខណ្ឌ ៨៩៦, ៩១៣។ សំណុំរឿង ០០២-ឯកសារ **E465** សាលក្រមក្នុងសំណុំរឿង ០០២/០២ កថាខណ្ឌ ៤១៨៩។ សំណុំរឿង ០០៤/២-ឯកសារ **D359/24** & **D360/33** មតិយោបល់របស់ចៅក្រមអន្តរជាតិនៃ អ.ប.ជ ទៅលើដីកាដំណោះស្រាយ កថាខណ្ឌ ៤៧៩។ *ផ្ទុយពី* ឯកសារ **D382/22** បណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ កថាខណ្ឌ ១៨០-១៨១។

337 *ផ្ទុយពី* ឯកសារ **D382/22** បណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ កថាខណ្ឌ ១៧១។

338 ឯកសារ **D219/538** កំណត់ហេតុស្តាប់ចម្លើយសាក្សី សឿន ម៉ាត់ ឆ.៣៨-៣៩, ៥៦, ៥៥។

339 ឯកសារ **D219/538** កំណត់ហេតុស្តាប់ចម្លើយសាក្សី សឿន ម៉ាត់ ឆ.៣៨។ *សូមមើលផងដែរ* ឆ.២០។

340 ឯកសារ **D219/538** កំណត់ហេតុស្តាប់ចម្លើយសាក្សី សឿន ម៉ាត់ ឆ.១៧, ៣០, ៨២។

341 ឯកសារ **D219/538** កំណត់ហេតុស្តាប់ចម្លើយសាក្សី សឿន ម៉ាត់ ឆ.១៧, ៣១, ៤៥។ *សូមមើលផងដែរ* ឆ.៣៧។

342 *សូមមើលឧទាហរណ៍* ឯកសារ **D1.3.15.1** របាយការណ៍របស់អ្នកជំនាញការ Craig Etcheson កថាខណ្ឌ ៦៧។ ឯកសារ **D34.1.10** បទសម្ភាសន៍របស់ ហេង ទាវ ដោយ Steve Heder EN 00964054-55 ("ទាហាន [...] សុទ្ធតែទាហានខ្ញុំ [...] ខ្ញុំប្រាប់ថា "ឲ្យដោះលែងទៅ!" វាដោះភ្លាម រួចអសើ អាកន្លែងនៅបាណន់ ហ្នឹង៤០ប្លាយនាក់។ "ដល់លែងបីថ្ងៃ វាចាប់បណ្តោយ"។ អ្នកចាប់ "គឺ តាទិត លេខាតំបន់")។ ឯកសារ **D219/117** កំណត់ហេតុស្តាប់ចម្លើយសាក្សី តុប សឿង ឆ.២០០។ ឯកសារ **D123/1/5.41** បទសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជា ជាមួយ ឡុង សុខឃី *ហៅ* ឡុង រដ្ឋា EN 00931545។ *សូមមើលផងដែរ* ឯកសារ **D1.3.11.15** បទសម្ភាសន៍របស់ ហេង ទាវ ដោយ Steve Heder EN 00388312-13។ ឯកសារ **D219/64** កំណត់ហេតុស្តាប់ចម្លើយសាក្សី ពៅ គឿន ឆ.២១ (មុនពេលក្លាយជាលេខាតំបន់១ គឺជាមេបញ្ជាការយោធា)។ *ផ្ទុយពី* ឯកសារ **D382/22** បណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ កថាខណ្ឌ ១៧១។

ក្រោមបង្គាប់របស់គាត់លើបញ្ហាសន្តិសុខ និងទំនងជាមានសិទ្ធិអំណាច និងការគ្រប់គ្រងបញ្ហាបុគ្គលិក[343]។ ឧទាហរណ៍ គាត់មិនយកចិត្តទុកដាក់ពន្យល់អំពីមូលហេតុ (i) កាលបរិច្ឆេទជាក់លាក់ដែលសាក្សី វី ផាន, ណុប ងឹម, ឈឿង ប៉ាន, ឈឿង ឈឿត, និងណាង នី បានជួបជាមួយ យឹម ទិត្យ មានការពាក់ព័ន្ធ នៅពេលដែលភស្តុតាងរបស់ពួកគេទាក់ទិននឹង កំឡុងពេលក្រោយគាត់ត្រូវបានតែងតាំងនៅតំបន់ ១[344] និង (ii) សាក្សី ឈឿង ប៉ាន និងឈឿង ឈឿត ចាំបាច់ត្រូវតែបានឮ យឹម ទិត្យ ឧទ្ទេសនាមខ្លួនឯងនៅក្នុងកិច្ចប្រជុំនានាដែលពួកគេបានចូលរួម នៅពេលពួកគេបានផ្តល់ភស្តុតាងអំពីថាតើពួកគេស្គាល់យឹម ទិត្យ ដោយរបៀបណា ទោះបីជាយ៉ាងដូច្នេះក្តី[345]។

110. ការវាយតម្លៃមួយចំណែកលើភស្តុតាងរបស់សាក្សី ធ្វើឲ្យគាត់ខកខានក្នុងការវាយតម្លៃថា ឧទាហរណ៍[346] អំណាចដែលអាចមានរបស់គាត់ក្នុងការការពារបុគ្គលមិនឲ្យរងការចាប់ខ្លួន និងសម្លាប់ត្រូវបានបង្ហាញឲ្យឃើញនៅក្នុង (i) ភស្តុតាងរបស់ ផរ ប៉ែត ដែលបញ្ជាក់ថា យឹម ទិត្យ សួរតាណោន "បើសិនជា ណោនឯង [...] សម្លាប់ពួកទាំងនេះ តើមាននណាការពារណោនឯង [...]?" ដែលជាបទបញ្ជាមួយសម្រាប់ឲ្យគេដោះលែងអ្នកទាំងនោះ ដោយសារតែតំណែងរបស់ យឹម ទិត្យ ធំជាង តាណោន[347] និង(ii) ភស្តុតាងរបស់ ឈឿង ប៉ាន ដែលបង្ហាញថា តាសាម៉ន រួចផុតពី

---

[343] យឹម ទិត្យ យល់ច្រឡំចំពោះសេចក្តីសន្និដ្ឋានរបស់ ស.ច.ស.អ ដែលថា គាត់មានសិទ្ធិអំណាច និងគ្រប់គ្រងលើបញ្ហាបុគ្គលិក (*សូមមើល* ខាងក្នុង) ជាបញ្ហា "ផ្ទាល់ខ្លួន"។ *សូមមើល* ឯកសារ **D382** ដីកាបញ្ជូនរឿងទៅជំនុំជម្រះ កថាខណ្ឌ ៣៦៤ៈ ជើងទំព័រ ៩៥៤។ *ផ្ទុយពី* ឯកសារ **D382/22** បណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ កថាខណ្ឌ ១៧២-១៧៣។

[344] *ផ្ទុយពី* ឯកសារ **D382/22** បណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ កថាខណ្ឌ ១៧៤។ ការជំទាស់របស់ យឹម ទិត្យ ដែលថា "ការខកខានរបស់ ស.ច.ស.អ ក្នុងការពិចារណាអំពីចំណុចពេលវេលានៃកិច្ចប្រជុំ មិនយុត្តិធម៌ និងមិនសមហេតុផលដែលបង្កើតបានជាការរំលោភឆន្ទានុសិទ្ធិរបស់ខ្លួន" មិនបាននាំយកនូវភាពច្បាស់លាស់បន្ថែមទៀតលើបញ្ហានេះទេ។ *សូមមើល* ឯកសារ **D382/22** បណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ កថាខណ្ឌ ១៧៥។ *សូមមើលផងដែរ* កថាខណ្ឌ ១៨៧។

[345] *សូមមើល* ឯកសារ **D219/368** កំណត់ហេតុស្តាប់ចម្លើយសាក្សី ឈឿង ប៉ាន ឆ.៩៣។ ឯកសារ **D219/953** កំណត់ហេតុស្តាប់ចម្លើយសាក្សី ងឹង ឈឿត ឆ.៦៩។ *ផ្ទុយពី* ឯកសារ **D382/22** បណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ កថាខណ្ឌ ១៧៤។

[346] *សូមមើលផងដែរ* ឯកសារ **D118/254** កំណត់ហេតុស្តាប់ចម្លើយសាក្សី ង៉ែត ឡយ ឆ.៤, ១៨។ ឯកសារ **D118/299** កំណត់ហេតុស្តាប់ចម្លើយសាក្សី ជួន ថន ឆ.២៤, ២១-២២។ *ផ្ទុយពី* ឯកសារ **D382/22** បណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ កថាខណ្ឌ ១៧២-១៧៤។

[347] ឯកសារ **D118/244** កំណត់ហេតុស្តាប់ចម្លើយសាក្សី ផរ ប៉ែត ឆ.៦, ៩។ *សូមមើលផងដែរ* ឯកសារ **D219/546** កំណត់ហេតុស្តាប់ចម្លើយសាក្សី ផរ ប៉ែត ឆ.៤៩ (សាក្សីនិយាយយោងការដោះលែងគាត់ទៅ យឹម ទិត្យ មិនមែន តាណោន ទេ)។ ឯកសារ **D382** ដីកាបញ្ជូនរឿងទៅជំនុំជម្រះ កថាខណ្ឌ ១៧៨-១៧៩, ១៨២។ *ផ្ទុយពី* ឯកសារ **D382/22** បណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ កថាខណ្ឌ ១៧៦-១៧៨។

សេចក្តីស្លាប់ដើម្បីជួយ យឹម ទិត្យ ដឹកនាំតំបន់១ និង សំខាន់ជាងនេះទៀតគឺជាអ្នកគ្រប់គ្រងទំនប់កង្កួត ជាការដ្ឋានដែល យឹម ទិត្យ មានការទទួលខុសត្រូវរួម[348]។

111. លើសពីនេះទៀត យឹម ទិត្យ ខិតខំព្យាយាមដោយមិនសមស្របក្នុងការមិនផ្តល់តម្លៃលើការសន្និដ្ឋានរបស់ ស.ច.ស.អ ពាក់ព័ន្ធនឹងការប្រជុំជាទៀងទាត់របស់ យឹម ទិត្យ ដែល ណុប ងឹម ចូលរួម។ ការមិនយល់ស្របរបស់ យឹម ទិត្យ ទៅនឹងសេចក្តីសម្រេចដែលមានសំអាងហេតុរបស់ ស.ច.ស.អ ដែលមិនពឹងផ្អែកលើការដកភស្តុតាងវិញរបស់ ណុប ងឹម ពាក់ព័ន្ធនឹងភាពញឹកញាប់នៃកិច្ចប្រជុំ គឺជាការសន្មតដោយមិនត្រឹមត្រូវថា លិខិតធានាដកចេញការភ័យខ្លាចទាំងអស់ដែលសាក្សីម្នាក់អាចមាន។ យឹម ទិត្យ ក៏សន្មតដោយមិនត្រឹមត្រូវដែរថា ពិការភាពភ្នែករបស់ ប្តី ណុប ងឹម ធ្វើឲ្យគាត់មិនអាចជាប្រភពនៃព័ត៌មានអំពីភាពញឹកញាប់ដែលគាត់បានជូន ណុប ងឹម ទៅប្រជុំជាមួយ យឹម ទិត្យ ក្នុងនាមជាប្តី មិនមែនជាក្នុងនាមជានិរសារទេ[349] ហើយ យឹម ទិត្យ មើលរំលងចំណុចដែលថា ណុប ងឹម មិនដែលត្រូវបានសួរឲ្យបញ្ជាក់ថាតើប្តីរបស់គាត់បានជូនគាត់ទៅប្រជុំមែន ឬយ៉ាងណា[350]។ បើទោះជាសន្មតថា យឹម ទិត្យ និយាយត្រូវដែលថា ណុប ងឹម ជួប ជាមួយ យឹម ទិត្យ មិនមុនខែកញ្ញា ឆ្នាំ១៩៧៨ ដែលតាមពិត មិនត្រឹមត្រូវយ៉ាងណាក្តី[351] ក៏គាត់ខកខាន

---

[348] ឯកសារ **D219/430** កំណត់ហេតុស្តាប់ចម្លើយសាក្សី ឈឿង ប៉ាន ឆ.២១។ ឯកសារ **D219/368** កំណត់ហេតុស្តាប់ចម្លើយសាក្សី ឈឿង ប៉ាន ឆ.១៤១។ *សូមមើលផងដែរ* ឯកសារ **D219/373** កំណត់ហេតុស្តាប់ចម្លើយសាក្សី ណំ ភន ឆ.៣១-៣២។ ឯកសារ **D118/138** កំណត់ហេតុស្តាប់ចម្លើយសាក្សី ទៀប ទិត្យ ឆ.១១។ *ផ្ទុយពី* ឯកសារ **D382/22** បណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ កថាខណ្ឌ ១៧៩។

[349] ឯកសារ **D219/974.1.2** ប្រតិចារិកនៃសក្ខីកម្មរបស់សាក្សី ណុប ងឹម ថ្ងៃទី០៥ ខែកញ្ញា ឆ្នាំ២០១៦ ទំព័រ ៣១ បន្ទាត់ ១៦-១៧។ ឯកសារ **D219/62** កំណត់ហេតុស្តាប់ចម្លើយសាក្សី ព្រាប កប ឆ.៦៤-៦៦, ៦៨។ ហេតុនេះ ការស្មានៗរបស់ យឹម ទិត្យ ដែលថាលិខិតធានាអះអាងអាចមានឥទ្ធិពលទៅលើភស្តុតាងរបស់សាក្សីទុកជាអសារបង់។ *ផ្ទុយពី* ឯកសារ **D382/22** បណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ កថាខណ្ឌ ១៨៤។

[350] ឯកសារ **D219/285** កំណត់ហេតុស្តាប់ចម្លើយសាក្សី ណុប ងឹម ឆ.៨១។ *ផ្ទុយពី* ឯកសារ **D382/22** បណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ កថាខណ្ឌ ១៨៤។

[351] *សូមមើល* ឯកសារ **D118/285** កំណត់ហេតុស្តាប់ចម្លើយសាក្សី ណុប ងឹម ឆ.២៨-២៩។ ឯកសារ **D219/835** កំណត់ហេតុស្តាប់ចម្លើយសាក្សី ណុប ងឹម ឆ.៥៨។ ឯកសារ **D219/974.1.2** ប្រតិចារិកនៃសក្ខីកម្មរបស់សាក្សី ណុប ងឹម ថ្ងៃទី០៥ ខែកញ្ញា ឆ្នាំ២០១៦ ទំព័រ ៣១។ ឯកសារ **D219/298** កំណត់ហេតុស្តាប់ចម្លើយសាក្សី ណុប ងឹម ចុះថ្ងៃទី០៧ ខែឧសភា ឆ្នាំ២០១៥ ឆ.៤។ *សូមមើលផងដែរ* ឯកសារ **D118/285** កំណត់ហេតុស្តាប់ចម្លើយសាក្សី ណុប ងឹម ឆ.៦៨។ ឯកសារ **D219/62** កំណត់ហេតុស្តាប់ចម្លើយសាក្សី ព្រាប កប ឆ.៣១។ ឯកសារ **D219/974.1.2** ប្រតិចារិកនៃសក្ខីកម្មរបស់សាក្សី ណុប ងឹម ថ្ងៃទី០៥ ខែកញ្ញា ឆ្នាំ២០១៦ ទំព័រ ៨០ បន្ទាត់ ១៩-២១។ *ផ្ទុយពី* ឯកសារ **D382/22** បណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ កថាខណ្ឌ ១៨៥។

ជាថ្មីម្តងទៀតក្នុងការពន្យល់ថាតើពេលវេលានៃកិច្ចប្រជុំនោះធ្វើឲ្យប៉ះពាល់ដល់ការសន្និដ្ឋានរបស់ ស.ច.ស.អ ដែរឬទេ ដែលថា គាត់ទំនងជាធ្វើជាលេខាតំបន់ ១ ចាប់ពីរង្វង់ខែមិថុនា ឆ្នាំ១៩៧៨ រហូតដល់ចុងរបបកម្ពុជាប្រជាធិបតេយ្យ ដោយផ្អែកលើភស្តុតាងដទៃទៀតដែលត្រូវបានពិចារណា នៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ។

## ៥. យឹម ទិត្យ ខកខានមិនបានបង្ហាញពីកំហុសណាមួយដែលអាចពិនិត្យឡើងវិញបាននៅក្នុងការសន្និដ្ឋានថា គាត់ទំនងជាលេខាតំបន់៣

112. យឹម ទិត្យ ខកខានមិនបានបង្ហាញពីកំហុសអង្គច្បាប់ ឬអង្គហេតុណាមួយ ដែលអាចពិនិត្យឡើងវិញបានក្នុងការវាយតម្លៃលើភស្តុតាង ឬការសន្និដ្ឋានដែលបានធ្វើឡើងនៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះពាក់ព័ន្ធនឹងតំណែងភរនីយភាពរបស់គាត់ជាលេខាតំបន់៣[352]។ ស.ច.ស.អ បានពឹងផ្អែកលើភស្តុតាងច្បាស់លាស់ និងស៊ីសង្វាក់ ពីអ្នកនៅក្រោមបង្គាប់របស់ យឹម ទិត្យ និងអ្នកដែលបានចូលរួមកិច្ចប្រជុំជាមួយ យឹម ទិត្យ នៅក្នុងតំបន់ ៣ ក្នុងការសន្និដ្ឋាន ដោយផ្អែកលើបទដ្ឋាន "ភរនីយភាព" ដែលអាចអនុវត្តបាន ថា យឹម ទិត្យ បានកាន់តួនាទីនេះ[353]។

113. ចាប់ពីដើមដំបូង ថាតើ ស.ច.ស.អ យោងដល់តំណែងតាមផ្លូវច្បាប់ ឬតួនាទីជាក់ស្តែង ជាលេខាតំបន់៣ មិនជាប់ពាក់ព័ន្ធឡើយ[354]។ ស.ច.ស.អ សន្និដ្ឋានថា យឹម ទិត្យ ដឹកនាំកិច្ចប្រជុំនៅក្នុងតំបន់ ៣ តែងតាំងកម្មាភិបាល ទំនាក់ទំនងជាមួយបណ្តាស្រុកពាក់ព័ន្ធនឹងបញ្ហាសន្តិសុខ និងសេដ្ឋកិច្ច និងមកពិនិត្យមន្ទីរស្រុកក្នុងតំបន់ ៣[355]។

114. វិធីសាស្ត្ររបស់ យឹម ទិត្យ ដូចដែលបានប្រើនៅក្នុងមូលដ្ឋានដទៃទៀត ជំទាស់តាមការជ្រើសរើសទៅលើភស្តុតាងដែល ស.ច.ស.អ ពឹងផ្អែកលើ។ ឧទាហរណ៍ យឹម ទិត្យ កំណត់ខុសលើភស្តុតាងរបស់ មូល អេង[356] ដែលជាអ្នកនៅក្រោមបង្គាប់របស់ យឹម ទិត្យ ក្នុងតំបន់ ៣។ ផ្ទុយនឹងការលើកឡើងរបស់ យឹម ទិត្យ ដែលថា មូល អេង "មិនដែលឮអំពី ការតែងតាំង តាទិត្យ ទៅក្នុង

---

[352] ឯកសារ **D382/22** បណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ កថាខណ្ឌ ១៦១។

[353] ឯកសារ **D382** ដីកាបញ្ជូនរឿងទៅជំនុំជម្រះ ជើងទំព័រ ៣៧២-៣៧៦។

[354] *ផ្ទុយពី* ឯកសារ **D382/22** បណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ កថាខណ្ឌ ១៨៩។

[355] ឯកសារ **D382** ដីកាបញ្ជូនរឿងទៅជំនុំជម្រះ ជើងទំព័រ ៣៧២-៣៧៦។

[356] ឯកសារ **D382/22** បណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ កថាខណ្ឌ ១៨៩-១៩០។

តួនាទីនេះឡើយ”[357] មូល អេង ប្រាប់អ្នកស៊ើបអង្កេតថា “យឹម ទិត្យ បញ្ជាតំបន់៣ [...] ខ្ញុំដឹងនៅពេលខ្ញុំឡើងជំនួសប្រធានស្រុក”បរវេល[358] និងស្រុកក្រោមការគ្រប់គ្រងរបស់ខ្ញុំត្រូវបានប្រគល់ឱ្យ តាទិត្យ”[359]។

115. យឹម ទិត្យ ក៏អះអាងដោយមិនត្រឹមត្រូវផងដែរថា មូល អេង ធ្វើការសន្និដ្ឋានអំពីតំណែងរបស់ យឹម ទិត្យ ពីព្រោះថា “យឹម ទិត្យ បានមកម្តងនៅចុងខែកញ្ញា ឬដើមខែតុលា ឆ្នាំ១៩៧៨” មកពិនិត្យវាលស្រែរបស់ មូល អេង”[360]។ ការពិតខុសគ្នាឆ្ងាយណាស់។ មូល អេង និយាយក្នុងចំណោមបញ្ហាផ្សេងៗថា គាត់បានជួប យឹម ទិត្យ ចំនួនពីរលើក “លើកទីមួយនៅពេលស្រុកបរវេលត្រូវបានផ្ទេរទៅតំបន់៣” និង“កិច្ចប្រជុំទីពីរគឺនៅពេលគាត់មកជួបខ្ញុំនៅកន្លែងខ្ញុំ មន្ទីរស្រុកបរវេល”[361] ថា ក្រោយពី យឹម ទិត្យ ពិនិត្យមន្ទីរស្រុក របស់ មូល អេង មូល អេង ក៏ “ធ្វើការទាក់ទងជាមួយ [យឹម ទិត្យ] តាមរយៈនិរសាររបស់គាត់មួយសប្តាហ៍ម្តង ហើយជួនកាល មួយខែម្តង”[362] ថា មូល អេង “ត្រូវរាយការណ៍ជូន តា ទិត្យ” ជាលេខាតំបន់៣[363] ថា យឹម ទិត្យ “បានណែនាំ [មូល អេង ឱ្យធ្វើស្រែ [...] និងការពារខ្មាំង” នៅក្នុងកិច្ចប្រជុំមួយ[364] និងថា មូល អេង “ទទួលបញ្ជា” ជាលាយលក្ខណ៍អក្សរពី យឹម ទិត្យ[365]។ មិនតែប៉ុណ្ណោះ មូល អេង បានប្រាប់អ្នកស៊ើបអង្កេតថា តាម៉ុក ផ្តល់ដល់ យឹម ទិត្យ ពីអំណាចក្នុងការដកកម្មាភិបាលភូមិភាគ

---

[357] ឯកសារ **D382/22** បណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ កថាខណ្ឌ ១៨៩។

[358] ឯកសារ **D219/294** កំណត់ហេតុស្តាប់ចម្លើយសាក្សី មូល អេង ឆ.៤២-៤៣។

[359] ឯកសារ **D219/294** កំណត់ហេតុស្តាប់ចម្លើយសាក្សី មូល អេង ឆ.១៥៧។ *សូមមើលផងដែរ* ស.&ឆ.៤៩, ឆ.១២៧។

[360] ឯកសារ **D382/22** បណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ កថាខណ្ឌ ១៨៩។

[361] ឯកសារ **D219/294** កំណត់ហេតុស្តាប់ចម្លើយសាក្សី មូល អេង ឆ.៥៣-៥៤។ *សូមមើលផងដែរ* ឆ.៤១។

[362] ឯកសារ **D219/294** កំណត់ហេតុស្តាប់ចម្លើយសាក្សី មូល អេង ឆ.៩៨។

[363] ឯកសារ **D219/294** កំណត់ហេតុស្តាប់ចម្លើយសាក្សី មូល អេង ឆ.៩៧។ *សូមមើលផងដែរ* ឆ.៨០, ស.&ឆ.១០០។

[364] ឯកសារ **D219/294** កំណត់ហេតុស្តាប់ចម្លើយសាក្សី មូល អេង ឆ.៨១។ *ផ្ទុយពី* ឯកសារ **D382/22** បណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ កថាខណ្ឌ ១៩២។

[365] ឯកសារ **D219/294** កំណត់ហេតុស្តាប់ចម្លើយសាក្សី មូល អេង ឆ.១៧៤-១៧៥។ *ផ្ទុយពី* ឯកសារ **D382/22** បណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ កថាខណ្ឌ ១៩២។

ពាយ័ព្យ[366] និង ថា យឹម ទិត្យ មានសិទ្ធិអំណាចចាប់ខ្លួន និងដោះស្រាយបញ្ហាសន្តិសុខនៅក្នុងតំបន់[367]។

116. ផ្ទុយទៅនឹងការអះអាងរបស់ យឹម ទិត្យ ថា ស.ច.ស.អ មានកំហុសក្នុងការសន្និដ្ឋានថា យឹម ទិត្យ ដឹកនាំការប្រជុំក្នុងតំបន់ ៣ និងថា "ពុំមានសាក្សីណាម្នាក់ដែលត្រូវបានលើកមកសំអាងនិយាយថា យឹម ទិត្យ តែងតាំងកម្មាភិបាលឲ្យកាន់តំណែងនានានៅក្នុងតំបន់៣ឡើយ"[368] ទេព សៀន និយាយថា គាត់ត្រូវបានគណៈកម្មាធិការស្រុកភ្នំសំពៅ (តំបន់៣)[369] ប្រាប់ឲ្យចូលរួមប្រជុំ នៅក្នុងកិច្ចប្រជុំនោះ យឹម ទិត្យ ឧទ្ទេសនាម ខ្លួនគាត់ថា "ទទួលខុសត្រូវតំបន់"[370] ហើយនៅក្នុងកិច្ចប្រជុំនោះ យឹម ទិត្យ "តែងតាំងកម្មាភិបាលឲ្យទទួលខុសត្រូវគណៈភូមិ និងគណៈឃុំ"[371]។

117. ស្រដៀងគ្នានេះដែរ ជួន ថន និយាយថា គាត់ត្រូវបានគេហៅឲ្យទៅប្រជុំនៅភ្នំសំពៅ[372] ដែលនៅក្នុងកិច្ចប្រជុំនោះ យឹម ទិត្យ "គឺជាអ្នកដែលពិភាក្សាអំពីចំណុចទាំងអស់"[373]។ យឹម ទិត្យ បានប្រាប់អ្នកចូលរួមប្រជុំថា "គាត់បានទទួលព័ត៌មានជាច្រើនពីប្រធានសហករណ៍ទាក់ទងនឹងអំពើចោរកម្ម ហើយនឹងសកម្មភាពខ្មាំងនៅតាមមូលដ្ឋានជាច្រើន" បានណែនាំឲ្យពួកគេ "តាមដានសកម្មភាពទាំងនោះជាប្រចាំ" និងប្រសិនបើរកឃើញខ្មាំង "យកពួកគេទៅអប់រំជាមុនសិន [...] កម្ទេច និងរាយការណ៍ទៅថ្នាក់លើ"[374]។

118. ការខិតខំរបស់ យឹម ទិត្យ ក្នុងការធ្វើឲ្យប៉ះពាល់ដល់សាក្សីទាំងនេះត្រូវបានប្រមូលផ្តុំនៅក្នុងការលើកឡើងដោយមិនត្រឹមត្រូវថា ទាំង ទេព សៀន និងជួន ថន "មិនបានកំណត់អត្តសញ្ញាណ

---

[366] ឯកសារ **D219/294** កំណត់ហេតុស្តាប់ចម្លើយសាក្សី មូល អេង ឆ.៦៥។

[367] ឯកសារ **D219/294** កំណត់ហេតុស្តាប់ចម្លើយសាក្សី មូល អេង ស.&ឆ.១៩០។

[368] ឯកសារ **D382/22** បណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ កថាខណ្ឌ ១៩០, ១៩៣។

[369] ឯកសារ **D118/87** កំណត់ហេតុស្តាប់ចម្លើយសាក្សី ទេព សៀន ឆ.២២-២៣។ *សូមមើលផងដែរ* ឆ.១៥, ៥៥។ សូមមើលបន្ថែមទៀត ឯកសារ **D381** ដីកាលើកលែងចោទប្រកាន់ កថាខណ្ឌ ១៤៩ លើកឡើងថា ឆេង ជាលេខាស្រុកបវេលក្នុងតំបន់៣។

[370] ឯកសារ **D118/87** កំណត់ហេតុស្តាប់ចម្លើយសាក្សី ទេព សៀន ឆ.២៦។ *សូមមើលផងដែរ* ឆ.២០, ២៥។

[371] ឯកសារ **D118/87** កំណត់ហេតុស្តាប់ចម្លើយសាក្សី ទេព សៀន ឆ.២៨។

[372] ឯកសារ **D118/245** កំណត់ហេតុស្តាប់ចម្លើយសាក្សី ជួន ថន ឆ.៤, ឆ.១២។

[373] ឯកសារ **D118/245** កំណត់ហេតុស្តាប់ចម្លើយសាក្សី ជួន ថន ឆ.១៧។

[374] ឯកសារ **D118/245** កំណត់ហេតុស្តាប់ចម្លើយសាក្សី ជួន ថន ឆ.១៧។

ដោយត្រឹមត្រូវ" ទៅលើយឹម ទិត្យ ឡើយ[375]។ ការគាំទ្ររបស់ យឹម ទិត្យ លើការអះអាងនេះ ជាចម្លើយមួយពីការថ្លែងរបស់ ទេព សៀន ដែលក្នុងនោះ ទេព សៀន ថ្លែងថា គាត់បានចូលរួមការប្រជុំតែមួយគត់ជាមួយ យឹម ទិត្យ[376] និងពុំមានអ្វីពាក់ព័ន្ធនឹង ជួន ចន ទេ[377]។

119. ចម្លើយបន្ថែមទាំងឡាយគាំទ្រថា យឹម ទិត្យ គឺជាលេខាតំបន់៣។ ឧទាហរណ៍ ឡុច អេង ប្រាប់ ស.ច.ស.អ ថា យឹម ទិត្យ គឺជា "គណៈតំបន់"នៅភ្នំសំពៅ[378] និងថា យឹម ទិត្យ មកដល់ភ្នំសំពៅក្រោយ ឡុច អេង និង"គេដាក់ឱ្យទទួលត្រូវខុសតំបន់"[379]។ ហេតុដូចនេះ ការអះអាងរបស់ យឹម ទិត្យ ដែលថា "ពុំមានភស្តុតាងក្នុងសំណុំរឿងដែលថា យឹម ទិត្យ ត្រូវបានតែងតាំងជាលេខាតំបន់៣" តាមភាពជាក់ស្តែង មិនត្រឹមត្រូវទេ[380]។

## ៦. យឹម ទិត្យ មិនបានបង្ហាញកំហុសណាមួយដែលអាចពិនិត្យឡើងវិញបាន នៅក្នុងការសម្រេចថា គាត់ប្រហែលជាលេខាតំបន់ ៤

120. យឹម ទិត្យ មិនបានបង្ហាញពីកំហុសអង្គហេតុ ឬអង្គច្បាប់ដែលអាចពិនិត្យឡើងវិញបាន នៅក្នុងការសម្រេចរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិដែលថា យឹម ទិត្យ ប្រហែលជាលេខាតំបន់ ៤ នៅពាក់កណ្តាលឆ្នាំ១៩៧៨[381]។

121. យឹម ទិត្យ មិនបានកំណត់អត្តសញ្ញាណភស្តុតាងផ្ទុយគ្នា ដើម្បីធ្វើឱ្យការសម្រេចរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិមានភាពទន់ខ្សោយឡើយ។ ទីមួយ យឹម ទិត្យ មិនបានពន្យល់ថាហេតុអ្វីទើបសហចៅក្រមស៊ើបអង្កេតអន្តរជាតិចាំបាច់ត្រូវពិចារណាទៅលើភស្តុតាងរបស់ ឡុច អេង អំពីថានរណាដែលជាលេខាតំបន់ ៤ ដែលបានបញ្ចប់អាណត្តិការងារ ដើម្បីធ្វើឱ្យប្រាកដថា មានភស្តុតាង

---

[375] ឯកសារ **D382/22** បណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ កថាខណ្ឌ ១៩៤។

[376] ឯកសារ **D382/22** បណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ កថាខណ្ឌ ១៩៤ *ដកស្រង់* ឯកសារ **D118/87** កំណត់ហេតុស្តាប់ចម្លើយសាក្សី ទេព សៀន ឆ.២៨។

[377] ឯកសារ **D382/22** បណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ កថាខណ្ឌ ១៩៤។

[378] ឯកសារ **D219/627** កំណត់ហេតុស្តាប់ចម្លើយសាក្សី ឡុច អេង ឆ.១២។ *សូមមើលផងដែរ* ឆ.១៣, ៣០។

[379] ឯកសារ **D219/627** កំណត់ហេតុស្តាប់ចម្លើយសាក្សី ឡុច អេង ឆ.១៣។

[380] ឯកសារ **D382/22** បណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ កថាខណ្ឌ ១៩៦។

[381] *ផ្ទុយពី* ឯកសារ D382/22 បណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ កថាខណ្ឌ ១៩៨ ដល់២០២ (មូលដ្ឋានរង ៥.២.៥)។ សូមមើលសារណាបឋម កថាខណ្ឌ ១៧, ២០, ២២ (បទដ្ឋាននៃការពិនិត្យ)។

គ្រប់គ្រាន់ថា យឹម ទិត្យ គឺជាលេខាតំបន់ ៤ បន្ទាប់ពីពេលនោះមក[382]។ សហចៅក្រមស៊ើបអង្កេតអន្តរជាតិបានពឹងផ្អែកការសម្រេចរបស់គាត់នេះទៅលើ ឡុច អេង ដែលបាន និយាយប្រាប់អ្នកស៊ើបអង្កេតរបស់ ក.ស.ច.ស ចំនួនបីដង ថា យឹម ទិត្យ គឺជាលេខានៅទីតាំង ដែលគាត់ធ្វើការ គឺនៅក្នុងតំបន់ ៤[383]។

122. ទីពីរ យឹម ទិត្យ បានអះអាងដោយមិនត្រឹមត្រូវថា ឡុច អេង មិនអាចដឹងបានថា គាត់គឺជាលេខាតំបន់ ៤ ទេ ព្រោះ ឡុច អេង មិនបានឮសេចក្តីប្រកាសផ្លូវការអំពីតួនាទីជាលេខាតំបន់ ៤ របស់គាត់[384]។ ប៉ុន្តែ ឡុច អេង បានដឹងអំពីតួនាទីរបស់ យឹម ទិត្យ តាមរយៈការដែល យឹម ទិត្យ ដឹកនាំកិច្ចប្រជុំ ដែលមានប្រធានស្រុកចូលរួម និងចំណុចថា តួនាទីរបស់ យឹម ទិត្យ ត្រូវបានគេដឹងឮជាទូទៅ នៅកន្លែងដែល ឡុច អេង ធ្វើការ[385]។

123. ទីបី ផ្ទុយពីការអះអាងរបស់ យឹម ទិត្យ ឡុច អេង ពិតជាបានដឹងថា តួនាទីរបស់ យឹម ទិត្យ គ្រប់ដណ្តប់ទៅលើអ្វីខ្លះ និងសិទ្ធិអំណាចអ្វីដែល យឹម ទិត្យ បានប្រើប្រាស់ ក្នុងនាមជាលេខាតំបន់ ៤[386] ឧទាហរណ៍ ឡុច អេង បានដឹងថា យឹម ទិត្យ "គាត់ជាគណៈតំបន់ គាត់គ្រប់គ្រង" "គាត់មកគ្រប់គ្រងស្រុក"[387] ហើយមានអំណាចបញ្ជា ចាត់តាំងឈ្លបឃុំ និងភូមិ ដើម្បីតាមដានកម្មាភិបាល ឬប្រជាជនសាមញ្ញ ដែលធ្វើសកម្មភាពមិនប្រក្រតី និងរាយការណ៍ទៅស្រុក[388]។ យឹម ទិត្យ ក៏មិន

---

[382] *ផ្ទុយពី* ឯកសារ D382/22 បណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ កថាខណ្ឌ ១៩៩។

[383] ឯកសារ D382 ដីកាបញ្ជូនរឿងទៅជំនុំជម្រះ ជើងទំព័រ ១០០១។ សូមមើលផងដែរ ឯកសារ **D219/627** កំណត់ហេតុស្តាប់ចម្លើយ ឡុច អេង ចម្លើយ ៤។ ឯកសារ D382 ដីកាបញ្ជូនរឿងទៅជំនុំជម្រះ កថាខណ្ឌ ១២៣។

[384] *ផ្ទុយពី* ឯកសារ D382/22 បណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ កថាខណ្ឌ ១៩៩។

[385] សូមមើល *ជាឧទាហរណ៍* ឯកសារ **D118/96** កំណត់ហេតុស្តាប់ចម្លើយ ឡុច អេង ចម្លើយ ៣១, ៣៣។ ឯកសារ **D219/884** កំណត់ហេតុស្តាប់ចម្លើយ ឡុច អេង ចម្លើយ ១៣។ សូមមើលផងដែរ ឯកសារ **D219/627** កំណត់ហេតុស្តាប់ចម្លើយ ឡុច អេង ចម្លើយ ១៨។

[386] *ផ្ទុយពី* ឯកសារ D382/22 បណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ កថាខណ្ឌ ១៩៩ ដល់២០០។

[387] ឯកសារ **D219/884** ឡុច អេង កំណត់ហេតុស្តាប់ចម្លើយ ចម្លើយ ៧, ១៣។ សូមមើលផងដែរ ឯកសារ **D219/627** កំណត់ហេតុស្តាប់ចម្លើយ ឡុច អេង ចម្លើយ ២៩។

[388] ឯកសារ **D118/96** កំណត់ហេតុស្តាប់ចម្លើយ ឡុច អេង ចម្លើយ ៣៥។ សូមមើលផងដែរ ឯកសារ **D219/627** កំណត់ហេតុស្តាប់ចម្លើយ ឡុច អេង ចម្លើយ ១៨, ២០ ដល់២១, ៤, ២៩។

បានពិចារណាលើភ័ស្តុតាងបន្ថែមនៅក្នុងសំណុំរឿង ទាក់ទងនឹងអំណាចដែលគាត់បានប្រើប្រាស់នៅក្នុងតំបន់ ៤ ទេ[389]។

## ៧. យឹម ទិត្យ មិនបានបង្ហាញពីកំហុសណាមួយ ដែលអាចពិនិត្យឡើងវិញបាន ក្នុងការសម្រេចថា គាត់ប្រហែលជាសមាជិកនៃគណៈកម្មាធិការភូមិភាគពាយ័ព្យ

124. យឹម ទិត្យ មិនបានបង្ហាញអំពីកំហុសអង្គហេតុ ឬអង្គច្បាប់ណាមួយ ដែលអាចត្រួតពិនិត្យបាន នៅក្នុងការសម្រេចរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ដែលថា យឹម ទិត្យ ប្រហែលជាសមាជិកនៃគណៈកម្មាធិការភូមិភាគពាយ័ព្យ ហើយប្រហែលជាមនុស្សទីពីរ ដែលមានអំណាចជាងគេនៅក្នុងភូមិភាគ បន្ទាប់ពីការតែងតាំងតាម៉ុកជាលេខាភូមិភាគពាយ័ព្យ[390]។

125. យឹម ទិត្យ បានជំទាស់ដោយមិនគួរឱ្យជឿជាក់ចំពោះការពឹងផ្អែករបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិទៅលើ ឈាន ប៊ា ដែលបានដឹងពីតាប៉ែតថា យឹម ទិត្យ បានបង្ហាញដល់តាប៉ែត នូវឯកសារមកពីមជ្ឈឹមដែលចាត់តាំង យឹម ទិត្យ ឱ្យទទួលខុសត្រូវលើភូមិភាគពាយ័ព្យ[391]។ យឹម ទិត្យ មើលរំលងថា ការដឹងរបស់ ឈាន ប៊ា ទាក់ទងនឹងការតែងតាំង យឹម ទិត្យ ត្រូវបានគាំទ្រដោយចម្លើយរបស់សាក្សីដទៃទៀត ដែលជាមូលដ្ឋាននៃការសម្រេចរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ[392]។ ឈាន ប៊ា ក៏បានដឹងព័ត៌មានពីតាប៉ែត ភ្លាមៗក្រោយពេលដែលគាត់បាន

---

[389] សូមមើល ឯកសារ **D219/872** Touch Mary កំណត់ហេតុស្តាប់ចម្លើយ ទូច ម៉ារី ចម្លើយ ១៤៨, ១៥៥, ១៦៥។ ឯកសារ **D219/836** កំណត់ហេតុស្តាប់ចម្លើយ ទូច ម៉ារី ចម្លើយ ១៦០, ១៦២, ១៦៤, ១៦៨។ សូមមើលផងដែរ ឯកសារ **D219/528** កំណត់ហេតុស្តាប់ចម្លើយ ឡាញ លន់ ចម្លើយ ៩១, ៩៣។

[390] *ផ្ទុយពី* ឯកសារ D382/**22** បណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ កថាខណ្ឌ ២០៣ ដល់២១៥ (មូលដ្ឋានរង ៥.២.៦)។ សូមមើល សារណាបឋម កថាខណ្ឌ ១៧, ២០, ២២ (បទដ្ឋាននៃការពិនិត្យ)។

[391] សូមមើល សារណាបឋម កថាខណ្ឌ 14 (សេរីភាពនៃភស្តុតាង)។ ឯកសារ D382 ដីកាបញ្ជូនរឿងទៅជំនុំជម្រះ ជើងទំព័រ ១០០២ កថាខណ្ឌ ៣៨៤។ *ផ្ទុយពី* ឯកសារ D382/**22** បណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ កថាខណ្ឌ ២០៥ ដល់២០៦។

[392] <u>សមាជិក រួមទាំងអនុលេខាភូមិភាគ/ មនុស្សទីពីរដែលមានអំណាចជាងគេបន្ទាប់ពី តាម៉ុក៖</u> ឯកសារ D382 ដីកាបញ្ជូនរឿងទៅជំនុំជម្រះ កថាខណ្ឌ ៣៨០ (*ដកស្រង់ ផងដែរ* ឯកសារ **D118/69** កំណត់ហេតុស្តាប់ចម្លើយ នួន មួន ចម្លើយ ១៤ ដល់១៧) ៣៨២ (*ដកស្រង់ ផងដែរ* ឯកសារ **D118/86** កំណត់ហេតុស្តាប់ចម្លើយ ញ៉ុក លី ចម្លើយ ២១ ដល់ ២២) ៣៨៣ (*ដកស្រង់ ផងដែរ* ឯកសារ **D20** កំណត់ហេតុស្តាប់ចម្លើយ ហាន់ ធី ERN 00699643 ឯកសារ **D118/150** កំណត់ហេតុស្តាប់ចម្លើយ ហែម មឿន ចម្លើយ ៦០ ដល់៦១, ឯកសារ **D118/222** កំណត់ហេតុស្តាប់ចម្លើយ ហែម មឿន ចម្លើយ ១៤, ឯកសារ **D219/64** កំណត់ហេតុស្តាប់ចម្លើយ ពៅ គឿន ចម្លើយ ២៨ ដល់២៩) ៣៨៤ (*ដកស្រង់ ផងដែរ* ឯកសារ **D118/108** លឹម ទីម កំណត់ហេតុស្តាប់ចម្លើយ ចម្លើយ ១៧)។ សូមមើលផងដែរ ឯកសារ **D219/917** កំណត់ហេតុស្តាប់ចម្លើយ ដៃ ទូច ចម្លើយ

ឃើញថាតាប៉ែត បានជួបជាមួយ យឹម ទិត្យ[393]។ ផ្ទុយពីការសន្និដ្ឋានមិនច្បាស់លាស់របស់ យឹម ទិត្យ ឈាន ប៉ា មិនចាំបាច់ត្រូវចូលរួមកិច្ចប្រជុំជាមួយ យឹម ទិត្យ មិនចាំបាច់ត្រូវជួប យឹម ទិត្យ លើសពីម្តង ឬបានដឹងអំពីតួនាទីនៅក្នុងគណៈកម្មាធិការភូមិភាគរបស់កម្មាភិបាល ដែលត្រូវបានបោសសម្អាត ដើម្បីអាចប្រាប់អ្នកស៊ើបអង្កេតរបស់ ក.ស.ច.ស អំពីអ្វីដែលតាប៉ែតបានដឹងនៅក្នុងការប្រជុំជាមួយ យឹម ទិត្យ[394]។

126. ប្រហែលគ្នានេះ ការវាយតម្លៃដោយមិនត្រឹមត្រូវរបស់ យឹម ទិត្យ ទៅលើភ័ស្តុតាងរបស់ លឹម ទីម មិនធ្វើឱ្យប៉ះពាល់ដល់ការសម្រេចរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិឡើយ។ លឹម ទីម បានចូលរួមការប្រជុំមួយដែល "គេឧទ្ទេសនាមថា តាទិត្យ ជាប្រធានភូមិភាគពាយ័ព្យ"[395]។ ផ្ទុយពីការអះអាងរបស់ យឹម ទិត្យ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ មិនដែលបានសម្រេចថា លឹម ទីម

---

១១, ១៣, ១៥។ ឯកសារ **D219/34** កំណត់ហេតុស្តាប់ចម្លើយ អ៊ុល ហឿន ចម្លើយ ៤៣។ ឯកសារ **D219/117** កំណត់ហេតុស្តាប់ចម្លើយ តុប សឹង ចម្លើយ ៧៨ ដល់៧៩។ ឯកសារ **D123/2/1.1a** កិច្ចសម្ភាសន៍ជាមួយ តុប សឹង ដោយមជ្ឈមណ្ឌលឯកសារកម្ពុជា ERN 00957635។ ឯកសារ **D105/4** កំណត់ហេតុស្តាប់ចម្លើយ ហ៊ុយ ក្រឹម ចម្លើយ ២០។ ឯកសារ **D118/75** កំណត់ហេតុស្តាប់ចម្លើយ ហ៊ុយ ក្រឹម ចម្លើយ ២៥។ ឯកសារ **D219/515** កំណត់ហេតុស្តាប់ចម្លើយ ធីន ឈួយ ចម្លើយ ៣០, ៤៧។ ឯកសារ **D1.3.11.53** កិច្ចសម្ភាសន៍រវាង តេន ជីម ជាមួយ SOAS ERN 00217754។ <u>ក្នុងការអនុវត្តជាក់ស្តែង</u>៖សូមមើល*ឧទាហរណ៍* ឯកសារ D382 ដីកាបញ្ជូនរឿងទៅជំនុំជម្រះ កថាខណ្ឌ ៣៨០ (*ដកស្រង់ ផងដែរ* ឯកសារ **D219/974.1.2** ប្រតិចារឹកសវនាការ ថ្ងៃទី៥ ខែកញ្ញា ឆ្នាំ២០១៦ (ណុប ធឹម) ទំព័រ ៤៦ ជួរ ៧ ដល់១០ ឯកសារ **D118/285** កំណត់ហេតុស្តាប់ចម្លើយ ណុប ធឹម ចម្លើយ ៥៥ ដល់៥៦។ សូមមើលផងដែរ ឯកសារ **D219/298** កំណត់ហេតុស្តាប់ចម្លើយ ណុប ធឹម ចម្លើយ ១៣ ដល់១៤។ ឯកសារ **D219/835** កំណត់ហេតុស្តាប់ចម្លើយ ណុប ធឹម ចម្លើយ ៨៥, ៩០, ៩៥)។ *ផ្ទុយពី* ឯកសារ D382/22 បណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ កថាខណ្ឌ ២០៥។

393 ឯកសារ **D118/136** កំណត់ហេតុស្តាប់ចម្លើយ ឈាន ប៉ា ចម្លើយ ១៣។ សូមមើលផងដែរ ឯកសារ **D118/271** កំណត់ហេតុស្តាប់ចម្លើយ ឈាន ប៉ា ចម្លើយ ២៦។ ឯកសារ **D118/136** កំណត់ហេតុស្តាប់ចម្លើយ ឈាន ប៉ា ចម្លើយ ១២។

394 យឹម ទិត្យ បង្ហាញដោយខុសឆ្គង អំពីការដឹងឮរបស់ ឈាន ប៉ា ទាក់ទងនឹងតួនាទីរបស់ តាញឹម និង តាគី នៅក្នុងគណៈកម្មាធិការភូមិភាគពាយ័ព្យ។ នៅពេលដែលគេសួរ ឈាន ប៉ា ថាតើ តាប៉ែត បានប្រាប់គាត់ដែរឬទេ អំពីទំនាក់ទំនងរវាង តាញឹម និង តាគី ទើបគាត់ឆ្លើយថា "ទេ" ហើយនៅពេលសួរថាតើគាត់ដឹង អំពីតួនាទីក្នុងឃោធារបស់ តាញឹម និង តាគីទេ ទើបគាត់ឆ្លើយថា "ខ្ញុំគ្មានយោបល់អ្វីទេ"។ សូមមើល ឯកសារ **D118/136** ឈាន ប៉ា កំណត់ហេតុស្តាប់ចម្លើយ ចម្លើយ ៦។ ឯកសារ **D118/271** កំណត់ហេតុស្តាប់ចម្លើយ ឈាន ប៉ា ចម្លើយ ៤៤ ដល់៤៥។ សូមមើលផងដែរ ឯកសារ **D219/233** កំណត់ហេតុស្តាប់ចម្លើយ ឈាន ប៉ា ចម្លើយ ៩។ *ផ្ទុយពី* ឯកសារ D382/22 បណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ កថាខណ្ឌ ២០៦។

395 ឯកសារ D382 ដីកាបញ្ជូនរឿងទៅជំនុំជម្រះ កថាខណ្ឌ ៣៨៤ (*ដកស្រង់ ផងដែរ* ឯកសារ **D118/108** កំណត់ហេតុស្តាប់ចម្លើយ លឹម ទីម ចម្លើយ ១៧)។ *ផ្ទុយពី* ឯកសារ D382/22 បណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ កថាខណ្ឌ ២០៧។

មិនអាចជឿជាក់បាន ពាក់ព័ន្ធនឹងការប្រជុំនេះឡើយ[396] ហើយ លឹម ទីម តែងនិយាយស្របៗគ្នារហូត អំពីទីតាំងនៃការប្រជុំនេះ[397]។

127. យឹម ទិត្យ ក៏បានអះអាងដោយមិនត្រឹមត្រូវថា សហចៅក្រមស៊ើបអង្កេតអន្តរជាតិបានបង្ហាញដោយមិនត្រឹមត្រូវពីភស្តុតាង ដើម្បីសម្រេចថា យឹម ទិត្យ មានតួនាទីនៅក្នុងគណៈកម្មាធិការភូមិភាគពាយ័ព្យ ហើយថា ជាក់ស្តែង គាត់ជាមនុស្សដែលមានអំណាចទីពីរ ព្រមទាំងជាអនុរបស់ តាម៉ុក នោះ[398]។ ការវាយតម្លៃលើភស្តុតាងមួយផ្នែកតូចរបស់ យឹម ទិត្យ នៅក្នុងសំណុំរឿង មិនបានពិចារណា (១) ថា តាប៉ែត មិនទាន់ត្រូវបានចាប់ខ្លួនទេ នៅពេលដែល ហាន់ ធី ឃើញ យឹម ទិត្យ ហើយបានដឹងអំពីតួនាទីរបស់ យឹម ទិត្យ នៅក្នុងគណៈកម្មាធិការភូមិភាគ ដូច្នេះហើយ ការដែល ហាន់ ធី បានជួបជាមួយ យឹម ទិត្យ មិនអាចកើតឡើងនៅបីថ្ងៃ មុនពេលវៀតណាមចូលមកដល់ទេ[399] (២) ការកែប្រែខ្លឹមសាររបស់ ហែម មឿន នៅក្នុងខ្លឹមសារនៃកំណត់ហេតុស្តាប់ចម្លើយ

---

[396] សហចៅក្រមស៊ើបអង្កេតអន្តរជាតិបានសម្រេចថា "ភស្តុតាងរបស់គាត់លើបញ្ហានេះ" ទាក់ទងនឹងការចាប់ខ្លួនមនុស្សមួយក្រុមនៅរោងចក្រស្ករកំពង់កុល មិនអាចជឿជាក់បាន នៅពេលដែលសហចៅក្រមស៊ើបអង្កេតអន្តរជាតិវាយតម្លៃទៅលើភស្តុតាងអំពីការសម្លាប់មនុស្ស និងការបាត់ខ្លួននៅទីតាំង។ សូមមើល ឯកសារ D382 ដីកាបញ្ជូនរឿងទៅជំនុំជម្រះ កថាខណ្ឌ ៧៤១ (គូសបញ្ជាក់បន្ថែម) ERN 01624781 (មានចំណងជើងថា "មនុស្សឃាត និងការបាត់ខ្លួន")។ *ផ្ទុយពី* ឯកសារ D382/22 បណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ កថាខណ្ឌ ២០៧ ដល់២០៨។

[397] លឹម ទីម មិនដែលបាននិយាយថា យឹម ទិត្យ បានចូលរួមការប្រជុំ នៅរោងចក្រស្ករកំពង់កុលទេ។ លឹម ទីម ក៏បាននិយាយដោយច្បាស់លាស់ នៅពេលដើមដំបូងក្នុងការស្តាប់ចម្លើយ លើកទីមួយរបស់គាត់ ថា យឹម ទិត្យថ "នៅក្រុងបាត់ដំបង ហើយគាត់មិនដែលមករោងចក្រស្ករនេះទេ" សូមមើល ឯកសារ **D118/108** លឹម ទីម កំណត់ហេតុស្តាប់ចម្លើយ ចម្លើយ ១៦។ ការដកស្រង់របស់ យឹម ទិត្យ ពីផ្នែកមួយនៃភស្តុតាងរបស់ លឹម ទីម មិនបាននិយាយថា យឹម ទិត្យ បានចូលរួមការប្រជុំ នៅរោងចក្រស្ករកំពង់កុល ឬសូម្បីប្រើប្រាស់ពាក្យ "កំពង់កុល" ឬ "រោងចក្រ"។ ប៉ុន្តែ យឹម ទិត្យ បានដកស្រង់ពីភស្តុតាង នៃការប្រជុំដែលធ្វើឡើងនៅ សាកលវិទ្យាល័យបាត់ដំបង នៅក្រុងបាត់ដំបងទៅវិញ។ *ផ្ទុយពី* ឯកសារ D382/22 បណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ កថាខណ្ឌ ២០៧ ជើងទំព័រ ៦០៩។

[398] *ផ្ទុយពី* ឯកសារ D382/22 បណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ កថាខណ្ឌ ២០៨។

[399] ឯកសារ **D118/63** កំណត់ហេតុស្តាប់ចម្លើយ ហាន់ ធី ចម្លើយ ២៦ ដល់៣១។ តាប៉ែត បាននិយាយថា គាត់ត្រូវបានចាប់ខ្លួន ហើយឃុំឃាំងប្រហែលមួយខែ ឬពីរខែ ក្រោយពេល រស់ ញឹម លេខាភូមិភាគពាយ័ព្យ ត្រូវបានចាប់ខ្លួន។ សូមមើល ឯកសារ D34.1.9 កិច្ចសម្ភាសន៍រវាង ហេង ទារ ហៅ តាប៉ែត ជាមួយ Steve Heder ERN 00965647-00965648 (នៅពេលតាញឹម ត្រូវបានចាប់ខ្លួន កូនប្រុសគាត់បាន ទូរស័ព្ទទៅភ្នំពេញ "ប្រហែលជាក្នុងខែហ្នឹងដែរ ខែ៨ហ្នឹង") ERN 00965616 ("៧៨ ចាប់ដាក់គុកនៅកំពង់ស្ពឺ")។ ឯកសារ **D1.3.18.2** ចម្លើយសារភាពនៅ មន្ទីរស-២១ របស់ មួល សម្បត្តិ ហៅ រស់ ញឹម ERN 0024661 (លេខាភូមិភាគពាយ័ព្យ ចុះថ្ងៃទី១៤ ខែមិថុនា ឆ្នាំ១៩៧៨)។ *ផ្ទុយពី* ឯកសារ D382/22 បណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ កថាខណ្ឌ ២០៨។

របស់គាត់ នៅពេលផ្ដល់សក្ខីកម្មក្នុងសំណុំរឿង ០០២/០២ អាចដោយសារតែការអន្តរាគមន៍ទៅលើក្រុមគ្រួសាររបស់គាត់ពីសំណាក់ប្រភពអនាមិកមួយ នៅយប់មុនពេលដែលគាត់ផ្ដល់សក្ខីកម្ម[400] និង (៣) ពៅ គឿន បានស្គាល់កម្មាភិបាលនៅក្នុងគណៈកម្មាធិការភូមិភាគ និងតំបន់១ មុនពេលពួកគេត្រូវបានបោសសម្អាត ហើយបានដឹងក្រោយពេលបោសសម្អាតថា យឹម ទិត្យ "មានមុខតំណែងជាគណៈតំបន់" ហើយ "ក្រោយមកទៀត តាទិត្យ ក៏គ្រប់គ្រងភូមិភាគពាយ័ព្យដែរ"[401]។

128. ការជំទាស់របស់ យឹម ទិត្យ ចំពោះការសង្កេតរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ដែលថា យឹម ទិត្យ មានតួនាទីប្រហែលនឹងអ្នកមុនរបស់គាត់គឺ តាប៉ែត មិនមានមូលដ្ឋានឡើយ[402]។ យឹម ទិត្យ មិនបានពន្យល់ថាតើ ការទាញឱ្យស្របគ្នាចំពោះភ័ស្តុតាងរបស់សាក្សី ទាក់ទងនឹងតួនាទីនៅភូមិភាគពាយ័ព្យរបស់ តាប៉ែត និង យឹម ទិត្យ មិនត្រូវបានអនុញ្ញាតឡើយ ជាពិសេសដោយសារតែការសម្រេចដែលស្របគ្នា នៅក្នុងយុត្តិសាស្ត្ររបស់ អ.វ.ត.ក លើសមាជិកភាពនៃគណៈកម្មាធិការបក្សកុម្មុយនីស្តកម្ពុជា[403]។ ការអះអាងរបស់ យឹម ទិត្យ ថា គាត់មិនបានជំនួស តាប៉ែត នៅក្នុងគណៈកម្មាធិការភូមិភាគពាយ័ព្យ ត្រូវបានបដិសេធដោយ តាប៉ែត ខ្លួនគាត់ផ្ទាល់ និងដោយសាក្សីដទៃផ្សេងទៀត[404]។

---

[400] សូមមើល ឯកសារ **D219/826.1** របាយការណ៍របស់ អង្គភាពគាំពារសាក្សី និងអ្នកជំនាញ ថ្ងៃទី១៧ ខែសីហា ឆ្នាំ២០១៦។ *ផ្ទុយពី* ឯកសារ D382/22 បណ្ដឹងឧទ្ធរណ៍របស់ យឹម ទិត្យ កថាខណ្ឌ ២០៨។

[401] សូមមើល ឯកសារ **D219/64** កំណត់ហេតុស្ដាប់ចម្លើយ ពៅ គឿន ចម្លើយ ១៧, ២១, ២៣, ២៥ ដល់២៦, ៤០, ២៧ ដល់ ២៨។ *ផ្ទុយពី* ឯកសារ D382/22 បណ្ដឹងឧទ្ធរណ៍របស់ យឹម ទិត្យ កថាខណ្ឌ ២០៨។

[402] *ផ្ទុយពី* ឯកសារ D382/22 បណ្ដឹងឧទ្ធរណ៍របស់ យឹម ទិត្យ កថាខណ្ឌ ២០៩។

[403] ឯកសារ D382 ដីកាបញ្ជូនរឿងទៅជំនុំជម្រះ កថាខណ្ឌ ១៥៦។ សំណុំរឿង ០០២ ឯកសារ **E465** សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង សំណុំរឿង ០០២/០២ កថាខណ្ឌ ៣៧៤។ សំណុំរឿង ០០២ ឯកសារ **E313** សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង សំណុំរឿង ០០២/០១ កថាខណ្ឌ ២១៩។

[404] ការដកតាប៉ែតពីតួនាទី៖ ឯកសារ D34.1.9 កិច្ចសម្ភាសន៍រវាង ហេង ទារ ហៅ តាប៉ែត ជាមួយ Steve Heder, ERN 00965647។ ឯកសារ **D287/2/1.1** កំណត់ត្រានៃការសម្ភាសន៍ ហេង ទារ ហៅ តាប៉ែត ដោយ Steve Heder, ERN 00217640។ ឯកសារ **D118/136** ឈាន ប៉ា កំណត់ហេតុស្ដាប់ចម្លើយ ចម្លើយ ២។ សូមមើលផងដែរ ឯកសារ **D219/896** កំណត់ហេតុស្ដាប់ចម្លើយ ជួង លួម ចម្លើយ ១២។ ២. ការចាប់ខ្លួនតាប៉ែត៖ តាប៉ែត បាននិយាយថា គាត់ត្រូវបានចាប់ខ្លួន និងឃុំខ្លួនប្រហែលមួយខែ ឬពីរខែ បន្ទាប់ពី រស់ ញឹម លេខាភូមិភាគពាយ័ព្យ ត្រូវបានចាប់ខ្លួន (ដែលមិនហួសពីថ្ងៃទី១៥ ខែមិថុនា ឆ្នាំ ១៩៧៨ បើតាមកំណត់ត្រារបស់មន្ទីរសន្តិសុខ ស-២១)។ នេះមានន័យថា តាប៉ែត ត្រូវបានចាប់ខ្លួនមិនលើសពីពាក់កណ្ដាល ខែសីហា ឆ្នាំ១៩៧៨ទេ។ សូមមើល ឯកសារ **D1.3.18.2** ចម្លើយសារភាពនៅ មន្ទីរស-២១ របស់ មូល សម្បត្តិ ហៅ រស់ ញឹម ERN 00780881។ ឯកសារ D34.1.9 កិច្ចសម្ភាសន៍រវាង ហេង ទារ ហៅ តាប៉ែត ជាមួយ Steve Heder, ERN 00965616។

129. ជាចុងក្រោយ យឹម ទិត្យ មិនបានពន្យល់ថាតើ ភ័ស្តុតាងរបស់ ឌុច ដែលថា តាសារុន គឺជាអនុលេខាភូមិភាគពាយ័ព្យនៅចុងរបបកម្ពុជាប្រជាធិបតេយ្យ រារាំងសហចៅក្រមស៊ើបអង្កេតអន្តរជាតិ មិនឲ្យពឹងផ្អែកទៅលើភ័ស្តុតាងរបស់សាក្សីជាច្រើន ដែលបានកត់សម្គាល់ឃើញ យឹម ទិត្យ នៅក្នុងភូមិភាគពាយ័ព្យ និងត្រូវបានគេប្រាប់ថា យឹម ទិត្យ នៅក្នុងគណៈកម្មាធិការ ជាមនុស្សដែលមានអំណាចទីពីរ នៅក្នុងភូមិភាគ ឬជាអនុប្រធានរបស់ តាម៉ុក[405]។ ទាំងនេះរួមទាំងភ័ស្តុតាងដែល យឹម ទិត្យ មិនបានជំទាស់ ព្រមទាំងភ័ស្តុតាងគាំទ្របន្ថែមផ្សេងទៀតនៅក្នុងសំណុំរឿង[406]។

---

សូមមើលផងដែរ ឯកសារ D**382** ដីកាបញ្ជូនរឿងទៅជំនុំជម្រះ កថាខណ្ឌ ៣៦២ ជើងទំព័រ ១០១០។ ឯកសារ **D118/136** កំណត់ហេតុស្តាប់ចម្លើយ ឈាន ប៊ាា ចម្លើយ ២, ៤៣។ ឯកសារ **D219/233** កំណត់ហេតុស្តាប់ចម្លើយ ឈាន ប៊ាាចម្លើយ ១៤, ១៨, ២១, ៤៩។ សហព្រះរាជអាជ្ញាអន្តរជាតិ កត់សម្គាល់ថា យឹម ទិត្យ នាពេលកន្លងមកហាក់ដូចជាចាត់ទុកថាអត្ថបទរបស់ Timothy Carney មានតម្លៃជាភស្តុតាងទាប។ សូមមើល ឯកសារ D**378/5** ចម្លើយតបរបស់ យឹម ទិត្យ ចំពោះដីកាសន្និដ្ឋានស្ថាពរ កថាខណ្ឌ ១២៣០។ *ផ្ទុយពី* ឯកសារ D**382/22** បណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ កថាខណ្ឌ ២១១ ដល់២១២។

405 <u>អនុលេខាភូមិភាគ/ មនុស្សទីពីរដែលមានអំណាចជាងគេបន្ទាប់ពី តាម៉ុក៖</u> ឯកសារ D**382** ដីកាបញ្ជូនរឿងទៅជំនុំជម្រះ កថាខណ្ឌ 380 (*ដកស្រង់* ឯកសារ **D118/69** កំណត់ហេតុស្តាប់ចម្លើយ នួន មួន ចម្លើយ ១៤ ដល់១៧) ៣៨២ (*ដកស្រង់* ឯកសារ **D118/86** កំណត់ហេតុស្តាប់ចម្លើយ ញឹក លី ចម្លើយ ២១ ដល់២២) ៣៨៣ (*ដកស្រង់* ឯកសារ **D20** កំណត់ហេតុស្តាប់ចម្លើយ ហាន់ ធី ERN 00699643 ឯកសារ **D118/150** កំណត់ហេតុស្តាប់ចម្លើយ ហែម មឿន ចម្លើយ ៦០ ដល់៦១ ឯកសារ **D118/222** កំណត់ហេតុស្តាប់ចម្លើយ ហែម មឿន ចម្លើយ ១៤ ឯកសារ **D219/64** កំណត់ហេតុស្តាប់ចម្លើយ ពៅ គឿន ចម្លើយ ២៨ ដល់២៩) ៣៨៤ (*ដកស្រង់* ឯកសារ **D118/136** កំណត់ហេតុស្តាប់ចម្លើយ ឈាន ប៊ាា ចម្លើយ ១៣ ឯកសារ **D118/271** កំណត់ហេតុស្តាប់ចម្លើយ ឈាន ប៊ាា ចម្លើយ ២៤ ដល់២៥ ឯកសារ **D118/108** កំណត់ហេតុស្តាប់ចម្លើយ លឹម ទីម ចម្លើយ ១៧)។ សូមមើលផងដែរ ឯកសារ **D219/917** កំណត់ហេតុស្តាប់ចម្លើយ ដៃ ទូច ចម្លើយ ១១, ១៣, ១៥។ ឯកសារ **D219/34** កំណត់ហេតុស្តាប់ចម្លើយ អ៊ុល ហឿន ចម្លើយ ៤៣។ ឯកសារ **D105/4** កំណត់ហេតុស្តាប់ចម្លើយ ហ៊ុយ គ្រឹម ចម្លើយ ២០។ <u>ក្នុងការអនុវត្តជាក់ស្តែង</u>៖សូមមើល *ឧទាហរណ៍* ឯកសារ D**382** ដីកាបញ្ជូនរឿងទៅជំនុំជម្រះ កថាខណ្ឌ ៣៨០ (*ដកស្រង់* ឯកសារ **D219/974.1.2.** ប្រតិចារឹកសវនាការ ថ្ងៃទី៥ ខែកញ្ញា ឆ្នាំ២០១៦ (ណុប ងឹម) ទំព័រ ៤៦ ជួរ ៧ ដល់ ១០ ឯកសារ **D118/285** កំណត់ហេតុស្តាប់ចម្លើយណុប ងឹម ចម្លើយ ៥៥ ដល់៥៦។ សូមមើលផងដែរ ឯកសារ **D219/298** កំណត់ហេតុស្តាប់ចម្លើយ ណុប ងឹម ចម្លើយ ១៣ ដល់១៤។ ឯកសារ **D219/835** កំណត់ហេតុស្តាប់ចម្លើយ ណុប ងឹម ចម្លើយ ៨៥, ៩០, ៩៥។ *ផ្ទុយពី* ឯកសារ D**382/22** បណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ កថាខណ្ឌ ២០៩ ដល់២១០។

406 សូមមើល *ឧទាហរណ៍* ឯកសារ D**382** ដីកាបញ្ជូនរឿងទៅជំនុំជម្រះ ជើងទំព័រ ១០០៥, ១០១០ (*ដកស្រង់ ផងដែរ* ឯកសារ **D118/86** កំណត់ហេតុស្តាប់ចម្លើយ ញឹក លី ចម្លើយ ៤, ១៨ ដល់២១)។ ឯកសារ **D219/298** កំណត់ហេតុស្តាប់ចម្លើយ ណុប ងឹម ចម្លើយ ១៣ ដល់១៤។ ឯកសារ **D219/835** កំណត់ហេតុស្តាប់ចម្លើយ ណុប ងឹម ចម្លើយ ៨៥, ៩០, ៩៥។ ឯកសារ **D219/917** កំណត់ហេតុស្តាប់ចម្លើយ ដៃ ទូច ចម្លើយ ១១, ១៣, ១៥។ ឯកសារ **D219/34** កំណត់ហេតុស្តាប់ចម្លើយ អ៊ុល ហឿន ចម្លើយ ៤៣។ ឯកសារ **D219/117** កំណត់ហេតុស្តាប់ចម្លើយ តុប សឹង ចម្លើយ ៧៨ ដល់៧៩។ ឯកសារ **D123/2/1.1a** កិច្ចសម្ភាសន៍ជាមួយ តុប សឹង ដោយមជ្ឈមណ្ឌលឯកសារកម្ពុជា ERN 01069554។ ឯកសារ **D105/4** កំណត់ហេតុស្តាប់

## ៨. យឹម ទិត្យ មិនបានបង្ហាញកំហុសណាមួយ ដែលអាចពិនិត្យឡើងវិញបាន នៅក្នុងការសម្រេចថា គាត់ប្រហែលជាបានចូលរួមយ៉ាងសំខាន់ក្នុងការអនុវត្តគោលនយោបាយបក្សកុម្មុយនីស្តកម្ពុជា នៅភូមិភាគពាយ័ព្យ (សហឧក្រិដ្ឋកម្មរួម ក)

130. យឹម ទិត្យ មិនបានបង្ហាញថាតើ ការសម្រេចរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ដែលថា យឹម ទិត្យ ប្រហែលជាបានចូលរួមចំណែកយ៉ាងសំខាន់ដល់សហឧក្រិដ្ឋកម្មរួម ក[407] គឺជាការរំលោភបំពានទៅលើឆន្ទានុសិទ្ធិ ឬជាកំហុសអង្គហេតុ ឬកំហុសអង្គច្បាប់ ដែលអាចពិនិត្យឡើងវិញបាន[408]ទេ។ យឹម ទិត្យ បានបំបែកដោយមិនត្រឹមត្រូវលើសហឧក្រិដ្ឋកម្មរួម ក ទៅជាគោលនយោបាយដ៏សំខាន់ និងបានលើកឡើងដោយប្រយោលថា ការចូលរួមចំណែកចាំបាច់ត្រូវតែធ្វើឡើងនៅក្នុងឧក្រិដ្ឋកម្មនីមួយៗ នៅក្នុងផែនការរួម ដែលផ្ទុយពីយុត្តាធិការរបស់ អ.វ.ត.ក[409]។

### <u>ក. យឹម ទិត្យ មិនបានបង្ហាញពីកំហុសណាមួយ ដែលអាចពិនិត្យឡើងវិញបាន ក្នុងការសម្រេចថា គាត់ប្រហែលជាបានចូលរួមក្នុងការបង្កើត និងគ្រប់គ្រងសហករណ៍ និងការដ្ឋាន</u>

131. យឹម ទិត្យ មិនបានប៉ះពាល់ដល់ការសម្រេចរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ដែលថា យឹម ទិត្យ ប្រហែលជាបានចូលរួមចំណែកយ៉ាងសំខាន់ចំពោះសហឧក្រិដ្ឋកម្មរួម ក តាមរយៈការចូលរួមរបស់គាត់នៅក្នុងការបង្កើត និងគ្រប់គ្រងសហករណ៍ និងការដ្ឋាន។

---

ចម្លើយ ហ៊ុយ គ្រឹម ចម្លើយ ២០។ ឯកសារ **D118/75** កំណត់ហេតុស្តាប់ចម្លើយ ហ៊ុយ គ្រឹម ចម្លើយ ២៥។ ឯកសារ **D219/515** កំណត់ហេតុស្តាប់ចម្លើយ ឆឺន ឈួយ ចម្លើយ ៣០, ៤៧។ ឯកសារ **D1.3.11.53** កិច្ចសម្ភាសន៍រវាង តេន ជឹម ជាមួយ SOAS, ERN 00217861។

[407] ឯកសារ D**382** ដីកាបញ្ជូនរឿងទៅជំនុំជម្រះ កថាខណ្ឌ ១០១៦i។

[408] *ផ្ទុយពី* ឯកសារ D**382/22** បណ្ដឹងឧទ្ធរណ៍របស់ យឹម ទិត្យ កថាខណ្ឌ ២២២ ដល់២៤៣ (មូលដ្ឋានរង ៥.៣.១)។ សូមមើល សារណាបឋម កថាខណ្ឌ ១៧, ២០, ២២ (បទដ្ឋាននៃការពិនិត្យ)។

[409] សូមមើល*ឧទាហរណ៍* សំណុំរឿង ០០២ ឯកសារ **D97/15/9** សាលដីការបស់អង្គបុរេជំនុំជម្រះលើសហឧក្រិដ្ឋកម្មរួម កថាខណ្ឌ ៣៨។ សំណុំរឿង ០០១ ឯកសារ **E188** សាលក្រមអង្គជំនុំជម្រះសាលាដំបូងលើសំណុំរឿង ឌុច កថាខណ្ឌ ៥០៨។ សំណុំរឿង ០០២ ឯកសារ **E313** សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង សំណុំរឿង ០០២/០១ កថាខណ្ឌ ៦៩៣។ ឯកសារ D**382** ដីកាបញ្ជូនរឿងទៅជំនុំជម្រះ ជើងទំព័រ ២៦៧។ សាលដីកាលើរឿងក្តី *Brđanin* កថាខណ្ឌ ៤២៧។ សាលដីកាលើរឿងក្តី *Popović* កថាខណ្ឌ ១៣៧៨។ សាលដីកាលើរឿងក្តី *Simba* កថាខណ្ឌ ២៥០។ សាលដីកាលើរឿងក្តី *Sesay* កថាខណ្ឌ ៦១១, ១០៣៤។

132. <u>ការត្រួតពិនិត្យ៖</u> ប្រសិនបើសម្រេចថាអាចទទួលយកបាន[410] យឹម ទិត្យ បានជំទាស់ដោយមិនត្រឹមត្រូវចំពោះសហចៅក្រមស៊ើបអង្កេតអន្តរជាតិ ដែលបានពឹងផ្អែកទៅលើភ័ស្តុតាងនៃអំពើរបស់ យឹម ទិត្យ នៅក្នុងភូមិភាគពាយ័ព្យ នៅមុនពាក់កណ្ដាលឆ្នាំ ១៩៧៧ និងនៅការដ្ឋានកំពឹងពួយ[411]។ យឹម ទិត្យ មើលរំលងថា ការស៊ើបអង្កេតក្នុងសំណុំរឿង ០០៤ ទៅលើការចោទប្រកាន់ដែលបានទទួលយក មិនកម្រិតកំណត់តាមពេលវេលា នៅក្នុងភូមិភាគពាយ័ព្យ[412] ហើយមិនបានពិចារណាថា ភ័ស្តុតាងទាក់ទងនឹងកំពឹងពួយ ពាក់ព័ន្ធជាមួយនឹងអង្គហេតុដែលស្ថិតក្នុងវិសាលភាពនៃសំណុំរឿង ០០៤ ហើយមិនមែនជាមូលដ្ឋាននៃការចោទប្រកាន់ យឹម ទិត្យ បញ្ជូនរឿងទៅជំនុំជម្រះទេ[413]។

133. លើសពីនេះទៀត យឹម ទិត្យ មានកំហុសដោយលើកឡើងថា នៅរាល់ពេលមានការចោទប្រកាន់ថាគាត់បានចុះត្រួតពិនិត្យការដ្ឋាន ចាំបាច់ត្រូវតែមានសាក្សីលើសពីម្នាក់ ដែលបានឃើញគាត់នៅការដ្ឋាន ក្នុងឱកាសនោះ[414]។ ទោះជាយ៉ាងណាក៏ដោយ យឹម ទិត្យ កំណត់ប្រភេទភ័ស្តុតាងរបស់សាក្សីដោយមិនត្រឹមត្រូវ ទាក់ទងនឹងវត្តមានរបស់គាត់ នៅការដ្ឋានទំនប់កង្ហត។ ឧទាហរណ៍[415] (១) សោម វណ្ណា បានឃើញ យឹម ទិត្យ ឆ្លងកាត់ផ្នែកនៃការដ្ឋានទំនប់កង្ហត ដែល សោម វណ្ណា ធ្វើ

[410] ទទ្បីករណ៍នេះ គឺមិនអាចទទួលយកបានទេ ដោយសារតែវាបង្កើតបានជា ការជំទាស់ទៅលើទម្រង់ នៃដីកាបញ្ជូនរឿង ទៅជំនុំជម្រះ។ សូមមើល កថាខណ្ឌ ៥៧ ដល់៦០ (ផ្នែក III.គ)។

[411] *ផ្ទុយពី* ឯកសារ D382/22 បណ្ដឹងឧទ្ធរណ៍របស់ យឹម ទិត្យ កថាខណ្ឌ ២២២, ២២៣ (សៅ ជាប់) ២២៤។

[412] សូមមើល កថាខណ្ឌ ៥៧ ដល់៦០ (ផ្នែក III.គ)។

[413] សម្រាប់ការបង្ហាញពី ឧទាហរណ៍ប្រហែលគ្នានៃទស្សនៈនេះ សូមមើល*ឧទាហរណ៍* វិធាន ៦៦ ស្ទួន(៥) នៃវិធានផ្ទៃក្នុង ។ សំណុំរឿង ០០២ ឯកសារ **F36** សំណុំរឿង ០០២/០១ សាលដីកាលើរឿងក្ដី កថាខណ្ឌ ៩០៨ ដល់៩០៩។ អង្គហេតុទាក់ទងនឹងការចូលរួមចំណែករបស់ យឹម ទិត្យ ក្នុងការបង្កើត និងគ្រប់គ្រង ទៅលើសហករណ៍ និងការដ្ឋាន ស្ថិតក្នុងវិសាលភាពនៃសំណុំរឿង ០០៤។ សូមមើល ឯកសារ **D65** ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែមស្ដីពីតំបន់១ និងខ្មែរក្រោម កថាខណ្ឌ ២១, ២៣។ ឯកសារ **D1** ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរលើកទីបី កថាខណ្ឌ ៧, ១១។ យឹម ទិត្យ មិនត្រូវបានចោទប្រកាន់បញ្ជូនរឿងទៅជំនុំជម្រះ ពីបទឧក្រិដ្ឋកម្មណាមួយ នៅការដ្ឋានកំពឹងពួយទេ។*ផ្ទុយពី* ឯកសារ D382/22 បណ្ដឹងឧទ្ធរណ៍របស់ យឹម ទិត្យ កថាខណ្ឌ ២២៤។

[414] សូមមើល សារណាបឋម កថាខណ្ឌ ១៤ (សេរីភាពនៃភស្តុតាង)។ *ផ្ទុយពី* ឯកសារ D382/22 បណ្ដឹងឧទ្ធរណ៍របស់ យឹម ទិត្យ កថាខណ្ឌ ២២៣ ដល់២២៤។

[415] សូមមើលផងដែរ ឯកសារ **D219/430** កំណត់ហេតុស្ដាប់ចម្លើយ ឈឿង ប៊ុន ចម្លើយ ១២១, ១២០។ ដូចខាងលើ ជើងទំព័រ ៣១៦, ៣២០ (ផ្នែក III.ង.៤)។ *ផ្ទុយពី* ឯកសារ D382/22 បណ្ដឹងឧទ្ធរណ៍របស់ យឹម ទិត្យ កថាខណ្ឌ ២២៣ (ឈឿង ប៊ុន) ជើងទំព័រ ៦៥៦។

ការ ដើម្បីទៅកាន់ផ្នែកមួយទៀតនៃការដ្ឋាន ហើយ សោម វណ្ណា បានពិភាក្សាអំពីផលប៉ះពាល់នៃវត្តមានរបស់ យឹម ទិត្យ មកលើរូបគាត់ និងពលករដទៃទៀត ហើយគាត់បានចូលរួមក្នុងការប្រជុំមួយជាមួយ យឹម ទិត្យ និងប្រធានការដ្ឋាន[416] (២) សៅ ជាប់ ដែលបានចូលរួមការប្រជុំជាមួយ យឹម ទិត្យ នៅទំនប់កង្អួត បានបញ្ជាក់យ៉ាងច្បាស់ថា "តាទិត្យ មួយជាប់តាម៉ុក កាលមុនខ្ញុំដើរតាម" ហើយបានឃើញដោយផ្ទាល់ថា យឹម ទិត្យ គឺ នៅភូមិភាគពាយ័ព្យ មុនពេលកម្មាភិបាលភូមិភាគនិរតីមកដល់[417]។

134. យឹម ទិត្យ ក៏បានធ្វើការសន្និដ្ឋានដោយគ្មានមូលដ្ឋានអំពីភស្តុតាងដែលគាត់អះអាងថា "ផ្ទុយដោយផ្ទាល់" ជាមួយនឹងសហចៅក្រមស៊ើបអង្កេតអន្តរជាតិដែលពឹងផ្អែកទៅលើ ហ៊ុយ ក្រឹម ទាក់ទងនឹងការចុះពិនិត្យរបស់ យឹម ទិត្យ ទៅកាន់ការដ្ឋានផ្សេងគ្នាជាច្រើន ដូចជា កំពីងពួយ។ ឧទាហរណ៍ យឹម ទិត្យ មានកំហុសដោយបានលើកឡើងថា ដោយសារតែ ធាម របៀប មិនដែលឃើញ យឹម ទិត្យ នៅកំពីងពួយ ចំណុចនេះបញ្ជាក់ថា យឹម ទិត្យ មិនដែលនៅការដ្ឋានទេ[418]។ ប្រហែលគ្នានេះដែរ ការពឹងផ្អែកដោយមិនត្រឹមត្រូវរបស់ យឹម ទិត្យ ទៅលើការត្រួតពិនិត្យដោយមិនលម្អិតរបស់គាត់ ចំពោះទស្សនាវដ្ដីរបស់បក្សកុម្មុយនីស្តកម្ពុជា មិនអាចបង្ហាញថា ហ៊ុយ ក្រឹម មិនដែលបានឃើញអត្ថបទរបស់ទស្សនាវដ្ដីកម្ពុជាប្រជាធិបតេយ្យ អំពីការងាររបស់ យឹម ទិត្យ ឡើយ[419]។

135. <u>ការប្រជុំ និងវគ្គរៀនសូត្រ</u>៖ ការកំណត់អត្តសញ្ញាដោយមិនត្រឹមត្រូវរបស់ យឹម ទិត្យ ទៅលើ "ភស្តុតាងដោះបន្ទុក និងភស្តុតាងផ្ទុយ" ផ្អែកទៅលើការខកខានរបស់គាត់ក្នុងការវាយតម្លៃជារួមទៅលើភស្តុតាងដែលសហចៅក្រមស៊ើបអង្កេតអន្តរជាតិបានពឹងផ្អែកទៅលើ។ ឧទាហរណ៍ (១) លេខ ភីវ មិនច្បាស់អំពីតួនាទីរបស់ យឹម ទិត្យ និងតាប៉ែត នៅពេលដែលពួកគាត់ដឹកនាំការប្រជុំរួម

---

[416] ឯកសារ **D219/239** កំណត់ហេតុស្តាប់ចម្លើយ សោម វណ្ណា ចម្លើយ ២, ៦ ដល់៧, ១៣, ១០។ ឯកសារ **D219/46** កំណត់ហេតុស្តាប់ចម្លើយ សោម វណ្ណា ចម្លើយ ៤១ ដល់៤២, ៤៤, ៤៣, ៣៩ ដល់៤០។ *ផ្ទុយពី* ឯកសារ D382/**22** បណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ កថាខណ្ឌ ២២៣។

[417] ឯកសារ **D219/956** កំណត់ហេតុស្តាប់ចម្លើយ សៅ ជាប់ ចម្លើយ ១១។ ឯកសារ **D219/981** កំណត់ហេតុស្តាប់ចម្លើយសៅ ជាប់ ចម្លើយ ៤៨ (កំណត់សម្គាល់៖ ឯកសារ **D219/825.1.2** បញ្ជីឈ្មោះអ្នកទោសមន្ទីរសន្តិសុខស-២១ របស់ ក.ស.ច.ស លេខរៀង ៩១៣ ERN 01123359 ដែលបានបង្ហាញអំពីពេលវេលានៃការចាប់ខ្លួន តាវ៉ាញ)។ សូមមើលផងដែរ ឯកសារ **D219/956** កំណត់ហេតុស្តាប់ចម្លើយ សៅ ជាប់ ចម្លើយ ១៥, ៩។ *ផ្ទុយពី* ឯកសារ D382/**22** បណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ កថាខណ្ឌ ២២៣។

[418] *ផ្ទុយពី* ឯកសារ D382/**22** បណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ កថាខណ្ឌ ២២៥។

[419] *ផ្ទុយពី* ឯកសារ D382/**22** បណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ កថាខណ្ឌ ២២៥ ជើងទំព័រ ៦៦៩។

គ្នា ប៉ុន្តែក្រោយពេលចាប់ខ្លួន តាប៉ែត គាត់បានដឹងថា យឹម ទិត្យ ដឹកនាំការប្រជុំ ក្នុងនាមជាលេខាតំបន់១[420] (២) ទៀប ទិត្យ "ប្រហែល" មិនច្រឡំថា ឃើញ យឹម ទិត្យ ថាជា តាប៉ែតទេ នៅក្នុងកិច្ចប្រជុំមួយ នៅការដ្ឋានទំនប់កង្ហត ដោយសារតែហេតុការណ៍នេះកើតឡើងបន្ទាប់ពីតាវ៉ាញត្រូវបានចាប់ខ្លួននៅក្នុងខែមិថុនា ឆ្នាំ១៩៧៧ ប៉ុន្តែ នៅមុនពេលចាប់ខ្លួន តាយ៉ាន នៅក្នុងខែកញ្ញា ឆ្នាំ១៩៧៧[421] គឺនៅក្នុងអំឡុងពេលដែលសាក្សីដទៃទៀតក៏បានឃើញផងដែរថា យឹម ទិត្យ នៅក្នុងតំបន់ ១[422] ហើយ ទៀប ទិត្យ បញ្ជាក់ថា គាត់គ្រាន់តែឮអំពីតាប៉ែត ប៉ុន្តែមិនដែលឃើញគាត់ឡើយ[423]។

136. <u>ការអនុវត្តវិន័យតឹងតែង</u>៖ ផ្ទុយពីការអះអាងរបស់ យឹម ទិត្យ ការសម្រេចរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ដែលថា យឹម ទិត្យ ចូលរួមក្នុងការអនុវត្តវិន័យតឹងតែង ផ្អែកលើភ័ស្តុតាងច្រើនជាងភ័ស្តុតាងរបស់ សោម វណ្ណា[424]។ ទោះជាក្នុងករណីណាក៏ដោយ សោម វណ្ណា បានដឹងឮគ្រប់គ្រាន់អំពីវត្តមានរបស់ យឹម ទិត្យ នៅទំនប់កង្ហត ដូចដែលបានពិភាក្សានៅក្នុងកថាខណ្ឌ ១៣៣ ខាងលើ[425]។

---

420 ឯកសារ **D219/210** កំណត់ហេតុស្តាប់ចម្លើយ លេខ *ភីវ* ចម្លើយ ៤, ៦។ ឯកសារ **D382** ដីកាបញ្ជូនរឿងទៅជំនុំជម្រះ កថាខណ្ឌ ៣៦២។ ដូចខាងលើ ជើងទំព័រ ៣២០ (ផ្នែក III.ង.៤)។ សូមមើលផងដែរ ឯកសារ **D219/236** កំណត់ហេតុស្តាប់ចម្លើយ លេខ *ភីវ* ចម្លើយ ៤, ១៧។ *ផ្ទុយពី* ឯកសារ **D382/22** បណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ កថាខណ្ឌ ២២៧។

421 ទៀប ទិត្យ បានឃើញ យឹម ទិត្យ ជាមួយតាយ៉ាន និងតាព្រំ ក្រោយពេលចាប់ខ្លួនតាវ៉ាញ និងនៅមុនពេលតាយ៉ាន ត្រូវបានបញ្ជូនទៅមន្ទីរសន្តិសុខស-២១ នៅថ្ងៃទី១២ ខែកញ្ញា ឆ្នាំ១៩៧៧។ សូមមើល ឯកសារ **D219/464** កំណត់ហេតុស្តាប់ចម្លើយ ទៀប ទិត្យ ចម្លើយ ៣៣, ៣៥ ដល់៣៧ (ការប្រជុំក្រោយពេល តាវ៉ាញត្រូវបានចាប់ខ្លួន) ចម្លើយ ២៨, ៣៨ (តាយ៉ាន និងតាព្រំបានចូលរួមក្នុងការប្រជុំ)។ ឯកសារ **D219/825.1.2** បញ្ជីឈ្មោះអ្នកទោសមន្ទីរសន្តិសុខស-២១ របស់ ក.ស.ច.ស ERN 01152612 លេខរៀង ១១៦៦៧ (តាយ៉ាន) ERN 01152589 លេខរៀង ៩១៣ (តាវ៉ាញ)។ សូមមើលផងដែរ ឯកសារ **D219/825.1.2** បញ្ជីឈ្មោះអ្នកទោសមន្ទីរសន្តិសុខស-២១ របស់ ក.ស.ច.ស ERN 01152805 លេខរៀង ៦២៧៣ (តាព្រំ)។ *ផ្ទុយពី* ឯកសារ **D382/22** បណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ កថាខណ្ឌ ២២៧។

422 សូមមើល *ឧទាហរណ៍* ឯកសារ **D382** ដីកាបញ្ជូនរឿងទៅជំនុំជម្រះ កថាខណ្ឌ ៣៥៤, ៤១៣ ដែលមានការសម្រេចដែល យឹម ទិត្យ មិនបានជំទាស់ទេ។ *ផ្ទុយពី* ឯកសារ **D382/22** បណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ កថាខណ្ឌ ២២៧។

423 ឯកសារ **D219/464** ទៀប ទិត្យ កំណត់ហេតុស្តាប់ចម្លើយ ចម្លើយ ៥៤។

424 សូមមើល ឯកសារ **D382** ដីកាបញ្ជូនរឿងទៅជំនុំជម្រះ កថាខណ្ឌ ៤០៨។ *ផ្ទុយពី* ឯកសារ **D382/22** បណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ កថាខណ្ឌ ២២៨។

425 *ផ្ទុយពី* ឯកសារ **D382/22** បណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ កថាខណ្ឌ ២២៨។

<u>ខ. យឹម ទិត្យ មិនបានបង្ហាញអំពីកំហុសឆ្គងណាមួយ ដែលអាចពិនិត្យឡើងវិញបាន នៅក្នុងការសម្រេចថា គាត់ប្រហែលជាបានចូលរួមពាក់ព័ន្ធក្នុងការកំណត់គោលដៅខ្មាំងបក្សកុម្មុយនីស្តកម្ពុជា</u>

137. ទឡ្ហីករណ៍របស់ យឹម ទិត្យ ផ្តោតទៅលើការចូលរួមរបស់គាត់នៅក្នុងការរៀបចំការបោសសម្អាត នៅក្នុងភូមិភាគពាយ័ព្យ ដោយមិនបានពិភាក្សាទាល់តែសោះ អំពីបញ្ហាគន្លឹះ ដូចជាការសម្រេច ទាក់ទងនឹងការអនុវត្តគោលនយោបាយបក្សកុម្មុយនីស្តកម្ពុជារបស់គាត់ នៅក្នុងភូមិភាគ ដូចជា ការអប់រំ "សមាសភាពមិនល្អ" ការសម្លាប់ពួកគេ និង "ខ្មាំង" និងការកំណត់គោលដៅ ទៅលើក្រុមជាក់លាក់[426]។

138. ទោះជាក្នុងស្ថានភាពណាក៏ដោយ ការត្រួតពិនិត្យមួយផ្នែកតូចរបស់ យឹម ទិត្យ ទៅលើការសម្រេច លើអង្គហេតុស្តីពីការបោសសម្អាត បានមើលរំលងការពឹងផ្អែករបស់សហចៅក្រមស៊ើបអង្កេត អន្តរជាតិ ទៅលើភ័ស្តុតាងដែលថា គាត់បានទៅភូមិភាគជាមួយកងកម្លាំងរបស់គាត់ និង តាម៉ុក[427] ដើម្បីគ្រប់គ្រងភូមិភាគ[428]។ លើសពីនេះទៀត ការខ្វែងយោបល់របស់ យឹម ទិត្យ ជាមួយនឹងការ ពឹងផ្អែករបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ទៅលើភ័ស្តុតាងរបស់ ហួន ជឿម ពាក់ព័ន្ធនឹង ការចូលរួមរបស់ យឹម ទិត្យ នៅក្នុងការចាប់ខ្លួនសមាជិកគណៈកម្មាធិការ រោងចក្រស្កសរកំពង់

---

[426] សូមមើល ឯកសារ **D382** ដីកាបញ្ជូនរឿងទៅជំនុំជម្រះ កថាខណ្ឌ ១០១៦i (ការសម្រេចលើអង្គច្បាប់) ដែលផ្អែក លើកថាខណ្ឌ ៤១៣ ដល់៤២៦ (ការសម្រេចលើអង្គហេតុ ស្តីពីការចូលរួមចំណែករបស់ យឹម ទិត្យ ក្នុងសហឧក្រិដ្ឋកម្មរួម ក នៅភូមិភាគពាយ័ព្យ) ។ *ផ្ទុយពី* ឯកសារ **D382/22** បណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ កថាខណ្ឌ ២៣២ ដល់២៣៧។

[427] សូមមើល ជាឧទាហរណ៍ ឯកសារ **D382** ដីកាបញ្ជូនរឿងទៅជំនុំជម្រះ ជើងទំព័រ ៧៤៩ (*ដកស្រង់ ផងដែរ* ឯកសារ **D118/150** កំណត់ហេតុស្តាប់ចម្លើយ ហែម មឿន ចម្លើយ ៦០ ឯកសារ **D219/294** កំណត់ហេតុស្តាប់ចម្លើយ មូល អេង ចម្លើយ ៦៣) ៧៥២ (*ដកស្រង់ ផងដែរ* ឯកសារ **D118/106** កំណត់ហេតុស្តាប់ចម្លើយ ហួន ជឿម ចម្លើយ ១២) ៧៤៨ (*ដកស្រង់ ផងដែរ* ឯកសារ **D219/19** កំណត់ហេតុស្តាប់ចម្លើយស៊ូ លន ចម្លើយ ៧៥៥, ៧៥៩)។ *ផ្ទុយពី* ឯកសារ **D382/22** បណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ កថាខណ្ឌ ២៣២ ដល់២៣៥។

[428] សូមមើល *ឧទាហរណ៍* ឯកសារ **D382** ដីកាបញ្ជូនរឿងទៅជំនុំជម្រះ ជើងទំព័រ ៧៤៩ (*ដកស្រង់ ផងដែរ* ឯកសារ **D118/150** កំណត់ហេតុស្តាប់ចម្លើយ ហែម មឿន ចម្លើយ ៦០ ឯកសារ **D118/86** កំណត់ហេតុស្តាប់ចម្លើយ ញ៉ែក លី ចម្លើយ ៤, ២០ ដល់ ២១) ៧៤៨ (*ដកស្រង់ ផងដែរ* ឯកសារ **D219/627** កំណត់ហេតុស្តាប់ចម្លើយ ឡុច អេង ចម្លើយ ១២ ដល់១៤)។ សូមមើលផងដែរ ឯកសារ **D382** ដីកាបញ្ជូនរឿងទៅជំនុំជម្រះ ជើងទំព័រ ៧៤៩ (*ដកស្រង់ ផងដែរ* ឯកសារ **D118/77** កំណត់ហេតុស្តាប់ចម្លើយ ណាង នី ចម្លើយ ២៣ ឯកសារ **D219/64** កំណត់ហេតុស្តាប់ចម្លើយ ពៅ គឿន ចម្លើយ ២៧ ដល់២៩ ឯកសារ **D219/263** កំណត់ហេតុស្តាប់ចម្លើយ ឆាំ លុយ ចម្លើយ ១១៧ ឯកសារ **D219/294** កំណត់ហេតុស្តាប់ចម្លើយ មូល អេង ចម្លើយ ៦៣ ឯកសារ **D219/233** កំណត់ហេតុស្តាប់ចម្លើយ ឈាន ប៊ា ចម្លើយ ១០)។ *ផ្ទុយពី* ឯកសារ **D382/22** បណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ កថាខណ្ឌ ២៣២ ដល់២៣៥។

កុល ដែលក្រោយមកត្រូវបានជំនួសដោយ តាយ៉ាន[429] កម្មាភិបាលភូមិភាគនិរតី មិនបានលើកឡើង (១) ហួន ជឿម ធ្វើការនៅកងទ័ពភូមិភាគពាយ័ព្យ ពីពាក់កណ្ដាលឆ្នាំ ១៩៧៦ ដល់ពាក់កណ្ដាលឆ្នាំ ១៩៧៨ និងបានដឹងពីកងទ័ពភូមិភាគថា យឹម ទិត្យ "នាំកម្លាំងរបស់គាត់ដោយផ្ទាល់" ទៅរោងចក្រ[430] (២) ចម្លើយរបស់ ហួន ជឿម ទាក់ទងនឹងការតែងតាំង តាយ៉ាន ត្រូវបានគាំទ្រដោយសាក្សី ដែលធ្វើការនៅរោងចក្រ[431] និង (៣) មជ្ឈមណ្ឌលឯកសារកម្ពុជា មិនដែលបានសួរ ហួន ជឿម អំពីការដឹងឮជាក់លាក់របស់គាត់ ពី យឹម ទិត្យ ឬរោងចក្រស្ករសឡើយ[432]។

__គ. យឹម ទិត្យ មិនបានបង្ហាញពីកំហុសឆ្គងណាមួយ ដែលអាចពិនិត្យឡើងវិញបាន ក្នុងការសម្រេចដែលថា គាត់ប្រហែលជាបានចូលរួមក្នុងការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ__

139. យឹម ទិត្យ មិនបានពន្យល់ថាហេតុអ្វីទើបវត្តមានរបស់គាត់នៅមុនពិធីរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ និងការប្រព្រឹត្តិរបស់គាត់ នៅក្រោយពិធីនេះ មិនបានគាំទ្រដល់ការសម្រេចដែលថា យឹម ទិត្យ បានចូលរួមចំណែកយ៉ាងសំខាន់ក្នុងសហឧក្រិដ្ឋកម្មរួម ក[433]។ យឹម ទិត្យ មិនបានពិចារណាលើភ័ស្តុតាង និងការសម្រេចទាក់ទងនឹងពាក្យពេចន៍របស់គាត់ ជាមួយអ្នកដែលត្រូវបានបង្ខំឲ្យរៀបអាពាហ៍ពិពាហ៍ "ឲ្យចេះស្រឡាញ់គ្នា" និងការតាមដានរបស់គាត់ ថាតើមាននរណាដែលមិនព្រមរស់នៅជាមួយគ្នា[434]។ លើសពីនេះទៀត យឹម ទិត្យ មិនបានបង្ហាញថាតើ អង្គហេតុដែលថា ការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំបានកើតឡើងនៅក្នុងតំបន់របស់គាត់ ដោយរបៀបណា

---

[429] សូមមើល សារណាបឋម កថាខណ្ឌ ១៤ (សេរីភាពនៃភស្តុតាង)។ *ផ្ទុយពី* ឯកសារ **D382/22** បណ្ដឹងឧទ្ធរណ៍របស់ យឹម ទិត្យ កថាខណ្ឌ ២៣៨។

[430] ឯកសារ **D118/106** ហួន ជឿម កំណត់ហេតុស្ដាប់ចម្លើយ ចម្លើយ ២, ១២។ សាក្សីក៏មានទំនាក់ទំនងស្នាក់នៅ ជាមួយតំបន់ដែលជាទីតាំងរោងចក្រស្ករសផងដែរ សូមមើល ERN 00978329។ *ផ្ទុយពី* ឯកសារ **D382/22** បណ្ដឹងឧទ្ធរណ៍របស់ យឹម ទិត្យ កថាខណ្ឌ ២៣៨។

[431] សូមមើល ឯកសារ **D118/108** កំណត់ហេតុស្ដាប់ចម្លើយ លឹម ទីម ចម្លើយ ៥។ ឯកសារ **D219/88** កំណត់ហេតុ ស្ដាប់ចម្លើយ ប៉ុល ស៊ិត ចម្លើយ ១៦។ ឯកសារ **D219/157** កំណត់ហេតុស្ដាប់ចម្លើយ ខយ ឆួយ ចម្លើយ ១១។ ឯកសារ **D382** ដីកាបញ្ជូនរឿងទៅជំនុំជម្រះ ជើងទំព័រ ១៩៥៨។ *ផ្ទុយពី* ឯកសារ **D382/22** បណ្ដឹងឧទ្ធរណ៍របស់ យឹម ទិត្យ កថាខណ្ឌ ២៣៨។

[432] សូមមើល ឯកសារ **D123/1/1.3a** កិច្ចសម្ភាសន៍រវាង ហួន ជឿម ជាមួយមជ្ឈមណ្ឌលឯកសារកម្ពុជា។ *ផ្ទុយពី* ឯកសារ **D382/22** បណ្ដឹងឧទ្ធរណ៍របស់ យឹម ទិត្យ កថាខណ្ឌ ២៣៨។

[433] សូមមើល ឯកសារ **D382** ដីកាបញ្ជូនរឿងទៅជំនុំជម្រះ កថាខណ្ឌ ១១០ ដល់១១១, ៤២៧។ *ផ្ទុយពី* ឯកសារ **D382/22** បណ្ដឹងឧទ្ធរណ៍របស់ យឹម ទិត្យ កថាខណ្ឌ ២៤២។

[434] សូមមើល ឯកសារ **D382** ដីកាបញ្ជូនរឿងទៅជំនុំជម្រះ កថាខណ្ឌ ៤២៧។ សូមមើលផងដែរ ឯកសារ **D382** ដីកាបញ្ជូនរឿងទៅជំនុំជម្រះ កថាខណ្ឌ ៣៦៧ (បានទទួលរបាយការណ៍ ស្ដីពីអត្រាកំណើត)។

បន្ទាប់ពីគាត់បានក្លាយជា លេខាជាក់ស្តែង[435] និងថា គាត់បានចូលរួមដោយសកម្ម ដោយមិនបាន រារាំងអ្នក ដែលត្រូវបានបង្គំឲ្យរៀបការ មិនបានគាំទ្រដល់ការសម្រេចថាគាត់ បានចូលរួមចំណែក យ៉ាងសំខាន់ ចំពោះសហឧក្រិដ្ឋកម្មរួមទាំងស្រុងទេ។

140. ផ្ទុយពីការអះអាងរបស់ យឹម ទិត្យ សហចៅក្រមស៊ើបអង្កេតអន្តរជាតិបានពិភាក្សាអំពីធាតុផ្សំ អត្តនោម័តរបស់ យឹម ទិត្យ សម្រាប់ឧក្រិដ្ឋកម្មទាំងអស់ ដែលបានកើតឡើងពីការអនុវត្តសហ ឧក្រិដ្ឋកម្មរួម ក[436]។

## ៩. យឹម ទិត្យ មិនបានបង្ហាញកំហុសណាមួយ ដែលអាចពិនិត្យឡើងវិញបាន នៅក្នុងការសម្រេចថា គាត់ប្រហែលជាបានចូលរួមយ៉ាងសំខាន់ក្នុងអំពើប្រល័យពូជសាសន៍ខ្មែរក្រោម (សហឧក្រិដ្ឋកម្មរួម ខ)

141. ការបង្ហាញដោយមិនត្រឹមត្រូវរបស់ យឹម ទិត្យ ទៅលើការសម្រេច ដោយមិនគិតអំពីភ័ស្តុតាងដែល មិនបានជាប្រយោជន៍ ហើយនឹងពឹងផ្អែកទៅលើគោលជំហរគតិយុត្តិដែលខុសឆ្គង មិនបានកំណត់ ពីកំហុសអង្គច្បាប់ ឬអង្គហេតុណាមួយ ដែលអាចពិនិត្យឡើងវិញបាន ឬការរំលោភបំពានទៅ លើឆន្ទានុសិទ្ធិក្នុងការសន្និដ្ឋានរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ដែលថា គាត់ប្រហែលជា បាន ចូលរួមចំណែកយ៉ាងសំខាន់ក្នុងសហឧក្រិដ្ឋកម្មរួម ខ[437]។

142. យឹម ទិត្យ បានលើកទឡ្ហីករណ៍ដោយមិនត្រឹមត្រូវថា ការសម្រេចរបស់សហចៅក្រមស៊ើបអង្កេត អន្តរជាតិ "មិនមានខ្លឹមសារ បរិបទ និងកាលបរិច្ឆេទច្បាស់លាស់ទេ"[438]។ យឹម ទិត្យ បានដកស្រង់ ដោយច្បោលៗ ត្រឹមតែការសម្រេចខ្លះៗ ដែលបានធ្វើឡើងក្នុងដីកាសម្រេចបញ្ជូនរឿងទៅជំនុំ ជម្រះ ដោយមិនគិតអំពីការសម្រេចពាក់ព័ន្ធដទៃទៀត[439]។ ប៉ុន្តែ សូម្បីតែក្នុងការដកស្រង់ច្បោលៗ

[435] សូមមើល ឯកសារ D382 ដីកាបញ្ជូនរឿងទៅជំនុំជម្រះ កថាខណ្ឌ ៩៨០។

[436] សូមមើល ឯកសារ D382 ដីកាបញ្ជូនរឿងទៅជំនុំជម្រះ កថាខណ្ឌ ១០៤០។ ចេតនាអាចទាញចេញពីការដឹងឮរបស់ បុគ្គលម្នាក់ រួមជាមួយការបន្តចូលរួម នៅក្នុងឧក្រិដ្ឋកម្ម។ សូមមើល ឯកសារ D382 ដីកាបញ្ជូនរឿងទៅជំនុំជម្រះ កថាខណ្ឌ ១០១៩, ១០២១ ដល់១០២២, ១០២៤។ សាលដីកាលើរឿងក្តី *Prlić* កថាខណ្ឌ ១៨០០, ១៩៧០, ២០១២, ២០៧៨។ សាលដីកា លើរឿងក្តី *Popović* កថាខណ្ឌ ១៣៦៩, ១៦៥២។ សាលដីកាលើរឿងក្តី *Đorđević* កថាខណ្ឌ ៥១២។ សាលដីកាលើរឿងក្តី *Krajišnik* កថាខណ្ឌ ២០២, ៦៩៧។ *ផ្ទុយពី* ឯកសារ D382/22 បណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ កថាខណ្ឌ ២៣០, ២៣៩, ២៤១។

[437] ឯកសារ D382/22 បណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ កថាខណ្ឌ ២៤៤ ដល់២៥០។

[438] ឯកសារ D382/22 បណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ កថាខណ្ឌ ២៤៧។

[439] ឯកសារ D382/22 បណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ កថាខណ្ឌ ២៤៦។

នោះក្តី ក៏ការកំណត់ប្រភេទរបស់ យឹម ទិត្យ មានភាពមិនត្រឹមត្រូវដែរ។ ឧទាហរណ៍ សម្រាប់ការប្រព្រឹត្តិនៅក្នុងភូមិភាគនិរតី ដែលនាំឱ្យមានសហឧក្រិដ្ឋកម្មរួមនេះ សហចៅក្រមស៊ើបអង្កេតអន្តរជាតិបានសម្រេចថា យឹម ទិត្យ បានព្រមានអ្នកចូលរួមកិច្ចប្រជុំមួយនៅក្នុងស្រុកគិរីវង់ នៅពាក់កណ្តាលឆ្នាំ ១៩៧៥ ថា នរណាដែល "រត់ចូលយួន" គឺជាខ្មាំង ហើយគេនឹងសម្លាប់ចោល[440]។ ដោយមិនបានវាស់ស្ទង់បាន យឹម ទិត្យ បានលើកឡើងថា ការព្រមានថា អ្នកណាដែលចូលដៃជាមួយយួន នឹងត្រូវសម្លាប់ចោល មិនមែនជាការ "គំរាមកំហែង" ទេ[441]។ សហចៅក្រមស៊ើបអង្កេតអន្តរជាតិក៏បានសម្រេចថា យឹម ទិត្យ និងកម្មាភិបាលតំបន់ ១៣ ដទៃទៀត បានចូលរួមកិច្ចប្រជុំរយៈពេល ១០ ថ្ងៃ នៅចុងឆ្នាំ១៩៧៦ នៅស្រុកអង្គរជ័យ ដែលនៅក្នុងការប្រជុំនោះ វៀតណាម និងអ្នកដែលមានសាច់ញាតិមកពីកម្ពុជាក្រោម ត្រូវបានចាត់ទុកថាជាខ្មាំង[442]។ លើសពីនេះទៀត សហចៅក្រមស៊ើបអង្កេតអន្តរជាតិបានសម្រេចថា នៅក្នុងការប្រជុំជាញឹកញាប់នៅចុងឆ្នាំ១៩៧៧ ឬដើមឆ្នាំ១៩៧៨ នៅស្រុកគិរីវង់ ដែលចូលរួមដោយមេឃុំ និងមេស្រុក យឹម ទិត្យ បានលើកយោងទៅរក "យួនខ្មែរ" នៅពេលពិភាក្សាអំពីបញ្ហាសន្តិសុខផ្ទៃក្នុង និងបានលើកឡើងថា វៀតណាមបានជ្រៀតចូល ព្រមទាំងធ្វើជាគិញនៅគ្រប់កម្រិតទាំងអស់នៃបក្សកុម្មុយនីស្តកម្ពុជា ហើយបានអំពាវនាវដល់អ្នកចូលរួមឱ្យរាយការណ៍ពីបុគ្គលបែបនេះទៅថ្នាក់លើ[443]។

143. ដូចគ្នានេះដែរ ពាក់ព័ន្ធជាមួយនឹងការប្រព្រឹត្តិនៅក្នុងភូមិភាគពាយ័ព្យ ដែលរួមចំណែកដល់ សហឧក្រិដ្ឋកម្មរួមនេះ ការអះអាងរបស់ យឹម ទិត្យ មិនបានទទួលជោគជ័យលើការសម្រេចរបស់ដីកាបញ្ជូនរឿងទៅជំនុំជម្រះទេ។ ឧទាហរណ៍ សហចៅក្រមស៊ើបអង្កេតអន្តរជាតិបានសម្រេចថា នៅទីតាំងមួយចំនួនក្នុងតំបន់១ ចាប់ពីដើមឆ្នាំ ១៩៧៧ រហូតដល់យ៉ាងហោចណាស់ ពាក់កណ្តាលឆ្នាំ ១៩៧៨ យឹម ទិត្យ បានថ្លែងនៅក្នុងការប្រជុំ ដែលចូលរួមដោយកម្មាភិបាល យោធា និងស៊ីវិល អំពីថាតើ វៀតណាមចង់លេបកម្ពុជាដោយរបៀបណា ដោយលើកយោងទៅរកកម្ពុជាក្រោម ធ្វើ

---

[440] ឯកសារ D382 ដីកាបញ្ជូនរឿងទៅជំនុំជម្រះ កថាខណ្ឌ ៣៨៨ *ដកស្រង់* ឯកសារ **D219/524** Nheb Noem កំណត់ហេតុស្តាប់ចម្លើយ ញេប នឹម ចម្លើយ ២០ ដល់២១, ៣៦, ៣៩។

[441] ឯកសារ D382/22 បណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ កថាខណ្ឌ ២៤៦។

[442] ឯកសារ D382 ដីកាបញ្ជូនរឿងទៅជំនុំជម្រះ កថាខណ្ឌ ៣៨៩ *ដកស្រង់* ឯកសារ **D219/488** កំណត់ហេតុស្តាប់ចម្លើយ ម៉ឹង វេត ចម្លើយ ៤៥ ដល់៤៨, ៦៤ ដល់៦៥។

[443] ឯកសារ D382 ដីកាបញ្ជូនរឿងទៅជំនុំជម្រះ កថាខណ្ឌ ៣៩០ *ដកស្រង់* ឯកសារ **D219/406** កំណត់ហេតុស្តាប់ចម្លើយ យូ ភ្នំ ចម្លើយ ១០, ១៧៥ ដល់១៧៩, ១១៧, ១៨៤ ដល់១៨៦, ១៩១ ដល់១៩៦។

ជាឧទាហរណ៍[444]។ សហចៅក្រមស៊ើបអង្កេតអន្តរជាតិបានសម្រេចបន្ថែមទៀតថា នៅក្នុងកិច្ចប្រជុំជាក់លាក់មួយនៅទំនប់កង្កួត មុនខែសីហា ឆ្នាំ១៩៧៨ ដែលមានមនុស្សចូលរួម ៧០០ ទៅ ៨០០ នាក់ រួមមានទាំងប្រធានស្រុក និងឃុំ និងប្រជាជនទូទៅនោះ យឹម ទិត្យ បានបញ្ជាក់ថា យួន និង "ខ្មាំងផ្ទៃក្នុង" ដទៃទៀត បានលាក់បំពួនក្នុងចំណោមប្រជាជន ហើយថា អ្នកចូលរួមត្រូវត្រួតពិនិត្យ និងរាយការណ៍អំពីខ្មាំងបែបនេះ ដើម្បីឲ្យ "អង្គការ" អាចសម្លាប់ពួកគេ[445]។ យឹម ទិត្យ បានដឹកនាំការប្រជុំមួយ នៅក្នុងឆ្នាំ១៩៧៨ ដើម្បីពិភាក្សាអំពី "ខ្មាំងយួន" ហើយគាត់បានបញ្ជាក់ថា "សម្លាប់អ្នកដែលអាចនិយាយភាសាវៀតណាម ឬអ្នកដែលជាប់ខ្សែយួន"[446]។

144. ការអះអាងរបស់ យឹម ទិត្យ ដែលថា ភ័ស្តុតាងដែលត្រូវបានពឹងផ្អែកលើ នៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ មិនបានបង្ហាញពីការចូលរួមចំណែកយ៉ាងសំខាន់ ក្នុងអំពើប្រល័យពូជសាសន៍ខ្មែរក្រោម នៅក្នុងបរិបទនៃជម្លោះប្រដាប់អាវុធជាមួយវៀតណាមនោះ មិនមានមូលដ្ឋានឡើយ[447]។ យឹម ទិត្យ មិនបានផ្តល់ការគាំទ្រសម្រាប់ការលើកឡើងដោយប្រយោលថា ខ្មែរក្រោមគឺជាគោលដៅរបស់យោធា។ លើសពីនេះទៀត ការសម្រេចរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិអំពីការសម្លាប់ខ្មែរក្រោមនៅក្នុងតំបន់ ដែលស្ថិតក្រោមសិទ្ធិអំណាចរបស់ យឹម ទិត្យ បានបង្ហាញម្តងហើយម្តងទៀត ពីជនរងគ្រោះជាជនស៊ីវិល រួមទាំងកុមារផង[448]។ គួរឲ្យកត់សម្គាល់នោះ ការសម្រេចប្រហែលគ្នានេះ ត្រូវបានធ្វើឡើងនៅក្នុងដីកាសម្រេចលើកលែងការចោទប្រកាន់[449]។

---

[444] ឯកសារ **D382** ដីកាបញ្ជូនរឿងទៅជំនុំជម្រះ កថាខណ្ឌ ៣៩៣ *ដកស្រង់* ឯកសារ **D219/236** កំណត់ហេតុស្តាប់ចម្លើយ លេខ ភីវ ចម្លើយ ១៩ ដល់២០។ ឯកសារ **D219/763** កំណត់ហេតុស្តាប់ចម្លើយ សៅ ជាប់ ចម្លើយ ១៣៣ ដល់១៣៥។ ឯកសារ **D219/368** កំណត់ហេតុស្តាប់ចម្លើយ ឈឿង ប៊ាន ចម្លើយ ៨៧ ដល់៩០។ ឯកសារ **D219/533** កំណត់ហេតុស្តាប់ចម្លើយ ឈឿង ប៊ាន ចម្លើយ ១១ ដល់១៤។

[445] ឯកសារ **D382** ដីកាបញ្ជូនរឿងទៅជំនុំជម្រះ កថាខណ្ឌ ៣៩៣ *ដកស្រង់* ឯកសារ **D219/285** កំណត់ហេតុស្តាប់ចម្លើយ រី ផាន់ ចម្លើយ ៣ ដល់៥។

[446] ឯកសារ **D382** ដីកាបញ្ជូនរឿងទៅជំនុំជម្រះ កថាខណ្ឌ ៣៩៧ *ដកស្រង់* ឯកសារ **D219/953** Chhoeng Chhoeurt កំណត់ហេតុស្តាប់ចម្លើយ ឈឹង ឈឿត ចម្លើយ ៧០ ដល់៧២, ៧៥, ៨២ ដល់៨៤។ សូមមើលផងដែរ ឯកសារ **D382** ដីកាបញ្ជូនរឿងទៅជំនុំជម្រះ កថាខណ្ឌ ៣៩៧ *ដកស្រង់* ឯកសារ **D118/77** កំណត់ហេតុស្តាប់ចម្លើយ ណាង នី ចម្លើយ ២៤, ២៩ ដល់៣០។

[447] ឯកសារ **D382/22** បណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ កថាខណ្ឌ ២៤៧។

[448] សូមមើល *ជាឧទាហរណ៍* ឯកសារ **D382** ដីកាបញ្ជូនរឿងទៅជំនុំជម្រះ កថាខណ្ឌ ៤៨៩ ដល់៤៩៣, ៥០៧, ៥២៣, ៥៣៣ ដល់៥៤៥, ៥៤៩ ដល់៥៥២, ៥៦០ ដល់៥៦១, ៥៧៥។

[449] សូមមើល ឯកសារ **D381** ដីកាសម្រេចលើកលែងចោទប្រកាន់ កថាខណ្ឌ ១៤៧, ១៦៤, ១៨៥ ដល់១៨៧, ៦៦៧ ដល់៦៦៩, ៦៨០ (សិទ្ធិ និងអំណាចរបស់ យឹម ទិត្យ) ២០៧, ២១២, ២១៩ ដល់២២០, ២៣៥, ២៥០, ២៥២ (ឧក្រិដ្ឋកម្មប្រឆាំងខ្មែរក្រោម

145. លើសពីនេះទៀត ការលើកឡើងរបស់ យឹម ទិត្យ ដែលថា សហចៅក្រមស៊ើបអង្កេតអន្តរជាតិមានកំហុសដោយមិនបានពន្យល់ថា តើសេចក្តីថ្លែងជាច្រើនរបស់ យឹម ទិត្យ ជាមួយកម្មាភិបាលស៊ីវិល និងយោធា នៅក្នុងភូមិភាគពាយ័ព្យ និងភូមិភាគនិរតី "នៅជិតទាំងពេលវេលា និងភូមិសាស្ត្រ ឬថាតើសេចក្តីថ្លែងទាំងនោះ ជំរុញឲ្យមានការសម្លាប់រង្គាល" បង្ហាញបានអំពីការយល់ខុសជាមូលដ្ឋានទៅលើច្បាប់ជាធរមាន[450]។ យុត្តិសាស្ត្ររបស់ អ.វ.ត.ក បានចែងថា "ការចូលរួមចំណែករបស់គាត់ ត្រូវតែសំខាន់ ប៉ុន្តែពុំមែនរហូតដល់ មិនអាចខ្វះបាននោះទេ"[451]។ ទោះជាក្នុងករណីណាក៏ដោយ នៅក្នុងបរិបទនៃរចនាសម្ព័ន្ធឋានានុក្រមរបស់បក្សកុម្មុយនីស្តកម្ពុជា និងវិធីសាស្ត្រដែលគោលនយោបាយ ត្រូវបានផ្សព្វផ្សាយទៅថ្នាក់ក្រោម ដោយអ្នកមានសិទ្ធិអំណាចដើម្បីឲ្យអនុវត្តនៅមូលដ្ឋាននោះ សេចក្តីថ្លែងបែបនេះ មានភាពពាក់ព័ន្ធច្បាស់លាស់ជាមួយនឹងការសម្លាប់ខ្មែរក្រោមដែលបានកើតឡើងហើយ។

146. លើសពីនេះទៀត ការអះអាងរបស់ យឹម ទិត្យ ដែលថា សហចៅក្រមស៊ើបអង្កេតអន្តរជាតិមិនបានពន្យល់ថា ការសម្រេចមួយណានៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ ទាក់ទងជាមួយនឹងការចូលរួមចំណែករបស់គាត់ក្នុងសហឧក្រិដ្ឋកម្មរួម និងការសម្រេចណាមួយទាក់ទងនឹងគោលនយោបាយរបស់បក្សកុម្មុយនីស្តកម្ពុជា ត្រូវបានបង្ហាញដោយមិនត្រឹមត្រូវ[452]។ ដីកាបញ្ជូនរឿងទៅជំនុំជម្រះបានរៀបរាប់លម្អិតថាតើ គោលនយោបាយរបស់បក្សកុម្មុយនីស្តកម្ពុជា "លុបបំបាត់ខ្មែរក្រោម" ដោយរបៀបណា[453] ឯសហឧក្រិដ្ឋកម្មរួម ខ "កម្ទេចក្រុមជាតិពន្ធុឲ្យផុតពូជ ខ្មែរក្រោម ឬយ៉ាងហោចណាស់ ក៏មួយផ្នែកធំនៃពួកគេ ដោយសារតែជាតិពន្ធុរបស់គេ"[454]។ ការចូលរួមចំណែកជាមួយសហឧក្រិដ្ឋកម្មរួម ខ ដូចគ្នានឹងការចូលរួមចំណែកជាមួយគោលនយោបាយរបស់បក្សកុម្មុយនីស្តកម្ពុជា ដែលដីកាបញ្ជូនរឿងទៅជំនុំជម្រះបញ្ជាក់ច្បាស់ថា "ចូលរួមចំណែកយ៉ាង

---

នៅភូមិភាគនិរតី) ១៣៥, ១៥៣ ដល់១៥៤, ២៥៩, ២៨៧, ៣១០, ៣២៨ ដល់៣២៩, ៣៤២ ដល់៣៤៣, ៣៥៨ ដល់៣៦០, ៣៦២, ៣៦៧ ដល់៣៦៨, ៣៧០, ៣៧៥ (ឧក្រិដ្ឋកម្មប្រឆាំងខ្មែរក្រោម នៅភូមិភាគពាយ័ព្យ)។

[450] ឯកសារ **D382/22** បណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ កថាខណ្ឌ ២៤៩។

[451] សំណុំរឿង ០០២**E465** សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង សំណុំរឿង ០០២/០២ កថាខណ្ឌ ៣៧១០ *ដកស្រង់ផងដែរ* សំណុំរឿង ០០២ ឯកសារ **F36** សាលដីកាលើសំណុំរឿង ០០២/០១ កថាខណ្ឌ ៩៨០។

[452] *ផ្ទុយពី* ឯកសារ **D382/22** បណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ កថាខណ្ឌ ២៤៦។

[453] ឯកសារ **D382** ដីកាបញ្ជូនរឿងទៅជំនុំជម្រះ កថាខណ្ឌ ២០៣។ សូមមើលផងដែរ កថាខណ្ឌ ១៩៦ ដល់២៧៥។

[454] ឯកសារ **D382** ដីកាបញ្ជូនរឿងទៅជំនុំជម្រះ កថាខណ្ឌ ១០០៨។ សូមមើលផងដែរ កថាខណ្ឌ ១០០៩ ដល់១០១២។

ច្រើនដល់គោលនយោបាយនានារបស់ ប.ក.ក ក្នុង [...] ការកម្ទេចខ្មែរក្រោម"[455]។ មិនមានមូលដ្ឋានសម្រាប់ការលើកឡើងថា ការទទួលខុសត្រូវរបស់ យឹម ទិត្យ អនុលោមតាមសហឧក្រិដ្ឋកម្មរួម ខ ផ្អែកលើពិរុទ្ធភាព ដោយសារការមានទំនាក់ទំនងជាមួយគ្នាឡើយ"[456]។

## ១០. យឹម ទិត្យ មិនបានបង្ហាញកំហុសណាមួយ ដែលអាចពិនិត្យឡើងវិញបាន នៅក្នុងការសម្រេចថា គាត់ប្រហែលជាបានចូលរួមយ៉ាងសំខាន់ក្នុងការធ្វើបាបនៅវត្តព្រះធាតុ (សហឧក្រិដ្ឋកម្មរួម ខ)

147. សហចៅក្រមស៊ើបអង្កេតអន្តរជាតិមិនបានទាញសន្និដ្ឋានថា "ការចូលរួមចំណែករបស់លោក យឹម ទិត្យ នៅក្នុងសហឧក្រិដ្ឋកម្មរួម ដោយសារតែការចោទអំពីសមាជិកភាពរបស់លោក យឹម ទិត្យ នៅក្នុងគណៈកម្មាធិការស្រុក"[457]ទេ។ ដីកាបញ្ជូនរឿងទៅជំនុំជម្រះមានភស្តុតាងអំពីសិទ្ធិអំណាចដែល យឹម ទិត្យ ប្រហែលមាន និងការចូលរួមពាក់ព័ន្ធនៅក្នុងឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តនៅវត្តព្រះធាតុ[458]។ ការដែល យឹម ទិត្យ បន្តមិនបានលើកឡើងដោយត្រឹមត្រូវអំពីខ្លឹមសារនៃចម្លើយរបស់សាក្សី មិនបានកំណត់ពីកំហុសអង្គច្បាប់ ឬកំហុសអង្គហេតុណាមួយ ឬការរំលោភបំពានទៅលើ ឆន្ទានុសិទ្ធិរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ក្នុងការសម្រេចថា យឹម ទិត្យ ប្រហែលជាបានចូលរួមចំណែកយ៉ាងសំខាន់ក្នុងសហឧក្រិដ្ឋកម្មរួម គ ទេ។

### <u>ក. យឹម ទិត្យ មិនបានបង្ហាញកំហុសឆ្គងណាមួយ ដែលអាចពិនិត្យឡើងវិញបាន ក្នុងការសម្រេចថា យឹម ទិត្យ ប្រហែលជាមួយទៅពិនិត្យវត្តព្រះធាតុជាទៀងទាត់</u>

148. ការដែល យឹម ទិត្យ មិនបានពិចារណាអំពីភស្តុតាងគន្លឹះ បានធ្វើឲ្យបរាជ័យដល់ការអះអាងរបស់គាត់ដែលថា សហចៅក្រមស៊ើបអង្កេតអន្តរជាតិមិនបានពិចារណាទៅលើភស្តុតាងទាំងស្រុងរបស់សាក្សី ដុក ចាន់, យូ ភ្នំ, ទន់ ស៊ួន, អោក ចន និង ហោ យ៉ន[459]។

---

[455] ឯកសារ **D382** ដីកាបញ្ជូនរឿងទៅជំនុំជម្រះ កថាខណ្ឌ ១០២២។ សូមមើលផងដែរ កថាខណ្ឌ ៣៨៦។

[456] *ផ្ទុយពី* ឯកសារ **D382/22** បណ្ដឹងឧទ្ធរណ៍របស់ យឹម ទិត្យ កថាខណ្ឌ ២៤៨។ មិនមានមូលដ្ឋានណាមួយ ក្នុងចំណោមមូលដ្ឋានដទៃទៀត នៃបណ្ដឹងឧទ្ធរណ៍ ដែល យឹម ទិត្យ បានយោងទៅក្នុងកថាខណ្ឌ ២៤៥ និង ២៥០ មានផលប៉ះពាល់ ឬមានការពាក់ព័ន្ធណាមួយជាមួយនឹងបញ្ហានៃការចូលរួមចំណែករបស់គាត់ ជាមួយសហឧក្រិដ្ឋកម្មរួមក្នុងការប្រព្រឹត្តិអំពើប្រល័យពូជសាសន៍ ប្រឆាំងខ្មែរក្រោម ដូច្នេះហើយមិនមានភាពពាក់ព័ន្ធទេ។

[457] *ផ្ទុយពី* ឯកសារ **D382/22** បណ្ដឹងឧទ្ធរណ៍របស់ យឹម ទិត្យ កថាខណ្ឌ ២៥២។

[458] ឯកសារ **D382** ដីកាបញ្ជូនរឿងទៅជំនុំជម្រះ កថាខណ្ឌ ៤៣៨ ដល់៤៦៩។

[459] ឯកសារ **D382/22** បណ្ដឹងឧទ្ធរណ៍របស់ យឹម ទិត្យ កថាខណ្ឌ ២៥៣។

149. យឹម ទិត្យ មិនបានពន្យល់ថា ការដែលគាត់ចោទប្រកាន់ពី "សក្ខីកម្មដែលផ្ទុយគ្នា" របស់ ដុក ចាន់ នោះគឺជាអ្វី[460]។ ដុក ចាន់ ធ្វើជាសន្តិសុខគុក នៅវត្តព្រះធាតុ ក្នុងឆ្នាំ១៩៧៥ ដូច្នេះហើយ គាត់បានដឹងអំពីអ្វីដែលបានកើតឡើងនៅមន្ទីរសន្តិសុខ។ ដុក ចាន់ បានប្រាប់អ្នកស៊ើបអង្កេតថា យឹម ទិត្យ ទទួលខុសត្រូវលើស្រុកគិរីវង់ក្នុងឆ្នាំ១៩៧៤ ហើយគាត់ត្រូវបានតម្លើងឋានៈទៅតំបន់ ១៣ នៅអំឡុងឆ្នាំ ១៩៧៦[461] ហើយថា ដុក ចាន់ បានចូលរួមក្នុងកិច្ចប្រជុំ សម្រាប់ប្រជាជនសាមញ្ញ នៅស្រុកគិរីវង់ ដែលក្នុងកិច្ចប្រជុំនោះ មានការប្រកាសអំពីតួនាទីរបស់ យឹម ទិត្យ[462] និងថា យឹម ទិត្យ ធ្លាប់ទៅពិនិត្យវត្តព្រះធាតុ "ទៀងទាត់"[463] ដើម្បីទៅជួបជាមួយប្រធានវត្តព្រះធាតុ[464] ព្រមទាំងពេលខ្លះ បានជួបពិភាក្សាជាមួយបុគ្គលិកវត្តព្រះធាតុ រួមទាំង ដុក ចាន់ ផងដែរ[465]។ ការកំណត់ប្រភេទនៃភ័ស្តុតាងរបស់ ដុក ចាន់ ដោយ យឹម ទិត្យ ថា "មិនមានភាពទាក់ទងតាមពេលវេលា" ដោយសារតែ ដុក ចាន់ បានបញ្ជាក់ថា គាត់ធ្វើការនៅវត្តព្រះធាតុ មួយរយៈនោះ មិនមានមូលដ្ឋានទេ[466]។ ដុក ចាន់ នៅតែស្ថិតនៅក្នុងតំបន់ ១៣ ក្រោយពេលធ្វើជាសន្តិសុខគុក នៅវត្តព្រះធាតុ ហើយបន្ទាប់មកគាត់បានត្រឡប់ ទៅស្រុកគិរីវង់វិញ[467] បានបង្ហាញពីការដឹងឮជាបន្តរបស់គាត់ អំពីរចនាសម្ព័ន្ធសិទ្ធិអំណាច នៅក្នុងតំបន់នោះ។

150. ប្រហែលគ្នានេះដែរ ការអះអាងថា ហោ យ៉ន ជាអ្នកទោសនៅវត្តព្រះធាតុ បានផ្តល់ភ័ស្តុតាងផ្ទុយអំពីចំនួនដងដែលគាត់បានឃើញ យឹម ទិត្យ នៅវត្តព្រះធាតុ មិនមែនជាការតំណាងពេញលេញសម្រាប់ភ័ស្តុតាងឡើយ[468]។ ហោ យ៉ន ហាក់ដូចជាបានញ៉ែកដាច់ពីគ្នានៅក្នុងចម្លើយរបស់គាត់ ទាក់ទងចំនួនដងដែលគាត់បានឃើញ យឹម ទិត្យ នៅវត្តព្រះធាតុ[469] ការដែលគាត់បានជួប យឹម

---

[460] ឯកសារ D382/22 បណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ កថាខណ្ឌ ២៥៣។

[461] ឯកសារ **D219/86** កំណត់ហេតុស្តាប់ចម្លើយ ដុក ចាន់ ចម្លើយ ៧។ សូមមើលផងដែរ ឯកសារ **D219/87** កំណត់ហេតុស្តាប់ចម្លើយ ដុក ចាន់ចម្លើយ ១៨។

[462] ឯកសារ **D219/87** កំណត់ហេតុស្តាប់ចម្លើយ ដុក ចាន់ ចម្លើយ ១៦ ដល់១៧។

[463] ឯកសារ **D219/86** កំណត់ហេតុស្តាប់ចម្លើយ ដុក ចាន់ ចម្លើយ ៨។ សូមមើលផងដែរ ចម្លើយ ៩

[464] ឯកសារ **D219/86** កំណត់ហេតុស្តាប់ចម្លើយ ដុក ចាន់ ចម្លើយ ៩។

[465] ឯកសារ **D219/86** កំណត់ហេតុស្តាប់ចម្លើយដុក ចាន់ ចម្លើយ ១០។

[466] ឯកសារ D382/22 បណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ កថាខណ្ឌ ២៥៣។

[467] ឯកសារ **D219/86** កំណត់ហេតុស្តាប់ចម្លើយ ដុក ចាន់ ចម្លើយ ២។

[468] ឯកសារ D382/22 បណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ កថាខណ្ឌ ២៥៣ ជើងទំព័រ ៧៧២។

[469] ឯកសារ **D105/6** កំណត់ហេតុស្តាប់ចម្លើយហោ យ៉ន ចម្លើយ ២២។

ទិត្យ នៅវត្តព្រះធាតុ[470] និងចំនួនដងដែលគាត់បានដឹងថា យឹម ទិត្យ នៅវត្តព្រះធាតុដើម្បីប្រមូលប្រមាត់[471]។ ទោះជាក្នុងករណីណាក៏ដោយ ការលើកឡើងរបស់ យឹម ទិត្យដែលថា "ជាអ្នកទោសម្នាក់" នៅវត្តព្រះធាតុ មិនអាចដឹងអំពីអត្តសញ្ញាណរបស់គាត់[472] ត្រូវបានជំទាស់ដោយ ហោ យ៉ន ដែលបានប្រាប់អ្នកស៊ើបអង្កេតថា យឹម ទិត្យ មានឈ្មោះល្បី[473] ហើយថា មានការប្រកាសនៅក្នុងការប្រជុំមួយ មុនពេលចុះពិនិត្យថា យឹម ទិត្យ នឹងមកវត្តព្រះធាតុ[474]។ ការដែលលើកឡើងថា ហោ យ៉ន មិនបានកំណត់អត្តសញ្ញាណ យឹម ទិត្យ នៅក្នុងរូបថត ដែលមជ្ឈមណ្ឌលឯកសារកម្ពុជាបានផ្តល់ជូន (ដែលមិនមានភ្ជាប់ក្នុងការសម្ភាសន៍ ដូច្នេះហើយមិនអាចផ្ទៀងផ្ទាត់បាន) មិនបានធ្វើឲ្យប៉ះពាល់ដល់ភ័ស្តុតាងរបស់គាត់ឡើយ ដោយសារតែសហចៅក្រមស៊ើបអង្កេតអន្តរជាតិមិនបានពឹងផ្អែកទៅលើការផ្ទៀងផ្ទាត់ដោយអត្តនោម័តទៅលើរូបរាងរបស់ យឹម ទិត្យ ទេ គឺសហចៅក្រមស៊ើបអង្កេតអន្តរជាតិពឹងផ្អែកទៅលើភ័ស្តុតាងទាំងមូល[475]។

151. យឹម ទិត្យ ក៏បានបង្ហាញដោយមិនត្រឹមត្រូវពីភ័ស្តុតាងរបស់ យូ ភ្នំ ដែលមិនអាចទៅជិតមន្ទីរសន្តិសុខ ថាមានន័យថា យូ ភ្នំ មិនដែលបានទៅវត្តព្រះធាតុ[476]។ យូ ភ្នំ បានលើកយោងយ៉ាងច្បាស់ទៅអគារឃុំឃាំងនៅក្នុងវត្តព្រះធាតុ មិនមែនទៅលើបរិវេណវត្តព្រះធាតុឡើយ[477] ដោយ យូ ភ្នំ បានប្រាប់អ្នកស៊ើបអង្កេតថា គាត់បានទៅពិនិត្យវត្តព្រះធាតុ ដើម្បីទៅជួប "បងប្រុសម្នាក់ឈ្មោះ

[470] ឯកសារ **D118/155** កំណត់ហេតុស្តាប់ចម្លើយ ហោ យ៉ន ចម្លើយ ៤៨។

[471] ឯកសារ **D219/55** កំណត់ហេតុស្តាប់ចម្លើយ ហោ យ៉ន ចម្លើយ ១០, ២០។ អ្នកស៊ើបអង្កេតបានរៀបរាប់ឡើងវិញ ដោយមិនត្រឹមត្រូវ នូវសំណួរចម្លើយពី ការស្តាប់ចម្លើយលើកមុន។ ប្រៀបធៀប ឯកសារ **D219/55** កំណត់ហេតុស្តាប់ចម្លើយ ហោ យ៉ន សំណួរ ២០ ជាមួយ ឯកសារ **D118/155** កំណត់ហេតុស្តាប់ចម្លើយ ហោ យ៉ន សំណួរ និងចម្លើយ ៤៨។

[472] ឯកសារ D382/22 បណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ កថាខណ្ឌ ២៥៣។

[473] ឯកសារ **D118/155** កំណត់ហេតុស្តាប់ចម្លើយ ហោ យ៉ន ចម្លើយ ១១៩។

[474] ឯកសារ **D118/155** កំណត់ហេតុស្តាប់ចម្លើយ ហោ យ៉ន ចម្លើយ ៤៧។ សូមមើលផងដែរ ឯកសារ **D219/55** កំណត់ហេតុស្តាប់ចម្លើយ ហោ យ៉ន ចម្លើយ ១២ ដល់១៧។ ឯកសារ **D118/155** កំណត់ហេតុស្តាប់ចម្លើយ ហោ យ៉ន សំណួរ និងចម្លើយ ១៣ ចម្លើយ ១៤។ ឯកសារ **D105/6** កំណត់ហេតុស្តាប់ចម្លើយ ហោ យ៉ន ចម្លើយ ១៣ ដល់១៦។

[475] *ផ្ទុយពី* ឯកសារ D382/22 បណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ កថាខណ្ឌ ២៥៣។ សូមមើល ឯកសារ **D105/6** កំណត់ហេតុស្តាប់ចម្លើយ ហោ យ៉ន ចម្លើយ ១៨ ដល់២០ និងប្រៀបធៀបជាមួយ ឯកសារ D381 ដីកាសម្រេចលើកលែងចោទប្រកាន់ កថាខណ្ឌ ១៨៨។

[476] ឯកសារ D382/22 បណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ កថាខណ្ឌ ២៥៣។

[477] ឯកសារ **D219/109** កំណត់ហេតុស្តាប់ចម្លើយ យូ ភ្នំ សំណួរ និងចម្លើយ ៩។ សូមមើលផងដែរ សំណួរ និងចម្លើយ ១២

ដុក ចាន់ ដែលជាអ្នកគ្រប់គ្រងអ្នកទោស" នៅទីនោះ[478]។ យឹម ទិត្យ បានព្យាយាមដោយបរាជ័យបន្ថែមទៀត ក្នុងការធ្វើឱ្យប៉ះពាល់ដល់ភ័ស្តុតាងរបស់ យូ ភ្នំ ដោយឆ្លើយដាក់ដោយខុសនូវភ័ស្តុតាងរបស់សាក្សីដទៃ ថាជារបស់ យូ ភ្នំ[479]។ ហេតុដូច្នេះ យឹម ទិត្យ មិនអាចធ្វើឱ្យប៉ះពាល់ដល់ភ័ស្តុតាងរបស់ យូ ភ្នំ ដែលថា គាត់បានឃើញ យឹម ទិត្យ "មកមើលមន្ទីរសន្តិសុខវត្តព្រះធាតុ ញឹកញាប់ដែរ"[480]។

152. ផ្ទុយពីការអះអាងរបស់ យឹម ទិត្យ ភ័ស្តុតាងរបស់ អោក ចន មិនបានយោងទៅលក្ខខណ្ឌទូទៅ នៅក្នុងរយៈពេលពីឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៩ ទេ[481]។ អោក ចន បានប្រាប់អ្នកស៊ើបអង្កេតថា គាត់បានឃើញ យឹម ទិត្យ ម្តង ឬពីរដង នៅពេលដែល អោក ចន ជាប់ឃុំឃាំងនៅវត្តព្រះធាតុ នៅក្នុងឆ្នាំ១៩៧៧[482]។ ការអះអាងរបស់ យឹម ទិត្យ ដែលថា ភ័ស្តុតាងរបស់ អោក ចន ដែលបានឃើញ យឹម ទិត្យ ត្រូវរងបញ្ហាដោយសារតែ អោក ចន ត្រូវបានឃុំឃាំងនៅក្នុងបន្ទប់ ដែលមិនមានបង្អួច ត្រូវបានបង្ហាញដោយមិនត្រឹមត្រូវ[483]។ អ្នកស៊ើបអង្កេតរបស់ ក.ស.ច.ស បានសួរសំណួរដដែលនេះ ថាតើ អោក ចន បានដឹងដោយរបៀបណា ថានោះគឺជា យឹម ទិត្យ ហើយ អោក ចន បានឆ្លើយតបថា "ងងឹតតែពេលយប់ប៉ុណ្ណោះ"[484] ដោយបន្ថែមថា "ពេលដែលខ្ញុំនៅកន្លែងផលិតស្រូវគឺខ្ញុំស្គាល់គាត់ហើយ"[485]។ លើសពីនេះទៀត ភ័ស្តុតាងរបស់ អោក ចន បង្ហាញថា គាត់បានជួប យឹម ទិត្យ ញឹកញាប់ នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ[486]។ យឹម ទិត្យ អះអាងថា សហចៅក្រមស៊ើបអង្កេតអន្តរជាតិ បានធ្វើការ "សម្រេចជាពិសេស" ចំពោះការដែល អោក ចន បានប្រាប់អ្នកស៊ើបអង្កេតថា រូបថតរបស់ យឹម ទិត្យ ដែលមជ្ឈមណ្ឌលឯកសារកម្ពុជា បានផ្តល់ឱ្យនោះ (ដែលមិនមានភ្ជាប់ជាឧបសម្ព័ន្ធ ជាមួយកិច្ចសម្ភាសន៍ ដូច្នេះហើយ មិនអាចផ្ទៀងផ្ទាត់បាន) "ដូចខៀវ

---

[478] ឯកសារ **D219/108** កំណត់ហេតុស្តាប់ចម្លើយ យូ ភ្នំ ចម្លើយ ៣។

[479] ឯកសារ D382/22 បណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ កថាខណ្ឌ ២៥៣ ជើងទំព័រ ៧៧៦ *ដកស្រង់*ភស្តុតាងរបស់ អោក ចន។

[480] ឯកសារ **D219/108** កំណត់ហេតុស្តាប់ចម្លើយ យូ ភ្នំ ចម្លើយ ៨។

[481] *ផ្ទុយពី* ឯកសារ D382/22 បណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ កថាខណ្ឌ ២៥៣។

[482] សូមមើល ឯកសារ **D105/5** អោក ចន កំណត់ហេតុស្តាប់ចម្លើយ ចម្លើយ ៨៨។ ឯកសារ **D118/156** អោក ចន កំណត់ហេតុស្តាប់ចម្លើយ ចម្លើយ ៧៥។ ឯកសារ **D219/369** កំណត់ហេតុស្តាប់ចម្លើយ អោក ចន ចម្លើយ ៨៦។

[483] *ផ្ទុយពី* ឯកសារ D382/22 បណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ កថាខណ្ឌ ២៥៣។

[484] ឯកសារ **D118/156** កំណត់ហេតុស្តាប់ចម្លើយ អោក ចន ចម្លើយ ៧៦។

[485] ឯកសារ **D118/156** កំណត់ហេតុស្តាប់ចម្លើយ អោក ចន ចម្លើយ ៧៦។

[486] ឯកសារ **D118/156** កំណត់ហេតុស្តាប់ចម្លើយ អោក ចន ចម្លើយ ៧៧។ ឯកសារ **D105/5** កំណត់ហេតុស្តាប់ចម្លើយ អោក ចន ចម្លើយ ៥៦ ដល់៥៧។

សំផន"[487]។ ទោះជាយ៉ាងណាក្ដី យឹម ទិត្យ ជាថ្មីម្ដងទៀត បានដកស្រង់ដោយមិនត្រឹមត្រូវ ដោយពឹងផ្អែកទៅលើតែមួយផ្នែកនៃដីកាបញ្ជូនរឿងទៅជំនុំជម្រះ ទាក់ទងជាមួយសាក្សីដែលមិនមែនជា អោក ចន[488]។

## ខ. យឹម ទិត្យ មិនបានបង្ហាញកំហុសណាមួយ ដែលអាចពិនិត្យឡើងវិញបាន ក្នុងការសម្រេចថា យឹម ទិត្យ ប្រហែលជាបានចូលរួម ក្នុងការសួរចម្លើយនៅវត្តព្រះធាតុ

153. ការអះអាងរបស់ យឹម ទិត្យ ដែលថា សហចៅក្រមស៊ើបអង្កេតអន្តរជាតិ មានកំហុសឆ្គងដោយសម្រេចថា "យឹម ទិត្យ បានចូលរួមដោយផ្ទាល់ក្នុងការសួរចម្លើយនៅវត្តព្រះធាតុ"[489] មិនមានមូលដ្ឋានឡើយ។ យឹម ទិត្យ មិនបានបញ្ជាក់ថាតើគាត់មានន័យបែបណាដែលថា "ចូលរួមដោយផ្ទាល់" បើទោះបីជាការសន្និដ្ឋានរបស់ដីកាបញ្ជូនរឿងទៅជំនុំជម្រះគឺថា យឹម ទិត្យ ប្រហែលជា "សួរនាំអ្នកទោស [...] និងបានបញ្ជា និងបានបញ្ជូនបញ្ជាបន្ត ឬយ៉ាងហោចណាស់យល់ព្រមឱ្យសួរចម្លើយ" អ្នកទោស[490]។

154. ទោះជាក្នុងករណីណាក៏ដោយ ការពណ៌នារបស់ យឹម ទិត្យ អំពីភ័ស្តុតាងរបស់ ទន់ ស៊ួន មិនត្រឹមត្រូវ[491]។ ផ្ទុយពីការអះអាងថា ចម្លើយថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០១៤ របស់ ទន់ ស៊ួន គឺ "ជាលើកដំបូង" ដែល ទន់ ស៊ួន បាននិយាយអំពី យឹម ទិត្យ សួរចម្លើយអ្នកទោសនៅវត្តព្រះធាតុ[492] ទន់ ស៊ួន បានប្រាប់អ្នកស៊ើបអង្កេត នៅថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ២០១៣ ថា គាត់បានឃើញ យឹម ទិត្យ នៅវត្តព្រះធាតុ "សួរចម្លើយអ្នកទោស"[493]។ លំដាប់ពេលវេលារបស់ យឹម ទិត្យ ចំពោះចម្លើយរបស់ ទន់ ស៊ួន បានលើកឡើងដោយមិនត្រឹមត្រូវថា ទន់ ស៊ួន បង្ហាញជាលើកដំបូងពី យឹម ទិត្យ សួរចម្លើយអ្នកទោស បន្ទាប់ពីបាន "អ្នកស៊ើបអង្កេតនៃ ក.ស.ច.ស បានស្ដាប់ចម្លើយក្រៅផ្លូវការ នៅថ្ងៃទី០៣

---

[487] ឯកសារ D382/22 បណ្ដឹងឧទ្ធរណ៍របស់ យឹម ទិត្យ កថាខណ្ឌ ២៥៣។ សូមមើល ឯកសារ **D105/5** កំណត់ហេតុស្ដាប់ចម្លើយ អោក ចន ចម្លើយ ១០៥។

[488] ឯកសារ D382/22 បណ្ដឹងឧទ្ធរណ៍របស់ យឹម ទិត្យ កថាខណ្ឌ ២៥៣ ជើងទំព័រ ៧៩១។ កថាខណ្ឌនៃដីកាបញ្ជូនរឿងទៅជំនុំជម្រះ ដកស្រង់ទាក់ទង ហោ យ៉ន

[489] ឯកសារ D382/22 បណ្ដឹងឧទ្ធរណ៍របស់ យឹម ទិត្យ កថាខណ្ឌ ២៥៥។

[490] ឯកសារ D382 ដីកាបញ្ជូនរឿងទៅជំនុំជម្រះ កថាខណ្ឌ ៤៦៣។

[491] ឯកសារ D382/22 បណ្ដឹងឧទ្ធរណ៍របស់ យឹម ទិត្យ កថាខណ្ឌ ២៥៥។

[492] ឯកសារ D382/22 បណ្ដឹងឧទ្ធរណ៍របស់ យឹម ទិត្យ កថាខណ្ឌ ២៥៥។

[493] ឯកសារ **D118/22** ទន់ ស៊ួន កំណត់ហេតុស្ដាប់ចម្លើយ ចម្លើយ ១៦។

ខែធ្នូ ឆ្នាំ២០១៤"[494]។ ប៉ុន្តែ អ្នកស៊ើបអង្កេត ក.ស.ច.ស បានបញ្ជាក់យ៉ាងច្បាស់ថា ទំនាក់ទំនងរវាងពួកគេ ជាមួយ ទន់ ស៊ួន គឺ "ផ្អែកលើព័ត៌មានដែលផ្តល់ ក្នុងការស្តាប់ចម្លើយកន្លងមក" ពីឆ្នាំ ២០១៣[495]។

155. យឹម ទិត្យ ក៏បានលើកឡើងដោយប្រយោលថា ភ័ស្តុតាងរបស់ ទន់ ស៊ួន ប្រហែលជាអាចត្រូវបានទទួលឥទ្ធិពលដោយសារការដាក់បង្ហាញដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរលើកទីបីរបស់សហព្រះរាជអាជ្ញាអន្តរជាតិ នៅក្នុងឆ្នាំ ២០១១[496]។ ការទាយស្មានដោយគ្មានមូលដ្ឋាននេះ មិនបានពិចារណាទៅលើ ការស្តាប់ចម្លើយជាលើកដំបូងរបស់ ទន់ ស៊ួន នៅក្នុងឆ្នាំ ២០០៨ ដែលលើកយោងទៅសិទ្ធិអំណាចរបស់ យឹម ទិត្យ នៅក្នុងស្រុកគិរីវង់[497]។ លើសពីនេះទៀត យឹម ទិត្យ បានចោទសួរថាតើ ទន់ ស៊ួន អាចស្តាប់ឮដោយរបៀបណា ពីសំណួរដែល យឹម ទិត្យ សួរទៅកាន់អ្នកទោស ប្រសិនបើ ទន់ ស៊ួន មិនត្រូវបានអនុញ្ញាតឲ្យចូលទៅក្នុងតំបន់ឃុំឃាំងអ្នកទោសនោះ[498] ប៉ុន្តែ ទន់ ស៊ួន បានប្រាប់អ្នកស៊ើបអង្កេតថា ការសួរចម្លើយធ្វើឡើងនៅកុដិព្រះសង្ឃ "ប្រហែលប្រាំពីរម៉ែត្រ" ពីកន្លែងដែល ទន់ ស៊ួន ជាប់ឃុំឃាំង នៅឃ្លាំងអារឈើ[499]។ លើសពីនេះទៀត ការអះអាងរបស់ យឹម ទិត្យ ដែលថា ទន់ ស៊ួន មិនច្បាស់ថាតើ យឹម ទិត្យ និយាយជាមួយអ្នកទោស ឬជាមួយបុគ្គលិកគុក គឺជាការខុសឆ្គង[500] ព្រោះចម្លើយរបស់ ទន់ ស៊ួន ពីការស្តាប់ចម្លើយ ច្បាស់លាស់ នៅពេលដែល ទន់ ស៊ួន លើកសំដៅទៅបុគ្គលិកគុក[501] ឬអ្នកទោស[502]។ ជាចុងក្រោយ ផ្ទុយពីការអះអាងរបស់ យឹម ទិត្យ ដែលថា ទន់ ស៊ួន ជាប់ឃុំឃាំងនៅក្នុងគុកចំនួនពីរ ហើយមិនច្បាស់

---

[494] ឯកសារ D382/22 បណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ កថាខណ្ឌ ២៥៥។

[495] ឯកសារ **D219/110** កំណត់ហេតុស្តាប់ចម្លើយទន់ ស៊ួន សំណួរ ១។

[496] ឯកសារ D382/22 បណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ កថាខណ្ឌ ២៥៥។ សូមមើលផងដែរ ដូចខាងលើ កថាខណ្ឌ ២៨ ដល់ ៣២។ (ផ្នែក III.ក.១)។

[497] ឯកសារ **D1.3.11.56** កំណត់ហេតុស្តាប់ចម្លើយ ទន់ ស៊ួន ដោយ ក.ស.ព ERN 00219252។

[498] ឯកសារ D382/22 បណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ កថាខណ្ឌ ២៥៥។

[499] ឯកសារ **D219/346** កំណត់ហេតុស្តាប់ចម្លើយ ទន់ ស៊ួន ចម្លើយ ៥៨ ដល់ ៥៩។

[500] ឯកសារ D382/22 បណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ កថាខណ្ឌ ២៥៦។

[501] ឯកសារ **D219/346** កំណត់ហេតុស្តាប់ចម្លើយ ទន់ ស៊ួន ចម្លើយ ៤៧, ៥២។ យឹម ទិត្យ បានដកស្រង់ចម្លើយ ៤៦ ដែលហាក់ដូចជាមានភាពខុសឆ្គង។ សូមមើល ឯកសារ D382/22 បណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ ជើងទំព័រ ៨១៩។

[502] ឯកសារ **D219/346** ទន់ ស៊ួន កំណត់ហេតុស្តាប់ចម្លើយ ចម្លើយ ៥៦ ដល់៥៧។

ថាតើការជាប់ឃុំនោះ នៅដើម ឬនៅចុងឆ្នាំ១៩៧៦ មិនមានន័យថា ភ័ស្តុតាងរបស់ ទន់ ស៊ួន មិនអាចពឹងផ្អែកលើបានឡើយនោះទេ[503]។

156. បន្ថែមពីលើសាក្សីទាំងអស់នេះ ភ័ស្តុតាងដទៃទៀតបានបង្ហាញពីការចូលរួមរបស់ យឹម ទិត្យ នៅក្នុង និងការទទួលខុសត្រូវចំពោះ ការសួរចម្លើយនៅវត្តព្រះធាតុ។ ឧទាហរណ៍ អតីតអ្នកជាប់ឃុំនៅវត្តព្រះធាតុឈ្មោះ អោក ចន បានបញ្ជាក់ថា "ក្រោយពេលតាទិត្យ ចេញទៅ គេបានយកអ្នកទោសទៅសួរចម្លើយ"[504]។ សាក្សីដទៃទៀតជាច្រើនបានប្រាប់អ្នកស៊ើបអង្កេតអំពីការសួរចម្លើយនៅវត្តព្រះធាតុ[505] ព្រមទាំងបានផ្តល់ភ័ស្តុតាងថា លទ្ធផលនៃការសួរចម្លើយ ត្រូវបានកត់ត្រាជាលាយលក្ខណ៍អក្សរ ហើយត្រូវបានបញ្ជូនទៅគណៈកម្មាធិការស្រុកគិរីវង់[506] បញ្ជូនទៅ យឹម ទិត្យ។

<u>គ. យឹម ទិត្យ មិនបានបង្ហាញកំហុសណាមួយ ដែលអាចពិនិត្យឡើងវិញបាន ក្នុងការសម្រេចថា យឹម ទិត្យ ប្រហែលបានចូលរួម ក្នុងការសម្លាប់មនុស្សនៅវត្តព្រះធាតុ</u>

157. យឹម ទិត្យ អះអាងដោយមិនស្របគ្នា ជាដំបូងថា ការសម្រេចរបស់ដីកាបញ្ជូនរឿងទៅជំនុំជម្រះដែលថា គាត់បានបញ្ជាឱ្យ "វះពោះ" អ្នកទោសនៅវត្តព្រះធាតុ ផ្អែកលើ "ត្រឹមតែភ័ស្តុតាងរបស់ ហោ យ៉ន"[507] ប៉ុន្តែ បន្ទាប់មក បញ្ជាក់ថា ការសម្រេច "ផ្អែកលើការវិភាគទៅលើភ័ស្តុតាងរបស់ ដុក ចាន់"[508] ព្រមទាំង "ការសម្រេចអំពីឋានានុក្រមបញ្ជាការនៅស្រុកគិរីវង់ទៅលើវត្តព្រះធាតុ"[509]។

---

[503] ឯកសារ D382/22 បណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ កថាខណ្ឌ ២៥៨។

[504] ឯកសារ **D118/156** កំណត់ហេតុស្តាប់ចម្លើយ អោក ចន ចម្លើយ ៦៨។

[505] សូមមើល*ឧទាហរណ៍* ឯកសារ **D219/189** កំណត់ហេតុស្តាប់ចម្លើយ ស៊ឹម ឈឿន ចម្លើយ ៣៥ ដល់៣៦។ ឯកសារ **D219/121** កំណត់ហេតុស្តាប់ចម្លើយ លឹម ងេន ចម្លើយ ៣១។ ឯកសារ **D118/112** កំណត់ហេតុស្តាប់ចម្លើយ វ៉ែន ណាត់ ចម្លើយ ៦ ដល់៨, ១១, ៥២។ ឯកសារ **D219/248** កំណត់ហេតុស្តាប់ចម្លើយ វ៉ែន ណាត់ ចម្លើយ ១១, ២៦, ៣១, ១២៦។ ឯកសារ **D219/316** កំណត់ហេតុស្តាប់ចម្លើយ ម៉ៅ ង៉ូវ ចម្លើយ ១៣, ៩៤, ៩៦ ដល់៩៨, ១០២ ដល់១០៤។ ឯកសារ **D219/369** កំណត់ហេតុស្តាប់ចម្លើយ អោក ចន ចម្លើយ ៩៤ ដល់៩៥, ៩៩ ដល់១០១។ ឯកសារ **D219/87** កំណត់ហេតុស្តាប់ចម្លើយ ដុក ចាន់ ចម្លើយ ១២។ ឯកសារ **D105/5** កំណត់ហេតុស្តាប់ចម្លើយ អោក ចន ចម្លើយ ៧៩, ៨៦។

[506] ឯកសារ **D219/189** កំណត់ហេតុស្តាប់ចម្លើយ ស៊ឹម ឈឿន ចម្លើយ ៣៥5។ ឯកសារ **D219/369** អោក ចន កំណត់ហេតុស្តាប់ចម្លើយ ចម្លើយ ៩៦។

[507] ឯកសារ D382/22 បណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ កថាខណ្ឌ ២៦០។

[508] ឯកសារ D382/22 បណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ កថាខណ្ឌ ២៦១។

[509] ឯកសារ D382/22 បណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ កថាខណ្ឌ ២៦២។

158. យឹម ទិត្យ មិនបានបង្ហាញថា ដីកាបញ្ជូនរឿងទៅជំនុំជម្រះវិភាគលើភ័ស្តុតាងដោយមិនត្រឹមត្រូវទេ។ ឧទាហរណ៍ ការអះអាងរបស់ យឹម ទិត្យ ដែលថា "សហចៅក្រមស៊ើបអង្កេតអន្តរជាតិ មិនបានពិចារណាថា ហោ យ៉ន ស្ថិតនៅក្នុងគុកនៅឆ្នាំ១៩៧៣" គឺជាការអះអាងមិនត្រឹមត្រូវ[510]។ ដីកាបញ្ជូនរឿងទៅជំនុំជម្រះបានពិភាក្សាយ៉ាងច្បាស់លាស់អំពីបញ្ហានេះ និងចំណុចដទៃទៀតនៃចម្លើយរបស់ ហោ យ៉ន នៅមុនពេលសន្និដ្ឋានថា "ហោ យ៉ន ទំនងជាជាប់ឃុំនៅវត្តព្រះធាតុ ក្នុងឆ្នាំ១៩៧៧ ឬឆ្នាំ១៩៧៨"[511]។ ការសម្រេចដោយមានសំអាងហេតុនេះត្រូវបានគាំទ្រដោយភ័ស្តុតាងដទៃទៀតដែលថា វត្តព្រះធាតុប្រហែលជាចាប់ផ្តើមដំណើរការនៅដើមឆ្នាំ១៩៧៥[512] ដែលដីកាសម្រេចលើកលែងចោទប្រកាន់ ក៏បានទទួលស្គាល់ផងដែរ[513]។

159. ដូចគ្នានេះដែរ យឹម ទិត្យ បានអះអាងដោយមិនត្រឹមត្រូវថា សហចៅក្រមស៊ើបអង្កេតអន្តរជាតិមិនបានពិចារណាពីភាពមិនស៊ីសង្វាក់គ្នានៅក្នុងភ័ស្តុតាងរបស់ ហោ យ៉ន ទាក់ទងនឹងហេតុការណ៍នៃការចូលរួមរបស់ យឹម ទិត្យ ក្នុងការ "វះពោះ" អ្នកទោស ដើម្បីវះយកប្រមាត់[514]។ ជាថ្មីម្តងទៀត សហចៅក្រមស៊ើបអង្កេតអន្តរជាតិបានពិនិត្យយ៉ាងលម្អិតទៅលើចម្លើយរបស់ ហោ យ៉ន មុនពេលសម្រេចជាស្ថាពរថា ដោយផ្អែកទៅលើ "ភាពមិនស៊ីចង្វាក់គ្នានៅក្នុងការស្តាប់ចម្លើយទាំងនោះ គេពុំអាចសន្និដ្ឋានឲ្យច្បាស់លាស់ចាំបាច់ថា យឹម ទិត្យ ពិតជាមានវត្តមានដោយផ្ទាល់ នៅកន្លែងដែលគេវះពោះ អ្នកទោសយកប្រមាត់"[515]។ ទោះជាយ៉ាងនេះក្តី សហចៅក្រមស៊ើបអង្កេតអន្តរជាតិបានបន្តសម្រេចថា "តែវាមានភាពច្បាស់លាស់គ្រប់គ្រាន់ថា គាត់បានចេញបញ្ជាឲ្យ "វះពោះ" អ្នកទោស ហើយថា គាត់បានឃើញគេយកប្រមាត់ ដាក់ក្នុងធុងមួយ ហើយគាត់បានទទួលប្រមាត់ទាំងនោះជាមួយ តាណាំ មែន"[516]។

160. យឹម ទិត្យ លើកឡើងដោយមិនត្រឹមត្រូវថា ហោ យ៉ន មិនបានដឹងអំពីមុខងាររបស់វត្តព្រះធាតុ ឬតួនាទីរបស់ យឹម ទិត្យ នៅក្នុងស្រុកគិរីវង់ទេ[517]។ ទោះជាយ៉ាងណាក្តី ហោ យ៉ន បានប្រាប់អ្នក

---

[510] ឯកសារ D382/22 បណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ កថាខណ្ឌ ២៦០។

[511] ឯកសារ D382 ដីកាបញ្ជូនរឿងទៅជំនុំជម្រះ កថាខណ្ឌ ៤៥៥។

[512] ឯកសារ D382 ដីកាបញ្ជូនរឿងទៅជំនុំជម្រះ កថាខណ្ឌ ៤៣៤ ជើងទំព័រ ១១៥៤។

[513] ឯកសារ D381 ដីកាសម្រេចលើកលែងចោទប្រកាន់, កថាខណ្ឌ ១៩០។

[514] ឯកសារ D382/22 បណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ កថាខណ្ឌ ២៦០។

[515] ឯកសារ D382 ដីកាបញ្ជូនរឿងទៅជំនុំជម្រះ កថាខណ្ឌ ៤៥៧។

[516] ឯកសារ D382 ដីកាបញ្ជូនរឿងទៅជំនុំជម្រះ កថាខណ្ឌ ៤៥៧។

[517] ឯកសារ D382/22 បណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ កថាខណ្ឌ ២៦០។

ស៊ើបអង្កេតថា យឹម ទិត្យ នៅក្នុងគណៈកម្មាធិការ ស្រុកគិរីវង់[518] ហើយថា "គ្រប់គ្នាស្គាល់" យឹម ទិត្យ នៅក្នុងស្រុកគិរីវង់[519] យឹម ទិត្យ បើកឡានហ្សីបតែម្នាក់ឯង ទៅចូលរួមប្រជុំជាមួយ មេឃុំ និងសហករណ៍នៅគិរីវង់[520] និងថា "ពេលដែលមានការប្រជុំ គឺគេប្រាប់ថា តាទិត និងតាណាំ នឹងមកគុកវត្តព្រះធាតុនេះ"[521]។ ហោ យ៉ន ពិតជាមានការដឹងឮច្បាស់លាស់ថា យឹម ទិត្យ គឺជាបុគ្គលដែលមានសិទ្ធិអំណាចសំខាន់[522] ដែលមានអំណាចក្នុងការបញ្ជាឲ្យសួរចម្លើយ និងសម្លាប់មនុស្សនៅវត្តព្រះធាតុ។

161. លើសពីនេះទៀត ការអះអាងរបស់ យឹម ទិត្យ ដែលថា មិនមាន "ភ័ស្តុតាងលម្អិត" ដែល ដុក ចាន់ អាចដឹងអំពីរចនាសម្ព័ន្ធរាយការណ៍ នៅវត្តព្រះធាតុនោះ គឺជាការអះអាងដែលមិនត្រឹមត្រូវ[523]។ ក្រៅពីការមិនមានភាពច្បាស់លាស់ ថាតើ យឹម ទិត្យ មានន័យបែបណាចំពោះ "ភ័ស្តុតាងលម្អិត" នៅដំណាក់កាលនេះ ក្នុងកិច្ចដំណើរការនីតិវិធី ដែលភាពគ្រប់គ្រាន់នៃភ័ស្តុតាង គឺជាកម្រិតអប្បបរមាសម្រាប់ដីកាបញ្ជូនរឿងទៅជំនុំជម្រះ[524] នោះ ដុក ចាន់ បានបញ្ជាក់ថា គាត់ជាបុគ្គលិកម្នាក់ ក្នុងចំណោមបុគ្គលិកគុកតែបួននាក់ប៉ុណ្ណោះ ដែលនៅបានប្រហែលពីរឆ្នាំ[525] ហើយ ដុក ចាន់ បានប្រាប់អ្នកស៊ើបអង្កេតថា វត្តព្រះធាតុគឺជាគុកស្រុក[526] ប្រធានមន្ទីរសន្តិសុខវត្តព្រះធាតុគឺ ព្រីង ហើយអនុប្រធានគឺ ឈឹម[527] ប្រធានសន្តិសុខរាយការណ៍ ទៅគណៈកម្មាធិការស្រុកគិរីវង់[528] យឹម ទិត្យ គឺជាលេខាស្រុកគិរីវង់[529] យឹម ទិត្យ ទៅពិនិត្យវត្តព្រះធាតុ ដើម្បីជួបជាមួយប្រធានសន្តិសុខ

---

[518] ឯកសារ **D118/155** កំណត់ហេតុស្តាប់ចម្លើយ ហោ យ៉ន ចម្លើយ ១៤។ ឯកសារ **D219/55** កំណត់ហេតុស្តាប់ចម្លើយ ហោ យ៉ន ចម្លើយ ១, ១៥, ១៩, ២៥។

[519] ឯកសារ **D118/155** កំណត់ហេតុស្តាប់ចម្លើយ ហោ យ៉ន ចម្លើយ ១១៩។

[520] ឯកសារ **D219/55** កំណត់ហេតុស្តាប់ចម្លើយ ហោ យ៉ន ចម្លើយ ២១។

[521] ឯកសារ **D118/155** កំណត់ហេតុស្តាប់ចម្លើយហោ យ៉ន ចម្លើយ ៤៧។

[522] សូមមើលផងដែរ ឯកសារ **D105/6** ហោ យ៉ន កំណត់ហេតុស្តាប់ចម្លើយ ចម្លើយ ១១។

[523] ឯកសារ D382/22 បណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ កថាខណ្ឌ ២៦១។

[524] សូមមើល សារណាបឋម កថាខណ្ឌ ១១ ដល់១២ (បទដ្ឋានបង្ហាញភស្តុតាង)។

[525] ឯកសារ **D219/86** ដុក ចាន់ កំណត់ហេតុស្តាប់ចម្លើយ ចម្លើយ ៣, ៥។

[526] ឯកសារ **D219/86** ដុក ចាន់ កំណត់ហេតុស្តាប់ចម្លើយ ចម្លើយ ៦។

[527] ឯកសារ **D219/86** ដុក ចាន់ កំណត់ហេតុស្តាប់ចម្លើយ ចម្លើយ ៥។

[528] ឯកសារ **D219/86** ដុក ចាន់ កំណត់ហេតុស្តាប់ចម្លើយ ចម្លើយ ៧។

[529] ឯកសារ **D219/86** ដុក ចាន់ កំណត់ហេតុស្តាប់ចម្លើយ ចម្លើយ ៧។

ព្រមទាំងកោះហៅប្រធានសន្តិសុខទៅ មន្ទីរស្រុក[530] ឃោធាស្រុកមកយកអ្នកទោសទៅ[531] មានការប្រជុំប្រចាំសប្តាហ៍ ដែលប្រធានសន្តិសុខ បានណែនាំដល់បុគ្គលិក និងប្រាប់បុគ្គលិកថា "ពីបញ្ហាពាក់ព័ន្ធការងារ នៅមន្ទីរសន្តិសុខ"[532] និងប្រធានសន្តិសុខ អានរបាយការណ៍ពីឃុំ អំពីការចោទប្រកាន់ពីកំហុស របស់អ្នកដែលត្រូវបានបញ្ជូកមកគុក[533]។ ដូច្នេះ ដុក ចាន់ បានដឹងអំពីរចនាសម្ព័ន្ធ និងដំណើរការនៅវត្តព្រះធាតុ[534]។

162. ជាចុងក្រោយ យឹម ទិត្យ បានអះអាងដោយមិនត្រឹមត្រូវថា ការសម្រេចរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ទាក់ទងនឹងឋានានុក្រមបញ្ជាការរវាងស្រុកគិរីវង់ និងវត្តព្រះធាតុ ផ្អែកលើ "សក្ខីកម្មពីរបីជួររបស់ ហុក ចន និងកាលបរិច្ឆេទ នៃការជាប់ឃុំឃាំងរបស់ ហោ យ៉ន"[535]។ យឹម ទិត្យ បានបញ្ជាក់ឡើងវិញពីការអះអាងរបស់គាត់ ទាក់ទងនឹងភាពអាចជឿជាក់បានរបស់ ហោ យ៉ន ដូចបានពិភាក្សានៅក្នុងកថាខណ្ឌ ១៥០ ខាងលើ។ ពាក់ព័ន្ធជាមួយ អោក ចន ទោះបីជាគាត់បាននិយាយថា គាត់មិនបានស្តាប់ឮថា យឹម ទិត្យ ចេញបញ្ជាឲ្យដោះលែងក្តី តែ អោក ចន ជឿជាក់ថា យឹម ទិត្យ បានចេញបញ្ជាឲ្យដោះលែងគាត់ ដោយសារតែ អោក ចន ត្រូវបានអនុញ្ញាតឲ្យចេញទៅ ក្រោយពេលដែល យឹម ទិត្យ មកវត្តព្រះធាតុ និងបានត្រួតពិនិត្យអ្នកទោស[536] គណៈកម្មាធិការស្រុកគិរីវង់ គឺជាថ្នាក់លើរបស់ប្រធានសន្តិសុខវត្តព្រះធាតុ ហើយប្រធានសន្តិសុខវត្តព្រះធាតុ មិនមានសិទ្ធិដោះលែងអ្នកទោសទេ[537] ហើយចម្លើយនៃការសួរចម្លើយរបស់ អោក ចន ត្រូវបានកត់ត្រា ហើយរាយការណ៍ដោយប្រធានសន្តិសុខវត្តព្រះធាតុ ទៅគណៈកម្មាធិការស្រុក

---

[530] ឯកសារ **D219/86** ដុក ចាន់ កំណត់ហេតុស្តាប់ចម្លើយ ចម្លើយ ៩។

[531] ឯកសារ **D219/86** ដុក ចាន់ កំណត់ហេតុស្តាប់ចម្លើយ ចម្លើយ ១៣។

[532] ឯកសារ **D219/87** កំណត់ហេតុស្តាប់ចម្លើយ ដុក ចាន់ ចម្លើយ ១០ ដល់១១។

[533] ឯកសារ **D219/87** កំណត់ហេតុស្តាប់ចម្លើយ ដុក ចាន់ ចម្លើយ ១២។

[534] *ផ្ទុយពី* ឯកសារ D**382/22** បណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ កថាខណ្ឌ ២៦១។

[535] ឯកសារ D**382/22** បណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ កថាខណ្ឌ ២៦២។

[536] ឯកសារ **D219/369** កំណត់ហេតុស្តាប់ចម្លើយ អោក ចន ចម្លើយ ១០៦ ដល់១០៩។

[537] ឯកសារ **D219/369** កំណត់ហេតុស្តាប់ចម្លើយ អោក ចន ចម្លើយ ៩៧។

គិរីវង់[538]។ ផ្ទុយពីការអះអាងរបស់ យឹម ទិត្យ អោក ចន បានប្រាប់អ្នកស៊ើបអង្កេតថា "សមាជិកគណៈស្រុក" ចេញបញ្ជាឱ្យសម្លាប់អ្នកទោស នៅវត្តព្រះធាតុ[539]។

## ១១. យឹម ទិត្យ មិនបានបង្ហាញថា ភ័ស្តុតាងរបស់ ចាន់ វិចិត្រ មានភាពពាក់ព័ន្ធជាមួយនឹងការសម្រេចដែលថា យឹម ទិត្យ ប្រហែលជាស្ថិតក្នុងចំណោម "អ្នកទទួលខុសត្រូវខ្ពស់បំផុត"

163. យឹម ទិត្យ បានអះអាងថា សហចៅក្រមស៊ើបអង្កេតអន្តរជាតិ "មិនបានយកមកពិចារណា" លើអ្វីដែល យឹម ទិត្យ បានរៀបរាប់ដោយមិនត្រឹមត្រូវថាជា "ភ័ស្តុតាងផ្ទុយ" របស់ ចាន់ វិចិត្រ" នៅពេលធ្វើការវាយតម្លៃលើយុត្តាធិការបុគ្គល[540]។ ជាដំបូង យឹម ទិត្យ មិនបានបង្ហាញថា សហចៅក្រមស៊ើបអង្កេតអន្តរជាតិមិនបានពិចារណាទៅលើភ័ស្តុតាងរបស់ ចាន់ វិចិត្រ ទេ[541]។ ទីពីរ យឹម ទិត្យ បានកំណត់ប្រភេទ ដោយគ្មានមូលដ្ឋានសោះ ចំពោះចម្លើយជាច្រើនរបស់ ចាន់ វិចិត្រ ថា ចាន់ វិចិត្រ "ព្យាយាមបំភ្លឺភ័ស្តុតាងរបស់គាត់" ចំពោះសហចៅក្រមស៊ើបអង្កេតអន្តរជាតិ[542]។ ទោះជាយ៉ាងនេះក្តី មិនមានឧទាហរណ៍ណាមួយដែល យឹម ទិត្យ បានលើកឡើង គាំទ្រដល់ចំណុចនេះឡើយ។ ឧទាហរណ៍ យឹម ទិត្យ បានដកស្រង់ថា ចាន់ វិចិត្រ បានប្រាប់អ្នកស៊ើបអង្កេតថា ការទទួលខុសត្រូវរបស់ យឹម ទិត្យ មិននៅដដែល ហើយថា យឹម ទិត្យ ពុំមានមុខតំណែងផ្លូវការទេ និងថា តាម៉ុកជាអ្នកផ្តល់ការងារទៅឱ្យ យឹម ទិត្យ [543]។ មិនត្រឹមតែមិនមែនផ្ទុយជាមួយនឹងតួនាទីរបស់ យឹម ទិត្យ ប៉ុណ្ណោះទេ ប៉ុន្តែ ចំណុចទាំងនេះគាំទ្រយ៉ាងខ្លាំងចំពោះការដែលថា យឹម ទិត្យ ប្រហែលជាមានសិទ្ធិអំណាចជាក់ស្តែងសំខាន់នៅក្នុងតំបន់ ១៣ ក្នុងអំឡុងពេលបួនខែក្នុងឆ្នាំ ១៩៧៥ ជាពេលដែល ចាន់ វិចិត្រ បានផ្តល់ភ័ស្តុតាងនោះ។

---

[538] ឯកសារ **D219/369** កំណត់ហេតុស្តាប់ចម្លើយ អោក ចន ចម្លើយ ៩៥។ សូមមើលផងដែរ ឯកសារ **D118/112** កំណត់ហេតុស្តាប់ចម្លើយ វ៉ែន ណាត់ ចម្លើយ ៥១។

[539] ឯកសារ **D219/369** កំណត់ហេតុស្តាប់ចម្លើយ អោក ចន ចម្លើយ ១០១។ *ផ្ទុយពី* ឯកសារ D382/22 បណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ កថាខណ្ឌ ២៦៣។

[540] ឯកសារ D382/22 បណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ កថាខណ្ឌ ១៣០។

[541] សូមមើល សារណាបឋម កថាខណ្ឌ ១៤ (សេរីភាពនៃភស្តុតាង)

[542] ឯកសារ D382/22 បណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ កថាខណ្ឌ ១៣០។ សូមមើលផងដែរ កថាខណ្ឌ ១៣២។

[543] ឯកសារ D382/22 បណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ កថាខណ្ឌ ១៣០។

164. ដោយផ្ទុយពីការអះអាងរបស់ យឹម ទិត្យ ភស្តុតាងរបស់ ចាន់ វិចិត្រ មានភាពច្បាស់លាស់ និងស៊ីសង្វាក់គ្នា។ យឹម ទិត្យ គឺជា "ប្រធានមន្ទីរភូមិភាគ"[544] យឹម ទិត្យ "នៅក្រោមបញ្ជារបស់តាម៉ុក តែម្តង។ ធ្វើការតំណាងឲ្យតាម៉ុក"[545] "តែពេលអត់តាម៉ុកទៅ ប្រហែលជាមានប្រជុំឲ្យតាទិត្យ ជំនួស"[546] យឹម ទិត្យ "មួយខេត្តតាកែវ ផ្នែកខាងលិច គឺគាត់ទៅទាំងអស់"[547] "មិនដែលប្រគល់ឲ្យអ្នកណាទេ គឺមានតែ តាទិត្យ និងអាបូរាណ ជាកូនចិញ្ចឹម"[548] និង "តំបន់តាកែវ អ្នកគ្រប់គ្រងធំជាងគេគឺ តាម៉ុក និងតាទិត្យហើយ។ គាត់ទាំងពីរនេះ គ្រប់គ្រងតាកែវទាំងមូល និងភូមិភាគទាំងមូល"[549]។

165. ចាន់ វិចិត្រ បានសរសេរកំណត់ត្រាដូចខាងក្រោមផងដែរ នៅក្នុងពេលស្តាប់ចម្លើយទាក់ទងនឹងសិទ្ធិអំណាចនៅក្នុងភូមិភាគនិរតី ៖ "រចនាសម្ព័ន្ធតាទិត្យ ជាសាខា តាម៉ុក ក្នុងរចនាសម្ព័ន្ធគឺជាស្តីទី [...] តាម៉ុក នៅក្រោមបង្គាប់របស់ តាម៉ុក ប្រើសម្រាប់ធ្វើការផ្សេងៗ ដោយមិនបាច់ចេញលិខិតតែងតាំង ប្រើមាត់ទទេរ"[550]។ ការរៀបរាប់នេះបានគាំទ្រយ៉ាងច្បាស់លាស់ចំពោះការសន្និដ្ឋានដែលថា យឹម ទិត្យ ប្រហែលជាមេដឹកនាំជាក់ស្តែង នៅក្នុងភូមិភាគនិរតី[551]។ ដូច្នេះ ចំពោះថាមូលដ្ឋានទីប្រាំរបស់ យឹម ទិត្យ ជំទាស់ចំពោះការសម្រេចដែលថា គាត់ស្ថិតក្នុងចំណោម "អ្នកទទួលខុសត្រូវខ្ពស់បំផុត" ចំពោះឧក្រិដ្ឋកម្មនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យនោះ ទឡ្ហីករណ៍របស់ យឹម ទិត្យ ទទួលបានការបរាជ័យ។

---

[544] ឯកសារ **D219/815.1** កិច្ចសម្ភាសន៍ជាមួយ ចាន់ វិចិត្រ ដោយមជ្ឈមណ្ឌលឯកសារកម្ពុជា ERN 01287841។

[545] ឯកសារ **D219/853** កំណត់ហេតុស្តាប់ចម្លើយ ចាន់ វិចិត្រ ចម្លើយ ៤០។

[546] ឯកសារ **D219/853** កំណត់ហេតុស្តាប់ចម្លើយ ចាន់ វិចិត្រ ចម្លើយ ៥១ សូមមើលផងដែរ ចម្លើយ ៥២។

[547] ឯកសារ **D219/853** កំណត់ហេតុស្តាប់ចម្លើយ ចាន់ វិចិត្រ ចម្លើយ ៦៦។

[548] ឯកសារ **D219/853** កំណត់ហេតុស្តាប់ចម្លើយ ចាន់ វិចិត្រ ចម្លើយ ១៤៤។ សូមមើលផងដែរ ចម្លើយ ១៤៣។

[549] ឯកសារ **D219/853** កំណត់ហេតុស្តាប់ចម្លើយ ចាន់ វិចិត្រ ចម្លើយ ១០១។

[550] ឯកសារ **D219/853** កំណត់ហេតុស្តាប់ចម្លើយ ចាន់ វិចិត្រ ចម្លើយ ១៧១។

[551] យឹម ទិត្យ បានអះអាងដោយមិនត្រឹមត្រូវនៅក្នុងកថាខណ្ឌ ១៣១ នៃបណ្តឹងឧទ្ធរណ៍របស់គាត់ថា ភស្តុតាងរបស់ វណ្ណ កុសល គាំទ្រដល់ការអះអាងថា ចម្លើយរបស់ ចាន់ វិចិត្រ ផ្ទុយនឹងការសម្រេចរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ លើសិទ្ធិអំណាចជាក់ស្តែង។ ទោះជាយ៉ាងនេះក្តី វណ្ណ កុសល គ្រាន់តែប្រាប់សហចៅក្រមស៊ើបអង្កេតអន្តរជាតិថា យឹម ទិត្យ "មិនមែនជាទ័ពដូចពួកខ្ញុំទេ"។ វណ្ណ កុសល គឺជាយោធានៅជួរមុខ ហើយមិនដែលបានជួប យឹម ទិត្យ ឡើយ តែគាត់បានដឹងថា យឹម ទិត្យ ធ្វើការនៅកម្រិតតំបន់នៅក្នុងភូមិភាគនិរតី។ សូមមើល ឯកសារ **D219/901** កំណត់ហេតុស្តាប់ចម្លើយ វណ្ណ កុសល ចម្លើយ ៣៥ ដល់៣៦។

## IV. សេចក្តីសន្និដ្ឋាន

166. បណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ គួរត្រូវបានបដិសេធចោល ដោយសារតែមិនបានបង្ហាញអំពីកំហុសអង្គច្បាប់ណាមួយ ដែលមោឃភាពដីកាសម្រេច មិនបានបង្ហាញអំពីកំហុសអង្គហេតុ ដែលបណ្តាលឲ្យមានភាពមិនយុត្តិធម៌ ឬការរំលោភបំពានទៅលើឆន្ទានុសិទ្ធិ ដែលបង្ខំឲ្យមានការសន្និដ្ឋានថា សហចៅក្រមស៊ើបអង្កេតអន្តរជាតិមិនបានប្រើប្រាស់ឆន្ទានុសិទ្ធិរបស់គាត់ តាមផ្លូវតុលាការឡើយ។ ក្រៅពីការលើកឡើងពីការអះអាងដែលមិនអាចទទួលយកបាន ទឡ្ហីករណ៍របស់ យឹម ទិត្យ ទាក់ទងនឹង មូលដ្ឋាន វិសាលភាព និងការបំពេញកិច្ចស៊ើបសួរ ព្រមទាំងច្បាប់ដែលត្រូវអនុវត្ត ការវាយតម្លៃទៅលើភ័ស្តុតាង និងការសន្និដ្ឋានដែលមាន នៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ មិនតម្រូវឲ្យមានការអន្តរាគមន៍ពីអង្គបុរេជំនុំជម្រះឡើយ។ សរុបមក យឹម ទិត្យ មិនបានបង្ហាញពីកំហុសណាមួយ ឬការរំលោភបំពានណាមួយ ដែលជាកត្តាសម្រេចកំណត់ជាមូលដ្ឋានពីសេចក្តីសម្រេចដោយឆន្ទានុសិទ្ធិរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ដែលថា យឹម ទិត្យ ស្ថិតក្នុងចំណោម "អ្នកទទួលខុសត្រូវខ្ពស់បំផុត" ចំពោះឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តឡើងនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ និងការចោទប្រកាន់បញ្ជូន យឹម ទិត្យ ទៅជំនុំជម្រះ។ ដោយមិនបានបង្ហាញពីការចោទប្រកាន់អំពីកំហុសឆ្គងណាមួយនោះ ការចោទប្រកាន់ជារួមរបស់ យឹម ទិត្យ អំពីផលប៉ះពាល់រួមនៃមូលដ្ឋានបណ្តឹងឧទ្ធរណ៍របស់គាត់ មិនមានមូលដ្ឋានឡើយ[552]។

167. អាស្រ័យហេតុនេះ ផ្អែកលើសំអាងហេតុដែលបានលើកឡើងមក សហព្រះរាជអាជ្ញាអន្តរជាតិស្នើសុំឲ្យអង្គបុរេជំនុំជម្រះមេត្តាច្រានចោលបណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ ហើយបញ្ជូនសំណុំរឿង ០០៤ ទៅជំនុំជម្រះ ដោយផ្អែកលើដីកាបញ្ជូនរឿងទៅជំនុំជម្រះ អនុលោមតាមមាត្រា ៧៧(១៣)(ខ) នៃវិធានផ្ទៃក្នុង។

សូមលោកចៅក្រម ទទួលយកបណ្តឹងឧទ្ធរណ៍នេះដោយក្តីគោរព។

| **កាលបរិច្ឆេទ** | **ឈ្មោះ** | **ទីកន្លែង** | **ហត្ថលេខា** |
|---|---|---|---|
| ថ្ងៃទី១៤ ខែកុម្ភៈ ឆ្នាំ២០២០ | Brenda J. HOLLIS<br>សហព្រះរាជអាជ្ញាអន្តរជាតិ | ភ្នំពេញ | [signature] |

[552] សូមមើល សំណុំរឿង ០០៤/២ ឯកសារ D359/24 និង ឯកសារ D360/33 សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ កថាខណ្ឌ ១៦៨។